# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់ —១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

1. វាក្យសព្ទទី ១ អាថ៌កំបាំងនៃជីវិតមនុស្ស
2. វាក្យសព្ទទី ២ ព្រះអម្ចាស់ស្រឡាញ់អ្នក
3. វាក្យសព្ទទី ៣ ព្រះគម្ពីរ
4. វាក្យសព្ទទី ៤ មានព្រះ
5. វាក្យសព្ទទី ៥ ព្រះគ្រិស្តគឺជាព្រះ
6. វាក្យសព្ទទី ៦ ជីវិតតាមរយៈសេចក្តីជំនឿ
7. វាក្យសព្ទទី ៧ ការប្រែចិត្ត និងការលន់តួបាប
8. វាក្យសព្ទទី ៨ ពិធីបុណ្យជ្រមុជ
9. វាក្យសព្ទទី ៩ ការធានានៃសេចក្តីសង្គ្រោះ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

10. វាក្យសព្ទទី ១០ សេចក្តីអធិដ្ឋាន
11. វាក្យសព្ទទី ១១ តើការអធិដ្ឋានបានឆ្លើយតបឬទេ ?
12. វាក្យសព្ទទី ១២ ការអានព្រះគម្ពីរ
13. វាក្យសព្ទទី ១៣ សារៈសំខាន់នៃការប្រជុំ
14. វាក្យសព្ទទី ១៤ ដៃគូខាងវិញ្ញាណ
15. វាក្យសព្ទទី ១៥ ការច្រៀងបទចម្រៀង
16. វាក្យសព្ទទី ១៦ ការសរសើរតម្កើង
17. វាក្យសព្ទទី ១៧ ការបានស្តារឡើងវិញរៀងរាល់ព្រឹក
18. វាក្យសព្ទទី ១៨ ការអំពាវនាវព្រះនាមព្រះអម្ចាស់
19. វាក្យសព្ទ័ទី ១៩ ការអានអធិដ្ឋានព្រះបន្ទូល
20. វាក្យសព្ទទី ២០ ការបរិភោគព្រះអម្ចាស់
21. វាក្យសព្ទទី ២១ ការផឹកព្រះអម្ចាស់
22. វាក្យសព្ទទី ២២ ការទទួលអំណរព្រះអម្ចាស់
23. វាក្យសព្ទទី ២៣ អានអធិដ្ឋាន សិក្សា ទន្ទេញ និង អធិប្បាយ

## ភាគ៣ ព្រះបន្ទូលនៃជីវិត

24. វាក្យសព្ទទី ២៤ ព្រះបន្ទូលនៃជីវិត
25. វាក្យសព្ទទី ២៥ ព្រះគម្ពីរច្បាប់ស្តារឡើងវិញ
26. វាក្យសព្ទទី ២៦ ការស្គាល់បទចម្រៀង
27. វាក្យសព្ទ័ទី ២៧  មេរៀសិក្សាជីវិតនៃព្រះគម្ពីរ
28. វាក្យសព្ទទី ២៨ ការសិក្សាសរុបរួមនៃព្រះគម្ពីរ
29. វាក្យសព្ទទី ២៩ ព្រះបន្ទូលបរិសុទ្ធសម្រាប់ស្តារឡើងវិញពេលព្រឹក


**ភាគ៤ ការចង្តើន្ទំកនុខជីវិត**

30. វាក្យសព្ទទី ៣០ ការបំពេញ(ចម្អែត)អ្នកស្រេកឃ្លានដោយរបស់ល្អ
31. វាក្យសព្ទទី ៣១ សេចក្តីស្រឡាញ់ព្រះ
32. វាក្យសព្ទទី ៣២ ការពិត សេចក្តីជំនឿ និងការបទពិសោធន៍
33. វាក្យសព្ទទី ៣៣ ការទំនាក់ទំនងជាមួយព្រះអម្ចាស់ផ្ទាល់ខ្លួន និងដោយសេចក្តីស្រលាញ់
34. វាក្យសព្ទទី ៣៤ អារម្មណ៍នៃជីវិត
35. វាក្យសព្ទទី ៣៥ ការប្រកបនៃជីវិត
36. វាក្យសព្ទទី ៣៦ សេចក្តីជំនឿ និង ការស្តាប់បង្គាប់
37. វាក្យសព្ទទី ៣៧ ការបទពិសោធន៍ព្រះគ្រិស្ត
38. វាក្យសព្ទទី ៣៨ ការសម្អាតអតីតកាល
39. វាក្យសព្ទទី ៣៩ ហេតុអ្វីបានជាពួកជឿរងទុក្ខលំបាក?
40. វាក្យសព្ទទី ៤០ ការប្រឈមមុខនឹងការបៀតបៀន
41. វាក្យសព្ទទី ៤១ ការតតាំងនឹងអារក្ស
42. វាក្យសព្ទទី ៤២ ការមិនស្រឡាញ់លោកិយ
43. វាក្យសព្ទទី ៤៣ ចេស្តានៃការថែរក្សារបស់ព្រះ
44. វាក្យសព្ទទី ៤៤ សេចក្តីសង្ឃឹមនៃជីវិតគ្រិស្ទាន


**ភាគ៥ ការដើរយោងតាមវិញ្ញាណ**

45. វាក្យសព្ទទី ៤៥ វិញ្ញាណមនុស្ស
46. វាក្យសព្ទទី ៤៦ ព្រះវិញ្ញាណដែលបានលាយបញ្ចូល
47. វាក្យសព្ទទី ៤៧ ការក្លាយជាវិញ្ញាណតែមួយនឹងព្រះអម្ចាស់
48. វាក្យសព្ទទី ៤៨ ការហ្វឹកហាត់ប្រើវិញ្ញាណ
49. វាក្យសព្ទទី ៤៩ ការបានពេញជាព្រះវិញ្ញាណ

50. វាក្យសព្ទទី ៥០ ការរស់នៅ និង ការដើរយោងតាមវិញ្ញាណ
ភាគ៦ សេចក្ដីសង្គ្រោះដ៏ពេញលេញរបស់ព្រះ
51. វាក្យសព្ទទី ៥១ ការប្រោសលោះផ្នែកផ្លូវច្បាប់
52. វាក្យសព្ទទី ៥២ សេចក្ដីសង្គ្រោះផ្នែកជីវិត
53. វាក្យសព្ទទី ៥៣ ព្រះត្រីឯកដែលជាជីវិតជ្រួលជ្រាបមនុស្សដែលមានបីផ្នែក
54. វាក្យសព្ទទី៥៤ ការកើតជាថ្មី
55. វាក្យសព្ទទី ៥៥ ការញែកចេញជាបរិសុទ្ធ
56. វាក្យសព្ទទី ៥៦ ការកែជាថ្មី
57. វាក្យសព្ទទី ៥៧ ការផ្លាស់ប្រែ
58. វាក្យសព្ទទី ៥៨ ការថតចម្លង
59. វាក្យសព្ទទី ៥៩ ការទទួលសិរីល្អ
ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ
60. វាក្យសព្ទទី ៦០ ផែនការគ្រប់គ្រងរបស់ព្រះ
61. វាក្យសព្ទទី ៦១ ការចែកចាយរបស់ព្រះ
62. វាក្យសព្ទទី ៦២ ការលាយបញ្ចូលគ្នារវាងព្រះជាមួយមនុស្ស
63. វាក្យសព្ទទី ៦៣ ព័ន្ធកិច្ចនៃយុគសម័យ
64. វាក្យសព្ទទី ៦៤ ព្រះត្រីឯកដែលបានឆ្លងកាត់ដំណាក់កាល
65. វាក្យសព្ទទី ៦៥ ព្រះគ្រិស្ដរួមបញ្ចូលគ្រប់ទាំងអស់
66. វាក្យសព្ទទី ៦៦ ព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់
67. វាក្យសព្ទទី ៦៧ ព្រះជាជីវិតអស់កល្ប
68. វាក្យសព្ទទី ៦៨ រូបកាយរបស់ព្រះគ្រិស្ដ
69. វាក្យសព្ទទី ៦៩ ក្រុមជំនុំ
70. វាក្យសព្ទទី ៧០ នគរ
71. វាក្យសព្ទទី ៧១ ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ដ
ភាគ៨ សេចក្ដីបើកសម្ដែងព្រះដ៏ខ្ពង់ខ្ពស់
72. វាក្យសព្ទទី ៧២ ព្រះបានក្លាយជាមនុស្ស ដើម្បីឱ្យមនុស្សអាចក្លាយជាព្រះ
73. វាក្យសព្ទទី ៧៣ ព័ន្ធកិច្ចដ៏ពេញលេញរបស់ព្រះគ្រិស្ដនៅក្នុងបីដំណាក់កាល
74. វាក្យសព្ទទី ៧៤ ការដំណើរជីវិតជាមនុស្សព្រះ

75. វាក្យសព្ទទី ៧៥ ពួកអ្នកមានជ័យជម្នះ
76. វាក្យសព្ទទី ៧៦ សភាពពិតនៃរូបកាយព្រះគ្រិស្ត
77. វាក្យសព្ទទី ៧៧ យេរូសាឡិមថ្មី
**ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់**
78. វាក្យសព្ទ ៧៨ សេចក្តីអាថ៌កំបាំងអស្ចារ្យ ព្រះគ្រិស្ត និងក្រុមជំនុំ
79. វាក្យសព្ទទី ៧៩ ប្រាំពីរដំណាក់កាលរបស់ក្រុមជំនុំ
80. វាក្យសព្ទទី ៨០ ការស្តារឡើងវិញរបស់ព្រះអម្ចាស់
81. វាក្យសព្ទទី ៨១ យើងជាអ្វី
82. វាក្យសព្ទទី ៨២ មូលដ្ឋាននៃក្រុមជំនុំ
83. វាក្យសព្ទទី ៨៣ វ៉ចម៉ែន នី
84. វាក្យសព្ទទី ៨៤ វិថនេសលី
85. វាក្យសព្ទទី ៨៥ ការស្គាល់បក្សពួកនិកាយ
86. វាក្យសព្ទទី ៨៦ ការដូចគ្នាប៉េះបិទជាមួយនឹងសេចក្តីខុសឆ្គង
87. វាក្យសព្ទទី ៨៧ អាកប្បកិរិយារបស់យើងចំពោះពួកអ្នកជឿដូចគ្នា
88. វាក្យសព្ទទី ៨៨ ការចុះចូលចំពោះអ្នកដែលមានសិទ្ធអំណាចគ្រប់គ្រងលើយើង
**ភាគ១០ ការកសាងក្រុមជំនុំ**
89. វាក្យសព្ទទី ៨៩ ការកសាងក្រុមជំនុំឡើង
90. វាក្យសព្ទទី ៩០ ផ្លូវដែលព្រះជាម្ចាស់បានកំណត់ទុក
91. វាក្យសព្ទទី ៩១ ជីពចរជីវិតនៅក្នុងការអនុវត្តផ្លូវដែលព្រះបានកំណត់ទុក
92. វាក្យសព្ទទី ៩២ ការដំណើរជីវិតរស់តែមួយគត់សម្រាប់ដំណឹងល្អ
93. វាក្យសព្ទទី ៩៣ ការឃ្វាលហ្វូងចៀមរបស់ព្រះអម្ចាស់
94. វាក្យសព្ទទី ៩៤ ក្រុមទ្រទ្រង់ជីវិត
95. វាក្យសព្ទទី ៩៥ ការប្រជុំក្រុម
96.វាក្យសព្ទទី ៩៦ ការប្រជុំតុព្រះអម្ចាស់
97. វាក្យសព្ទទី ៩៧ ការប្រជុំអធិប្បាយ
98. វាក្យសព្ទទី ៩៨ ការថ្វាយទ្រព្យសម្បត្តិ
99. វាក្យសព្ទទី ៩៩ ការចូលរួមនៅក្នុងការប្រជុំធំៗ និងការហ្វឹកហ្វឺនទាំងឡាយ
100. វាក្យសព្ទទី ១០០ ការរួមបញ្ចូលនៃរូបកាយព្រះគ្រិស្ត

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី១ អាថ៌កំបាំងនៃជីវិតមនុស្ស

**ដកស្រង់ពី:**

រ៉ូម ៩:២៣ ហើយបើទ្រង់ចង់បើកឱ្យភាជនៈ ដែលគួរនឹងសេចក្តីមេត្តាករុណា ដែលទ្រង់បានរៀបចំជាមុន បានស្គាល់សេចក្តីវិសេសនៃសិរីល្អដ៏បរិសុទ្ធរបស់ទ្រង់វិញ ។

យើងគឺជាភាជនៈរបស់ព្រះដើម្បីដាក់ និងសម្តែងព្រះ ។ នៅពេលដែលអំពើបាបចូលមកក្នុងមនុស្ស ធ្វើឱ្យមនុស្សប្រព្រឹត្តអំពើបាប ។ ដោយសារព្រះគ្រិស្តបានសុគតនៅលើឈើឆ្កាង ហើយបានសម្រេចការប្រោសលោះ ដូច្នេះយើងត្រូវតែជឿហើយទទួលបុណ្យជ្រមុជទឹក ។

**ខ្លឹមសារ:**

លោកុប្បត្តិ ១:២៦ក ទ្រង់ក៏មានព្រះបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ។

រ៉ូម ៩:២៣ ហើយបើទ្រង់ចង់បើកឱ្យភាជនៈ ដែលគួរនឹងសេចក្តីមេត្តាករុណា ដែលទ្រង់បានរៀបចំជាមុន បានស្គាល់សេចក្តីវិសេសនៃសិរីល្អដ៏បរិសុទ្ធរបស់ទ្រង់វិញ ។

យ៉ូហាន ១:២៩ លុះស្អែកឡើង យ៉ូហានឃើញព្រះយេស៊ូ ដែលទ្រង់កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក!

I. **"ហើយព្រះជាម្ចាស់ទ្រង់មានបន្ទូលថា" ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើងឱ្យមានភាពដូចយើង"—លោកុប្បត្តិ ១:២៦ក:**
   A. ព្រះបានបង្កើតមនុស្សឱ្យមានរូប និងភាពដូចទ្រង់ ពីព្រោះមនុស្សត្រូវបានបង្កើតឡើងដូចជាភាជនៈសម្រាប់ដាក់ព្រះទ្រង់ផ្ទាល់ ។ ដូចគ្នានេះដែរ ស្រោមដៃត្រូវបានបង្កើតឡើងតាមរូបភាពដូចដៃ ពីព្រោះស្រោមដៃត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រាប់ដាក់ដៃ—ខ២៦ ។

B. ទ្រង់បានបង្កើតយើងឱ្យមានរូបដូចជាទ្រង់ និងភាពដូចទ្រង់ ដូច្នេះយើងអាចនឹងល្មមសម្រាប់ទ្រង់ដើម្បីដាក់ព្រះអង្គទ្រង់នៅក្នុងយើង—ខ២៦ ។

**II. "ហើយបើទ្រង់ចង់បើកឱ្យភាជនៈ ដែលគួរនឹងសេចក្តីមេត្តាករុណា ដែលទ្រង់បានរៀបចំជាមុន បានស្គាល់សេចក្តីវិសេសនៃសិរីល្អដ៏បរិសុទ្ធរបស់ទ្រង់វិញ"—រ៉ូម ៩:២៣ ។**

**III. នៅពេលអំពើបាបចូលមកក្នុងមនុស្ស វាក្លាយជាអំណាចដែលធ្វើឱ្យមនុស្សប្រព្រឹត្តអំពើបាប ។ ព្រះគ្រិស្តបានសុគតនៅលើឈើឆ្កាង ហើយបានបង្ហូរព្រះលោហិតរបស់ទ្រង់ដើម្បីលាងសម្អាតអំពើបាបរបស់យើង និងបំពេញសម្រេចការប្រោសលោះ—យ៉ូហាន ១:២៩; រ៉ូម ៥:១២:**

A. ក្នុងនាមជាកូនចៀមនៃព្រះ ព្រះគ្រិស្តបានសុគត ដើម្បីដកយកអំពើបាបចេញពីលោកិយ—យ៉ូហាន ១:២៩ ។

B. ក្នុងនាមជាគ្រាប់ស្រូវសាលីមួយគ្រាប់ ព្រះគ្រិស្តបានសុគត ដោយការធ្លាក់ចុះទៅក្នុងសេចក្តីស្លាប់ ដើម្បីបញ្ចេញជីវិតរបស់ព្រះ—១០:២៤ ។

**IV. "អ្នកណាដែលជឿ ហើយទទួលបុណ្យជ្រមុជទឹក នោះនឹងបានសង្គ្រោះ"—ម៉ាកុស ១៦:១៦ :**

A. ការជឿ គឺការទទួលយកព្រះអម្ចាស់យេស៊ូ ។ យើងគួរតែបើកមាត់របស់យើងហើយអំពាវនាវរកព្រះអម្ចាស់អស់ពីដួងចិត្តរបស់យើង ដើម្បីឱ្យទ្រង់នឹងចូលទៅក្នុងយើង—ខ១៦ ។

B. បន្ទាប់ពីយើងបានជឿលើព្រះអម្ចាស់ យើងចាំបាច់ត្រូវតែបានទទួលជ្រមុជទឹក—ខ១៦ ។

**V. "ឱ!នេះជារឿងដ៏សែនអ_ស្ចារ្យ គឺព្រះយេ_ស៊ូ ហើយនិងរូបខ្ញុំ ខ្ញុំនៅក្នុងទ្រង់ ទ្រង់គង់ក្នុងខ្ញុំជាអាថ៌_កំបាំងជារឿង អ_ស្ចារ្យ"—(បទចម្រៀងខ្មែរលេខ ១៧៧, អង់គ្លេសលេខ ២៣៣) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី២ ព្រះជាម្ចាស់ស្រឡាញ់អ្នក

**ដកស្រង់ពី :**

យ៉ូហាន ៣:១៦ ព្រះអង្គទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាព្រះអង្គប្រទានព្រះរាជបុត្រតែមួយរបស់ទ្រង់ ដើម្បីឱ្យ អស់អ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះនឹងមិនត្រូវវិនាសឡើយតែឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។

ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់! ទ្រង់បានខ្វល់ខ្វាយពីតម្រូវការរបស់មនុស្ស ។ ព្រះគ្រិស្តបានយាងមកសុគត ដើម្បីដោះស្រាយបញ្ហានៃអំពើបាបរបស់យើង ។ ប្រសិនបើអ្នកនិយាយទៅកាន់ព្រះជាម្ចាស់ថា "ទូលបង្គំជាមនុស្សមានបាប ទូលបង្គំស្ម័គ្រចិត្ត ហើយចង់ទទួលយកព្រះអង្គ" នោះអ្នកនឹងបានសង្គ្រោះ!

**ខ្លឹមសារ :**

១យ៉ូហាន ៤:១៦ខ ព្រះអម្ចាស់ គឺជាសេចក្តីស្រឡាញ់ ។

យ៉ូហាន ៣:១៦ ព្រះអង្គទ្រង់ស្រឡាញ់មនុស្សលោកដល់ម្លេះ បានជាព្រះអង្គប្រទានព្រះរាជបុត្រតែមួយរបស់ទ្រង់ ដើម្បីឱ្យអស់អ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះនឹងមិនត្រូវវិនាសឡើយ តែឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។

រ៉ូម ៥:៨ ប៉ុន្តែព្រះបានផ្តល់សេចក្តីស្រឡាញ់របស់ទ្រង់មកយើងនៅពេលដែលយើងមានបាបនៅឡើយ ព្រះគ្រិស្តទ្រង់សុគតសម្រាប់យើងរាល់គ្នា ។

I. **"ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់" ។ "ព្រះអង្គទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះបានជាព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់……"—១យ៉ូហាន ៤:១៦ខ, យ៉ូហាន ៣:១៦:**
   A. "ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់" នេះគឺជាការពិត! ព្រះជាម្ចាស់ គឺជាសេចក្តីស្រឡាញ់ ទ្រង់មិនអាចជួយបាន ប៉ុន្តែស្រឡាញ់ ទ្រង់មិនមានព្រះទ័យសុខស្រួលឡើយ ប្រសិនបើទ្រង់មិនបានស្រឡាញ់ ។

B. ទ្រង់បានស្រឡាញ់ និងបានប្រទានឱ្យ ។ ទ្រង់បានប្រទានព្រះអម្ចាស់យេស៊ូដល់មនុស្សលោក ដើម្បីសុគតសម្រាប់មនុស្សលោក និងបំពេញសម្រេចសេចក្ដីសង្គ្រោះនៅលើឈើឆ្កាង ។
C. ដោយព្រោះហេតុនេះហើយ ទើបព្រះគម្ពីរបានបង្ហាញយើងនូវការពិតដ៏អស្ចារ្យមួយនេះ នោះគឺថា សេចក្ដីស្រឡាញ់នៃព្រះជាម្ចាស់ បានសម្ដែងចេញនៅក្នុងសេចក្ដីស្លាប់របស់ព្រះគ្រិស្ដ ។

II. **"អស់អ្នកណាដែលជឿដល់ទ្រង់មិនត្រូវវិនាសឡើយ ប៉ុន្តែមានជីវិតអស់កល្បវិញ"—ខ១៦ :**
A. សព្វថ្ងៃនេះ ខ្ញុំកំពុងនិយាយរឿងមួយ នោះគឺថា ព្រះចង់បានអ្នក និងស្រឡាញ់អ្នក ។
B. ទ្រង់បានដោះស្រាយរាល់បញ្ហារបស់យើង ទ្រង់មិនបានទុកកន្លែងសម្រាប់ឱ្យយើងធ្វើការងារឡើយ ។ យើងមិនចាំបាច់ធ្វើអ្វីទាំងអស់ លើកលែងតែការជឿនូវអ្វីដែលព្រះអម្ចាស់បានបំពេញសម្រេចរួចហើយប៉ុណ្ណោះ ។
C. ខ្ញុំសង្ឃឹមថា អ្នកអាចចងចាំថា ព្រះ គឺជាសេចក្ដីស្រឡាញ់! ប្រសិនបើអ្នកនិយាយទៅកាន់ព្រះថា "ទូលបង្គំជាមនុស្សមានបាប ទូលបង្គំស្ម័គ្រចិត្ត និងចង់ទទួលយកព្រះអង្គ" នោះអ្នកនឹងបានសង្គ្រោះ! ក្រោយមក ព្រះអង្គនឹងរីករាយព្រះទ័យ ហើយអ្នកក៏នឹងរីករាយចិត្តជាមួយនឹងទ្រង់ផងដែរ ។

III. **"ព្រះមេត្តាជាបទចម្រៀងខ្ញុំ ចិត្តថ្វាយបង្គំមាត់សរសើរ ព្រះគុណទ្រង់គ្មានអ្វីណាមួយប្រៀបស្មើ បានទាំងដួងចិត្តជីវិតខ្ញុំ ទ្រង់ស្រឡាញ់យើង ទ្រង់ស្រឡាញ់យើង ចាត់ព្រះបុត្រាមករកយើង"—(បទចម្រៀងខ្មែរលេខ ៣១, អង់គ្លេសលេខ ៣៩) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៣ ព្រះគម្ពីរ

**ដកស្រង់ពី :**

២ធីម៉ូថេ ៣:១៦ គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត ។

ព្រះគម្ពីរ គឺជាខ្យល់ដង្ហើមរបស់ព្រះ ដែលទ្រង់បានបញ្ចេញ ។ ព្រះ គឺជាពន្លឺ ជាជីវិត ជាសេចក្តីស្រឡាញ់ ជាចេស្តារ និង ជាប្រាជ្ញា ។ល។ ចំណុចទាំងនេះហើយដែលព្រះជាម្ចាស់បានបញ្ចេញចូលទៅក្នុងព្រះគម្ពីរ ។ ព្រះគម្ពីរមានប្រាជ្ញា ដែលអាចឱ្យយើងបានសង្គ្រោះ ។

**ខ្លឹមសារ :**

២ធីម៉ូថេ ៣:១៦ គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឱ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត ។

២ពេត្រុស ១:២១ មនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ។

២ធីម៉ូថេ ៣:១៥ បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រិស្តយេស៊ូផង ។

I. **"គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ" ហើយ "មនុស្សបរិសុទ្ធរបស់ព្រះ ដែលបានទាយ ដោយសារព្រះវិញ្ញាណបរិសុទ្ធទ្រង់បណ្តាលវិញ"—២ធីម៉ូថេ ៣:១៦; ២ពេត្រុស ១:២១ :**

A. ព្រះបន្ទូលរបស់ព្រះ មកដល់មនុស្សដោយសារព្រះវិញ្ញាណបរិសុទ្ធ ។ ហើយមនុស្សទាំងនេះនិយាយដោយសារព្រះវិញ្ញាណបរិសុទ្ធជាអ្នកបណ្តាល ដូចជាទូកក្តោងត្រូវបានខ្យល់បក់ផាត់ និងធ្វើចលនាដោយសារខ្យល់—ខ២១ ។

B. ពួកអ្នកសរសេរព្រះគម្ពីរ គឺត្រូវបានបណ្តាលដោយព្រះវិញ្ញាណបរិសុទ្ធ និងនៅក្រោមចេស្តាររបស់ព្រះវិញ្ញាណបរិសុទ្ធ ហើយត្រូវបានបក់និងនាំដោយសារព្រះវិញ្ញាណដើម្បីសម្តែងព្រះបន្ទូលរបស់ព្រះ ។ ព្រះគម្ពីរមិនបានចេញមកពីមនុស្ស ឬជាការបញ្ចេញគំនិតពីមនុស្សឡើយ ផ្ទុយទៅវិញមនុស្សទាំងនេះ បានសរសេរព្រះបន្ទូលដែលចេញមកពីព្រះ—ខ២១ ។

II. **ព្រះគម្ពីរ គឺជាខ្យល់ដង្ហើមរបស់ព្រះ ដែលទ្រង់បានបញ្ចេញ—២ធីម៉ូថេ ៣:១៦ :**

A. កាលណាយើងដកដង្ហើមចេញ នោះគឺជាខ្យល់ដង្ហើមរបស់យើង ហើយខ្យល់ដង្ហើមនេះគឺចេញមកពីខ្លួនរបស់យើង ។ ដូច្នេះ ព្រះគម្ពីរដែលជាខ្យល់ដង្ហើមរបស់ព្រះ គឺជាអ្វីមួយដែលចេញមកពីរូបអង្គព្រះជាម្ចាស់—ខ១៦ ។

B. ព្រះគម្ពីរផ្ទុកនូវអង្គធាតុរបស់ព្រះ ។ ព្រះ គឺជាពន្លឺ ជាជីវិត ជាសេចក្តីស្រឡាញ់ ជាចេស្តារ និង ជាប្រាជ្ញា ។ល។ ចំណុចទាំងនេះហើយដែលព្រះបានបញ្ចេញចូលទៅក្នុងព្រះគម្ពីរ—យ៉ូហាន ១:៩ ។

III. **បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឱ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រិស្តយេស៊ូផង—២ធីម៉ូថេ ៣:១៥ ។**

IV. **សូមហូប និងសូមផឹកពីព្រះអង្គយេស៊ូ / សូមហូបដោយការអាន ផឹកដោយអធិដ្ឋាន / ខ្ញុំហូបហើយខ្ញុំផឹកដោយអានអធិដ្ឋាន / អានអធិដ្ឋានអាចឱ្យខ្ញុំស្កប់ចិត្តបាន / ព្រះអង្គចិញ្ចឹមខ្ញុំឱ្យខ្ញុំបានផឹក បំពេញអស់ការឃ្លាន បំបាត់ការស្រេក ឱ្យខ្ញុំរីករាយមានកម្លាំងក្នុងជីវិត បំពេញអស់ការឃ្លាន បំបាត់ការស្រេក—(បទចម្រៀងខ្មែរលេខ ៥៨៦ , អង់គ្លេលេខ ៨១១) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៤ មានព្រះ

**ដកស្រង់ពី:**

ទំនុកតម្កើង ១៩:១ ផ្ទៃមេឃសម្ដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ ។

យើងដឹងថា មានព្រះ ដោយសារការរៀបចំនូវអ្វីគ្រប់យ៉ាងនៅក្នុងសកលលោក ទោះបី យើងមិនអាចមើលឃើញទ្រង់ក៏ដោយ ។ យើងត្រូវតែនិយាយថា ព្រះមានពិត ទ្រង់គឺជាព្រះ ដ៏មានព្រះជន្មរស់ ។ យើងគួរតែបើកមាត់របស់យើង ហើយហៅព្រះអង្គអស់ពីដួងចិត្តរបស់ យើង ដើម្បីឱ្យព្រះអង្គចូលមកក្នុងយើង ។

**ខ្លឹមសារ:**

ទំនុកតម្កើង ១៩:១ ផ្ទៃមេឃសម្ដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ ។

រ៉ូម ១:១៩ ព្រោះការអ្វីដែលអាចនឹងស្គាល់ពីព្រះបាន នោះបានសម្ដែងមកក្នុងពួក គេហើយ ដោយព្រះទ្រង់សម្ដែងការនោះឱ្យគេឃើញជាក់ ។

ហេព្រើរ ១១:៦ខ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ។

I. **"ផ្ទៃមេឃសម្ដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ"—ទំនុកតម្កើង ១៩:១ :**
   A. យើងដឹងថា គឺមានព្រះដោយសារការរៀបចំនូវអ្វីគ្រប់យ៉ាងនៅក្នុងសកលលោក ទោះបីយើងមិនអាចមើលឃើញទ្រង់ក៏ដោយ—រ៉ូម ១:២០ ។

B. រាល់បាតុភូតនៃធម្មជាតិមានតុល្យភាព បានរៀបចំ ពេញដោយអត្ថន័យ និងមុខងារ រីឯសកលលោកនេះវិញ ត្រូវបានបង្កើតដោយមួយអង្គ ដែលមានព្រះបញ្ញាដ៏ជ្រាលជ្រៅ ចំណេះដឹងដ៏ទូលំទូលាយ និងការរចនាដ៏ស្មុគស្មាញ—ខ២០ ។

**II. ចិត្តរបស់យើងប្រកែករកការគង់នៅរបស់ព្រះ ។ គ្រប់គ្នាកំពុងតែស្វះស្វែងរកព្រះ ។ ការនោះត្រូវតែមានការគង់នៅរបស់ព្រះនៅក្នុងសកលលោក—ខ១៩:**

A. ចំពោះរាល់តម្រូវការខាងក្នុងរបស់មនុស្ស គឺត្រូវគ្នានឹងការផ្គត់ផ្គង់ខាងក្រៅរបស់គាត់ ។ ឧទាហរណ៍ ចំណង់អាហារនៅខាងក្នុងខ្លួនមនុស្ស គឺត្រូវបានបំពេញដោយការផ្គត់ផ្គង់អាហារផ្សេងៗគ្នា ដែលនៅខាងក្រៅខ្លួនមនុស្ស ។

B. មនុស្សគ្រប់រូបមានសេចក្ដីប៉ងប្រាថ្នាជ្រាលជ្រៅចំពោះព្រះជាម្ចាស់ ។ បើគ្មានព្រះគង់នៅទេ នោះយើងក៏នឹងមិនមានសេចក្ដីប៉ងប្រាថ្នានៅក្នុងចិត្តរបស់យើងដែរ ។

**III. "ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន"—ហេព្រើរ.១១:**

A. យើងត្រូវតែនិយាថា ព្រះមានពិត ។ ទ្រង់ គឺជាព្រះដ៏មានព្រះជន្មរស់—១ថែស្សាឡូនីច ១:៩ ។

B. ព្រះអម្ចាស់យេស៊ូវរបស់យើង គឺជាព្រះអង្គទ្រង់ផ្ទាល់ ។ យើងគួរតែបើកមាត់របស់យើង ហើយហៅព្រះអង្គអស់ពីដួងចិត្តរបស់យើង ដើម្បីឱ្យព្រះអង្គចូលមកក្នុងយើង ។

**IV. "មានព្រះយេស៊ូជាព្រះសង្គ្រោះ ទ្រង់ទទួលគ្រប់យ៉ាងជំនួស ឲ្យខ្ញុំបានរស់ សុចរិតគ្រប់គ្រា ទ្រង់ជាកម្លាំងរាល់វេលា"—(បទចម្រៀងខ្មែរលេខ ៣៩៥, អង់គ្លេសលេខ ៥៣៧) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៥ ព្រះគ្រិស្តគឺជាព្រះ

**ដកស្រង់ពី:**

រ៉ូម ៩:៥ខ ព្រះគ្រិស្តដែលទ្រង់ខ្ពស់លើសទាំងអស់ ជាព្រះដ៏មានពរអស់កល្បជានិច្ច អា-ម៉ែន ។

ព្រះគ្រិស្ត គឺជាព្រះ ។ ទ្រង់គឺជាអធិបតីលើចក្រវាឡ ។ គ្មានព្រះណាផ្សេងក្រៅពីទ្រង់ឡើយ ។ ការមានទ្រង់ជាព្រះពរ គឺជាព្រះពរដ៏ធំ! ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះពួកគេអាចទទួលអំណរនូវអ្វីគ្រប់យ៉ាងដែលជារបស់ព្រះ ។

**ខ្លឹមសារ:**

រ៉ូម ៩:៥ខ ព្រះគ្រិស្តដែលទ្រង់ខ្ពស់លើសទាំងអស់ ជាព្រះដ៏មានពរអស់កល្បជានិច្ច អា-ម៉ែន ។

១កូរិនថូស ៨:៤ខ នោះយើងដឹងថា ក្នុងលោកិយនេះ រូបព្រះមិនជាអ្វីទេ ហើយថាគ្មានព្រះណាទៀត ក្រៅពីព្រះតែ១ឡើយ ។

យ៉ូហាន ១:១២ ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ ។

I. **"ព្រះគ្រិស្ត គឺជាព្រះ ។ ទ្រង់ គឺជាព្រះអម្ចាស់នៃការបង្កបង្កើត និងជាអធិបតីលើចក្រវាឡ"—រ៉ូម ៩:៥ :**
   A. ព្រះគ្រិស្ត គឺជាព្រះអង្គទ្រង់ផ្ទាល់ ។ ទ្រង់ គឺជាព្រះ—ខ៥ ។
   B. រូបព្រះទាំងអស់ គឺសុទ្ធតែក្លែងក្លាយ និងមិនមែនជាព្រះដ៏ពិតនោះទេ—ទំនុកតម្កើង ១១៥:៤—៧ ។

II. **ព្រះគ្រិស្ត គឺជាព្រះពិតតែមួយគត់នៅក្នុងសកលលោក ។ គ្មានព្រះណាទៀតក្រៅពីទ្រង់ឡើយ—១កូរិនថូស ៨:៤; រ៉ូម ៩:៥:**

A. "រីឯ.....គឺជាព្រះតែ១ព្រះអង្គ នោះសូមឱ្យទ្រង់បានល្បីព្រះនាម និងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន"—១ធីម៉ូថេ ១:១៧ ។

B. "ព្រះគ្រិស្តដែលទ្រង់ខ្ពស់លើសទាំងអស់ ជាព្រះដ៏មានពរអស់កល្បជានិច្ច អាម៉ែន"—រ៉ូម ៩:៥ ។

III. **"ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ"—យ៉ូហាន ១:១២ :**

A. ព្រះពរតែមួយគត់នៅក្នុងសកលលោកទាំងមូល គឺជាព្រះអង្គទ្រង់ផ្ទាល់ ។ ទ្រង់ គឺជាព្រះពរ និងជាចំណែកដ៏ពិតរបស់យើង ។ ការមានទ្រង់ជាព្រះពរ គឺជាព្រះពរដ៏ធំ!—ជនគណនា ៦:២៣-២៦ ។

B. ពួកយើងអាចទទួលអំណរនូវអ្វីគ្រប់យ៉ាងដែលជារបស់ព្រះ នៅពេលដែលយើងបានត្រឡប់ជាកូនព្រះ គ្រប់ភាពបរិបូររបស់ទ្រង់ទាំងអស់ គឺជាព្រះពរ និងជាកម្មសិទ្ធិរបស់យើង ។

IV. **ជីវិតខ្ញុំបានផ្លាស់ប្រែយ៉ាងអស្ចារ្យគ្រប់សណ្ឋាន តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត / មានពន្លឺនៃព្រះអង្គបានភ្លឺមកពេញទាំងប្រាណ តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត / តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត / តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត / នោះចិត្តខ្ញុំបានត្រេកអរដ៏រីករាយខ្លាំងក្រៃលែង / តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត—(បទចម្រៀងខ្មែរលេខ ២៤១, បទជាភាសាអង់គ្លេស ៣០៩) ។**

## ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៦ ជីវិតតាមរយៈសេចក្ដីជំនឿ

### ដកស្រង់ពី:

យ៉ូហាន ៣:១៦ ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណា ដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។

ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ ។ ដូចជាយើងទទួលបានអាហារ និងទឹក តាមរយៈការបរិភោគ និងការផឹកជាយ៉ាងណា នោះយើងក៏ត្រូវតែទទួលយកព្រះអម្ចាស់យេស៊ូតាមរយៈការជឿយ៉ាងនោះដែរ ។ ពួកយើងជឿ ពួកយើងជឿ ពួកយើងជឿ ដូច្នេះហើយទើបពួកយើងនិយាយ ។

### ខ្លឹមសារ :

យ៉ូហាន ១៤:៦ក ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត ។

៣:១៦ ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណា ដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។

១:១២ ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ ។

### I. "ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ"—១យ៉ូហាន ៥:១២ :

A. "ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត"—យ៉ូហាន ១៤:៦ក ។

B. "ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ"—យ៉ូហាន ៦:៣៥ខ ។

II. **"អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ"—យ៉ូហាន ៣:៣៦ :**

A. ការជឿចូលទៅក្នុងទ្រង់ គឺមិនដូចជាការជឿលើទ្រង់ទេ ។ ការជឿលើទ្រង់ គឺជាការជឿថា ព្រះអង្គគឺជាព្រះដ៏ពិត ហើយប្រាកដ ប៉ុន្តែការជឿចូលទៅក្នុងទ្រង់ គឺជាការទទួលយកទ្រង់ និងបានរួមជាតែមួយជាមួយនឹងទ្រង់ ។ មុនដំបូងគឺការទទួលស្គាល់ការពិតនៅផ្នែកខាងក្រៅ ចុងក្រោយគឺការទទួលបានជីវិតនៅផ្នែកខាងក្នុង—៣:១៦ ។

B. ដូចជាការដែលយើងទទួលបានអាហារ និង ទឹកតាមរយៈការបរិភោគ និង ការផឹកជាយ៉ាងណា នោះពួកយើងក៏ត្រូវការទទួលយកព្រះអម្ចាស់យេស៊ូតាមរយៈការជឿលើព្រះអង្គជាយ៉ាងនោះដែរ—៦:៥៤ក ។

III. **" ពួកយើងជឿ ពួកយើងជឿ ពួកយើងជឿ ទើបយើងនិយាយ ។ ពួកយើងជឿ ពួកយើងជឿ ពួកយើងជឿ ទើបយើងនិយាយ ។ ចេញឱ្យឆ្ងាយពីគ្រប់គំនិតសង្ស័យ ទៅឯវិញ្ញាណរួមបញ្ចូលនៃជំនឿ ។ អធិដ្ឋានដើម្បីទាក់ទងព្រះនៅក្នុងវិញ្ញាណដែលគង់នៅក្នុងខាងក្នុង ព្រោះទ្រង់ផ្ទាល់ជាផ្លូវរបស់អ្នក"—ពួកយើងជឿ ពួកយើងជឿ ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៧ ការប្រែចិត្ត និងការលន់តួបាប

**ដកស្រង់ពី:**

កិច្ចការ ២០:២១ក គឺពីការប្រែចិត្ត ទៅឯព្រះ ហើយពីសេចក្តីជំនឿ ជឿដល់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងរាល់គ្នា ។

ការប្រែចិត្ត គឺទាក់ទងនឹងការផ្លាស់ប្តូរចិត្ត ។ ព្រះស្អប់អំពើបាប ។ ប្រសិនបើយើងចង់ភ្លក់សេចក្តីអំណរនៃសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ដ៏បរិបូរ យើងត្រូវតែចូលមករកព្រះអម្ចាស់ ហើយលន់តួបាបរបស់យើងយ៉ាងហ្មត់ចត់ ។

**ខ្លឹមសារ:**

កិច្ចការ ២០:២១ក គឺពីការប្រែចិត្ត ទៅឯព្រះ ហើយពីសេចក្តីជំនឿ ជឿដល់ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើងរាល់គ្នា ។

១យ៉ូហាន ១:៩ បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិតប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសម្អាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។

អេសាយ ១:១៨ ទោះបើអំពើបាបរបស់ឯង ដូចជា ពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ ។

I. **ការប្រែចិត្តដ៏ពិតបណ្តាលឱ្យមនុស្សងាកមករកព្រះ ហើយងាកចេញពីការមិនចង់ និងមិនប្រឈមមុខចំពោះព្រះ—កិច្ចការ ២០:២១ :**
   A. ប្រសិនបើយើងមិនមានព្រះ យើងនឹងមិនស្តប់ចិត្តឡើយ—សាស្តា ២:១, ១១ ។
   B. បើគ្មានព្រះគ្រិស្ត គ្រប់ទាំងអស់ គឺទទេ ! បើមានព្រះគ្រិស្តនៅខាងក្នុង គឺបានគ្រប់ទាំងអស់ ! គ្រប់ទាំងអស់ គឺទទេ មានតែព្រះគ្រិស្តប៉ុណ្ណោះ គឺបានគ្រប់យ៉ាង!—បទចម្រៀងលេខខ្មែរលេខ ៧០១ (អង់គ្លេសលេខ ១០៨០) ។

C. យោងទៅតាមភាសាដើមនៅក្នុងព្រះគម្ពីរ ការប្រែចិត្តទាក់ទងនឹងការផ្លាស់ប្រែចិត្ត ។ យើងត្រូវប្រែចិត្តដោយបែរគំនិតរបស់យើងពីរឿងផ្សេងទៀតមករកទ្រង់ ។ បងប្អូននឹងស្ដាប់ចិត្តនឹងទ្រង់ ដ្បិតទ្រង់មិនអសារឥតការទេ!—បទចម្រៀងខ្មែរលេខ ៧០១ (អង់គ្លេសលេខ១០៨០) កិច្ចការ ៣:១៩ ។

**II. ទុច្ចរិត និងភាពអយុត្តិធម៌ គឺជាអំពើបាប ។ ព្រះស្អប់បាប—១យ៉ូហាន ៣:៤; ៥:១៧ ។**

**III. បើយើងសារភាពបាបរបស់យើង នោះព្រះជាម្ចាស់នឹងអត់ទោសឱ្យយើងរាល់គ្នា ហើយព្រះលោហិតរបស់ព្រះអម្ចាស់នឹងសម្អាតយើងពីអំពើទុច្ចរិតគ្រប់យ៉ាង—អេភេសូរ ១:១០:**

A. «ទ្រង់នឹងមានសេចក្ដីអាណិតអាសូរ ដល់យើងរាល់គ្នាទៀត ទ្រង់នឹងកម្រាបសេចក្ដីទុច្ចរិតរបស់យើងនៅក្រោមព្រះបាទ ហើយនឹងបោះអស់ទាំងអំពើបាបរបស់យើងទៅក្នុងសមុទ្រជ្រៅ»—មីកា ៧:១៩ ។

B. «ទោះបើអំពើបាបរបស់ឯង ដូចជា ពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ»—អេសាយ ១:១៨ ។

**IV. "ព្រះគុណអស្ចារ្យ! ជាស័ព្ទពិរោះ / ដែលប្រោសមនុស្សយ៉ាងដូចខ្ញុំ! ពីដើមបាត់បង់ តែទ្រង់សង្គ្រោះ ក៏ខ្វាក់ តែទ្រង់អប់រំ ។ ព្រះគុណបង្រៀនឱ្យកោតខ្លាចព្រះ ក៏បានកម្ចាត់ភ័យទៅ / ព្រះគុណដែលទ្រង់ផ្ដល់មកបានឈ្នះ / ឱ្យចិត្តខ្ញុំបានស៊ប់នៅ! / ព្រះយេស៊ូបានសន្យានឹងជួយ /ខ្ញុំពឹងបន្ទូលដ៏ពិត /ទ្រង់ការពារខ្ញុំ ក៏គង់ជាមួយ ដរាបដល់អស់ជីវិត ។ "—ព្រះគុណ អស្ចារ្យ (លេខ ២៤៧ អង់គ្លេសលេខ ៣១៣) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៨ ពិធីបុណ្យជ្រមុជ

**ដកស្រង់ពី :**

ម៉ាកុស ១៦:១៦ អ្នកណាដែលជឿ ហើយទទួលជ្រមុជទឹក នោះនឹងបានសង្គ្រោះ ។

ការជ្រមុជទឹក គឺជាការចូលទៅក្នុងជីវិតគ្រិស្ទាន ។ អ្នកណាដែលជឿ ហើយទទួលជ្រមុជទឹក នោះនឹងបានសង្គ្រោះ ។ សេចក្ដីសង្គ្រោះ ធ្វើឱ្យមនុស្សអរសប្បាយ "នៅថ្ងៃនេះខ្ញុំផឹកទឹករស់នៃជីវិត ស្រស់ស្រាយរីករាយក្រៃលែង ខ្ញុំផឹកទឹករស់នៃជីវិត ដែលឥតមានព្រំដែនកំណត់ឡើយណា" ។

**ខ្លឹមសារ :**

ម៉ាកុស ១៦:១៦ អ្នកណាដែលជឿ ហើយទទួលជ្រមុជទឹក នោះនឹងបានសង្គ្រោះ ។

កិច្ចការ ២២:១៦ ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលពិធីជ្រមុជទឹក ... ដោយការអំពាវនាវព្រះនាមព្រះអម្ចាស់ ។

I. **ការជ្រមុជទឹក គឺជាការចូលទៅក្នុងការដំណើរជីវិតគ្រិស្ទាន—ម៉ាកុស ១៦:១៦ :**
   A. ការជឿ និងការទទួលជ្រមុជទឹក អាចប្រៀបធៀបជាមួយនឹងជើងទាំងពីររបស់យើងក្នុងការដើរមួយជំហាន ។ ដំបូង យើងជឿ ហើយការជឿរបស់យើងអាចប្រៀបធៀបជាមួយនឹងកន្លះជំហាននៃការដើររបស់យើង—ខ១៦ ។
   B. បន្ទាប់មកទៀតយើងទទួលជ្រមុជទឹក ដែលការជ្រមុជទឹករបស់យើង អាចប្រៀបធៀបពីជំហានពេញលេញនៃការដើររបស់យើង ។ ទាំងការជឿ និងការជ្រមុជទឹក ធ្វើឱ្យយើងមានជំហានដែលពេញលេញ—ខ១៦ ។

II. **"ឥឡូវនេះ តើអ្នកបង្អង់ចាំអ្វីទៀត ចូរក្រោកឡើង ទទួលពិធីជ្រមុជទឹក ... ដោយការអំពាវនាវព្រះនាមព្រះអម្ចាស់"—កិច្ចការ ២២:១៦ :**
   A. នៅពេលដែលមនុស្សម្នាក់បានទទួលជឿក្នុងព្រះអម្ចាស់ គាត់គួរតែទទួលជ្រមុជទឹកភ្លាមមួយរំពេច ដោយពុំចាំបាច់រង់ចាំ—ខ១៦ ។

B. ពេលដែលអ្នកទទួលជ្រមុជទឹក អ្នកគួតែអំពាវនាវព្រះនាមព្រះអម្ចាស់ ។ ការអំពាវនាវនេះ គឺជាការប្រកាសថា អ្នកដែលទទួលជ្រមុជទឹក បានបែរមករកព្រះអម្ចាស់វិញ—ខ១៦ ។

C. ភាសាក្រិក បេធីសស្សូ ( Baptiszo ) មានន័យថា "មុជចូល ឬ នៅក្រោម"—ខ១៦ ។

**III. អ្នកណាដែលជឿ ហើយទទួលជ្រមុជទឹក នោះនឹងបានសង្គ្រោះ—ម៉ាកុស ១៦:១៦ :**

A. សេចក្តីសង្គ្រោះធ្វើឱ្យមនុស្សអរសប្បាយ—ទំនុកតម្កើង ៥១:១២; ៣២:៧ ។

B. សេចក្តីសង្គ្រោះធ្វើឱ្យយើង ទទួលបានការអត់ទោស អាចផ្សះផ្សារជាមួយព្រះ អាចទទួលបានជីវិតព្រះ និងថែមទាំងអាចសូម្បីតែទទួលបានព្រះជាម្ចាស់ទ្រង់ផ្ទាល់—មីកា ១៦:១៦ ។

**IV. "ច្រើនឆ្នាំនឿយហត់ស្វែងរកមិនជួបទឹកដ៏រស់ ជាទឹកដ៏រស់ហូរដល់អស់កល្ប គ្រប់ទាំងអស់ក្នុងលោកមិនអាចគាប់ចិត្តប្រាថ្នា គ្មានអ្វីអាចឱ្យស្កប់ចិន្តា នៅថ្ងៃនេះខ្ញុំផឹកទឹកដ៏រស់ហូរដល់អស់កល្ប នៅថ្ងៃនេះខ្ញុំផឹកទឹករស់នៃជីវិត ស្រស់ស្រាយរីករាយក្រៃលែង ខ្ញុំផឹកទឹករស់នៃជីវិតដែលឥតមានព្រំដែនកំណត់ឡើយណា"—(បទចម្រៀងខ្មែរលេខ ២៥៩, អង់គ្លេសលេខ ៣២២) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ១ អាថ៌កំបាំងនៃជីវិតមនុស្ស

## វាក្យសព្ទទី៩ ការធានានៃសេចក្តីសង្គ្រោះ

**ដកស្រង់ពី :**

១យ៉ូហាន ៥:១៣ ខ្ញុំបានសរសេរសេចក្តីទាំងនេះផ្ញើរមកអ្នក ដែលជឿដល់ព្រះនាមព្រះបុត្រានៃព្រះដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ ។

នៅខណៈពេលដែលមនុស្សម្នាក់ទទួលជឿ គាត់ត្រូវបានសង្គ្រោះ ។ ការធានានៃសេចក្តីសង្គ្រោះរបស់យើង គឺផ្អែកលើព្រះបន្ទូលរបស់ព្រះ ផ្អែកលើការធ្វើបន្ទាល់ពីព្រះវិញ្ញាណជាមួយនិងវិញ្ញាណរបស់យើង និងផ្អែកលើការពិតថា យើងស្រឡាញ់បងប្អូន ។ ដូច្នេះ យើងនឹងដងទឹកចេញពីអណ្តូងនៃសេចក្តីសង្គ្រោះដោយអំណរ ។

**ខ្លឹមសារ :**

១យ៉ូហាន ៥:១៣ ខ្ញុំបានសរសេរសេចក្តីទាំងនេះផ្ញើរមកអ្នក ដែលជឿដល់ព្រះនាមព្រះបុត្រានៃព្រះដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ ។

រ៉ូម ៨:១៦ ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ ។

១យ៉ូហាន ៣:១៤ក យើងដឹងថាយើងបានឆ្លងផុតពីសេចក្តីស្លាប់ចូលមកក្នុងជីវិតហើយ ពីព្រោះយើងស្រឡាញ់បងប្អូន ។

**I. ភស្តុតាងផ្នែកខាងក្រៅ–រ៉ូម ១០:១៣; ១យ៉ូហាន ៥:១៣:**

A. ព្រះជាម្ចាស់ប្រើព្រះគម្ពីរ ដោយមិនបញ្ជាក់ថា យើងមានជីវិតរបស់ទ្រង់ឡើយ–ខ១៣ ។

B. យើងមិនត្រូវការអារម្មណ៍របស់យើងឡើយ ។ យោងទៅតាមសេចក្ដីថ្លែងការណ៍ធម្មតា យើងអាចដឹងច្បាស់ថា យើងបានទទួលព្រះគុណ ប្រយោជន៍ឱ្យយើងបានសង្គ្រោះ–ខ ១៣ ។

II. **ភស្តុតាងផ្នែកខាងក្នុង–រ៉ូម ៨:១៥, ១៦; កាឡាទី ៤:៦:**

A. ចាប់តាំងពីយើងហៅព្រះជាម្ចាស់ថា "អ័ប្បា ព្រះវរបិតា" ដោយស្វ័យប្រវត្ត ទាំងមានអារម្មណ៍ផ្អែមល្ហែម និងសុខស្រួល ការនេះបង្ហាញថា យើងមានជីវិតរបស់ព្រះ និងជាកូនចៅដែលកើតពីព្រះ–ខ៦ ។

B. ដូច្នេះ តាមរយៈការធ្វើបន្ទាល់ខាងក្នុងរបស់ព្រះវិញ្ញាណជាមួយនិងវិញ្ញាណយើង យើងអាចដឹងប្រាកដថា យើងគឺជាកូនរបស់ព្រះ ហើយថាយើងបានសង្គ្រោះ–រ៉ូម ៨:១៦ ។

III. **ភស្តុតាងនៃសេចក្ដីស្រឡាញ់–១យ៉ូហាន ៤:៧; ៣:១៤:**

A. ១យ៉ូហាន ៣:១៤ និយាយថា "យើងដឹងថាយើងបានឆ្លងផុតពីសេចក្ដីស្លាប់ចូលមកក្នុងជីវិតហើយ ពីព្រោះយើងស្រឡាញ់បងប្អូន" ។

B. ដោយយើងមានសេចក្ដីស្រឡាញ់ចំពោះបងប្អូនក្នុងព្រះអម្ចាស់ នោះជាភស្តុតាងដែលយើងដឹងថា យើងបានសង្គ្រោះហើយ–៤:៧; ៣:១៤ ។

IV. **"ហេតុនោះ ចូរអ្នក ដងទឹកដោយអំណរ ពីអណ្ដូងនៃសេចក្ដីសង្គ្រោះ / ហើយនៅគ្រានោះ អ្នកពោលថា អព្រះគុណ / ហេតុនោះ ចូរអ្នក ដងទឹកដោយអំណរ ពីអណ្ដូងនៃសេចក្ដីសង្គ្រោះ / ហើយនៅគ្រានោះ អ្នកពោលថា អព្រះគុណ" "ហេតុនោះ ចូរអ្នកដងទឹកដោយអំណរ"–បទចម្រៀងខ្មែរលេខ ៧៩០ (អង់គ្លេសលេខ ១៣៤០) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១០ សេចក្តីអធិដ្ឋាន

**ដកស្រង់ពី:**

ភីលីព ៤:៦ កុំឱ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិដ្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង ។

នៅក្នុងជីវិតខាងឯវិញ្ញាណរបស់យើង សេចក្តីអធិដ្ឋាន គឺជាការដកដង្ហើម ។ នៅពេលដែលយើងអធិដ្ឋាន សេចក្តីមេត្តា ហើយនិងព្រះគុណនឹងក្លាយជាទន្លេហូរនៅក្នុងយើង និងផ្គត់ផ្គង់យើង នេះពិតជារង្វាន់!

**ខ្លឹមសារ :**

ភីលីព ៤:៦ កុំឱ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិដ្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង ។

ហេព្រើរ ៤:១៦ ដូច្នេះ ត្រូវឱ្យយើងរាល់គ្នា មកដល់បល្ល័ង្កនៃព្រះគុណដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ ។

I. **សារៈសំខាន់ដំបូងនៃការអធិដ្ឋានគឺ ស្រូបយកព្រះចូលមកក្នុងយើង—ទំនុកតម្កើង ៥៥:១ :**
   A. នៅពេលដែលយើងដកដង្ហើមចេញ យើងបញ្ចេញកាបូនឌីអុកស៊ីតដែលមាននៅក្នុងខ្លួនយើង ពេលយើងដកដង្ហើមចូល យើងស្រូបយកអុកស៊ីសែនដែលនៅខាងក្រៅយើង—១៧:៦ ។
   B. ដោយដកដង្ហើមចេញ យើងកម្ចាត់ភាពទន់ខ្សោយពីខ្លួនយើង រីឯដោយការដកដង្ហើមចូល យើងទទួលយកព្រះចេស្តារបស់ព្រះ ។

II. **"កុំឱ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិដ្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង"—ភីលីព ៤:៦:**

A. ប្រសិនបើយើងមិនផ្ទេរសេចក្តីខ្វល់ខ្វាយទាំងអស់ទៅព្រះ ដើម្បីឱ្យទ្រង់ទទួលយកទេ នោះសេចក្តីខ្វល់ខ្វាយទាំងអស់នៃលោកិយនេះ នឹងធ្វើទុក្ខយើងរហូតដល់ស្លាប់ ។ យើងមិនត្រូវអនុញ្ញាតឱ្យកង្វល់ក្នុងលោកិយនេះសង្កត់សង្កិនមកលើយើងឡើយ យើងត្រូវតែប្រគល់វាទៅព្រះ ។

B. ប្រសិនបើយើងទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូមរបស់យើងរាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិដ្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង នោះនឹងមានលទ្ធផលល្អបំផុត ។ "យ៉ាងនោះ សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នាក្នុងព្រះគ្រិស្តយេស៊ូ" នេះហើយជាសេចក្តីសន្យារបស់ទ្រង់—ខ៧ ។

**III. "ដូច្នេះ ត្រូវឱ្យយើងរាល់គ្នា មកដល់បល្ល័ង្កនៃព្រះគុណដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ"—ហេព្រើរ ៤: ១៦ :**

A. អត្ថប្រយោជន៍ដ៏ធំបំផុតក្នុងការអធិដ្ឋាននៅចំពោះព្រះ និងការទំនាក់ទំនងជាមួយព្រះ គឺយើងទទួលបានសេចក្តីមេត្តាករុណា និងរកបានព្រះគុណសម្រាប់ជាជំនួយនៅពេលត្រូវការ ដើម្បីបំពេញរាល់សេចក្តីត្រូវការរបស់យើង ។

B. សេចក្តីអធិដ្ឋាន គឺជាផ្លូវដើម្បីឆ្ពោះទៅមុខបល្ល័ង្កនៃព្រះគុណ ។ នៅពេលដែលយើងអធិដ្ឋាន នោះការខិតជិតបល្ល័ង្កនៃព្រះគុណ ព្រះមេត្តាករុណា និងព្រះគុណ នឹងក្លាយជាទន្លេដែលហូរនៅក្នុងយើង ហើយផ្គត់ផ្គង់ដល់យើង ។ នេះពិតជារង្វាន់!—៧:២៥ ។

**IV. "ព្រះយេស៊ូជាមិត្តសម្លាញ់ពិត ទ្រង់ទទួលទោសជួសយើងខ្ញុំ មានច្បាប់ចូលទៅគាល់ព្រះអង្គជិត ទាំងទូលប្រាប់គ្រប់រឿងតូចធំ យើងខ្ញុំតែងតែខានមានសុខសាន្ត ក៏មានចិត្តព្រួយថប់បារម្ភ គឺពីព្រោះតែភ្លេចអធិដ្ឋាន សូមពរពីព្រះអង្គឧត្តម"—(បទចម្រៀងខ្មែរលេខ ៥៧១, អង់គ្លេសលេខ ៧៨៩) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១១ តើការអធិដ្ឋានបានឆ្លើយតបឬទេ ?

ដកស្រង់ពី :

យ៉ូហាន ១៦:២៤ខ ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បី ឱ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត ។

ព្រះអម្ចាស់បានសន្យាថា បើយើងសូម នោះនឹងត្រូវបានប្រទានឱ្យដល់យើង ដើម្បីឱ្យសេចក្ដីអំណររបស់យើងបានពោរពេញពិត ។ សព្វថ្ងៃនេះ ប្រសិនបើយើងអធិដ្ឋានដោយឥតឈប់ឈរ យើងនឹងរស់នៅក្នុងជីវិតគ្រិស្ទានដែលពេញទៅដោយសេចក្ដីអំណរនៅលើផែនដី ។

ខ្លឹមសារ :

យ៉ូហាន ១៦:២៤ខ ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឱ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត ។

ម៉ាកុស ១១:២៤ គ្រប់ទាំងសេចក្ដីអ្វីដែលអ្នករាល់គ្នាអធិដ្ឋានសូម ចូរជឿថា បានហើយ នោះនឹងបានមែន ។

កិច្ចការ ៦:៤ក ឯយើងខ្ញុំ នឹងខំព្យាយាមក្នុងសេចក្ដីអធិដ្ឋាន ។

I. យ៉ូហាន ១៦ មានបន្ទូលថា ព្រះបានឆ្លើយតបនៅពេលដែលយើងសូមនៅក្នុងព្រះនាមរបស់ព្រះអម្ចាស់ ដើម្បីឱ្យសេចក្ដីអំណររបស់យើងរាល់គ្នាបានពោរពេញពិត—ខ២៤:
   A. សេចក្ដីសន្យារបស់ព្រះអម្ចាស់ចំពោះសេចក្ដីអធិដ្ឋាន គឺទូលំទូលាយណាស់ ។ ដរាបណាយើងកំពុងតែអធិដ្ឋាន នោះទ្រង់នឹងធ្វើនូវអ្វីដែលយើងសូម—១៤:១៣ ។
   B. យើងគួរតែទូលសូមព្រះពីភាពចាំបាច់ ។ យើងមិនគួរសូមដោយឥតសមហេតុផល ឬហួសហេតុពេកឡើយ—យ៉ាកុប ៤:៣ ។

II. គោលការណ៍សម្រាប់សេចក្ដីអធិដ្ឋាន ដែលត្រូវបានឆ្លើយតប គឺជាសេចក្ដីជំនឿ—ម៉ាកុស ១១:២៤:
   A. គ្រប់ទាំងសេចក្ដីអ្វីដែលអ្នករាល់គ្នាអធិដ្ឋានសូម ចូរជឿថា បានហើយ នោះនឹងបានមែន—យ៉ាកុប ១:៦-៧ ។

B. សេចក្តីជំនឿ គោរព និងថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ។ ទាំងសេចក្តីអធិដ្ឋានទាំងអស់ត្រូវបានស្តាប់ឮនៅលើមូលដ្ឋាននេះ—ម៉ាកុស ១១:២៤ ។

III. ៉ឯយើងខ្ញុំ នឹងខំព្យាយាមក្នុងសេចក្តីអធិដ្ឋាន៉—កិច្ចការ ៦:៤ :

A. សេចក្តីអធិដ្ឋាន គឺដូចជាការចែវទូកនៅលើទឹក ។ ប្រសិនបើបងប្អូនមិនតស៊ូទេ បងប្អូនមុខជាត្រូវបានដឹកទៅតាមខ្សែទឹកខាងក្រោម ។ ការខ្ជាប់ខ្ជួនក្នុងសេចក្តីអធិដ្ឋាន គឺជាការខំព្យាយាមបន្តដោយស្មោះអស់ពីចិត្ត—ខ៤ ។

B. ដោយសេចក្តីអធិដ្ឋាន សូមឱ្យព្រះអម្ចាស់ថែរក្សាបញ្ហាទាំងអស់នៅក្នុងការរស់នៅរបស់យើង ។ ទ្រង់នឹងថែរក្សាយើង ហើយនិងបំពេញតាមតម្រូវការរបស់យើង ។

C. សព្វថ្ងៃនេះ ប្រសិនបើយើងអធិដ្ឋានដោយឥតឈប់ឈរ យើងនឹងរស់នៅក្នុងជីវិតគ្រិស្ទានដែលពេញទៅដោយសេចក្តីអំណរនៅលើផែនដី—យ៉ូហាន ១៦:២៤ ។

IV. ៉ចូលទីប-រិ-សុទ្ធ បំផុតនៃព្រះអង្គ ព្រះគុណឧ-ត្តមហូរដូចខ្សែទឹក ចូលទីប-រិ-សុទ្ធ បំផុតនៃព្រះអង្គ ព្រះគុណឧ-ត្តមហូរដូចខ្សែទឹក ហា-លេ-លូ-យ៉ា ហា-លេ-លូ-យ៉ា ព្រះគុណឧ-ត្តមហូរដូចខ្សែទឹក ។៉—(បទចម្រៀងជាភាសាខ្មែរលេខ ៥៥៧, ភាសាអង់គ្លេសលេខ ៧៧០) ។

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១២ ការអានព្រះគម្ពីរ

**ដកស្រង់ពី :**

២ធីម៉ូថេ ៣:១៦ក គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ។

ការអានព្រះបន្ទូល គឺជាការស្រូបយកព្រះពីព្រះគម្ពីរ ។ នៅពេលដែលយើងចូលមកឯព្រះគម្ពីរ យើងត្រូវតែបរិភោគ និងផឹកព្រះអង្គដូចជាអាហាររបស់យើង ។ នៅពេលដែលយើងបរិភោគព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងមានសេចក្តីអំណរ និងការអរសប្បាយនៅក្នុងចិត្តរបស់យើង ។

**ខ្លឹមសារ:**

២ធីម៉ូថេ ៣:១៦ក គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ ។

យេរេមា ១៥:១៦ ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្តីអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ ។

**I. ព្រះគម្ពីរទាំងមូល គឺជាព្រះបន្ទូលរបស់ព្រះ ដែលជាខ្យល់ដង្ហើមរបស់ទ្រង់–២ធីម៉ូថេ ៣:១៦ក :**

A. ការអានព្រះបន្ទូល គឺជាការស្រូបយកព្រះពីព្រះគម្ពីរ ។ ផ្លូវដែលព្រះបានកំណត់ទុកសម្រាប់យើង ដើម្បីទទួលអំណរទ្រង់ គឺការអានព្រះបន្ទូល ។

B. "មនុស្សមិនមែនរស់ ដោយសារតែនំប៉ុងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះមកដែរ" ។ គ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះ គឺជាអាហារខាងវិញ្ញាណរបស់មុនស្ស—ម៉ាថាយ ៤:៤ ។

II. "ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ហើយ" — យេរេមា ១៥:១៦ :

A. ឥរិយាបថរបស់យើងចំពោះការមកឯព្រះគម្ពីរ គួរតែជាការបរិភោគ ។ នៅពេលដែលយើងមកឯព្រះគម្ពីរ យើងត្រូវតែបរិភោគ និងផឹកព្រះអម្ចាស់ជាអាហាររបស់យើង ។ យើងត្រូវតែដកដង្ហើមចូលព្រះអង្គទ្រង់ផ្ទាល់ និងទទួលអំណរទ្រង់ ។

B. ពីមួយថ្ងៃទៅមួយថ្ងៃ យើងត្រូវការមកឯព្រះបន្ទូលគ្រប់ពេលវេលា ។ យើងកាន់តែអាន យើងនឹងកាន់តែបានស្កប់ចិត្ត កាន់តែបានបំពេញ កាន់តែមានកម្លាំង និងកាន់តែបានចម្រើនកម្លាំង—ទំនុកតម្កើង ១១៩:១០៥ ។

C. "ហើយព្រះបន្ទូលរបស់ទ្រង់ជាសេចក្តីអំណរ ហើយជាទីរីករាយចិត្តដល់ទូលបង្គំ" អាហារល្អតែងតែធ្វើឱ្យយើងរីករាយ ។ ព្រះបន្ទូលរបស់ព្រះអម្ចាស់ គឺដូចគ្នា ។ នៅពេលដែលយើងបរិភោគព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងមានសេចក្តីអំណរ និងជាទីរីករាយនៅក្នុងចិត្តរបស់យើង—យេរេមា ១៥:១៦ខ ។

III. "សូមឱ្យព្រះអង្គជាពិធីជប់លៀងខ្ញុំ បំពេញដោយព្រះវិញ្ញាណ និងព្រះបន្ទូល/ ក្នុងពិធីជប់លៀង ខ្ញុំហូបផឹកព្រះអង្គ ឱ្យបានអំណរភាពប-រិ-បូរណ៍ព្រះអង្គ ។ ទ្រង់បំ-បាត់ការហេវស្រេក ឱ្យខ្ញុំស្កប់ចិត្ត/ ព្រះអង្គចិ-ញ្ចឹមខ្ញុំ ឱ្យខ្ញុំបានផឹក/ បំ-ពេញអស់ការឃ្លាន បំ-បាត់ការស្រេក/ ឱ្យខ្ញុំរីករាយ មានកម្លាំងក្នុងជី-វិត /បំពេញអស់ការឃ្លាន/ បំ-បាត់ការស្រេក"—(បទចម្រៀងខ្មែរលេខ ៥៨៦, ភាសាអង់គ្លេសលេខ ៨១១) ។

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១៣ សារៈសំខាន់នៃការប្រជុំ

**ដកស្រង់ពី :**

ហេព្រើរ ១០:២៥ក ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ។

ចំពោះគ្រិស្ទាន ការប្រជុំ គឺដូចជាទឹកចំពោះត្រី ឬដូចជាខ្យល់អាកាសចំពោះបក្សាបក្សី ។ ត្រីត្រូវការរស់នៅក្នុងទឹក ហើយសត្វហើរត្រូវការរស់នៅក្នុងខ្យល់អាកាស រីឯគ្រិស្ទានទាំងឡាយត្រូវរក្សាជីវិតរបស់ខ្លួនដោយការប្រជុំ ។

**ខ្លឹមសារ :**

ហេព្រើរ ១០:២៥ក ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ។

ម៉ាថាយ ១៨:២០ ដ្បិតកន្លែងណាដែលមាន២ ឬ៣នាក់ ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្តាលចំណោមអ្នកទាំងនោះដែរ ។

I. **ដើម្បីរស់នៅ ព្រះជាម្ចាស់បានកំណត់ថា គ្រិស្ទានត្រូវតែប្រជុំគ្នា—ម៉ាថាយ ១៨:២០ :**
   A. ជីវិតគ្រិស្ទានរបស់យើង គឺមិនដូចជាជីវិតមេអំបៅ ដែលធ្វើ (ប្រព្រឹត្ត) តាមតែខ្លួនឯងឡើយ ។ ជីវិតរបស់យើង គឺដូចជាជីវិតសត្វចៀម ដែលតម្រូវឱ្យយើងជួបជុំគ្នា ហើយរស់នៅក្នុងជីវិតនៃការប្រជុំ ។
   B. ប្រសិនបើអ្នកជឿថ្មីមិនបានមកប្រជុំ នោះគាត់នឹងមិនមានសេចក្តីអំណរ សេចក្តីសុខសាន្ត ឬសេចក្តីកម្សាន្តចិត្តឡើយ ។
   C. ក៏ប៉ុន្តែ ប្រសិនបើគាត់មកប្រជុំ នោះគាត់នឹងមានសេចក្តីអំណរនៅខាងក្នុងនៅខណៈពេលគាត់ច្រៀង ប្រកប អធិដ្ឋាន សរសើរតម្កើង និងថ្វាយបង្គំជាមួយនឹងពួកបងប្អូន ព្រោះការនេះ គឺជាបុគ្គលិកលក្ខណៈនៃជីវិតរបស់ព្រះ—១កូរិនថូស ១៤:២៦ ។

II. **យើងត្រូវការប្រជុំគ្នា ដូចជាត្រីត្រូវការទឹក សត្វស្លាបត្រូវការខ្យល់អាកាស រីឯមនុស្សត្រូវការដកដង្ហើម—ហេព្រើរ ១០:២៥ :**

A. យើងត្រូវការមើលឃើញថា ការប្រជុំមិនមែនជាសកម្មភាពយូរៗម្តងរបស់គ្រិស្ទាន នោះទេ ប៉ុន្តែការប្រជុំ គឺជាជីវិតគ្រិស្ទាន ដូចជាការបរិភោគ និង ការលាងសម្អាត ប្រចាំថ្ងៃ គឺជាផ្នែកមួយនៃជីវិតរបស់មនុស្ស ។ ដូច្នេះ ទាំងនេះមិនមែនជាសកម្មភាព យូរៗម្តងឡើយ តែជាមូលដ្ឋានគ្រឹះនៃការរស់នៅរបស់ពួកគេ ។

B. ហេព្រើរ ១០:២៥ និយាយថា "ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ" ។ យើងត្រូវការប្រជុំគ្នា ដ្បិតការប្រជុំមានសារៈសំខាន់ណាស់ចំពោះយើង ហើយយើង មិនគួរបោះបង់ការប្រជុំចោលឡើយ ។

III. **"បំណងខ្លឹមសារក្នុងការប្រជុំ គ្រប់គ្នារីករាយដោយភាពឧត្តម ចំណុចកណ្តាលជារូប អង្គទ្រង់ នាំគ្នាសម្តែងព្រះគ្រិស្ត"—(បទចម្រៀងខ្មែរលេខ ៦២៤, អង់គ្លេសលេខ ៨៦៤) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

# ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

# វាក្យសព្ទទី១៤ ដៃគូខាងវិញ្ញាណ

**ដកស្រង់ពី :**

សាស្តា ៤:៩-១០ មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង...ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ ។

ពេញមួយជីវិតរបស់យើង ដៃគូខាងវិញ្ញាណគឺជាមិត្តល្អបំផុត ។ នៅក្នុងជីវិតក្រុមជំនុំគ្រប់គ្រិស្ទាន គួរតែមានដៃគូខាងវិញ្ញាណខ្លះ បន្ទាប់មកទើបគាត់អាចនឹងរឹងមាំ អំណរ និងជាគ្រិស្ទានដ៏ត្រឹមត្រូវ ។

**ខ្លឹមសារ:**

២ធីម៉ូថេ ២:២២ ចូរឱ្យរត់ពីសេចក្តីស្រើបស្រាលរបស់ក្មេងៗចេញ ហើយដេញតាមសេចក្តីសុចរិត សេចក្តីជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីមេត្រី ជាមួយនឹងអស់អ្នកដែលអំពាវនាវដល់ព្រះអម្ចាស់ អំពីចិត្តដ៏បរិសុទ្ធវិញ ។

សាស្តា ៤:៩-១០ មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង...ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ ។

I. **"ចូរឱ្យរត់ពីសេចក្តីស្រើបស្រាលរបស់ក្មេងៗចេញ ហើយដេញតាមសេចក្តីសុចរិត សេចក្តីជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីមេត្រី ជាមួយនឹងអស់អ្នកដែលអំពាវនាវដល់ព្រះអម្ចាស់ អំពីចិត្តដ៏បរិសុទ្ធវិញ"–២ធីម៉ូថេ ២:២២ :**

   A. យើងត្រូវតែមានជីវិតនៃការរត់គេច ហើយដេញតាម ប៉ុន្តែ នៅពេលដែលបងប្អូនខំប្រឹងរត់គេច ហើយដេញតាម នោះបងប្អូននឹងរកឃើញថា បងប្អូនមិនអាចធ្វើដោយខ្លួនឯងបានឡើយ ។

B. គោលការណ៍សម្រាប់ពួកបរិសុទ្ធទាំងនៅក្នុងសញ្ញាចាស់ និងសញ្ញាថ្មី គឺថា ពួកគេបានដាក់ក្នុងក្រុមជាមួយគ្នា ។ ដូច្នេះ ពួកយុវជនត្រូវការរត់ពីសេចក្តីស្រើបស្រាលរបស់ក្មេងៗចេញ ហើយដេញតាមព្រះអម្ចាស់ជាមួយនឹងដៃគូមួយចំនួន ។

**II. "មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង...ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញតែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ"–សាស្តា ៤:៩-១០ :**

A. ពេញមួយជីវិតរបស់យើង ដៃគូខាងវិញ្ញាណគឺជាមិត្តល្អបំផុត ។ នៅក្នុងជីវិតក្រុមជំនុំគ្រប់គ្រិស្ទាន គួរតែមានដៃគូខាងវិញ្ញាណខ្លះ ។

B. យុវជនត្រូវការមានយ៉ាងហោចណាស់ដៃគូម្នាក់ ។ ជាពិសេសនៅពេលយើងមានការលំបាក យើងត្រូវការដៃគូកាន់តែច្រើន បន្ទាប់មកទើបគាត់អាចក្លាយជារឹងមាំ អំណរ និងក្លាយជាគ្រិស្ទានដ៏ត្រឹមត្រូវបាន ។

**III. "ការបង្កើតថ្មីក្លាយជារូបកាយ មិនមែនបុគ្គលរស់នៅម្នាក់ឯង យើងរួមបម្រើជាមួយនឹងគ្នា រួមសហការ រួមបម្រើ"—(បទចម្រៀងខ្មែរលេខ ៦៥៦, អង់គ្លេសលេខ ៩១២) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១៥ ការច្រៀងបទចម្រៀង

**ដកស្រង់ពី :**

អេភេសូរ ៥:១៩ ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ និងចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ។

បទចម្រៀង គឺជាការបង្ហាញពីអារម្មណ៍ល្អបំផុតរបស់មនុស្ស ។ ការច្រៀង គឺជាលក្ខណៈលេចធ្លោមួយរបស់គ្រិស្ទាន ។ ជីវិតប្រចាំថ្ងៃរបស់យើង គួរតែបានពេញដោយការច្រៀងថ្វាយដល់ព្រះអម្ចាស់ ។

**ខ្លឹមសារ :**

អេភេសូរ ៥:១៩ ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ និងចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ។

ទំនុកតម្កើង ១០៤:៣៣ កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ាជាដរាប កាលទូលបង្គំមាននៅៗឡើយ នោះនឹងច្រៀងសរសើរដល់ព្រះនៃទូលបង្គំ ។

I. **បទចម្រៀង គឺជាការបង្ហាញពីអារម្មណ៍ល្អបំផុតរបស់មនុស្ស—ទំនុកតម្កើង ៥៥:១ :**
   A. អារម្មណ៍ជ្រៅបំផុតដែលហូរចេញពីចិត្តរបស់មនុស្ស គឺជាអារម្មណ៍ដែលបានបង្ហាញនៅក្នុងបទចម្រៀង ។
   B. ព្រះចង់ឱ្យយើងមានអារម្មណ៍ល្អ និងទន់ភ្លន់ ។ ព្រះចង់ដឹកនាំកូនចៅរបស់ទ្រង់ឆ្ពោះទៅដំណើរមួយដែលមានអារម្មណ៍ល្អប្រសើរជាងមុន ទន់ភ្លន់ជាងមុន និងចូលចិត្តបទចម្រៀងច្រើនជាងមុន ។

II. "ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ និងចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត"—អេភេសូរ ៥:១៩:

A. ពេលណាយើងបើកមាត់របស់យើងសរសើរដល់ព្រះអម្ចាស់ ឬ ច្រៀងថ្វាយទ្រង់ នោះយើងនឹងអរសប្បាយ ។

B. យើងគួរតែច្រៀងព្រះបន្ទូលមិនត្រឹមតែនៅក្នុងការប្រជុំ ប៉ុន្តែ ជាពិសេសនៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង បងប្អូនអាចច្រៀងតាមរបៀបដែលខុសជាមួយនឹងទំនុកភ្លេង តែបងប្អូនកាន់តែច្រៀង បងប្អូនកាន់តែរីករាយ ។ បងប្អូនកាន់តែច្រៀង បងប្អូនកាន់តែស្រស់ស្រាយ ។

C. ខ្ញុំតែងតែច្រៀងជានិច្ច ។ ជារៀងរាល់ថ្ងៃ ពេលខ្ញុំដើរលេង ខ្ញុំច្រៀង ។ ការច្រៀង គឺជាលក្ខណៈលេចធ្លោមួយរបស់គ្រិស្ទាន ។ ចំពោះតន្ត្រី ខ្ញុំមិនពូកែទេ ប៉ុន្តែ ខ្ញុំចូលចិត្តច្រៀងជាងអ្វីៗផ្សេងទៀត ។ ពេលខ្ញុំច្រៀងតាមរបៀបនេះ នោះការព្រួយបារម្ភទាំងឡាយរបស់ខ្ញុំ បានបាត់ទៅ ហើយជម្ងឺទាំងអស់ត្រូវបានដកចេញ ។

D. "កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ាជាដរាប កាលទូលបង្គំមាននៅៗឡើយ នោះនឹងច្រៀងសរសើរដល់ព្រះនៃទូលបង្គំ"—ទំនុកតម្កើង ១០៤:៣៣ ។

III. "យើងនឹងច្រៀងថ្វាយព្រះអង្គដោយប្រើវិញ្ញាណ យើងនឹងច្រៀងថ្វាយព្រះអង្គដោយប្រើវិញ្ញាណពីខាងក្នុង យើងនឹងច្រៀងហាលេលូយ៉ាព្រះយេស៊ូ រួមជាតែមួយនឹងទ្រង់ក្នុងវិញ្ញាណ" (បទចម្រៀងខ្មែរលេខ ៩០២, បទជាភាសាអង់គ្លេសលេខ ១១៩១) ។

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងវិញ្ញាណ

## វាក្យសព្ទទី ១៦ ការសរសើរតម្កើង

**ដកស្រង់ពី :**

ទំនុកតម្កើង ៦៩:៣០ ទូលបង្គំនឹងច្រៀងទំនុកសរសើរដល់ព្រះនាមរបស់ព្រះ ហើយនឹងលើកតម្កើងទ្រង់ដោយអរព្រះគុណ ។

ការសរសើរតម្កើង គឺជាការថ្វាយសិរីល្អដល់ព្រះ ។ ការសរសើរតម្កើង គឺជាការងារដ៏ខ្ពង់ខ្ពស់បំផុត ដែលធ្វើឡើងដោយប្រជារាស្ត្ររបស់ព្រះ ។ នៅពេលដែលយើងចាប់ផ្តើមច្រៀង និងសរសើរតម្កើង ព្រះអង្គទ្រង់បញ្ជូនជំនួយមក ។ ពួកយើងត្រូវតែសរសើរតម្កើងព្រះឥតឈប់ឈរ ។

**ខ្លឹមសារ :**

ទំនុកតម្កើង ៦៩:៣០ ទូលបង្គំនឹងច្រៀងទំនុកសរសើរដល់ព្រះនាមរបស់ព្រះ ហើយនឹងលើកតម្កើងទ្រង់ដោយអរព្រះគុណ ។

១៥០:៦ គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើមបានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។

I. **ការសរសើរតម្កើង គឺជាការថ្វាយសិរីល្អដល់ព្រះ ។ ការសរសើរតម្កើង គឺជាការងារដ៏ខ្ពង់ខ្ពស់បំផុត ដែលធ្វើឡើងដោយប្រជារាស្ត្ររបស់ព្រះ—១របាក្សត្រ ២៣:៣០ :**
   A. ព្រះអង្គទ្រង់គាប់គួរសរសើរនូវគ្រប់ទាំងអស់ ។ ការសរសើរតម្កើងរបស់ពួកយើង គឺជាសិរីល្អរបស់ព្រះអង្គ—១៦:២៥ ។
   B. កូនសោសម្ងាត់ដើម្បីយកឈ្នះនូវគ្រប់ស្ថានការទាំងអស់ គឺជាការសរសើរតម្កើងព្រះ ។ ប្រសិនបើបងប្អូនមានអារម្មណ៍ថាឯកា ចូរគ្រាន់តែនិយាយថា "អូ ព្រះអម្ចាស់ អាម៉ែន ហាលេលូយ៉ា!" ក្នុងរយៈពេលតិចជាងប្រាំនាទី នោះបងប្អូននឹងមានអារម្មណ៍

ថា ព្រះអម្ចាស់ទ្រង់គង់នៅជាមួយបងប្អូន ។ អ្វីក៏ដោយដែលបងប្អូនត្រូវការ ការសរសើរតម្កើងនេះនឹងនាំរបស់ទាំងនោះមកបងប្អូន ។

C. ព្រះចូលចិត្តឱ្យយើងសរសើរតម្កើងដល់ទ្រង់តាមរបៀបនេះ ។ ព្រះត្រូវបានលើកតម្កើងឡើងតាមរយៈការសរសើររបស់យើង ដូច្នេះពួកយើងគួរតែរៀនសរសើរតម្កើងដល់ព្រះអង្គឱ្យកាន់តែច្រើន—ទំនុកតម្កើង ២២:៣ ។

**II. "ទូលបង្គំនឹងច្រៀងទំនុកសរសើរដល់ព្រះនាមរបស់ព្រះ ហើយនឹងលើកដំកើងទ្រង់ដោយអរព្រះគុណ"—៦៩:៣០ :**

A. ការល្អប្រសើរបំផុត ការកម្សាន្តចិត្តល្អបំផុត ហើយនិងការលើកទឹកចិត្តល្អបំផុត គឺទាំងអស់ស្ថិតនៅក្នុងការច្រៀងសរសើរតម្កើង ។ នៅពេលដែលយើងចាប់ផ្តើមច្រៀងសរសើរតម្កើង ព្រះបញ្ជូនជំនួយមក—១១៩:១៧៥ ។

B. ខណៈពេលពួកយើងច្រៀងសរសើរតម្កើង ព្រះអង្គសរសើរនៅក្នុងការសរសើរតម្កើងរបស់ ពួកយើង ។ នៅពេលណាដែលយើងច្រៀង ព្រះយេស៊ូគួរតែច្រៀងនៅខាងក្នុងការច្រៀងរបស់យើង ម្លោះហើយទើបយើងមិនអាចបញ្ចប់ការសរសើរតម្កើងរបស់យើង ព្រោះយើងកាន់តែសរសើរតម្កើងច្រើនយ៉ាងណា យើងនឹងកាន់តែមានការសរសើរតម្កើងច្រើនយ៉ាងនោះដែរ ។

C. "គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើមបានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ"—ទំនុកតម្កើង ១៥០:៦ ។

**III. "សូមសរ_សើរ សូមសរ_សើរ គ្រប់គ្នា_អំ_ណរ រីក_រាយ សូម សរ_សើរ សូមសរ_សើរ គ្រប់គ្នាស្រែកច្រៀង_ស_ប្បាយ សូមចូលមកព្រះវរ_បិ_តា ដោយ ព្រះ បុ_ត្រា សូមថ្វាយសិ_រី_ ល្អ ដល់ទ្រង់ធ្វើការ អ_ស្ចារ្យ"—(បទចម្រៀងខ្មែរលេខ ៣៨, អង់គ្លេសលេខ ៣៩) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១៧ ការបានស្តារឡើងវិញរៀងរាល់ព្រឹក

**ដកស្រង់ពី:**

សុភាសិត ៤:១៨ តែផ្លូវរបស់មនុស្សសុចរិត ធៀបដូចជា ពន្លឺដែលកំពុងតែរះឡើង ដែលភ្លឺកាន់តែខ្លាំងឡើង ដរាបដល់ពេញកម្លាំង ។

ដួងអាទិត្យរះឡើងស្រស់ថ្មីរាល់តែព្រឹក ។ សេចក្តីសប្បុរស និងសេចក្តីមេត្តាករុណារបស់ព្រះអ-ម្ចាស់ គឺថ្មីរាល់តែព្រឹក ។ យើងគួរតែដើរតាមដួងអាទិត្យ ដើម្បីបានស្តារឡើងវិញ និងមានការចាប់ផ្តើមថ្មីរៀងរាល់ព្រឹក ។

**ខ្លឹមសារ:**

សុភាសិត ៤:១៨ តែផ្លូវរបស់មនុស្សសុចរិត ធៀបដូចជា ពន្លឺដែលកំពុងតែរះឡើង ដែលភ្លឺ កាន់តែខ្លាំងឡើង ដរាបដល់ពេញកម្លាំង ។

ទំនុកតម្កើង ១១៩:១៤៧ ទូលបង្គំ បានភ្ញាក់មុនពេលព្រលឹមស្រាង ហើយបានបន្លឺឡើងថា ទូលបង្គំ បានសង្ឃឹមដល់ព្រះបន្ទូលទ្រង់ ។

**I. "តែផ្លូវរបស់មនុស្សសុចរិត ធៀបដូចជា ពន្លឺដែលកំពុងតែរះឡើង ដែលភ្លឺ កាន់តែខ្លាំងឡើង ដរាបដល់ពេញកម្លាំង" ។ យើងគួរតែដើរតាមដួងអាទិត្យ ដើម្បីបានស្តារឡើងវិញ និងមានការចាប់ផ្តើមថ្មីរាល់តែព្រឹក—សុភាសិត ៤:១៨:**

A. យើងត្រូវក្រោកឡើងជាមួយដួងអាទិត្យជារៀងរាល់ព្រឹក ដ្បិតសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ គឺថ្មីរាល់តែព្រឹក—បរិទេវ ៣:២២-២៣ ។

B. យើងប្រហែលជាស្ថិតក្នុងស្ថានភាពមួយដែលពេញទៅដោយការសោកសៅ ប៉ុន្តែយើងអាចរីករាយដោយការបានស្តារឡើងវិញរៀងរាល់ព្រឹក—១របាក្សត្រ ១៦:១០ ។

**II. ការបានស្តារឡើងវិញ គឺការដែលព្រះអម្ចាស់បានប៉ះពាល់យើងសារជាថ្មី ដ្បិតពេលណាដែលព្រះអម្ចាស់ប៉ះពាល់យើង យើងនឹងបានស្តារឡើងវិញ—ទំនុកតម្កើង ១១៩:១៤៧:**

A. ទំនុកតម្កើងនិយាយថា "ទូលបង្គំបាន ភ្ញាក់មុនពេលព្រលឹមស្រាង ហើយបានបន្លឺឡើង" ។ ការបន្លឺនៅទីនេះ គឺការហៅដោយនិយាយថា "អូ ព្រះអម្ចាស់!" "អូ ព្រះ អម្ចាស់យេស៊ូ ។ អូ អម្ចាស់យេស៊ូ" ។ កាលណាយើងអំពាវនាវនាមព្រះអម្ចាស់កាន់តែច្រើន នោះយើងកាន់តែបានស្រស់ថ្មី—រ៉ូម ១០:១២ ។

B. ការបន្លឺនៅទីនេះ គឺជាការអធិដ្ឋាន និងការនិយាយទៅកាន់ព្រះអម្ចាស់ ។ ការហៅបូកនិងការនិយាយទៅកាន់ព្រះអម្ចាស់ គឺប្រៀបដូចជាការដកដង្ហើមដ៏ជ្រៅរបស់មនុស្ស ។ ចូរបងប្អូននិយាយចេញនូវអ្វីទាំងអស់ដែលបងប្អូនមាន ហើយទទួលយកព្រះគុណរបស់ព្រះអម្ចាស់ចុះ—ទំនុកតម្កើង ១៤២:២ ។

C. បន្ទាប់មក យើងអាចយកមួយ ឬពីរខពីព្រះបន្ទូលដ៏បរិសុទ្ធ ដើម្បីប្រើក្នុងសេចក្ដីអធិដ្ឋានរបស់យើង ។ ចូរកុំខ្វល់ខ្វាយចំពោះការយល់របស់បងប្អូនច្រើនពេក ។ ចូរយកចិត្តទុក ដាក់ក្នុងការអំពាវនាវនាមព្រះអម្ចាស់ដោយការទាក់ទងនឹងព្រះអម្ចាស់ ដ្បិតការនេះជួយឱ្យបងប្អូនមានការទាក់ទងដោយផ្ទាល់ មានភាពស្រស់ថ្មី និងស្និទ្ធស្នាល និងប្រកបដោយសេចក្ដីស្រឡាញ់ជាមួយព្រះអម្ចាស់—អេភេសូរ ៦:១៧ ។

III. **"ព្រះយេស៊ូ ព្រះអង្គទ្រង់ចាប់ដួងចិត្តខ្ញុំ / ដួងចិត្តខ្ញុំត្រូវការទ្រង់គ្រប់វេលា / សូមទ្រង់ជួយខ្ញុំរួចពីវិធីសាសនា / ហើយគ្រាន់តែរស់ជាមួយទ្រង់ជានិច្ច / នៅពេលនេះខ្ញុំសម្លឹងមើលព្រះភក្ត្រទ្រង់ / ដួងចិត្តខ្ញុំពេញដោយសិរីព្រះអង្គ / សូមសោយរាជ្យនៅក្នុងដួងចិត្តរបស់ខ្ញុំ / ដោយវិញ្ញាណព្រះអង្គរួមជាតែមួយ" ។ (បទចម្រៀងខ្មែរលេខ ៨៣១, បទជាភាសាអង់គ្លេសលេខ ១១៥៩) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

# ភាគ២ ការហ្វឹកហាត់ខាងវិញ្ញាណ

# វាក្យសព្ទទី១៨ ការអំពាវនាវព្រះនាមព្រះអម្ចាស់

**ដកស្រង់ពី :**

រ៉ូម ១០:១២ ទ្រង់មានគ្រប់ជាបរិបូរ សម្រាប់អស់អ្នកណាដែលអំពាវរកទ្រង់ ។

ការនិយាយថា "ព្រះយេស៊ូជាព្រះម្ចាស់" ការនេះគឺជាការដែលយើងហៅព្រះនាមព្រះអម្ចាស់ ។ នេះគឺជាវិធីដ៏រីករាយក្នុងការផឹកទឹកពីប្រភពនៃសេចក្តីសង្គ្រោះរបស់ព្រះ ហើយក៏ជាវិធីដ៏រីករាយក្នុងការធ្វើឱ្យព្រះជាម្ចាស់ក្លាយជាសេចក្តីអំណររបស់យើងផងដែរ ដែលនោះគឺជាការទទួលអំណរទ្រង់នោះឯង ។

**ខ្លឹមសារ :**

រ៉ូម ១០:១២ក-១៣ ទ្រង់មានគ្រប់ជាបរិបូរ សម្រាប់អស់អ្នកណាដែលអំពាវរកទ្រង់ "ហើយគ្រប់គ្នាដែល គឺអស់អ្នកណាដែលអំពាវនាវព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ" ។

ទំនុកតម្កើង ១១៦:១៣ គឺខ្ញុំនឹងទទួលយកពែងនៃសេចក្តីសង្គ្រោះ ហើយនឹងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា ។

I. **ការនិយាយ "ព្រះយេស៊ូជាព្រះម្ចាស់" នោះជាការដែលយើងអំពាវនាវព្រះនាមព្រះអម្ចាស់"—១របាក្សត្រ ១៦:៨ :**
   A. ក្នុងភាសាក្រិក ពាក្យអំពាវនាវ មានន័យថា " ការហៅរកនរណាម្នាក់" " ការហៅនរណាម្នាក់ដោយឈ្មោះ" ឬនិយាយម្យ៉ាងទៀត គឺជាការហៅនរណាម្នាក់ដោយហៅឈ្មោះរបស់គាត់ឮៗ ។
   B. ការអំពាវនាវព្រះនាមរបស់ព្រះអម្ចាស់ ក៏មានន័យថា ស្រែកហៅរកទ្រង់ និងបទពិសោធន៍ការដកដង្ហើមខាងវិញ្ញាណ ។ យើងត្រូវការដកដង្ហើមវែងៗដោយការអំពាវនាវព្រះនាមទ្រង់ "អូ ព្រះអម្ចាស់យេស៊ូ" ។ យើងមិនគួរឈប់ដកដង្ហើមនោះទេ

។ "ហេតុនោះ ទ្រង់បានផ្ទៀងព្រះកាណ៌មកស្តាប់ខ្ញុំ បានជាខ្ញុំនឹងអំពាវនាវដល់ទ្រង់អស់១ជីវិត"—ទំនុកតម្កើង.១១៦:២ ។

II. **"ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ"— រ៉ូម.១០:១៣ :**

A. ការអំពាវព្រះនាមព្រះអម្ចាស់ គឺអាចជួយរំដោះយើងឱ្យយើងរួចផុតពី រឿងរ៉ាវអវិជ្ជមានទាំងឡាយ ដូចជាសេចក្តីឈឺចាប់ ទុកព្រួយ សេចក្តីស្លាប់ ហើយនឹងឋានឃុំព្រលឹង ។ ប្រសិនបើបងប្អូន ចង់រួចផុតពីរឿងរ៉ាវទាំងអស់នេះ បងប្អូនគួរតែអំពាវព្រះនាមព្រះអម្ចាស់—ទំនុកតម្កើង ៨៦:៧; ១១៦:៣ ។

B. យើងអាចរួមមានចំណែកក្នុងសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់ តាមរយៈការអំពាវរកទ្រង់ ។ "ខ្ញុំនឹងទទួលពែងនៃសេចក្តីសង្គ្រោះ ហើយនឹងអំពាវនាវព្រះនាមព្រះអម្ចាស់" ។

III. **ទ្រង់មានគ្រប់ជាបរិបូរ សម្រាប់អស់អ្នកណាដែលអំពាវរកទ្រង់ ។ វិធីក្នុងការទទួលអំណរភាពបរិបូររបស់ទ្រង់ គឺតាមរយៈការអំពាវនាវព្រះនាមទ្រង់—រ៉ូម ១០:១២ខ :**

A. នេះជាសេចក្តីបង្គាប់ និងជាបំណងព្រះហឫទ័យរបស់ព្រះ ដែលតម្រូវឱ្យទ្រង់ ព្រោះជាវិធីដ៏រីករាយក្នុងការផឹកទឹកពីប្រភពនៃសេចក្តីសង្គ្រោះរបស់ព្រះ ហើយក៏ជាវិធីដ៏រីករាយ ក្នុងការធ្វើឱ្យព្រះជាម្ចាស់ក្លាយជាសេចក្តីអំណររបស់យើងដែរ ដែលនោះគឺជាការទទួលអំណរទ្រង់នោះឯង ។ ហេតុដូច្នេះហើយប្រជារាស្ត្ររបស់ព្រះ ត្រូវតែអំពាវនាវរកទ្រង់ជាប្រចាំថ្ងៃ ។

B. សម្រាប់យើង វិធីដើម្បីរួមមានចំណែកក្នុងព្រះមេត្តាដ៏ធំធេងរបស់ទ្រង់ នោះគឺជាការអំពាវនាវរកទ្រង់ ។ យើងកាន់តែអំពាវនាវរកទ្រង់ច្រើនប៉ុនណា នោះយើងកាន់តែទទួលអំណរព្រះគុណរបស់ទ្រង់ច្រើនប៉ុណ្ណោះដែរ—ទំនុកតម្កើង ៨៦:៥ ។

IV. **"នាមព្រះយេស៊ូជាស័ព្ទពិរោះ កំសាន្តទុក្ខយើងរាល់គ្នា/ ទោះបីលំបាកជួបទុក្ខវេនា ខ្ញុំច្រៀងសរសើរគ្រប់គ្រា /ព្រះរាជបុត្រាប្រសើរខ្ពង់ខ្ពស់ ព្រះអង្គជាព្រះសង្គ្រោះ / កើតមកសុគតព្រះយើងរាល់គ្នា បង្ហូរលោហិតប្រោសលោះ" (បទចម្រៀងខ្មែរលេខ ៦៦ /វគ្គទី១, បទជាភាសាអង់គ្លេសលេខ ៦៦/ វគ្គទី៦) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី១៩ ការអានអធិដ្ឋានព្រះបន្ទូល

**ដកស្រង់ពី:**

អេភេសូរ ៦:១៧-១៨ យក ... ព្រះបន្ទូលរបស់ព្រះ ព្រមទាំងប្រើសេចក្តីអធិដ្ឋាន និងសេចក្តីទូលអង្វរ ។

ការអានការអធិដ្ឋានគឺដើម្បីទទួលព្រះបន្ទូលរបស់ព្រះអម្ចាស់តាមរយៈការអធិដ្ឋាន ។ តាមរយៈការអានអធិដ្ឋាន យើងទទួលបានព្រះបន្ទូលរបស់ព្រះអម្ចាស់ចូលមកក្នុងយើង ហើយតាមរយៈការកិនរំលាយសារធាតុចិញ្ចឹមនៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះព្រះបន្ទូលរបស់ព្រះអម្ចាស់ក្លាយជាការផ្គត់ផ្គង់ដល់យើង ។

**ខ្លឹមសារ:**

អេភេសូរ ៦:១៧-១៨ យក ... ព្រះបន្ទូលរបស់ព្រះ ព្រមទាំងប្រើសេចក្តីអធិដ្ឋាន និងសេចក្តីទូលអង្វរ ។

យេរេមា ១៥:១៦ ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំក៏បានទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ទ្រង់ ជាសេចក្តីអំណរ ហើយជាសេចក្តីអំណរដល់ចិត្តទូលបង្គំ ។

I. **"យក ... ព្រះបន្ទូលរបស់ព្រះ ព្រមទាំងប្រើសេចក្តីអធិដ្ឋាន និងសេចក្តីទូលអង្វរ ។—អេភេសូរ ៦:១៧-១៨:**

A. យើងយកអត្ថបទព្រះគម្ពីរមកធ្វើជាសេចក្តីអធិដ្ឋាន និងអានអធិដ្ឋាន ។ ការអានអធិដ្ឋាន គឺយើងមិនត្រឹមតែអាន និងអធិដ្ឋានក្នុងពេលដំណាលគ្នាប៉ុណ្ណោះទេ តែយើងក៏បង្វែរអត្ថបទដែលយើងកំពុងតែអាន ឱ្យទៅជាពាក្យនៃសេចក្តីអធិដ្ឋានដើម្បីអធិដ្ឋានជាមួយផងដែរ ។

B. យើងគួរតែអានអធិដ្ឋានជារៀងរាល់ថ្ងៃ ទាំងនៅក្នុងស្ថានភាពគ្រប់ប្រភេទ ។ នៅពេលណាដែលយើងមានបញ្ហាដោយសាររឿងអវិជ្ជមាននៅខាងក្នុងយើង នោះយើងគួរតែយកព្រះបន្ទូលរបស់ព្រះតាមរយៈសេចក្ដីអធិដ្ឋាន—ខ១៧ ។

C. កាលណាយើងអានអធិដ្ឋានដដែលៗបែបនេះកាន់តែច្រើន នោះអត្ថប្រយោជន៍ដែលយើងទទួលបាន គឺកាន់តែស៊ីជម្រៅ កាន់តែប្រសើរឡើង និងកាន់តែបរិបូរ—ទំនុកតម្កើង ៤២:១ ។

**II. "ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំបានទទួលទានលេបចូលអស់" ។ តាមរយៈការអានអធិដ្ឋាន យើងនឹងទទួលបានព្រះបន្ទូលរបស់ព្រះអម្ចាស់ដូចជាយើងទទួលបានអាហារដោយការបរិភោគដែរ—យេរេមា ១៥:១៦ :**

A. អង្គធាតុនៅក្នុងព្រះគម្ពីរគឺដូចជាអាហារ ។ តាមរយៈការអានអធិដ្ឋាន យើងនឹងទទួលបានព្រះបន្ទូលរបស់ព្រះអម្ចាស់ចូលទៅក្នុងយើង ហើយតាមរយៈការកិនរំលាយសារធាតុចិញ្ចឹមដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះព្រះបន្ទូលរបស់ព្រះអម្ចាស់ក្លាយជាការផ្គត់ផ្គង់ដល់យើង—ម៉ាថាយ ៤:៤ ។

B. គ្រប់ពេល មិនថាពេលថ្ងៃ ឬពេលយប់ ពេលព្រឹក ឬពេលល្ងាច យើងអាចបើកព្រះគម្ពីរហើយអានអធិដ្ឋានពីរបីខ ។ នៅទីបំផុត បងប្អូននឹងមើលឃើញថា ព្រះគម្ពីរទាំងមូល គឺជាសៀវភៅអធិដ្ឋាន ។

C. "ហើយព្រះបន្ទូលរបស់ទ្រង់ ជាសេចក្ដីអំណរ ហើយជាសេចក្ដីអំណរដល់ចិត្តទូលបង្គំ" ។ ព្រះបន្ទូលនៅក្នុងព្រះគម្ពីរ គឺជាអាហាររបស់យើង ។ ដូច្នេះ យើងគួរតែបរិភោគព្រះបន្ទូល ។

**III. "ខ្ញុំអំណរព្រះបន្ទូលដែលទ្រង់ប្រទាន / ទ្រង់ផ្គត់ផ្គង់ឱ្យរហូតដល់ខ្ញុំបាត់ឃ្លាន / ខ្ញុំវិលមកឯទ្រង់វិញ នៅក្នុងវិញ្ញាណ / ខ្ញុំក៏ឈប់ស្រេកដោយផឹកទឹកព្រះវិញ្ញាណ ។ ព្រះអង្គចិញ្ចឹមខ្ញុំឱ្យខ្ញុំបានផឹក បំពេញអស់ការឃ្លាន បំបាត់ការស្រេក ឱ្យខ្ញុំរីករាយមានកម្លាំងក្នុងជីវិត / បំពេញអស់ការឃ្លាន បំបាត់ការស្រេក"—(បទចម្រៀងខ្មែរលេខ ៥៨៦ /វគ្គទី៦, បទជាភាសាអង់គ្លេសលេខ ៨១១) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

# ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

# វាក្យសព្ទទី ២០ ការបរិភោគព្រះអម្ចាស់

**ដកស្រង់ពី :**

យ៉ូហាន ៦:៣៥ ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ.....។

ការបរិភោគគឺជាការទទួលយក ។ អ្វីដែលយើងទទួលយកនឹងក្លាយជាការផ្គត់ផ្គង់ផ្នែកខាងក្នុងរបស់យើង ។ យើងត្រូវបន្តការទទួលយកព្រះអម្ចាស់ដោយការបរិភោគទ្រង់ ។

**ខ្លឹមសារ :**

យ៉ូហាន ៦:៣៥ ព្រះយេស៊ូមានព្រះបន្ទូលថា ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ។

៥៧ខ អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងរស់ដោយសារខ្ញុំ ។

I. **ការបរិភោគ គឺជាការទទួល ។ ការបរិភោគព្រះអម្ចាស់ គឺជាជោគវាសនារបស់យើង—លោកុប្បត្តិ ២:១៦ :**
   A. បំណងព្រះទ័យរបស់ព្រះជាម្ចាស់ គឺឱ្យយើងបរិភោគទ្រង់ និងទទួលយកទ្រង់ធ្វើជាជីវិតរបស់យើង ។
   B. ប្រសិនបើយើងចង់ទទួលបានសារធាតុចិញ្ចឹម យើងត្រូវការបរិភោគ និងផឹក ។ ជារៀងរាល់ថ្ងៃ យើងគួរបរិភោគអ្វីម្យ៉ាងដែលរស់នៅលើពិភពលោកធ្វើជាសារធាតុចិញ្ចឹមរបស់យើង—យ៉ូហាន ៦:៥៤ ។

II. **ខ្ញុំជានំបុ័ងជីវិត ... អ្នកណាដែលបរិភោគខ្ញុំ អ្នកនោះនឹងរស់ដោយសារខ្ញុំ» ។ ការបរិភោគខាងវិញ្ញាណរបស់យើង ត្រូវតែនៅបន្តដោយឥតឈប់ឈរ—យ៉ូហាន ៦:៣៥, ៥៧ :**

A. អ្វីដែលយើងទទួលនឹងក្លាយជាការផ្គត់ផ្គង់ផ្នែកខាងក្នុងរបស់យើង ។ ដ្បិតដោយសារ និងតាមរយៈការផ្គត់ផ្គង់ពីនំបុ័ងជីវិតនៅផ្នែកខាងក្នុងបែបនេះហើយ ទើបយើងអាចរស់នៅលើផែនដីបាន ។

B. យើងអាចបញ្ចប់ពីការសិក្សា ប៉ុន្តែយើងមិនអាចបញ្ចប់ពីការបរិភោគបានឡើយ ។ យើងត្រូវតែបរិភោគច្រើនដងក្នុងមួយថ្ងៃ ។ ដូចគ្នានេះដែរ យើងត្រូវបន្តការទទួលយកព្រះអ-ម្ចាស់ដោយការបរិភោគទ្រង់ ។

C. "គេនឹងបានឆ្អែត ដោយរបស់ដ៏បរិបូរក្នុងដំណាក់ទ្រង់" ។ ដូច្នេះ យើងគួរបរិភោគព្រះអ-ម្ចាស់ពេញមួយថ្ងៃ—ទំនុកតម្កើង ៣៦:៨ ។

**III. "ខ្ញុំអំណរព្រះបន្ទូលដែលទ្រង់ប្រទាន ទ្រង់ផ្គត់ផ្គង់ឲ្យរហូតដល់ខ្ញុំបាត់ឃ្លាន ខ្ញុំវិលមកឯទ្រង់វិញ នៅក្នុងវិញ្ញាណ ខ្ញុំក៏ឈប់ស្រេកដោយផឹកទឹកព្រះវិញ្ញាណ"—(បទចម្រៀងខ្មែរលេខ ៥៨៦, អង់គ្លេសលេខ ៨១១) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី២១ ការផឹកព្រះអម្ចាស់

**ដកស្រង់ពី :**

យ៉ូហាន ៧:៣៧ខ ព្រះយេស៊ូទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឱ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ ។

ព្រះអង្គគឺជាទឹកនៃជីវិតសម្រាប់ឱ្យយើងផឹកទ្រង់ ។ នេះគឺជាផ្លូវដើម្បីបានទ្រង់ ព្រោះការផឹកគឺជាកាទទួល ។ តាមរយៈការផឹក យើងទទួលបានព្រះគ្រិស្តចូលមកខាងក្នុងយើង ។ វិធីដើម្បីផឹក គឺការអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ ។ ការអំពាវនាវផ្លាស់ប្តូរយើង និងអាចធ្វើឱ្យយើងរីករាយ ។

**ខ្លឹមសារ :**

យ៉ូហាន ៧:៣៧ខ ព្រះយេស៊ូទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឱ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ ។

អេសាយ ១២:៣-៤ក ដោយហេតុនោះឯងរាល់គ្នានឹងដងទឹកពីអណ្តូងនៃសេចក្តីសង្គ្រោះដោយអំណរ......ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ចូរអំពាវនាវដល់ព្រះនាមទ្រង់ !

I. **"ព្រះយេស៊ូទ្រង់ឈរបន្លឺឧទានប្រកាសឡើងថា បើអ្នកណាស្រេក ចូរឱ្យអ្នកនោះមកឯខ្ញុំ ហើយផឹកចុះ" ព្រះអង្គគឺជាទឹកនៃជីវិតសម្រាប់ឱ្យយើងផឹកទ្រង់ ។ នេះគឺជាផ្លូវដើម្បីបានទ្រង់ ព្រោះការផឹកគឺជាកាទទួល—យ៉ូហាន ៧:៣៧ខ :**

A. "ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក" ។ យើងត្រូវតែដង្ហក់រក និង ស្រេកទ្រង់ ហើយនិងផឹកទ្រង់ ដ្បិតតាមរយៈការផឹកនេះហើយ ទើបយើងទទួលបានព្រះគ្រិស្តចូលមកខាងក្នុងយើង—ទំនុកតម្កើង ៤២:១ ។

B. នៅពេលដែលយើងភ្ញាក់ពីព្រឹកព្រលឹម យើងគួរតែផឹកទឹកដ៏រស់ជាមុន ។ ខណៈពេលដែលយើងលាងសម្អាត និងស្លៀកពាក់ យើងអាចផឹកទឹកដ៏រស់ ។ យើងទាំងអស់គ្នាត្រូវតែផឹកព្រះអម្ចាស់យេស៊ូរាល់ថ្ងៃ!—យ៉ូហាន ៧:៣៧ ។

II. **"ដោយហេតុនោះឯងរាល់គ្នានឹងដងទឹកពីអណ្តូងនៃសេចក្តីសង្គ្រោះ.... ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ចូរអំពាវនាវដល់ព្រះនាមទ្រង់"—អេសាយ ១២:៣-៤ក :**

A. ទោះបីយើងនៅទីណាក៏ដោយ យើងអាចបើកទៅព្រះអង្គហើយនិយាយថា "អូព្រះ អម្ចាស់អើយ អាម៉ែន ព្រះអម្ចាស់យេស៊ូ អាម៉ែន ព្រះអម្ចាស់" ។ នេះគឺជាវិធីដើម្បីបន្តនូវការទទួលយកទ្រង់របស់យើងដោយការផឹកទ្រង់—រ៉ូម ១០:១២ខ ។

B. ជួនកាលខ្ញុំអាចដឹងខ្លួនពីបន្ទុកដ៏ធ្ងន់នៅក្នុងខ្លួនខ្ញុំ ។ ខ្ញុំក៏ចាប់ផ្តើមអំពាវនាវរកព្រះនាមព្រះអម្ចាស់ដោយស្វ័យប្រវត្ត ដ្បិតការអំពាវនាវរបស់យើងផ្លាស់ប្តូរយើង និងអាចធ្វើឱ្យយើងរីករាយ ។ ប្រសិនបើយើងចង់អំពាវនាវដល់ព្រះនាមព្រះអម្ចាស់រយៈពេលកន្លះម៉ោង នោះយើងនឹងវង្វេងស្មារតីជាមួយនឹងភាពរីករាយ—ទំនុកតម្កើង ១៤៥:១៨ ។

III. **"ខ្ញុំតាំងចិត្តហូបហើយផឹកព្រះអង្គ វិញ្ញាណទទួលទ្រង់ឡើងជាទ្វេ រហូតពោរពេញដោយទ្រង់ក្នុងកាយ ទ្រង់ប្រទានឲ្យព្រះពរជីវិត។"—(បទចម្រៀងខ្មែរលេខ ១៧៧, អង់គ្លេសលេខ ២៣៣) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី២២ ការទទួលអំណារព្រះអម្ចាស់

**ដកស្រង់ពី :**

យ៉ូហាន ៦:៣៥ក ព្រះយេស៊ូមានបន្ទូលថា ខ្ញុំជានំប៉័ងជីវិត ។

ព្រះអម្ចាស់យេស៊ូមានបន្ទូលថា "ខ្ញុំជានំប៉័ងជីវិត" ។ យើងត្រូវតែបរិភោគទ្រង់ និងទទួលអំណារទ្រង់ជាប្រចាំថ្ងៃ ។ ភាពបរិបូររបស់ទ្រង់ គឺមិនចេះរីងស្ងួតឡើយ ប្រសិនបើយើងឆ្ពោះទៅរកទ្រង់ ហើយចំណាយពេលវេលាជាមួយទ្រង់ ។ កាលណាយើងនឹងភ្លេចបញ្ហារបស់យើង នោះទឹកមុខរបស់យើង ត្រូវបានបំពេញទៅដោយសេចក្ដីរីករាយ ។

**ខ្លឹមសារ :**

យ៉ូហាន ៦:៣៥ក ព្រះយេស៊ូមានបន្ទូលថា ខ្ញុំជានំប៉័ងជីវិត ។

យ៉ូហាន ៦:៦៣ ...ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណ និងជីវិតវិញ ។

I. **ព្រះអម្ចាស់យេស៊ូមានបន្ទូលថា "ខ្ញុំជានំប៉័ងជីវិត" ។ យើងត្រូវតែបរិភោគទ្រង់ និងទទួលអំណារទ្រង់ជាប្រចាំថ្ងៃ—យ៉ូហាន ៦:៣៥ :**
   A. សភាពពិតរបស់ព្រះអម្ចាស់យេស៊ូជានំប៉័ងនៃជីវិត គឺនៅក្នុងព្រះបន្ទូលរបស់ព្រះអម្ចាស់ ។
   B. យើងកាន់តែទាក់ទង និងរែកញែកជាមួយនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ច្រើនយ៉ាងណា នោះយើងនឹងត្រូវបានបម្រុងចិញ្ចឹមកាន់តែច្រើនយ៉ាងនោះដែរ ។

II. **មានគន្លឹះពីរយ៉ាងដើម្បីទទួលអំណារព្រះអម្ចាស់ គឺព្រះបន្ទូល និងវិញ្ញាណ—យ៉ូហាន ៦:៦៣:**
   A. ដើមឡើយព្រះអង្គគឺជាព្រះបន្ទូលដែលនៅឆ្ងាយពីពួកយើង តែឥឡូវនេះ ព្រះអង្គគឺជាព្រះវិញ្ញាណដែលគង់នៅក្នុងយើង ។
   B. សរសើរតម្កើងព្រះអម្ចាស់ដែលយើងមានព្រះបន្ទូលនៅក្នុងដៃរបស់យើង ហើយនិងព្រះវិញ្ញាណនៅក្នុងវិញ្ញាណរបស់យើង ដូច្នេះដើម្បីទទួលអំណារភាពបរិបូរទាំងអស់

របស់ព្រះគ្រិស្ត យើងត្រូវតែទាក់ទងព្រះបន្ទូលផ្នែកខាងក្រៅ និងព្រះវិញ្ញាណផ្នែកខាងក្នុង ។

C. ព្រះអម្ចាស់ដែលបងប្អូនបានទាក់ទង ក្លាយជាភាពបរិបូរដែលរួមបញ្ចូលគ្រប់ទាំងអស់ដ៏មិនអាចវាស់វែងបានដល់បងប្អូន ។ ទ្រង់គឺជាអ្វីណាមួយដែលបងប្អូនត្រូវការ ។ ប្រសិនបើបងប្អូនត្រូវការការកម្សាន្តចិត្ត ព្រះអង្គគឺជាការកម្សាន្តចិត្ត ។ ប្រសិនបើបងប្អូនត្រូវការពន្លឺ ព្រះអង្គគឺជាពន្លឺ ។ ប្រសិនបើបងប្អូនត្រូវការកម្លាំង ព្រះអង្គគឺជាកម្លាំង ។ ព្រះអង្គគឺជាអ្វីគ្រប់យ៉ាងដែលបងប្អូនត្រូវការ ។

III. **ទីនេះខ្ញុំមានចិត្តត្រេកអរអំណររាល់ថ្ងៃ / ព្រោះក្ដីសុខសាន្តទ្រង់ប្រទាន / មានព្រះអង្គល្ងងលោមចម្រើនគ្រប់ពេលវេលា /ប្រទានព្រះពរទ្រង់ដល់ខ្ញុំ /នៅថ្ងៃនេះខ្ញុំផឹកទឹករស់ហូរដល់អស់កល្ប / នៅថ្ងៃនេះខ្ញុំផឹកទឹករស់នៃជី-វិត / ស្រស់ស្រាយរីករាយក្រៃ-លែង / ខ្ញុំផឹកទឹករស់នៃជី-វិត ដែលឥតមានព្រំ-ដែនកំ-ណត់ឡើយណា ។ (បទចម្រៀងខ្មែរលេខ ២៥៨, បទជាភាសាអង់គ្លេសលេខ ៣២២) ។**

# ការពន្យល់បកស្រាយសង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០ វាក្យសព្ទ

## ភាគ២ ការហ្វឹកហាត់ខាងឯវិញ្ញាណ

## វាក្យសព្ទទី ២៣ អានអធិដ្ឋាន សិក្សា ទន្ទេញ និង អធិប្បាយ

**ដកស្រង់ពី:**

អេភេសូរ ៦:១៧ ចូរយកសេចក្តីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ។

អសទអ (អានអធិដ្ឋាន សិក្សា ទន្ទេញ និង អធិប្បាយ) ។ ការអានអធិដ្ឋាន គឺជាការប្រើពាក្យពីព្រះគម្ពីរមកធ្វើជាសេចក្តីអធិដ្ឋានរបស់យើង ។ នេះគឺជាមធ្យោបាយដ៏ត្រឹមត្រូវ និងមានប្រយោជន៍បំផុត ។

**ខ្លឹមសារ :**

អេភេសូរ ៦:១៧ ចូរយកសេចក្តីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ។

កូល៉ុស ៣:១៦ក ចូរឱ្យព្រះបន្ទូលនៃព្រះគ្រិស្ត បានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង ។

១កូរិនថូស ១៤:៣១ ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា តែត្រូវសម្តែងម្នាក់ម្តងៗ ដើម្បីឱ្យគ្រប់គ្នាបានរៀនតាម ហើយឱ្យគ្រប់គ្នាបានសេចក្តីទូន្មានដែរ ។

I. **ការអានអធិដ្ឋាន គឺជាការប្រើពាក្យពីព្រះគម្ពីរមកធ្វើជាសេចក្តីអធិដ្ឋានរបស់យើង—អេភេសូរ ៦:១៧ :**

   A. គ្រប់ពាក្យនៃបទគម្ពីរទាំងមូល គឺជាការបញ្ចេញដង្ហើមរបស់ព្រះ ។ តើបងប្អូនអាចទទួលយកការបញ្ចេញដង្ហើមរបស់ព្រះចូលទៅក្នុងខ្លួនបងប្អូនដោយរបៀបណា ? គឺដោយការអធិដ្ឋានពាក្យនៃបទគម្ពីរ ។

B. មិនថានៅពេលព្រឹក ឬនៅពេលណា អស់អ្នកណាដែលបានស្គាល់រសជាតិនៃការអានអធិដ្ឋាន នោះនឹងមិនបោះបង់ការអានអធិដ្ឋានចោលឡើយ ពីព្រោះការអានអធិដ្ឋានធ្វើឱ្យយើងអាចអំណរ ។

**II. ការសិក្សា ធ្វើឱ្យយើងប្រដាប់ខ្លួនជាស្រេចក្នុងការពន្យល់បកស្រាយព្រះបន្ទូលដល់អ្នកដទៃ—កិច្ចការ ៨:៣១-៣២ ។**

**III. យើងត្រូវតែអានអធិដ្ឋាន សិក្សា និង ទន្ទេញនូវចំណុចណាដែលយើងបានសិក្សា—កូល៉ុស ៣:១៦ ។**

**IV. ការអធិប្បាយ គឺជាកានិយាយសម្រាប់ព្រះអម្ចាស់ និយាយចេញព្រះអម្ចាស់ ដើម្បីចែកចាយទ្រង់ដល់អ្នកដទៃ ដោយការនិយាយរបស់យើង—១កូរិនថូស ១៤:៣១ :**

A. នៅក្នុងបទគម្ពីរ ពួកហោរាមិនមែនជាមនុស្សធម្មតាទេ ។ ពួកគេជាមនុស្សដែលនិយាយសម្រាប់ព្រះ ។ នេះជាការដ៏មានសិរីល្អ!

B. អ្នកខ្លះមានអារម្មណ៍ថា មានតែមនុស្សមួយចំនួនប៉ុណ្ណោះ ទើបអាចមានការមានបន្ទូលរបស់ព្រះ តែព្រះគម្ពីរនិយាយថា "ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា តែត្រូវសម្តែងម្នាក់ម្តងៗ" ហើយបន្តនិយាយថា "ដូច្នេះ បងប្អូនអើយ ចូរសង្វាតឱ្យបានចេះអធិប្បាយ" ។

C. ប្រសិនបើយើងអនុវត្ត អសទ (អានអធិដ្ឋាន សិក្សា និង ទន្ទេញ) រាល់ថ្ងៃ នោះប្រាកដណាស់យើងនឹងអធិប្បាយនៅក្នុងការប្រជុំថ្ងៃព្រះអម្ចាស់ ហើយយើងគួរតែអធិប្បាយនូវអ្វីដែលយើងបានទន្ទេញ ។

**V. "សូមកាច់នំ_ប៉័ង ជី_វិត ឱ ព្រះអង្គអើយ ដូចទ្រង់បានកាច់ប្រ_ទាន ដល់ពួកសិស្ស ហើយខ្ញុំស_ង្វាតរកព្រះអង្គ ឱ ព្រះដ៏ខ្ពស់ ចិត្តខ្ញុំដ_ង្ហក់ រកព្រះប_ន្ទូល ដ៏រស់"—(បទចម្រៀងខ្មែរលេខ ៥៨៣, អង់គ្លេសលេខ ៥៨៣) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

# ភាគ៣ ព្រះបន្ទូលនៃជីវិត

# វាក្យសព្ទទី២៤ ព្រះបន្ទូលនៃជីវិត

**ដកស្រង់ពី:**

យ៉ូហាន៦:៦៣ខ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណ និងជីវិតវិញ ។

ព្រះគម្ពីរទាំងមូលគឺជាព្រះបន្ទូលនៃជីវិត ដែលជាព្រះបន្ទូលរបស់ព្រះ មិនត្រឹមតែសម្រាប់ឱ្យយើងរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ឱ្យយើងភ្លក់ និងអំណរទៀតផង ។ ដូច្នេះ យើងត្រូវតែចូលមកឯព្រះបន្ទូលនៃជីវិតដែលជាព្រះគម្ពីរជាប្រចាំថ្ងៃ ។

**ខ្លឹមសារ:**

យ៉ូហាន ៦:៦៣ខ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណ និងជីវិតវិញ ។

ម៉ាថាយ ៤:៤ មនុស្សមិនមែនរស់ ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូល ដែលចេញពីព្រះឱស្ឋព្រះមកដែរ ។

I. **"ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណ និងជីវិតវិញ"—យ៉ូហាន ៦:៦៣ :**

   A. ដើម្បីឱ្យព្រះក្លាយជាជីវិតរបស់មនុស្ស ព្រះអង្គត្រូវតែក្លាយជាព្រះបន្ទូលដើម្បីចេញមកឯមនុស្ស ក្នុងចំណោមមនុស្ស និងចូលទៅក្នុងមនុស្ស—១:១ ។
   B. ព្រះបន្ទូលរបស់ព្រះ មិនត្រឹមតែសម្រាប់ឱ្យយើងរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ឱ្យយើងភ្លក់ អំណរ និងយកចូលមកក្នុង ដែលនោះគឺសម្រាប់ឱ្យយើងបរិភោគទៀតផង ។
   C. ពេលណាក៏ដោយឱ្យតែយើងចូលមកឯព្រះគម្ពីរ យើងត្រូវតែដឹងថា យើងកំពុងតែមកទាក់ទងព្រះគ្រិស្ដជាជីវិតរបស់យើង—៦:៦៣ ។

II. **ក្នុងនាមជាព្រះបន្ទូលនៃជីវិត ព្រះគម្ពីរគឺជាអាហារសម្រាប់យើង ។ ដូច្នេះ យើងត្រូវតែចូលមកឯព្រះបន្ទូលនៃជីវិតដែលជាព្រះគម្ពីរជាប្រចាំថ្ងៃ—ម៉ាថាយ ៤:៤; យេរេមា ១៥: ១៦ :**

A. ប្រសិនបើយើងចូលមកឯព្រះគម្ពីរជាមួយនឹងវិញ្ញាណដ៏រស់ ដោយស្វ័យប្រវត្តិ យើងនឹងអំណរព្រះបន្ទូលនៃជីវិត ។ បន្ទាប់មក យើងនឹងបានផ្គត់ផ្គង់ ចម្រើនកម្លាំង រហ័សរហួន បំភ្លឺ ស្រស់ថ្មី បម្រុងចិញ្ចឹម និងលាងសម្អាត ។

B. ពេលណាក៏ដោយឱ្យតែយើងយក និងរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះយើងទទួល បានការផ្គត់ផ្គង់ជីវិត បន្ទាប់មកយើងនឹងទទួលបានការផ្គត់ផ្គង់ដ៏ពិត និងបរិភោគពឹងលើព្រះអម្ចាស់តាមរយៈការអានព្រះបន្ទូល—ម៉ាថាយ.៤:៤ ។

C. ពេលដែលយើងបានបរិភោគព្រះបន្ទូល ព្រះបន្ទូលក្លាយជាសេចក្ដីអំណរនៅផ្នែកខាងក្នុង និងជាសេចក្ដីរីករាយផ្នែកខាងក្រៅ—យេរេមា ១៥:១៦ ។

III. **ព្រះអង្គចិត្តខ្ញុំក៏ឃ្លាន វិញ្ញាណក៏ស្រេក /ខ្ញុំចង់ឱ្យទ្រង់ផ្គត់-ផ្គង់ /ចិ-ញ្ចឹមគ្រប់ពេល / អ្វីដែលខ្ញុំត្រូវការមានតែទ្រង់មួយទេ / ទ្រង់បំ-បាត់ការហេវស្រេក ឱ្យខ្ញុំស្ងប់ចិត្ត / ព្រះអង្គចិ-ញ្ចឹមខ្ញុំឱ្យខ្ញុំបានផឹក /បំ-ពេញអស់ការឃ្លាន បំ-បាត់ការស្រេក / ឱ្យខ្ញុំរីករាយមានកម្លាំងក្នុងជី-វិតបំពេញអស់ការឃ្លាន បំ-បាត់ការស្រេក ។ (បទជាភាសាខ្មែរលេខ ៥៨៦, បទជាភាសាអង់គ្លេស ៨១១ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៣ ព្រះបន្ទូលនៃជីវិត

## វាក្យសព្ទទី២៥ ព្រះគម្ពីរច្បាប់ស្ដារឡើងវិញ

**ដកស្រង់ពី :**

ទំនុកតម្កើង ១១៩:១៣០ ការបើកសម្ដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ ក៏ធ្វើឱ្យមនុស្សឆោតល្ងង់មានយោបល់ ។

ព្រះគម្ពីរច្បាប់ស្ដារឡើងវិញ ធ្វើតាមគំរូមុនៗដែលបានកំណត់ដោយអ្នកនិពន្ធសំខាន់ ដែលមានជាភាសាអង់គ្លេស និងយកឯកសារទាំងនេះធ្វើជាឯកសារយោង ដោយស្រាវជ្រាវយ៉ាងទូលំទូលាយទៅលើអត្ថន័យនៃអត្ថបទដើម និងព្យាយាមបង្ហាញអត្ថន័យនេះជាមួយភាសាអង់គ្លេស ដើម្បីដល់ចំណុចងាយស្រួលយល់ និងអាចអានបាន ។ យើងត្រូវការឱ្យតម្លៃព្រះគម្ពីរ និងអានដោយយកចិត្តទុកដាក់ ។

**ខ្លឹមសារ :**

ទំនុកតម្កើង ១១៩:១៣០ ការបើកសម្ដែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ ក៏ធ្វើឱ្យមនុស្សឆោតល្ងង់មានយោបល់ ។

២ធីម៉ូថេ ៣:១៦ គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឱ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឮកឱ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ។

I. ព្រះគម្ពីរច្បាប់ស្ដារឡើយវិញ ស្រាវជ្រាវយ៉ាងទូលំទូលាយទៅលើអត្ថន័យនៃអត្ថបទដើម និងព្យាយាមបង្ហាញអត្ថន័យនេះជាមួយភាសាអង់គ្លេស ដើម្បីដល់ចំណុចងាយស្រួលយល់ និងអាចអានបាន—**២ធីម៉ូថេ ៣:១៦**:

   A. ព្រះគម្ពីរច្បាប់ស្ដារឡើងវិញ ធ្វើតាមគំរូមុនៗដែលបានកំណត់ដោយអ្នកនិពន្ធ សំខាន់ដែលមានជាភាសាអង់គ្លេស និងយកឯកសារទាំងនេះធ្វើជាឯកសារយោង ដោយមិនត្រឹមតែរួមបញ្ចូលមេរៀន ដែលទទួលបានពីការពិនិត្យលើការអនុវត្តរបស់អ្នកដទៃប៉ុណ្ណោះ

ទេ តែថែមទាំងព្យាយាមជៀសវាងពីភាពលម្អៀង និងការវិនិច្ឆ័យមិនត្រឹមត្រូវផង ដែរ—២:១៥ ។

B. ច្បាប់នេះ ដឹកនាំយ៉ាងសេរីដោយច្បាប់ផ្សេងទៀត ដោយព្យាយាមផ្តល់នូវពាក្យពេចន៍សម្រាប់ការបើកសម្តែងនៅក្នុងព្រះបន្ទូលរបស់ព្រះដ៏ល្អបំផុត ដែលអាចបានបង្ហាញនៅក្នុងភាសាអង់គ្លេសដ៏អស្ចារ្យ និងត្រឹមត្រូវបំផុត ។

II. ការបកប្រែនេះ អាចត្រូវបានចាត់ទុកថា ជាការប្រមូលផ្តុំចំណេះដឹងនៃការបើកសម្តែងរបស់ព្រះ ដែលពួកបរិសុទ្ធទាំងអស់បានទទួលក្នុងរយៈពេលពីរពាន់ឆ្នាំចុងក្រោយនេះ—ទំនុកតម្កើង ១១៩:១៣០:

A. អស់រយៈពេលជាច្រើនសតវត្សរ៍ ការយល់ដឹងអំពីការបើកសម្តែងរបស់ព្រះដែលពួកបរិសុទ្ធបានកាន់កាប់ គឺតែងតែពឹងផ្អែកលើពន្លឺដែលពួកគេបានទទួល ហើយការយល់ដឹងនេះបានរីកចម្រើនជាលំដាប់ ។

B. យើងបានទទួលមរតកនៃសេចក្តីពិតដែលពួកគេបានឃើញ ហើយដោយព្រះមេត្តាករុណារបស់ព្រះអម្ចាស់ យើងកំពុងឈរនៅលើស្មារបស់ពួកគេ និងបានបន្តទៅមើលទៀត ។

III. ខអធិប្បាយទាំងឡាយសង្កត់ធ្ងន់លើការបើកសម្តែងនៃសេចក្តីពិត ពន្លឺខាងវិញ្ញាណ និងការផ្គត់ផ្គង់នៃជីវិត—យ៉ូហាន ៦:៦៣:

A. ខអធិប្បាយទាំងឡាយ គឺជួយយើងដោះស្រាយបញ្ហាធម្មតា និងបញ្ហាលំបាកទាំងឡាយនៅក្នុងគម្ពីរសញ្ញាថ្មី—ទំនុកតម្កើង ១១៩:១៣០ ។

B. ខអធិប្បាយទាំងឡាយ គឺចែកចាយនូវការផ្គត់ផ្គង់ជីវិតដល់បងប្អូន—យ៉ូហាន ៦:៦៣ ។

IV. "មានតែព្រះបន្ទូលយើងអាចស្គាល់ព្រះអង្គ មានតែព្រះបន្ទូលយើង ស្តាប់សូរសៀងទ្រង់បើកសម្តែងសេចក្តីពិត ដល់គ្រប់មនុស្ស ហើយសម្តែងអង្គទ្រង់តាមបទគម្ពីរនោះ។"—(បទចម្រៀងខ្មែរលេខ ៥៨១, អង់គ្លេសលេខ ៨0១) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៣ ព្រះបន្ទូលនៃជីវិត

## វាក្យសព្ទទី២៦ ការស្គាល់បទចម្រៀង

**ដកស្រង់ពី :**

កូល៉ុស ៣:១៦ ទាំងបង្រៀន ហើយទូន្មានគ្នា ដោយនូវទំនុកតម្កើង ទំនុកបរិសុទ្ធ និង ចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ ។

បទចម្រៀង គឺជាការបង្ហាញពីអារម្មណ៍ល្អបំផុតរបស់មនុស្ស ។ យើងដែលជាគ្រិស្ទាន គឺ ជាអ្នកដែលមានបទចម្រៀង និងជាមនុស្សដែលច្រៀង ។ បងប្អូនអាចច្រៀងតាមរបៀបដែល ខុសជាមួយនឹងទំនុកភ្លេង ប៉ុន្តែ បងប្អូនកាន់តែច្រៀង បងប្អូនកាន់តែរីករាយ ។ បងប្អូនកាន់តែ ច្រៀង បងប្អូនកាន់តែស្រស់ស្រាយ ។

**ខ្លឹមសារ :**

កូល៉ុស ៣:១៦ ទាំងបង្រៀន ហើយទូន្មានគ្នា ដោយនូវទំនុកតម្កើង ទំនុកបរិសុទ្ធ និង ចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ ។

ទំនុកតម្កើង ១០៤:៣៣ កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ា ។

I. **បទចម្រៀង គឺជាការបង្ហាញពីអារម្មណ៍ល្អបំផុតរបស់មនុស្ស ។** យើងគួរតែមានចំនេះដឹង ជាមូលដ្ឋានអំពីបទចម្រៀង ព្រោះដើម្បីស្គាល់បទចម្រៀងបាន យើងត្រូវដឹងអំពីចំណុច សំខាន់មួយចំនួនពីខ្លឹមសារនៃបទចម្រៀង—**កូល៉ុស ៣:១៦ :**
   A. ដំបូង យើងត្រូវតែស្គាល់បទចម្រៀងខ្លះៗ ដែលទាក់ទងនឹងការប្រទានពរ និងការ បទពិសោធន៍ព្រះត្រីឯក ។
   B. ចំណុចសំខាន់ពីខ្លឹមសារនៃបទចម្រៀងមួយទៀត គឺការចាក់បំពេញដោយព្រះវិញ្ញាណ ។
   C. យើងត្រូវតែស្គាល់បទចម្រៀងមួយចំនួន ដែលទាក់ទងនឹងការបានដូចគ្នាប៉េះបិទ ជាមួយនឹងព្រះគ្រិស្ត ។

D. ការបទពិសោធន៍ព្រះគ្រិស្ត គឺជាចំណុចសំខាន់មួយផ្សេងទៀតពីខ្លឹមសារនៃបទចម្រៀង ។

E. យើងត្រូវតែស្គាល់បទចម្រៀងលើចំណុចសំខាន់ៗនៃជីវិតខាងក្នុង ក្រុមជំនុំ ការផានានៃសេចក្ដីសង្គ្រោះ ការថ្វាយខ្លួន និងការកម្សាន្តចិត្តក្នុងពេលមានទុក្ខលំបាក ។

F. យើងក៏ត្រូវតែស្គាល់បទចម្រៀងលើចំណុចសំខាន់ៗនៃសង្គ្រាមខាងវិញ្ញាណ ដំណឹងល្អការប្រជុំ ទីសង្ឃឹមយ៉ាងឧត្ដម និងការលេចចេញចុងក្រោយផងដែរ ។

**II. យើងដែលជាគ្រិស្ទាន គឺជាអ្នកដែលមានបទចម្រៀង និងជាមនុស្សដែលច្រៀង—ទំនុកតម្កើង ១០៤:៣៣ :**

A. ការប្រជុំគួរតែពេញដោយការច្រៀង និងការសរសើរតម្កើង ។ នៅពេលដែលយើងមកប្រជុំ យើងត្រូវតែបើកមាត់របស់យើង ព្រោះនៅពេលដែលមាត់របស់យើងបើកចិត្តរបស់យើងបើក ហើយវិញ្ញាណរបស់យើងក៏បើកផងដែរ—កូល៉ុស ៣:១៦ ។

B. ខ្ញុំតែងតែច្រៀងជានិច្ច ។ ជារៀងរាល់ថ្ងៃ ពេលខ្ញុំដើរលេង ខ្ញុំច្រៀង ។ ចំពោះតន្ត្រី ខ្ញុំមិនពូកែទេ ប៉ុន្តែ ខ្ញុំចូលចិត្តច្រៀងច្រើនជាងអ្វីៗទាំងអស់ ។ ពេលខ្ញុំច្រៀងតាមរបៀបនេះ នោះការព្រួយបារម្ភទាំងឡាយរបស់ខ្ញុំ បានបាត់ទៅ ហើយជម្ងឺទាំងអស់ត្រូវបានដកចេញ ។ សរសើរតម្កើងព្រះអម្ចាស់សម្រាប់ការប្រទានបទចម្រៀងល្អៗជាច្រើនដល់យើង ។

**III. "សរសើរកូនចៀមកាន់តែខ្លាំងឡើង ទាំងជួបជុំគ្នាលើកតម្កើង សំនៀងរាប់ម៉ឺនប្រគំមូលមី ស្រែកអឺងកងពេញផ្ទៃប្រថពី"—(បទចម្រៀងខ្មែរលេខ ១១០,អង់គ្លេសលេខ ១២៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៣ ព្រះបន្ទូលនៃជីវិត

## វាក្យសព្ទទី២៧ មេរៀសិក្សាជីវិតនៃព្រះគម្ពីរ

**ដកស្រង់ពី:**

យ៉ូហាន ៥:៣៩ អ្នករាល់គ្នាស្ទង់មើលគម្ពីរ ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ ។

គោលបំណងសំខាន់នៃមេរៀនសិក្សាជីវិត គឺដើម្បីចែកចាយជីវិត ។ មេរៀនសិក្សាជីវិតទាំងប៉ុន្មាន មិនមែនជំនួសឱ្យព្រះគម្ពីរទេ ប៉ុន្តែជាការបើកសម្តែង និងការពន្យល់ពីព្រះគម្ពីរ ។ យើងគួរតែស្រឡាញ់ព្រះគម្ពីរ និងធ្វើឱ្យខ្លួនយើងចូលទៅក្នុងព្រះគម្ពីរ តាមរយៈការសិក្សាអំពីមេរៀនសិក្សាជីវិត ។

**ខ្លឹមសារ :**

យ៉ូហាន ៥:៣៩ អ្នករាល់គ្នាស្ទង់មើលគម្ពីរ ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក គឺជាគម្ពីរនោះឯង ដែលធ្វើបន្ទាល់ពីខ្ញុំ ។

ទំនុកតម្កើង ១១៩:១៣០ ការបើកសម្តែងព្រះបន្ទូលទ្រង់ នោះផ្សាយពន្លឺចេញ ក៏ធ្វើឱ្យមនុស្សឆោតល្ងង់មានយោបល់ ។

I. **លក្ខណៈពិសេសនៃមេរៀនជីវិត គឺជាការចង្អុលបង្ហាញពីប្រធានបទសំខាន់ៗ និងទិដ្ឋភាពទាំងអស់—ទំនុកតម្កើង ១១៩:១៣០:**
   A. នៅពាសពេញយុគសម័យកាល ការពិបាកបំផុតសម្រាប់ពួកអ្នកអានព្រះគម្ពីរ គឺថាការយល់ដឹងអំពីព្រះគម្ពីររបស់ពួកគេ ត្រូវបានបែកខ្ញែក និងរាក់សើរៗ ។
   B. មេរៀនសិក្សាជីវិតទាំងឡាយ មានចំណុចកណ្តាលមួយ ហើយក៏មានការពន្យល់ និងនិយមន័យជាក់លាក់ពីរឿងរ៉ាវផ្សេងៗផងដែរ ហេតុដូច្នេះហើយទើបពួកអ្នកអានក៏យល់បានដូចគ្នា ។

C. យើងអាចពិនិត្យមើលប្រភេទ(តួយ៉ាង)ទាំងនេះ ដោយការបទពិសោធន៍ជាក់ស្តែងរបស់យើង ហើយអនុវត្តប្រភេទ(តួយ៉ាង)ទាំងនេះនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង ។

II. **មុខងាររបស់មេរៀនទាំងឡាយនៃមេរៀនសិក្សាជីវិតរួមមាន—យ៉ូហាន ៥:៣៩:**

A. គឺនាំមនុស្សចូលទៅក្នុងសេចក្តីពិតនៃព្រះគម្ពីរ—ទំនុកតម្កើង ១១៩: ១៣០ ។

B. គឺដឹកនាំមនុស្សឱ្យប៉ះពាល់ជីវិត—យ៉ូហាន ៥:៣៩ ។

C. ប្រសិនបើយើងយកមេរៀនទាំងឡាយនៃមេរៀនសិក្សាជីវិត ធ្វើជាខ្លឹមសារនៃការប្រកបគ្នារបស់យើង នោះការប្រជុំនឹងមានភាពបរិបូរ ។

D. តាមរយៈការសិក្សាអំពីមេរៀនសិក្សាជីវិត យើងអាចបង្ហាញភស្តុតាង និងអាចធ្វើទីបន្ទាល់បានថា យើងស្រឡាញ់ព្រះគម្ពីរច្រើនប៉ុនណា ហើយយើងធ្វើឱ្យខ្លួនយើងចូលទៅក្នុងព្រះគម្ពីរបានច្រើនប៉ុនណា ។

III. **"សូមកាច់នំ-ប៉័ងជី-វិត / ឱ្យព្រះអង្គអើយ ដូចទ្រង់ / បានកាច់ប្រ-ទានដល់ពួកសិស្ស / ហើយខ្ញុំស-ង្វាតរកព្រះអង្គ / ឱ្យព្រះដ៏ខ្ពស់ចិត្ត / ខ្ញុំដ-ង្ហក់រកព្រះបន្ទូលដ៏រស់"** (បទចម្រៀងជាភាសាខ្មែរលេខ ៥៨៣ ,អង់គ្លេសលេខ ៨០៦) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៣ ព្រះបន្ទូលនៃជីវិត

## វាក្យសព្ទទី ២៨ ការសិក្សាសរុបរួមនៃព្រះគម្ពីរ

**ដកស្រង់ពី :**

១ធីម៉ូថេ ២:៤ ដែលទ្រង់សព្វព្រះហឫទ័យ ឱ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឱ្យបានស្គាល់ សេចក្តីពិត ។

ការសិក្សាសរុបរួមនៃព្រះគម្ពីរ គឺជាការយល់នូវផ្នែកខាងក្នុងដ៏ពិតប្រាកដពីអ្វីដែលព្រះគម្ពីរបង្រៀន ដែលជាធាតុដើមផ្នែកខាងក្នុងនៃការបើកសម្តែងរបស់ព្រះ ។ ប្រាកដណាស់ យើងត្រូវតែចូលទៅដល់ចំណុចកំពូលនៃការសិក្សាខាងឯវិញ្ញាណ ។

**ខ្លឹមសារ :**

១ធីម៉ូថេ ២:៤ ដែលទ្រង់សព្វព្រះហឫទ័យ ឱ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឱ្យបានស្គាល់សេចក្តីពិត ។

នេហេមា ៨:៨ ពួកអ្នកទាំងនោះបានអានមើល ក្នុងគម្ពីរក្រឹត្យវិន័យរបស់ព្រះ ព្រមទាំងស្រាយន័យសេចក្តីឱ្យគេបានយល់បទដែលអានមើលនោះ ។

I. **ការសិក្សាសរុបរួមនៃព្រះគម្ពីរ គឺជាការយល់នូវផ្នែកខាងក្នុងដ៏ពិតប្រាកដ ពីអ្វីដែលព្រះគម្ពីរបង្រៀន ដែលជាធាតុដើមផ្នែកខាងក្នុងនៃការបើកសម្តែងរបស់ព្រះ—នេហេមា ៨:៨ :**
   A. ការសិក្សាសរុបរួមនៃព្រះគម្ពី គឺជាការសិក្សាមួយដែលកាន់តែស៊ីជម្រៅជាងមេរៀនសិក្សាជីវិតនៃព្រះគម្ពីរ ។
   B. ភាពបរិបូរណ៍ទាំងអស់ គឺមាននៅក្នុងព្រះគម្ពីរ ប្រៀបដូចជាមាសនៅក្នុងអណ្តូងរ៉ែជាយ៉ាងណា នោះយើងក៏ត្រូវតែចូលទៅដល់ទីជម្រៅនៃការសរុបរួមរបស់បទគម្ពីរបរិសុទ្ធយ៉ាងនោះដែរ ។

C. តាមរយៈការសរុបរួមនៃព្រះគម្ពីរបែបនេះ ព្រះអម្ចាស់អាចបើកសម្តែងធាតុដើមផ្នែកខាងក្នុងនៃការបើកសម្តែងរបស់ព្រះមកដល់យើង ពីមួយវគ្គទៅមួយវគ្គ ដ្បិតនេះជាធាតុដើមដើម្បីបម្រុងចិញ្ចឹមយើង ។

**II. "ដែលទ្រង់សព្វព្រះហឫទ័យ ឱ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឱ្យបានស្គាល់សេចក្តីពិត" បងប្អូនត្រូវតែរៀនចូលទៅក្នុងសេចក្តីពិត និយាយសេចក្តីពិត និងអនុញ្ញាតឱ្យសេចក្តីពិតទាំងនោះ ក្លាយមកជាបទពិសោធន៍របស់បងប្អូន—១ធីម៉ូថេ ២:៤ :**

A. យើងមិនគួរក្លាយជាពួកអ្នកដែល "ជិះស្គីលើទឹកកក" នៃព្រះបន្ទូលនោះទេ ។ យើងត្រូវតែបំបែកទឹកកក និងចូលទៅក្នុងទីជម្រៅនៃសេចក្តីពិត ។

B. នៅក្នុងផ្លូវនៃសេចក្តីពិត ព្រះអម្ចាស់បានលើកយើងឡើងទាំងស្រុង ព្រោះក្នុងចំណោមគ្រិស្ទានទាំងអស់ ពួកយើងបានឈរនៅលើចំណុចកំពូលក្នុងការស្គាល់សេចក្តីពិត ។

C. ប្រាកដណាស់ យើងត្រូវតែចូលទៅដល់ចំណុចកំពូលនៃការអប់រំខាងវិញ្ញាណ ការលើកស្ទួយរឿងរ៉ាវទាំងនេះ ការបំពេញសម្រេចរឿងរ៉ាវនេះ និងការចូលទៅក្នុងរឿងរ៉ាវទាំងនេះ ។

**III. "សូមប្រោសឱ្យខ្ញុំបានភ្លឺយល់សេចក្តីពិត ដូចបានប្រោសដល់ពួកសិស្សកាលទ្រង់គង់ជិតនោះអស់ចំណាងនៃបាបនឹងត្រូវផ្តាច់ចេញ ហើយខ្ញុំនឹងមានចិត្តបរិសុទ្ធពោរពេញ" (បទចម្រៀងជាភាសាខ្មែរលេខ ៥៨៣, អង់គ្លេសលេខ ៨០៦) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៣ ព្រះបន្ទូលនៃជីវិត
## វាក្យសព្ទទី ២៩ ព្រះបន្ទូលបរិសុទ្ធសម្រាប់ស្តារឡើងវិញពេលព្រឹក

**ដកស្រង់ពី :**

ទំនុកតម្កើង ១១៩:១៤៧ ទូលបង្គំបានភ្ញាក់មុនពេលព្រលឹមស្រាង ហើយបានបន្លឺឡើងថា ទូលបង្គំបានសង្ឃឹមដល់ព្រះបន្ទូលទ្រង់ ។

*ព្រះបន្ទូលបរិសុទ្ធសម្រាប់ស្តារឡើងវិញពេលព្រឹក* ដែលមានផ្ទុកនូវអត្ថបទព្រះគម្ពីរខយោង ឬខអធិប្បាយ និងមេរៀនសិក្សាជីវិតទាំងឡាយ គឺសម្រាប់ឱ្យយើងអានអធិដ្ឋាន និងទទួលអំណរព្រះអម្ចាស់រាល់ពេលព្រឹក ។ នៅទីនោះ យើងរស់ដោយបរិភោគព្រះគ្រិស្ត ដើម្បីទទួលអំណរ និងភ្លក់ទ្រង់ ។ យើងត្រូវការរៀនទទួលអំណរព្រះអម្ចាស់តាមរបៀបនេះ ។

ខ្លឹមសារ :

ទំនុកតម្កើង ១១៩:១៤៧ ទូលបង្គំបានភ្ញាក់មុនពេលព្រលឹមស្រាង ហើយបានបន្លឺឡើងថា ទូលបង្គំបានសង្ឃឹមដល់ព្រះបន្ទូលទ្រង់ ។

សុភាសិត ៤:១៨ តែផ្លូវរបស់មនុស្សសុចរិត ធៀបដូចជាពន្លឺដែលកំពុងតែរះឡើង ដែលភ្លឺកាន់តែខ្លាំងឡើង ដរាបដល់ពេញកម្លាំង ។

I. **ព្រះបន្ទូលបរិសុទ្ធសម្រាប់ស្តារឡើងវិញពេលព្រឹក បានជួយដល់ពួកបរិសុទ្ធឱ្យបានស្តារឡើងវិញដោយព្រះអម្ចាស់ជារៀងរាល់ព្រឹក ។ វិធីដែលមានប្រសិទ្ធភាពបំផុត ដើម្បីដំណើរជីវិតគ្រិស្ទាន គឺដោយមានការទ្រទ្រង់ជីវិត រស់នៅ និងសកម្មចាំយាមជាមួយនឹងព្រះអម្ចាស់នៅពេលព្រឹក—សុភាសិត ៤:៨ :**

   A. នៅពេលយើងទទួលអំណរព្រះអម្ចាស់ ជាមួយនឹងសម្ភារស្តារឡើងវិញពេលព្រឹកនៅពេលព្រឹក យើងអានប្រយោគច្រើន ដោយមិនត្រឹមតែអានពាក្យជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវបង្វែរពាក្យទាំងប៉ុន្មានឱ្យទៅជាសេចក្តីអធិដ្ឋានផងដែរ ។

B. នៅទីនោះ យើងរស់ដោយបរិភោគព្រះគ្រិស្ត ដើម្បីទទួលអំណរ និងភ្លក់ទ្រង់ ។ នៅពេលយើងទទួលអំណរព្រះគ្រិស្តតាមរបៀបដោយការរស់ ដោយបរិភោគទ្រង់បែបនេះ យើងត្រូវបានស្កប់ចិត្ត—ទំនុកតម្កើង ៤២:៧ ។

II. ***ព្រះបន្ទូលបរិសុទ្ធសម្រាប់ស្តារឡើងវិញពេលព្រឹក*** **ដែលមានផ្ទុកនូវអត្ថបទព្រះគម្ពីរខយោង ឬខអធិប្បាយ និងមេរៀនសិក្សាជីវិតទាំងឡាយ គឺសម្រាប់ឱ្យយើងអានអធិដ្ឋាន និងទទួលអំណរព្រះអម្ចាស់រាល់ពេលព្រឹក—ទំនុកតម្កើង ១១៩:១៤៧-១៤៨ :**

A. ខគម្ពីរទាំងឡាយមិនចាំបាច់មានការពន្យល់បន្ថែមទេ ។ តម្រូវការតែមួយគត់ គឺត្រូវអានដដែលៗ និងអានសង្កត់ធ្ងន់ ។ ការអានដដែលៗ គឺជាការអានផ្ទួនៗ (ច្រំដែល) រីឯការអានសង្កត់ធ្ងន់ គឺជាការអានផ្តោតសំខាន់លើ ។

B. ការអានអធិដ្ឋាន មានផ្ទុកនូវការអានដដែលៗ អានសង្កត់ធ្ងន់ និងការអានឱ្យមានជីវិត ។ ទាំង ៤ របៀបនេះបានលាយបញ្ចូលគ្នា គឺជាវិធីអានដ៏ល្អបំផុត ។

C. "ខ្ញុំហូបហើយខ្ញុំផឹកដោយអានអធិដ្ឋាន អានអធិដ្ឋានអាចឱ្យខ្ញុំស្កប់ចិត្តបាន" ។ យើងកាន់តែអានអធិដ្ឋាន យើងកាន់តែមានអារម្មណ៍ថាព្រះបន្ទូលបរិបូរប៉ុនណា—(បទចម្រៀងខ្មែរលេខ ៥៨៦ វគ្គទី៧ , អង់គ្លេសលេខ ៨១១) ។

III. **សូមហូប និងសូមផឹកពីព្រះអង្គយេស៊ូ / សូមហូបដោយការអាន ផឹកដោយអធិដ្ឋាន / ខ្ញុំហូបហើយខ្ញុំផឹកដោយអានអធិដ្ឋាន / អានអធិដ្ឋានអាចឱ្យខ្ញុំស្កប់ចិត្តបាន /*ព្រះអង្គចិញ្ចឹមខ្ញុំ ឱ្យខ្ញុំបានផឹក / បំពេញអស់ការឃ្លាន បំបាត់ការស្រេក / ឱ្យខ្ញុំរីករាយ មានកម្លាំងក្នុងជីវិត / បំពេញអស់ការឃ្លាន បំបាត់ការស្រេក* —(បទចម្រៀងខ្មែរលេខ ៥៨៦ វគ្គទី៧ , អង់គ្លេសលេខ ៨១១) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

### វាក្យសព្ទទី៣០ ការបំពេញ(ចម្អែត)អ្នកស្រេកឃ្លានដោយរបស់ល្អ

ដកស្រង់ពី :

លូកា ១:៥៣ ឯមនុស្សឃ្លាន ទ្រង់បានចម្អែតដោយរបស់ល្អ តែពួកអ្នកមាន ទ្រង់បាន បណ្តេញឱ្យទៅទទេវិញ ។

ព្រះគុណរបស់ព្រះ ត្រូវបានបម្រុងទុកសម្រាប់មនុស្សមួយប្រភេទ នោះគឺអ្នកស្រេកឃ្លាន ។ យើងត្រូវតែដឹងថា ការជឿនទៅមុខខាងឯវិញ្ញាណ គឺផ្អែកលើការស្រេកឃ្លានរបស់យើង ។ មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត ។

ខ្លឹមសារ :

លូកា ១:៥៣ ឯមនុស្សឃ្លាន ទ្រង់បានចម្អែតដោយរបស់ល្អ តែពួកអ្នកមាន ទ្រង់បានបណ្តេ-ញឱ្យទៅទទេវិញ ។

ម៉ាថាយ ៥:៦ មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត ។

I. លូកា ១:៥៣ និយាយថា "ឯមនុស្សឃ្លាន ទ្រង់បានចម្អែតដោយរបស់ល្អ តែពួកអ្នក មាន ទ្រង់បានបណ្តេញឱ្យទៅទទេវិញ" ខនេះបង្ហាញឱ្យយើងឃើញថា ព្រះគុណរបស់ព្រះ ត្រូវបានបម្រុងទុកសម្រាប់មនុស្សមួយប្រភេទ នោះគឺអ្នកស្រេកឃ្លានម្នាក់ :
   A. មានតែអស់អ្នកដែលមានតម្រូវការខ្លាំងនៅផ្នែកខាងក្នុង និងអស់អ្នកដែលបានតាំងចិត្តដើម្បីជួបព្រះប៉ុណ្ណោះ ទើបនឹងទទួលព្រះគុណរបស់ទ្រង់ ។
   B. យើងត្រូវដឹងថា ការជឿនទៅមុខខាងឯវិញ្ញាណ គឺផ្អែកទៅលើការស្រេកឃ្លានរបស់យើង ។

II. ម៉ាថាយ ៥:៦ និយាយថា "មានពរហើយ អស់អ្នកដែលស្រេកឃ្លាននូវសេចក្តីសុចរិត ដ្បិតអ្នកទាំងនោះនឹងបានឆ្អែត" ពួកអ្នកដែលស្រេកឃ្លាន នឹងបានឆ្អែត ដ្បិតពួកគេគឺជាពួកអ្នកដែលមានពរ ។

A. រាល់ការជឿនទៅមុខខាងឯវិញ្ញាណទាំងអស់ ចាប់ផ្តើមនៅពេលដែលព្រះចាប់ផ្តើមធ្វើការល្អនៅក្នុងមនុស្សតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដោយការបង្កើតឱ្យមានចំណង់យ៉ាងខ្លាំងនៅផ្ទៃកខាងក្នុង ។

B. ការដុនដាប គឺចេញមកពីការព្រងើយកន្តើយពីខ្លួនឯង រីឯការជឿនទៅមុខ គឺចេញមកពីការស្រេកឃ្លាន ។ ដំបូង ព្រះវិញ្ញាណបរិសុទ្ធបង្កើតឱ្យមានសេចក្តីប៉ងប្រាថ្នាដែលមិនចេះអស់នៅក្នុងយើងកាន់តែច្រើន ហើយបន្ទាប់មកព្រះជាម្ចាស់យាងចូលមកក្នុងយើង ដើម្បីធ្វើឱ្យយើងស្កប់ចិត្ត និងបានឆ្អែត ។

III. យើងត្រូវតែអនុវត្តការងារនៃការធ្វើឱ្យនៅទទេស្អាតរបស់ទ្រង់ជាមុនសិន ដ្បិតនៅពេលណាដែលយើងនៅទទេស្អាត ព្រះអម្ចាស់នឹងចម្អែតយើង ។ ព្រះកំពុងរង់ចាំឱ្យយើងទុកខ្លួនយើងឱ្យនៅទទេស្អាត—ម៉ាថាយ ៥:៦ ។

IV. ខ្សោយណាស់ឥតមានកម្លាំងសោះ / តែខ្ញុំពឹងផ្អែកលើព្រះហស្ត / ឱ្យវិញ្ញាណនៃព្រះដ៏សប្បុរស / សូមឱ្យសូមសណ្ឋិតឥលូវ / *សូមសណ្ឋិតនៅក្នុងចិត្ត / ឱ្យព្រះយេស៊ូសូមផ្ទុមថ្មិត / ឱ្យវិញ្ញាណនៃព្រះយាងមក / សណ្ឋិតពោរពេញក្នុងចិត្តផងខ្ញុំ* / (ចម្រៀងជាភាសាខ្មែរលេខ ២១៧ , ភាសាអង់គ្លេសលេខ ២៦៧) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៣១ សេចក្តីស្រឡាញ់ព្រះ

## ដកស្រង់ពី:

ម៉ាថាយ ២២:៣៧-៣៨ នោះព្រះយេស៊ូមានបន្ទូលថា "ត្រូវឱ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឱ្យអស់ពីចិត្ត គំនិត អស់ពីព្រលឹង ហើយអស់អំពីគំនិតឯង" ។ នេះជាបទបញ្ញត្តទីមួយដែលសំខាន់ជាងគេបំផុត ។

យើងត្រូវតែស្រឡាញ់ព្រះ ។ សេចក្តីស្រឡាញ់ព្រះ តម្រូវឱ្យយើងស្រឡាញ់អស់ពីចិត្ត អស់ពីព្រលឹង និងអស់ទាំងគំនិត ។ នេះជាបទបញ្ញត្តទី១ ហើយក៏ជាបទបញ្ញត្តដ៏សំខាន់បំផុតដែរ ។ សូមឱ្យអ្នកក្លាយជាអ្នកងប់ងល់ស្រឡាញ់ព្រះអម្ចាស់យេស៊ូគ្រិស្ត!

## ខ្លឹមសារ:

ម៉ាថាយ ២២:៣៧-៣៨ — នោះព្រះយេស៊ូមានបន្ទូលថា "ត្រូវឱ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឱ្យអស់ពីចិត្ត គំនិត អស់ពីព្រលឹង ហើយអស់អំពីគំនិតឯង" ។ នេះជាបទបញ្ញត្តទីមួយដែលសំខាន់ជាងគេបំផុត ។

រ៉ូម ៨:២៨ — តែយើងដឹងថាគ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្តីល្អដល់អ្នក ដែល ស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅតាមព្រះតម្រិះទ្រង់ ។

I. **"នោះព្រះយេស៊ូមានបន្ទូលថា" ត្រូវឱ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯង ឱ្យ អស់ពីចិត្ត គំនិត អស់ពីព្រលឹង ហើយអស់អំពីគំនិតឯង ។ នេះជាបទបញ្ញត្តទីមួយ ដែលសំខាន់បំផុត"—ម៉ាថាយ ២២:៣-៣៨:**
   A. នេះជាបទបញ្ញតទី១ ក៏ជាបញ្ញត្តដ៏សំខាន់បំផុតដែរ ។
   B. ព្រះសព្វព្រះទ័យឱ្យយើងស្រឡាញ់ទ្រង់ ពីព្រោះនេះជាការបានទ្រង់ ។ ព្រះជាម្ចាស់មិនត្រឹមតែចង់ឱ្យយើងជឿព្រះអង្គប៉ុណ្ណោះទេ តែក៏ត្រូវឱ្យស្រឡាញ់ព្រះអង្គផងដែរ ។

II. រ៉ូម ៨:២៨ និយាយថា "តែយើងដឹងថាគ្រប់ការទាំងអស់ផ្សំគ្នា សម្រាប់សេចក្ដីល្អដល់អ្នកដែលស្រឡាញ់ព្រះ" ។ មនុស្សជាច្រើនស្គាល់ខនេះយ៉ាងច្បាស់ ។ មានតែមនុស្សមួយប្រភេទដែលអំណរនឹងសេចក្ដីល្អនេះប៉ុណ្ណោះ ជាអស់អ្នកដែលស្រឡាញ់ព្រះ:

A. ព្រះអង្គមិនកែប្រែអ្វីៗទេ ។ ទ្រង់ផ្លាស់ប្ដូរចិត្តរបស់អ្នក ។ ប្រសិនបើអ្នកស្រឡាញ់ព្រះ នោះអ្វីៗទាំងអស់ ទោះបីជាគ្មានការផ្លាស់ប្ដូរក៏ដោយ ក៏នឹងដំណើរការល្អសម្រាប់អ្នកដែរ ។

B. ពេលខ្លះអ្នកត្អូញត្អែរក្នុងរឿងគ្រប់យ៉ាងដែលកើតឡើង នៅក្នុងការដំណើរជីវិតរបស់អ្នក តែបើមានសេចក្ដីស្រឡាញ់នៅទីនោះ គ្រប់រឿងទាំងអស់នោះ នឹងគ្មានន័យចំពោះអ្នកទៀតទេ ។ សេចក្ដីស្រឡាញ់ព្រះ នឹងធ្វើឱ្យការមិនស្កប់ស្កល់នឹងបរិស្ថានជុំវិញក្លាយជាការទទួលយកបានដោយស្កប់ស្កល់មួយ ។

III. សូមឱ្យអ្នកក្លាយជាអ្នកងប់ងល់ស្រឡាញ់ព្រះអម្ចាស់យេស៊ូគ្រិស្តជាទីបំផុត! —ម៉ាថាយ .២២:៣៧-៣៨ ។

IV. សូមទ្រង់រក្សា នូវដួងចិត្តដ៏ស្មោះ / មិនដែលនឹកក្បត់ ឬគេចបែរពីទ្រង់ /ដួងចិត្តបរិសុទ្ធមើលឃើញតែព្រះអង្គ /ដួងចិត្តស្រឡាញ់ទ្រង់ ឱ្យតម្លៃតែព្រះអង្គ ។ / ក្ដីស្រឡាញ់នៃទ្រង់បង្ខំរូបខ្ញុំឱ្យថ្វាយ/ អូរ! នេះជាឯកសិទ្ធិ ខ្ញុំថ្វាយខ្លួនដល់ព្រះអង្គ /ខ្ញុំស្រឡាញ់ទ្រង់ ដួងចិត្តខ្ញុំ / ស្រឡាញ់ទ្រង់អស់មួយជីវិត។—(បទចម្រៀងខ្មែរ ទំព័រ ៥៤៧) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី៣២ ការពិត សេចក្តីជំនឿ និងការបទពិសោធន៍

**ដកស្រង់ពី :**

អេភេសូរ ២:៨ ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ។

គ្រប់ទាំងការពិតទាំងអស់របស់ព្រះ គឺជាការងាររបស់ព្រះផ្ទាល់ ។ នៅក្នុងន័យម្យ៉ាង សេចក្តីជំនឿ គឺជាការឆែកមើលលុយនៅក្នុងធនាគារ រីឯ "ការពិត" គឺការមានលុយនៅក្នុងធនាគារ ។ ការឆែកមើលលុយ គឺជា "សេចក្តីជំនឿ" ឯការចំណាយលុយ គឺជា "ការបទពិសោធន៍" ។ គ្រប់ទាំងអស់ដែលយើងត្រូវធ្វើ គឺការជឿយ៉ាងពេញទំហឹងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងទទួលខុសត្រូវសម្រាប់ការប្រទានបទពិសោធន៍ឱ្យយើង ។

**ខ្លឹមសារ :**

អេភេសូរ ២:៨ ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ។

២កូរិនថូស ៥:៧ ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ ។

I. **ការពិត មានន័យថា ព្រះបានបំពេញសម្រេចនូវអ្វីគ្រប់យ៉ាងសម្រាប់មនុស្ស ។ គ្រប់ទាំងការពិតទាំងអស់របស់ព្រះ គឺជាកិច្ចការរបស់ព្រះផ្ទាល់ គឺមិនមែនចេញមកពីការខំប្រឹងរបស់មនុស្សឡើយ—អេភេសូរ ២:៨ :**
   A. ការពិត គឺជាសេចក្តីសន្យារបស់ព្រះ ការប្រោសលោះ កិច្ចការ និងអំណោយទានទាំងឡាយដែលឥតបង់ថ្លៃរបស់ទ្រង់ ។

B. នៅក្នុងព្រះគម្ពីរ ព្រះមិនដែលស្នើសុំឱ្យយើងធ្វើអ្វីណាមួយ ដែលទ្រង់ចាត់ទុកថាជាការពិតដែលបានបំពេញសម្រេចនោះឡើយ ។ គ្រប់ទាំងអស់ដែលយើងត្រូវធ្វើ គឺការបំពេញសម្រេចនូវជំហានសាមញ្ញមួយ នោះគឺការជឿ ។

II. **"ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ"—២កូរិនថូស ៥:៧ :**

A. សេចក្តីជំនឿ គឺការទទួលយកការពិត នោះគឺថា ការទទួលស្គាល់ពួកគេថាជាការពិត ។ នៅក្នុងន័យម្យ៉ាង សេចក្តីជំនឿ គឺជាការឆែកមើលលុយនៅក្នុងធនាគារ រីឯ "ការពិត" គឺការមានលុយនៅក្នុងធនាគារ ។ ការឆែកមើលលុយ គឺជា "សេចក្តីជំនឿ" ឯការចំណាយលុយ គឺជា "ការបទពិសោធន៍" ។

B. ការពិត សេចក្តីជំនឿ ការបទពិសោធន៍ ជាលំដាប់លំដោយដែលព្រះបានកំណត់ទុក ។ សេចក្តីជំនឿ គឺជាមធ្យោបាយតែមួយគត់នៃការប្រែក្លាយការពិតឱ្យទៅជាការបទពិសោធន៍ ។

III. **ការបទពិសោធន៍ គឺជាការរស់នៅដ៏ត្រឹមត្រូវរបស់ពួកអ្នកជឿ ដែលពួកគេមានសុវត្ថិភាពតាមរយៈការជឿក្នុងព្រះជាម្ចាស់ ។ នៅពេលណាដែលការល្បួង និងការសាកល្បងមកដល់ យើងគួរតែជឿលើព្រះបន្ទូល និងការពិតរបស់ព្រះ ។ គ្រប់ទាំងអស់ដែលយើងត្រូវធ្វើ គឺការជឿយ៉ាងពេញទំហឹងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះទ្រង់នឹងទទួលខុសត្រូវសម្រាប់ការប្រទានបទពិសោធន៍ឱ្យយើង—ខ៧ ។**

IV. **"នៅក្រោមស្លាបទ្រង់ជាទីពំ_នាក់ដ៏ សុខសាន្តទោះយប់ង_ងឹត ខ្យល់ព្យុះ បក់ឥតស្រាកស្រាន្ត តែខ្ញុំនៅទុកចិត្តថា ទ្រង់មើលថែខ្ញុំបាន_ទាំងជួយឲ្យខ្ញុំក្លាយជាកូនរ_បស់ព្រះ នៅក្រោមស្លាបទ្រង់ នៅក្រោមស្លាបទ្រង់ អ្នកណាអាចឆក់យកចេញបាន នៅក្រោមស្លាបទ្រង់គឺជាផ្ទះសុខសាន្ត រស់ជាមួយទ្រង់ដល់អស់កល្ប។"—(បទចម្រៀងខ្មែរលេខ ៤៩២, អង់គ្លេសលេខ ៥៦៥) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី៣៣ ការទំនាក់ទំនងជាមួយព្រះអម្ចាស់ផ្ទាល់ខ្លួន និងដោយសេចក្ដីស្រឡាញ់

**ដកស្រង់ពី :**

បទចម្រៀងសាឡូម៉ូន ១:២-៤ ឱបើប្ដីនឹងថើបខ្ញុំដោយព្រះឱស្ឋទៅ ពីព្រោះសេចក្ដីស្រឡាញ់របស់ទ្រង់វិសេសជាងស្រាទំពាំងបាយជូរ ។ សូមទាញនាំខ្ញុំម្ចាស់ នោះយើងខ្ញុំនឹងរត់តាមទ្រង់ ។

ការដែលគួរឱ្យចាប់អារម្មណ៍បំផុត អំពីអាពិហ៍ពិពាហ៍ គឺនៅពេលថើបគ្នា ។ នេះជារឿងរ៉ាវផ្ទាល់ខ្លួនដែលប្រកបដោយសេចក្ដីស្រឡាញ់បំផុត ។ អ្នកស្វែងរកបាននិយាយថា "សូមទាញខ្ញុំម្ចាស់" ។ នេះជារឿងផ្ទាល់ខ្លួន ។ យើងចង់ឱ្យទ្រង់គង់នៅជាមួយនឹងយើង ជាលក្ខណៈផ្ទាល់ខ្លួននិងប្រកបដោយសេចក្ដីស្រឡាញ់បំផុត ។

**ខ្លឹមសារ :**

បទចម្រៀងសាឡូម៉ូន ១:២-៤ ឱបើប្ដីនឹងថើបខ្ញុំដោយព្រះឱស្ឋទៅ ពីព្រោះសេចក្ដីស្រឡាញ់របស់ទ្រង់វិសេសជាងស្រាទំពាំងបាយជូរ ។ សូមទាញនាំខ្ញុំម្ចាស់ នោះយើងខ្ញុំនឹងរត់តាមទ្រង់ ។

I. **ព្រះបានបង្កើតយើងមកឱ្យមានចិត្តស្វែងរកទ្រង់ ដើម្បីឱ្យទ្រង់បានជាទីស្កប់ចិត្តដល់យើង—បទចម្រៀងសាឡូម៉ូន ១:២-៤ :**
   A. គ្មានអ្វីធ្វើឱ្យមនុស្សស្កប់ស្កល់បានឡើយ មិនខ្វល់ថា ពួកគេសម្រេចបាន ឬទទួលបានអ្វីពីលោកិយ គឺមិនអាចធ្វើឱ្យគេស្កប់ចិត្តឡើយ ពីព្រោះនៅខាងក្នុងពួកគេ គឺមានចិត្តនៃការស្វែងរកព្រះ ។
   B. បទចម្រៀងសាឡូម៉ូន គឺជាសៀវភៅមួយប្រាប់យើងពីរបៀបដែលអាចធ្វើឱ្យយើងស្កប់ចិត្តជាមួយនឹងព្រះ ហើយគ្មានផ្លូវណាផ្សេង ក្រៅពីសង្វាតឱ្យបានព្រះគ្រិស្តទេ ។

II. "ឱបើប្ដីនឹងថើបខ្ញុំដោយព្រះឱស្ឋទៅ" នេះមានន័យថា សង្វាតរកព្រះគ្រិស្ដ ហើយការដែលចាប់អារម្មណ៍បំផុតអំពីអាពាហ៍ពិពាហ៍ គឺនៅពេលថើប ។ នេះជារឿងផ្ទាល់ខ្លួននិងប្រកបដោយសេចក្ដីស្រឡាញ់បំផុត—ខ២ :

A. យោងតាមសញ្ញាថ្មី ផ្លូវដែលព្រះបានកំណត់ទុកឱ្យមនុស្សក្នុងការទទួលយកទ្រង់ជាលក្ខណៈផ្ទាល់ខ្លួន និងប្រកបដោយសេចក្ដីស្រឡាញ់ គឺដំបូងត្រូវជឿទ្រង់ ។ ជឿទ្រង់គឺត្រូវទទួលយកទ្រង់ជាជីវិតព្រះចូលមកក្នុងយើង ។

B. បន្ទាប់ពីយើងជឿព្រះគ្រិស្ដ យើងត្រូវស្រឡាញ់ទ្រង់ ។ ជឿត្រូវទទួលយកព្រះគ្រិស្ដ ហើយស្រឡាញ់ត្រូវសង្វាតរកទ្រង់ ។

III. អ្នកស្វែងរកបាននិយាយថា "សូមទាញខ្ញុំម្ចាស់" នេះជាការធ្វើដោយផ្ទាល់ និងប្រកបដោយសេចក្ដីស្រឡាញ់របស់ទ្រង់ ។ យើងចង់ឱ្យទ្រង់គង់នៅជាមួយនឹងយើង ជាលក្ខណៈផ្ទាល់ខ្លួន និងប្រកបដោយសេចក្ដីស្រឡាញ់—ខ៤ ។

IV. យើងខ្ញុំសូមស្រឡាញ់ទ្រង់ ខ្លាំងជាងពេលមុន សូមស្ដាប់ពាក្យអង្វរខ្ញុំ បំពេញការសុំ រក្សាខ្ញុំឱ្យថេរនៅ ស្រឡាញ់ព្រះអង្គជ្រាលជ្រៅ ស្រឡាញ់តែទ្រង់ខ្លាំងជាងពេលមុន—(បទចម្រៀងខ្មែរ ២៨១, អង់គ្លេស ៣៦៨) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី៣៤ អារម្មណ៍នៃជីវិត

**ដកស្រង់ពី :**

រ៉ូម ៨:៦ ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្ដីស្លាប់ទទេ ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត និងសេចក្ដីសុខសាន្តវិញ ។

នៅពេលយើងជឿចូលទៅក្នុងព្រះគ្រិស្ដ ជីវិតរបស់ទ្រង់បង្កើតឱ្យមានអារម្មណ៍នៃជីវិត ។ នៅផ្នែកអវិជ្ជមាន អារម្មណ៍នៃជីវិត គឺជាអារម្មណ៍នៃសេចក្ដីស្លាប់ ។ នៅផ្នែកវិជ្ជមាន អារម្មណ៍នៃជីវិត ផ្ដល់ឱ្យយើងនូវសម្បជញ្ញៈនៃការដើរតាមរឿងរ៉ាវវិជ្ជមាន ។ យើងត្រូវការដើរតាមអារម្មណ៍នៃជីវិតផ្នែកខាងក្នុង ដើម្បីឱ្យជីវិតព្រះចម្រើនធំនៅក្នុងយើងដោយគ្មានការរាំងស្ទះ ។

**ខ្លឹមសារ :**

រ៉ូម ៨:៦ ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្ដីស្លាប់ទទេ ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត និងសេចក្ដីសុខសាន្តវិញ ។

អេភេសូរ ៤:១៩ គេលែងខ្លាចបាប បានជាគេប្រគល់ខ្លួនទៅខាងសេចក្ដីអាសអាភាស ដើម្បីនឹងប្រព្រឹត្តសេចក្ដីស្មោកគ្រោកគ្រប់យ៉ាង ដោយចិត្តរក់វិញ ។

### I. នៅពេលយើងជឿចូលទៅក្នុងព្រះគ្រិស្ដ ជីវិតរបស់ទ្រង់បង្កើតឱ្យមានអារម្មណ៍នៃជីវិតនៅក្នុងយើង—រ៉ូម ៦:៦:

A. នៅផ្នែកអវិជ្ជមាន អារម្មណ៍នៃជីវិត គឺជាអារម្មណ៍នៃសេចក្ដីស្លាប់ ។ អារម្មណ៍នៃសេចក្ដីស្លាប់ គឺជាអារម្មណ៍នៃភាពកម្សោយ ភាពទទេ ភាពមិនស្រួល ភាពមិនស្ងប់ចិត្ត ការបាក់ទឹកចិត្ត ភាពស្ងួត ភាពងងឹត និងការឈឺចាប់ជាដើម ។ល។

B. នៅផ្នែកវិជ្ជមាន អារម្មណ៍នៃជីវិត មានមុខងារក្នុងការផ្តល់ឱ្យយើងនូវសម្បជញ្ញៈនៃការដើរតាមរឿងរ៉ាវវិជ្ជមាន ដូចជា កម្លាំង ការស្កប់ចិត្ត ភាពសុខសាន្ត ការឈប់សម្រាក ការដោះលែង ភាពរស់រវើក ត្រជាក់ត្រជំ ការចែងចាំង កម្សាន្តចិត្ត ។ល។

C. អេភេសូរ ៤:១៩ និយាយថា "គេលែងខ្លាចបាប" លែងខ្លាច នៅទីនេះសំដៅលើការដឹងខ្លួននៃសម្បជញ្ញៈរបស់មនុស្ស ។ ទាំងផ្នែកវិជ្ជមាន និងផ្នែកអវិជ្ជមាន អារម្មណ៍នៃជីវិត គឺតែងតែមានទំនាក់ទំនងទៅនឹងការដឹងខ្លួននៃសម្បជញ្ញៈ ។

## II. ការចម្រើនធំនៃជីវិតព្រះនៅក្នុងយើង គឺអាស្រ័យទៅលើការយកចិត្តទុកដាក់ចំពោះអារម្មណ៍នៃជីវិត—១យ៉ូហាន ២:២៧ :

A. ប្រសិនបើយើងធ្វេសប្រហែសចំពោះអារម្មណ៍នៃជីវិតនៅផ្នែកខាងក្នុង យើងនឹងរារាំងដល់ការចម្រើនធំនៃជីវិត ។ យើងត្រូវការចំណាយពេលឱ្យគ្រប់គ្រាន់ជាមួយព្រះអម្ចាស់ ដើម្បីលន់តួអំពើបាប ការបរាជ័យ និងការប្រព្រឹត្តរំលងរបស់យើងឱ្យបានហ្មត់ចត់ ប្រយោជន៍ឱ្យអារម្មណ៍នៃជីវិតនៅផ្នែកខាងក្នុងយើង នឹងបានវាងវៃ ហើយនិងខ្លាំង ។

B. បន្ទាប់មកយើងត្រូវការដើរតាមអារម្មណ៍នៃផ្នែកខាងក្នុង ដូច្នេះយើងអាចឱ្យជីវិតរបស់ព្រះចម្រើនធំនូវអ្វីដែលបានលាក់ទុក ។

## III. ព្រះគ្រិស្តជាជីវិតខ្ញុំទ្រង់រស់នៅខាងក្នុង / នាំភាពពោរពេញនៃទ្រង់បំពេញខ្ញុំឥតឈប់ / ដោយនិស្ស័យព្រះវិសុទ្ធញែកខ្ញុំជាបរិសុទ្ធ / ចេស្តារស់ឡើងនៃព្រះខ្ញុំបានជ័យជម្នះ / ជីវិតទ្រង់គ្រប់បរិបូរថែមទាំងមានការហូរ / ឱ្យខ្ញុំរីករាយកន្លងបានអំណរព្រះអង្គ / ជីវិតលេបសេចក្តីស្លាប់ខ្សោយប្រែជារឹងមាំ / រួចផុតអស់ទាំងចំណងធ្លាក់ចុះបានខ្ពស់ឡើង (បទចម្រៀងជាភាសាខ្មែរលេខ ៣៨១, អង់គ្លេសលេខ ៨៤១) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត
## វាក្យសព្ទទី៣៥ ការប្រកបនៃជីវិត

### ដកស្រង់ពី:

១យ៉ូហាន ១:២-៣ (......ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច ដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឱ្យយើងខ្ញុំឃើញ)......ដើម្បីឱ្យអ្នករាល់គ្នាមានសេចក្តីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្តីប្រកបរបស់យើងខ្ញុំ នោះគឺប្រកបនឹងព្រះវរបិតា ហើយនឹងព្រះយេស៊ូគ្រិស្ត ជាព្រះរាជបុត្រាទ្រង់ ។

នៅក្នុងភាសាក្រិក ពាក្យ ប្រកប មានន័យថា "ការចែករំលែកគ្នា" ។ ការប្រកបនៃជីវិត គឺជាការហូរនៃជីវិតព្រះនៅខាងក្នុងយើង "សូមអធិដ្ឋានប្រកបនឹងព្រះយេស៊ូ ស្តាប់បន្ទូលទ្រង់ដោយស្មោះត្រង់ ចាប់អារម្មណ៍ពីបំណងព្រះអង្គ បង្កើតផលផ្លែពីខាងក្នុង" (បទចម្រៀងខ្មែរលេខ ៥៦៨, អង់គ្លេសលេខ ៧៨៤) ។

### ខ្លឹមសារ:

១យ៉ូហាន ១:២-៣ (......ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច ដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឱ្យយើងខ្ញុំឃើញ)......ដើម្បីឱ្យអ្នករាល់គ្នាមានសេចក្តីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្តីប្រកបរបស់យើងខ្ញុំ នោះគឺប្រកបនឹងព្រះវរបិតា ហើយនឹងព្រះយេស៊ូគ្រិស្ត ជាព្រះរាជបុត្រាទ្រង់ ។

៧ តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូគ្រិស្ត ជាព្រះរាជបុត្រានៃទ្រង់ ក៏សម្អាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់ ។

I. នៅក្នុងភាសាក្រិក ពាក្យ ប្រកប មានន័យថា "ការចែករំលែកគ្នា" ។ ការប្រកបនៃជីវិត គឺជាការហូរនៃជីវិតព្រះនៅខាងក្នុងយើង ជាខ្សែបញ្ឈរវាងព្រះវរបិតា ព្រះរាជបុត្រា និងយើង និងជាខ្សែផ្ដេករវាងយើង និងគ្នាទៅវិញទៅមក—១យ៉ូហាន ១:២-៣:

A. ដំណើរឈាមរត់ គឺជាការពន្យល់បង្ហាញយ៉ាងល្អអំពីការហូរនៃជីវិត ។ ឈាមនៅក្នុងខ្លួនប្រាណរបស់យើង ហូរ រត់គ្រប់ពេល ហើយដំណើរឈាមរត់ ឬការហូរនេះ គឺជារូបភាពដ៏ល្អអំពីការប្រកបនៃជីវិតខាងវិញ្ញាណ ដែលជាការហូរនៃជីវិតព្រះ ។

B. នៅក្នុង១យ៉ូហាន ១:២-៣ និយាយថា ជីវិតដ៏នៅអស់កល្បបានប្រាប់ដល់យើងរាល់គ្នា ប្រយោជន៍ឱ្យយើងមានការប្រកប ។ ដូចជាចរន្តអគ្គិសនីចេញពីរោងចក្រថាមពលជាយ៉ាងណា នោះការប្រកបចេញពីជីវិតអស់កល្បជាយ៉ាងនោះដែរ ដ្បិតជីវិតអស់កល្ប គឺជាប្រភពនៃការប្រកបនេះ ។

II. **"តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូគ្រិស្ដ ជាព្រះរាជបុត្រានៃទ្រង់ ក៏សម្អាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់"—ខ៧ :**

A. លទ្ធផលដំបូងបានពីការប្រកបនៃជីវិត គឺថាផ្ដល់ពន្លឺដល់យើង ។ ព្រះគឺជាពន្លឺ ហើយបើយើងមានការប្រកបជាមួយទ្រង់ យើងគឺស្ថិតនៅក្នុងពន្លឺ ។

B. ការប្រកបនៃជីវិត មិនត្រឹមតែនាំមកនូវពន្លឺដល់យើងប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងនាំមកនូវការសម្អាតជាក់ស្ដែងនៃឈាមដល់យើងផងដែរ ។

III. **"សូមអធិដ្ឋានប្រកបនឹងទ្រង់ / ស្ដាប់បន្ទូលទ្រង់ដោយស្មោះត្រង់ / ចាប់អារម្មណ៍ពីបំណងព្រះអង្គ / បង្កើតផលផ្លែពីខាងក្នុង / សូមអធិដ្ឋានប្រកបនឹងទ្រង់ /រីករាយនៅចំពោះព្រះភក្ត្រ /ភាពស្រស់ព្រះអង្គជ្រួតជ្រាបដួងចិត្ត /ជាពន្លឺសិរីល្អពិត ។** *សូមអធិដ្ឋានប្រកបនឹងទ្រង់ /វិញ្ញាណស្វែងរកព្រះភក្ត្រទ្រង់ /ទូលសួមនិងស្ដាប់នៅមុខព្រះអង្គ /នៅទីកំបាំងរង់ចាំទ្រង់"* បទចម្រៀងខ្មែរលេខ ៥៦៨, បទជាភាសាអង់គ្លេសលេខ ៧៨៩ ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៣៦ សេចក្តីជំនឿ និង ការស្តាប់បង្គាប់

**ដកស្រង់ពី :**

រ៉ូម ៦:១១-១៣ ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯបាប តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រិស្តយេស៊ូ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ហេតុនោះកុំឱ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នាដែលតែងតែស្លាប់ ដើម្បីនឹងស្តាប់តាមសេចក្តីប៉ងប្រាថ្នារបស់បាបនោះឡើយ... គឺត្រូវប្រគល់ខ្លួនទៅព្រះដូចជាបានរស់ពីស្លាប់នោះឡើងវិញ ។

មានគោលការណ៍២យ៉ាងនៃការដំណើរជីវិតគ្រិស្ទាន : មួយគឺជាសេចក្តីជំនឿ មួយទៀតគឺ ការស្តាប់បង្គាប់ ។ សេចក្តីពិតផ្នែកខាងក្រៅ ត្រូវការឱ្យយើងជឿ ។ បន្ទាប់ពីយើងមានសេក្តីជំនឿដ៏រស់ហើយ ពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវការរៀនស្តាប់បង្គាប់ព្រះ ។ ព្រះអង្គមិនស្កប់ព្រះហឫទ័យទេ លុះត្រាតែយើងមានការស្តាប់បង្គាប់យ៉ាងខ្ជាប់ខ្ជួន ។

**ខ្លឹមសារ :**

រ៉ូម ៦:១១-១៣ ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯបាប តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រិស្តយេស៊ូ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ហេតុនោះកុំឱ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នាដែលតែងតែស្លាប់ ដើម្បីនឹងស្តាប់តាមសេចក្តីប៉ងប្រាថ្នារបស់បាបនោះឡើយ... គឺត្រូវប្រគល់ខ្លួនទៅព្រះដូចជាបានរស់ពីស្លាប់នោះឡើងវិញ ។

I. **មានគោលការណ៍២យ៉ាងនៃការដំណើរជីវិតគ្រិស្ទាន : មួយគឺជាសេចក្តីជំនឿ មួយទៀតគឺ ការស្តាប់បង្គាប់ ។ នៅក្នុងការប្រកបជាមួយព្រះជាម្ចាស់ ពួកយើងត្រូវការនូវ សេចក្តីជំនឿ និង ការស្តាប់បង្គាប់ជារៀងរាល់ថ្ងៃ—រ៉ូម ៦:១១-១៣ ។**
II. **សេក្តីពិតផ្នែកខាងក្រៅទាំងអស់ ត្រូវបានបំពេញសម្រេច ហើយក៏ពិត ។ ទាំងនេះត្រូវការការជឿរបស់យើងម្នាក់ៗ—ខ១១-១៣ :**

A. ការជឿ មិនមែនជាការផ្លាស់ប្តូរព្រះបន្ទូលរបស់ព្រះ ឱ្យទៅជាសភាពពិតនោះទេ តែគឺជាការជឿថា ព្រះបន្ទូលរបស់ព្រះ គឺជាសភាពពិត ។

B. ពួកយើងត្រូវតែជឿលើព្រះបន្ទូលរបស់ព្រះជាជាង ការជឿលើកាលៈទេសៈ ឬ អារម្មណ៍របស់យើង ។

**III. បន្ទាប់ពីយើងមានសេក្តីជំនឿដ៏រស់ហើយ ពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវការរៀនស្តាប់បង្គាប់ព្រះ—អេភេសូរ ៤:៣០ :**

A. អ្វីក៏ដោយឱ្យតែព្រះទាមទារពីយើង យើងត្រូវតែស្តាប់បង្គាប់ មិនត្រឹមតែស្តាប់បង្គាប់តែមួយដងប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែស្តាប់បង្គាប់ជាបន្តបន្ទាប់ ។

B. ព្រះអង្គមិនស្កប់ព្រះហឫទ័យទេ លុះត្រាតែយើងមានការស្តាប់បង្គាប់យ៉ាងខ្ជាប់ខ្ជួន ។ សូមឱ្យព្រះអង្គប្រទានពរយើង និងធ្វើឱ្យយើងបានគ្រប់លក្ខណ៍នៅចំពោះព្រះអង្គ នោះគឺថា សូមឱ្យយើងបានក្លាយជាមនុស្សដែលជឿ និងស្តាប់បង្គាប់ព្រះអង្គ ។

**IV. "ខ្ញុំថ្វាយបង្គំដល់អង្គព្រះគ្រិស្ត ស្តាប់តាមព្រះវិញ្ញាណទ្រង់ដឹកនាំ ខ្ញុំក៏សម្តែងសិរីព្រះអង្គដោយសារព្រះគុណឃូរលង់។"—(បទចម្រៀងខ្មែរលេខ ៣៨៤ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី៣៧ ការបទពិសោធន៍ព្រះគ្រិស្ត

**ដកស្រង់ពី:**

កូល៉ុស ៣:៤ កាលណាព្រះគ្រិស្តដ៏ជាជីវិតនៃយើង បានលេចមក នោះអ្នករាល់គ្នានឹងលេចមក ក្នុងសិរីល្អជាមួយនឹងទ្រង់ដែរ ។

ព្រះគ្រិស្តមានវត្តមានគង់នៅ និងអាចរកបាន ។ ទ្រង់គឺជាជីវិតរបស់យើង ។ ការបទពិសោធន៍ព្រះគ្រិស្ត គឺជាការយកព្រះគ្រិស្តធ្វើជាជីវិត និងជាការរស់ដោយព្រះគ្រិស្ត ។ យើងត្រូវរៀនធ្វើជាមនុស្សម្នាក់ដែលបទពិសោធព្រះគ្រិស្តក្នុងផ្លូវជាក់ស្ដែង ។

**ខ្លឹមសារ :**

កូល៉ុស ៣:៤ កាលណាព្រះគ្រិស្តដ៏ជាជីវិតនៃយើង បានលេចមក នោះអ្នករាល់គ្នានឹងលេចមកក្នុងសិរីល្អ ជាមួយនឹងទ្រង់ដែរ ។

១កូរិនថូស ១៥:៤៥ អ័ដាមចុងក្រោយបង្អស់បានក្លាយជាព្រះវិញ្ញាណដែលផ្ដល់ជីវិត ។

I. **ការបទពិសោធន៍ព្រះគ្រិស្ត គឺជាការយកព្រះគ្រិស្តធ្វើជាជីវិត និងជាការរស់ដោយព្រះគ្រិស្តយ៉ាងនោះឯង—កូល៉ុស៣:៤ :**
   A. ព្រះគ្រិស្តកំពុងមានព្រះជន្មរស់នៅ ពិតប្រាកដ មានវត្តមានគង់នៅ និងអាចរកបាន ។
   B. ព្រះគ្រិស្ត គឺជាជីវិត ជាគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់របស់យើង និងជាចំណែកតែមួយគត់ ដែលព្រះបានប្រទានមកយើង ។ យើងត្រូវការបទពិសោធទ្រង់តាមផ្លូវជាក់ស្ដែង ។

II. **ដើម្បីបទពិសោធព្រះគ្រិស្តទ្រង់ផ្ទាល់ យើងត្រូវដឹងថា សព្វថ្ងៃនេះព្រះគ្រិស្ត គឺជាព្រះវិញ្ញាណ—១កូរិនថូស ១៥:៤៥ខ:**

A. "អ័ដាមចុងក្រោយបង្អស់បានក្លាយជាព្រះវិញ្ញាណផ្តល់ជីវិត" ។ សព្វថ្ងៃនេះ ព្រះគ្រិស្ត គឺជាព្រះវិញ្ញាណ ។ សម្រាប់យើង ផ្លូវដើម្បីបទពិសោធន៍ព្រះគ្រិស្តធ្វើជាជីវិត គឺត្រូវបទពិសោធព្រះវិញ្ញាណ ។

B. យើងម្នាក់ៗត្រូវតែធ្វើការសម្រេចចិត្តថា ចាប់ពីពេលនេះតទៅ យើងនឹងរៀនធ្វើជាគ្រិស្ទានធម្មតាម្នាក់ ដែលបទពិសោធព្រះគ្រិស្តតាមផ្លូវជាក់ស្តែង ។

III. **"ព្រះអង្គទ្រង់ជាជីវិតក្នុងខ្ញុំ ទ្រង់ជាទ្រព្យធននានា / ទ្រង់សែនសុភាពទ្រង់សែនស្ពាលស្និទ្ធ បំភ្លឺក្នុងខ្ញុំជានិច្ច / ទោះតម្រូវការខ្ញុំតូចឬធំ ទ្រង់បំពេញខ្ញុំឥតខាន / ឱ្យខ្ញុំស្កប់ចិត្តឱ្យខ្ញុំរីករាយ បំភ្លឺខ្ញុំដោយវិញ្ញាណ / ព្រះអង្គទ្រង់ជាវិញ្ញាណជីវិត ឱ្យខ្ញុំបានចូលជិតស្និទ្ធ / ស្រឡាញ់អំណរ សរសើរចូលចិត្ត ទាំងថ្មីស្រស់ថ្លា ប្រិមប្រិយ (បទចម្រៀងខ្មែរលេខ ៤០០ អង់គ្លេសលេខ ៥៣៩) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៣៨ ការសម្អាតអតីតកាល

**ដកស្រង់ពី :**

លូកា ១៩:៨ ឯសាខេ ក៏ឈរទូលទ្រង់ថា មើលព្រះអម្ចាស់អើយ ទូលបង្គំចែកទ្រព្យទូលបង្គំពាក់កណ្តាលឱ្យដល់មនុស្សក្រីក្រ ហើយបើទូលបង្គំបានហូតពន្ធបំបាត់ចំពោះអ្នកណា នោះទូលបង្គំនឹងសងគេ១ជា៤វិញ ។

ការសម្អាតអតីតកាលបន្ទាប់ពីយើងទទួលបានសេចក្តីសង្គ្រោះ គឺសំដៅលើការបញ្ចប់នូវរបៀបរស់នៅចាស់ និងកិរិយាប្រព្រឹត្តចាស់របស់យើង ។ ការអនុវត្តនូវការសម្អាតអតីតកាលរបស់យើង គឺយោងទៅតាមកម្លាំងបណ្តាលពីព្រះវិញ្ញាណដែលនៅផ្ទៃកខាងក្នុង ។ យើងគួរតែមានការសម្អាតអតីតកាលយ៉ាងច្បាស់លាស់ ហើយត្រូវចាត់ការជាមួយរឿងនេះ នោះយើងនឹងមានជីវិតគ្រិស្ទានដែលប្រសើរ ។

**ខ្លឹមសារ :**

លូកា ១៩:៨ ឯសាខេ ក៏ឈរទូលទ្រង់ថា មើលព្រះអម្ចាស់អើយ ទូលបង្គំចែកទ្រព្យទូលបង្គំពាក់កណ្តាលឱ្យដល់មនុស្សក្រីក្រ ហើយបើទូលបង្គំបានហូតពន្ធបំបាត់ចំពោះអ្នកណា នោះទូលបង្គំនឹងសងគេ១ជា៤វិញ ។

ភីលីព ២:១៣ ដ្បិតគឺជាព្រះហើយ ដែលបណ្តាលចិត្តអ្នករាល់គ្នា ឱ្យមានទាំងចំណង់ចង់ធ្វើ ហើយឱ្យបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ ។

I. **ការសម្អាតអតីតកាលបន្ទាប់ពីយើងទទួលបានសេចក្តីសង្គ្រោះ គឺសំដៅលើការបញ្ចប់នូវរបៀបរស់នៅចាស់ និងកិរិយាប្រព្រឹត្តចាស់របស់យើង—លូកា ១៩:៨ :**
   A. ខណៈពេលដែលសាខេទទួលបានសេចក្តីសង្គ្រោះ នោះគាត់មានចិត្តប្រគល់សំណងចំពោះអ្នកដែលគាត់បានហូតពន្ធបំបាត់១ជា៤វិញ លើសជាងនេះទៅទៀតគាត់បានប្រគល់នូវទ្រព្យសម្បត្តិរបស់គាត់ពាក់កណ្តាលដល់ជនក្រីក្រ ។ ពួកអ្នកជឿនៅក្រុងថែ

ស្សាឡូនីច ក្នុងពេលដែលពួកគេជឿព្រះអម្ចាស់ នោះពួកគេបានបែរចេញពីរូបគោរពទាំងឡាយមកបម្រើព្រះដ៏មានព្រះជន្មរស់វិញ ។

B. នៅក្នុងនោះមានរឿងរ៉ាវបួនប្រភេទ : (១) រឿងរ៉ាវដែលមិនសុចរិត (២) រឿងរ៉ាវដែលមិនត្រឹមត្រូវ (៣) រឿងរ៉ាវដែលអាក្រក់ និងមិនស្អាត (៤) រស់នៅក្នុងផ្លូវចាស់ ។

II. **ការអនុវត្តនៃការសម្អាតអតីតកាល គឺមិនមែនយោងទៅតាមសេចក្ដីបង្គាប់នៃច្បាប់ផ្នែកខាងក្រៅនោះទេ ប៉ុន្តែយោងទៅតាមការចលនានៃព្រះវិញ្ញាណដែលនៅផ្នែកខាងក្នុង—ភីលីព ២:១៣ :**

A. ប្រសិនបើយើងអនុញ្ញាតឱ្យព្រះវិញ្ញាណធ្វើការនៅក្នុងយើង នោះទ្រង់នឹងដឹកនាំយើងឱ្យសម្អាតអតីតកាល និងចាត់ការជាមួយរឿងនោះជាមិនខាន ដោយសារចេស្ដានៃជីវិតនៅផ្នែកខាងក្នុង ។

B. យើងគួរតែធ្វើការសម្អាតអតីតកាលទាំងស្រុង ហើយត្រូវចាត់ការជាមួយរឿងនេះ រហូតទាល់តែយើងត្រូវបានបំពេញនៅផ្នែកខាងក្នុងដោយជីវិត និងសេចក្ដីសុខសាន្ត ។ នេះជាតម្រូវការដើម្បីឱ្យយើងអាចមានជីវិតគ្រិស្ទានដែលប្រសើរឡើង ហើយអាចរក្សាទីបន្ទាល់សម្រាប់ព្រះអម្ចាស់ និងអាចដើរតាមព្រះអម្ចាស់នៅក្នុងការបន្តទៅមុខទៀតជាមួយទ្រង់ ។

III. **"បានឈប់សម្រាករីករាយសុខុម ឥឡូវព្រះគ្រិស្តថតចម្លងក្នុងខ្ញុំ ជីវិតនិស្ស័យរបស់ព្រះអង្គ ត្រូវបានកសាងចូលមកក្នុងខ្ញុំ គ្រប់យ៉ាងរបស់ខ្ញុំត្រូវបានបញ្ចប់ ព្រះគ្រិស្តលេចមកដោយព្រះចេស្ដា" (២ដង) ចម្រៀងលេខ ៣៧៨ ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៣៩ ហេតុអ្វីបានជាពួកអ្នកជឿរងទុក្ខលំបាក?

### ដកស្រង់ពី:

២កូរិនថូស ៤:១៦ ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ ប៉ុន្តែទោះបីមនុស្សខាងក្រៅរបស់យើងខ្ញុំកំពុងតែពុកលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែជាថ្មីឡើងរៀងរាល់ថ្ងៃជានិច្ចវិញ ។

គោលបំណងជាចម្បងនៃការរងទុក្ខលំបាក ជាពិសេសទាក់ទងនឹងកូនរបស់ព្រះ គឺថានិស្ស័យព្រះតែមួយអាចត្រូវបានចាក់ចូលមកក្នុងនិស្ស័យមនុស្ស ដើម្បីឱ្យយើងអាចរួមមានចំណែកក្នុងភាពបរិសុទ្ធរបស់ទ្រង់បាន ។ យើងត្រូវតែរីករាយនឹងអ្វីទាំងអស់ដែលព្រះវរបិតាប្រទានដល់យើង ។

### ខ្លឹមសារ:

២កូរិនថូស ៤:១៦ ហេតុនោះយើងខ្ញុំមិនណាយចិត្តឡើយ ប៉ុន្តែទោះបីមនុស្សខាងក្រៅរបស់យើងខ្ញុំកំពុងតែពុកលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែជាថ្មីឡើងរៀងរាល់ថ្ងៃជានិច្ចវិញ ។

ហេព្រើរ ១២:១០ ដ្បិតឪពុកយើងតែងវាយប្រដៅយើង តាមតែខណៈចិត្តរបស់ចិត្តគាត់ប៉ុណ្ណោះ តែមិនមែនជាយូរឆ្នាំទេ ចំណែកព្រះដែលទ្រង់វាយផ្ចាល់ នោះសម្រាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឱ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់ ។

I. **“ប៉ុន្តែទោះបីមនុស្សខាងក្រៅរបស់យើងខ្ញុំកំពុងតែពុកលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែជាថ្មីឡើងរៀងរាល់ថ្ងៃជានិច្ចវិញ”—២កូរិនថូស ៤:១៦:**
   A. ព្រះគម្ពីរនិយាយពីការបង្កបង្កើតពីរ គឺការបង្កបង្កើតចាស់ និងការបង្កបង្កើតថ្មី ។ ទោះបីការបង្កបង្កើតចាស់ បានលេចមកដោយព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះដ៏មាន

ព្រះជន្មរស់ក៏ដោយ តែព្រះអង្គទ្រង់មិនគង់នៅក្នុងវាទេ ។ និស្ស័យចាស់ត្រូវតែខ្ចាត់ខ្ចាយ ដើម្បីធ្វើឱ្យមានផ្លូវសម្រាប់ព្រះអង្គ ។

B. គឺថានេះ ជាការបំផ្លាញនិស្ស័យចាស់ដែលនាំមកនូវការបង្កបង្កើតចាស់ ផ្តល់ឱកាសឱ្យព្រះនៃការរស់ឡើងវិញ ធ្វើការចែករំលែកអង្គទ្រង់ផ្ទាល់ចូលទៅក្នុងអ្នកដែលទ្រង់បង្កើតមក ដើម្បីបន្ថែមសមាសធាតុថ្មីចូលទៅក្នុងជីវិតរបស់យើង ។

II. **"ដ្បិតឪពុកយើងតែងវាយប្រដៅយើង តាមតែខណៈចិត្តរបស់ចិត្តគាត់ប៉ុណ្ណោះ តែមិនមែនជាយូរឆ្នាំទេ ចំណែកព្រះដែលទ្រង់វាយផ្ទាល់ នោះសម្រាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឱ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់"—ហេព្រើរ ១២:១០:**

A. វាយប្រដៅ គឺជាព្រះវរបិតាដែលចាត់ការជាមួយនឹងកូនៗរបស់ទ្រង់ ដែលអាចឱ្យពួកគេបានទទួលនូវនិស្ស័យបរិសុទ្ធរបស់ទ្រង់ ។ ការវាយប្រដៅរបស់ព្រះ ជាការចាត់ការរបស់ព្រះជាមួយយើង ដើម្បីនាំយើងចូលទៅក្នុងបំណងរបស់ទ្រង់ ។

B. គោលបំណងជាចម្បងនៃការរងទុក្ខលំបាក ជាពិសេសទាក់ទងនឹងកូនៗរបស់ព្រះ គឺថានិស្ស័យរបស់ព្រះអាចត្រូវបានចាក់ចូលមកក្នុងនិស្ស័យមនុស្ស ។

III. **ចូរកុំអធិដ្ឋានដើម្បីឱ្យការរងទុក្ខលំបាកនឹងមកដល់ឡើយ ។ ម៉្យាងវិញទៀត យើងត្រូវតែរីករាយនឹងអ្វីៗដែលព្រះវរបិតាប្រទានមកយើង ពីព្រោះយើងដឹងថាអ្វីៗទាំងអស់គឺស្ថិតនៅក្នុងព្រះហស្តរបស់ទ្រង់—១កូរិនថូស ១០:១៣ ។**

IV. **តែខ្ញុំព្រមរងទុក្ខតែម្នាក់ឯង មិនសុំអ្វីរុងរឿងឡើយ/ចិត្តខ្ញុំស្រេកឃ្លានស្មោះត្រង់ឥតស្បើយតាមទ្រង់ដល់ទីបំផុត ។/ សិរីល្អខ្ញុំរង់ចាំថ្ងៃមុខ ឧបសគ្គរងទុក្ខយ៉ាងណា / ខ្ញុំមិនទទួលក្តីលោកា ព្រោះតែព្រះអង្គម្ចាស់ខ្ញុំ—(បទចម្រៀងខ្មែរលេខ, ៩៦៨ អង់គ្លេសលេខ ៩៦០) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៧០ នគរ

**ដកស្រង់ពី:**

ម៉ាកុស ៤:២៦ ទ្រង់ក៏មានព្រះបន្ទូលថា នគរព្រះធៀបដូចជាមនុស្សម្នាក់ ដែលព្រោះពូជនៅដី ។

នគរ គឺជាព្រះគ្រិស្តដ៏អស្ចារ្យ ដែលបានសាបព្រោះចូលមកក្នុងយើង និងចម្រើនធំនៅខាងក្នុងយើង រហូតដល់យើងឈានដល់ភាពពេញវ័យជាចាស់ទុំ ។ នគរព្រះសព្វថ្ងៃ គឺជាការហ្វឹកហ្វឺនដ៏ពិត តែនៅពេលព្រះគ្រិស្តយាងមកសោយរាជ្យ នគរនឹងក្លាយជារង្វាន់ដ៏ធំ ។

**ខ្លឹមសារ** :

ម៉ាកុស ៤:២៦ ទ្រង់ក៏មានព្រះបន្ទូលថា នគរព្រះធៀបដូចជាមនុស្សម្នាក់ ដែលព្រោះពូជនៅដី ។

រ៉ូម ៥:១៧ ដ្បិតបើសិនជាសេចក្តីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្តីរំលង ដូច្នេះ ប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូគ្រិស្ត ។

## I. នគរ គឺជាព្រះគ្រិស្តដ៏អស្ចារ្យ ដែលប្រៀបដូចជាគ្រាប់ពូជមួយគ្រាប់ដែលបានសាបព្រោះចូលទៅក្នុងមនុស្សនៅលើផែនដី ហើយគ្រាប់ពូជនេះ ចម្រើនធំនៅក្នុងចិត្តរបស់យើង ដើម្បីក្លាយជានគរ—ម៉ាកុស ៤:២ ។

A. នគរព្រះ គឺជារឿងរាវនៃជីវិត ។ ពេលដែលគ្រាប់ពូជចម្រើនធំនៅខាងក្នុងពួកគេនោះហើយគឺជាការចម្រើនធំនៃនគរ ។

B. អាចិកំបាំងក្នុងការចូលទៅក្នុងនគរ គឺការចម្រើនធំក្នុងជីវិត ។ យើងចូលទៅក្នុងនគរ រាល់ថ្ងៃ ដោយការចម្រើនធំនៃជីវិតផ្នែកខាងក្នុង—ខ២៦-២៧ ។

**II. សម្រាប់យើង សព្វថ្ងៃនេះ នគរ គឺជាការហ្វឹកហ្វឺន ។ យើងត្រូវតែរៀនពីរបៀបការបានហ្វឹកហ្វឺន ដើម្បីក្លាយជាស្តេច—រ៉ូម៥:១៧ ។**

A. គ្រួសាររាជវង្សនៅចក្រភពអង់គ្លេស ត្រូវតែបង្វឹកបង្ហាត់ព្រះរាជា ឬមហាក្សត្រី តាំងពីជំនាន់យុវវ័យមកម្ល៉េះ ។ ដូច្នេះ យើងត្រូវតែហ្វឹកហ្វឺន និងត្រូវបានគ្រប់គ្រង ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការធ្វើជាស្តេចនៅឋានសួគ៌ ។

B. យើងត្រូវសោយរាជ្យជាស្តេច លើអំពើបាប សេចក្តីស្លាប់ និងសាតាំង ។ ដើម្បីសោយរាជ្យបាន គឺត្រូវធ្វើជាស្តេច ។ សព្វថ្ងៃនេះ ជីវិតគ្រិស្ទានរបស់យើង គួរតែជាជីវិតក្នុងភាពជាស្តេច និងជាជីវិតដែលសោយរាជ្យ ។

**III. ដំណឹងល្អនៃនគររួមទាំងដំណឹងល្អនៃព្រះគុណ (កិច្ចការ ២០:២៤) មិនត្រឹមតែនាំមនុស្សចូលទៅក្នុងសេចក្តីសង្គ្រោះរបស់ព្រះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់នគរឋានសួគ៌ផងដែរ (វិវរណៈ ១:៩);**

A. ការសង្កត់ធ្ងន់នៃដំណឹងល្អនៃនគរគឺស្ថិតនៅលើការគ្រប់គ្រងផ្នែកឋានសួគ៌របស់ព្រះ និងអំណាចរបស់ព្រះអម្ចាស់ ។

B. ទីបន្ទាល់នេះត្រូវតែរាលដាលដល់ផែនដីទាំងមូលមុនចុងបញ្ចប់នៃគ្រានេះ ជាពេលដែលមានទុក្ខវេទនាដ៏ធំ ។

**IV. យើងនឹងមានភាពជាស្តេចជារួមគ្នា និងទទួលសេចក្តីអំណរបំផុតនៃជីវិតព្រះជាមួយទ្រង់នៅក្នុងនគរមួយពាន់ឆ្នាំ—២០:៤, ៦ ។**

V. ថ្ងៃនេះនគរព្រះជាការហ្វឹកហ្វឺនដល់ខ្ញុំ / តែពេលព្រះគ្រិស្តសោយរាជ្យនឹងក្លាយជារង្វាន់ធំ / ដើម្បីបំពេញសម្រេចផែនការរបស់ព្រះអង្គ / ដើម្បីបំពេញសម្រេចផែនការរបស់ព្រះអង្គ ។ យើងបានកើតជាថ្មីជាស្តេចនិងជាកូនព្រះ / ទើបត្រូវហ្វឹកហ្វឺនឱ្យក្លាយជាអ្នកមានជ័យជម្នះ / ឱ្យដឹងពីការគ្រប់គ្រងជាស្តេចក្នុងនគរព្រះ / អំណាចជាស្តេចត្រូវបានសម្តែងដោយឫទ្ធិតេជះ—(ចម្រៀងខ្មែរលេខ ៧៥១ បទអង់គ្លេសលេខ ៩៤៧) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៤១  ការតតាំងនឹងអារក្ស

**ដកស្រង់ពី:**

យ៉ាកុប ៤:៧  ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតតាំងនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។

វិធីដើម្បីតតាំងនឹងអារក្ស គឺដោយសេចក្ដីជំនឿ ។ ប្រសិនបើយើងជឿលើព្រះគ្រិស្ដ ហើយទុកចិត្តទ្រង់ជាអ្នកមានជ័យរបស់យើង នោះយើងនឹងបទពិសោធន៍ចេស្ដានូវជ័យជម្នះរបស់ព្រះគ្រិស្ដជានិច្ច ។ យើងត្រូវរៀននិយាយថាបាទ / ចាសចំពោះព្រះវរបិតា ហើយថាទេចំពោះអារក្សគ្រប់ពេល ។

**ខ្លឹមសារ:**

យ៉ាកុប ៤:៧ ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតតាំងនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។

១ពេត្រុស ៥:៨-៩ក ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ចូរតតាំងនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុងលោកិយនេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ ។

I. **នៅក្នុងអត្ថបទដើម ពាក្យថាសាតាំង មានន័យថា "អ្នកប្រឆាំង និងជាខ្មាំងសត្រូវ" :**
   A. អារក្សប្រឆាំងនឹងអ្វីៗទាំងអស់ដែលព្រះធ្វើ ។ លើសពីនេះទៅទៀត វាតែងតែប្រឆាំងនឹងកូនៗរបស់ព្រះ—១ពេត្រុស ៥:៨-៩ ។
   B. ដើម្បីតតាំងនឹងអារក្សមានន័យថា យើងតតាំងនឹងវាដោយជ័យជម្នះរបស់ព្រះគ្រិស្ដ ។

II. **តតាំងនឹងវា ដោយមានសេចក្តីជំនឿមុតមាំរបស់អ្នក ។ អារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ៥ៈ៨-៩:**

A. ដំបូង យើងត្រូវតែជឿថា ព្រះអម្ចាស់ត្រូវបានលេចមកក្នុងគោលបំណងបំផ្លាញកិច្ចការរបស់អារក្ស—១យ៉ូហាន ៣:៨ ។

B. ទីពីរ យើងត្រូវតែជឿថា តាមរយៈការសុគត ព្រះអម្ចាស់យេស៊ូត្រូវបានបំផ្លាញវាដែលមានអំណាចនៃសេចក្តីស្លាប់ គឺជាអារក្ស—ហេព្រើរ ២:១៤; ១យ៉ូហាន ៣:៨ ។

C. ទីបី យើងត្រូវតែជឿថា ការរស់ឡើងវិញរបស់ព្រះអម្ចាស់ បានធ្វើឱ្យសាតាំងអាម៉ាស់ ។ សាតាំងលែងមានមធ្យោបាយមកវាយប្រហារយើងទៀតហើយ—កូល៉ុស ២:១២-១៥; ភីលីព ៣:១០ ។

D. ទីបួន យើងត្រូវតែជឿថា ការយាងទៅឋានដ៏ខ្ពស់របស់ព្រះអម្ចាស់ បានធ្វើឱ្យទ្រង់ខ្ពស់លើសជាងអំណាចរបស់សាតាំងទាំងអស់ ។ ព្រះអម្ចាស់យេស៊ូបានគង់នៅឋានសួគ៌រួចហើយ ហើយមានអំណាចខ្លាំងជាងសាតាំងទៅទៀត—អេភេសូរ ២:៦ ។

III. **សូមឱ្យយើងមានសេចក្តីជំនឿចំពោះរឿង ៤ យ៉ាង ដែលព្រះអម្ចាស់បានបំពេញសម្រេចសម្រាប់យើងរួចហើយ និងសូមឱ្យយើងមានជំនឿរឹងមាំដើម្បីតតាំងនឹងសាតាំងហើយបដិសេធការងាររបស់វាមកលើយើង—១ពេត្រុស ៥:៨-៩ ។**

IV. **ចំពោះសាតាំងខ្ញុំសូមថា ទេ តែព្រះវរបិតាខ្ញុំ អាមែន ឱ្យទ្រង់នឹងបានសម្រេចបំណងគ្រោងការគ្រប់យ៉ាងឥតសៅហ្មង ពេលខ្ញុំធ្វើតាមព្រះរាជបញ្ជា សូមទ្រង់ប្រទាន ឱ្យចេស្តាឱ្យខ្ញុំបានពេញដោយព្រះវិញ្ញាណ សម្រេចបំណងដែលទ្រង់មាន ។ (បទចម្រៀងលេខ ៦៤០, អង់គ្លេស ៨៨០) ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី៤២ ការមិនស្រឡាញ់លោកិយ

**ដកស្រង់ពី :**

១យ៉ូហាន ២:១៥ កុំឱ្យស្រឡាញ់លោកិយ ឬរបស់អ្វីដែលនៅក្នុងលោកិយនេះឱ្យសោះ បើអ្នកណាស្រឡាញ់លោកិយ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ ។

"លោកិយ" មានន័យថា "ប្រព័ន្ធ" ឬ "អង្គការ" ។ សាតាំងដណ្តើមមនុស្សតាមរយៈការរៀបចំខាងលោកិយ និងប្រព័ន្ធរបស់វា ។ នៅក្នុងគម្ពីរសញ្ញាថ្មី យើងត្រូវបានបង្គាប់មិនឱ្យស្រឡាញ់លោកិយ ។ ក្តីស្រឡាញ់ព្រះ គឺជាផ្លូវដ៏ល្អបំផុត ដើម្បីញែកយើងចេញពី និងមិនឱ្យសៅហ្មងដោយលោកិយ ។

**ខ្លឹមសារ :**

១យ៉ូហាន ២:១៥ កុំឱ្យស្រឡាញ់លោកិយ ឬរបស់អ្វីដែលនៅក្នុងលោកិយនេះឱ្យសោះ បើអ្នកណាស្រឡាញ់លោកិយ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ ។

យ៉ាកុប ៤:៤ តើមិនដឹងទេឬអីថា ដែលស្រឡាញ់ដល់លោកិយ នោះគឺជាខ្មាំងសត្រូវនឹងព្រះហើយ ដូច្នេះ អ្នកណាដែលចូលចិត្តចង់ធ្វើជាមិត្តសម្លាញ់នឹងលោកិយ នោះឈ្មោះថា បានតាំងខ្លួនជាខ្មាំងសត្រូវនឹងព្រះវិញ ។

១យ៉ូហានទី ២:១៧ ឯលោកិយនេះ និងសេចក្តីប៉ងប្រាថ្នារបស់វា នោះកំពុងកន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ ។

I. **១យ៉ូហាន ២:១៥ និយាយថា "កុំឱ្យស្រឡាញ់លោកិយ ឬរបស់អ្វីដែលនៅក្នុងលោកិយនេះឱ្យសោះ បើអ្នកណាស្រឡាញ់លោកិយ អ្នកនោះគ្មានសេចក្ដីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ" :**
   A. "លោកិយ" មានន័យថា "ប្រព័ន្ធ" ឬ "អង្គការ" ។ សាតាំងដណ្ដើមមនុស្សតាមរយៈការរៀបចំខាងលោកិយ និងប្រព័ន្ធរបស់វា ។
   B. នៅចំពោះព្រះជាម្ចាស់ លោកិយ គឺកង្វក់ វារិតតែកង្វក់ជាងអំពើបាបទៅទៀត ។ ដូច្នេះ យើងដែលជាអ្នកត្រូវបានព្រះអម្ចាស់សង្គ្រោះពីលោកិយ គួររក្សាខ្លួនឯងកុំឱ្យសៅហ្មងពីភាពកង្វក់របស់វា—ខ១៥ ។

II. **"ឯលោកិយនេះ និងសេចក្ដីប៉ងប្រាថ្នារបស់វា នោះកំពុងកន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ"—ខ១៧ :**
   A. លោកិយ និងរបស់ទាំងឡាយដែលនៅក្នុងវា គឺស្ថិតនៅក្រោមការប្រតិបត្តិនៃការជំនុំជម្រះ របស់ព្រះ ។ ចុងបំផុតរបស់ពួកវា គឺនៅមិនយូរទៀតទេ គឺនៅសល់តិចណាស់សម្រាប់ភាពអស់កល្ប ពួកវានឹងកន្លងទៅ—យ៉ូហាន ១២:៣១ ។
   B. យើងត្រូវតែរស់ជាជីវិតមួយដែលត្រូវបានញែកចេញពីលោកិយ ។ យើងត្រូវតែរក្សាខ្លួនយើងកុំឱ្យសៅហ្មងពីលោកិយឱ្យសោះ ។ ក្ដីស្រឡាញ់ព្រះ គឺជាផ្លូវដ៏ល្អបំផុតដើម្បីញែកយើងចេញពី និងមិនឱ្យសៅហ្មងដោយលោកិយ ។ តាមរយៈ សេចក្ដីស្រឡាញ់ព្រះ យើងអាចរក្សាខ្លួនយើងចេញពីការស្រឡាញ់លោកិយ ហើយនិងរក្សាយើងចេញពីការដណ្ដើមយក និងការស្មោកគ្រោករបស់លោកិយ—១យ៉ូហាន ២:១៥ ។

III. **"លះបង់លោកិយដើម្បីព្រះគ្រិស្ដ / មិនត្រូវការអ្វីល្អវិសេស / ទោះមានគ្រប់យ៉ាងក៏មិនឆ្អែតឆ្អន់ / មានតែព្រះគ្រិស្ដទើបគ្រប់គ្រាន់ / *ភាពសម្បូរទ្រង់មិនអាចពណ៌នា / បរិបូរមិនអាចឱ្យគណនា / ផ្អែមល្ហែមជ្រាលជ្រៅរាល់ពេលវេលា / ខ្ញុំភ្លក់រសជាតិទ្រង់គ្រប់គ្រា*—(បទចម្រៀងជាភាសាខ្មែរលេខ ៤៣៧ , អង់គ្លេសលេខ ១០២៥ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

## វាក្យសព្ទទី ៨៣ ព្រះចេស្តានៃការថែរក្សារបស់ព្រះ

**ដកស្រង់ពី :**

១ពេត្រុស ១:៥ក គឺឱ្យយើងរាល់គ្នា ដែលព្រះចេស្តានៃព្រះកំពុងតែថែរក្សា ដោយសារជំនឿ ។

យើងត្រូវជឿព្រះចេស្តានៃការថែរក្សារបស់ព្រះ ។ ដើម្បីបទពិសោធការថែរក្សារបស់ព្រះ យើងត្រូវនិយាយទៅព្រះអម្ចាស់ថា "ទូលបង្គំប្រគល់ខ្លួនឱ្យទ្រង់ថែរក្សា ។ ទូលបង្គំជឿព្រះ ព្រះចេស្តាថែរក្សារបស់ទ្រង់ ។

**ខ្លឹមសារ :**

១ពេត្រុស ១:៥ក គឺឱ្យយើងរាល់គ្នា ដែលព្រះចេស្តានៃព្រះកំពុងតែថែរក្សា ដោយសារជំនឿ ។

២ធីម៉ូថេ ១:១២ គឺដោយហេតុនោះ បានជាខ្ញុំរងទុក្ខទាំងនេះ តែខ្ញុំមិនខ្មាសទេ ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់អាចនឹងថែរក្សាបញ្ញើ ដែលខ្ញុំបានផ្ញើទុកនឹងទ្រង់ ដរាបដល់ថ្ងៃនោះឯង ។

យ៉ូស្វេ ១៤:១១ សព្វថ្ងៃនេះ ខ្ញុំនៅតែមានកំឡាំង ដូចក្នុងកាលដែលលោកម៉ូសេបានចាត់ខ្ញុំឱ្យទៅនោះនៅឡើយ កម្លាំងខ្ញុំឥឡូវនេះក៏ដូចជាកាលពីដើមដែរ សម្រាប់នឹងទៅច្បាំងទាំងចេញ ទៅហើយចូលមកវិញផង ។

**I. ១ពេត្រុស ១:៥ និយាយពីការ "ត្រូវបានថែរក្សាដោយព្រះចេស្តារបស់ព្រះ ដោយសារជំនឿ":**

A. យើងត្រូវតែជឿព្រះចេស្តានៃការថែរក្សារបស់ព្រះ ។ ប្រសិនបើយើងទុកចិត្តលើទ្រង់នោះរឿងរ៉ាវអស្ចារ្យនឹងកើតឡើង ។

B. រៀងរាល់ពេលព្រឹក នៅពេលយើងក្រោកពីដំណេក យើងគួរនិយាយទៅទ្រង់ថា "ឱព្រះជាម្ចាស់អើយ អរព្រះគុណទ្រង់ចំពោះការថែរក្សាទូលបង្គំពីថ្ងៃម្សិលមិញ ហើយថ្ងៃនេះ ទ្រង់នឹងនៅតែថែរក្សាទូលបង្គំ ។ ទូលបង្គំមិនដឹងថា នឹងមានសេចក្ដីល្បួងណាកើតមានដល់ទូលបង្គំនោះទេ ។ ហើយទូលបង្គំមិនអាចធ្វើអ្វីបានឡើយ តែទូលបង្គំជឿថា ទ្រង់នឹងថែរក្សាទូលបង្គំ" ។

II. **"កម្លាំងខ្ញុំឥឡូវនេះក៏ដូចជាកាលពីដើមដែរ សម្រាប់នឹងទៅច្បាំងទាំងចេញទៅហើយចូលមកវិញផង"—យ៉ូស្វេ ១៤:១១ :**

A. នេះជាពាក្យរបស់កាលែប ។ កម្លាំងរបស់កាលែបនៅតែដដែលដូចកាលដែលគាត់និយាយជាមួយនឹងលោកម៉ូសេ ទោះបីស្ថិតក្នុងជីវិតប្រចាំថ្ងៃជាធម្មតា និងជីវិតនៅក្រោមស្ថានការណ៍តានតឹង ។

B. ទោះបី៤០ឆ្នាំកន្លងផុតទៅក៏ដោយ ក៏គាត់នៅតែមានកម្លាំងដូចកាលនៅពីក្មេង ។ ត្រង់នេះយើងមើលឃើញពីព្រះចេស្ដានៃការថែរក្សារបស់ព្រះ ។

III. **២ធីម៉ូថេ ១:១២ និយាយថា "ដ្បិតខ្ញុំស្គាល់ព្រះដែលខ្ញុំបានជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់អាចនឹងថែរក្សាបញ្ញើ ដែលខ្ញុំបានបានផ្ញើទុកនឹងទ្រង់ ដរាប់ដល់ថ្ងៃនោះឯង" :**

A. ព្រះអម្ចាស់ទ្រង់នឹងរក្សាការពារយើង ប៉ុន្តែយើងត្រូវប្រគល់ខ្លួនរបស់យើងទៅក្នុងព្រះហស្ថរបស់ទ្រង់ ។

B. ដើម្បីបទពិសោធការថែរក្សាការពាររបស់ព្រះអម្ចាស់ យើងត្រូវតែនិយាយទៅទ្រង់ថា "ទូលបង្គំប្រគល់ខ្លួនចំពោះការថែរក្សាការពាររបស់ទ្រង់ ហើយទូលបង្គំជឿលើព្រះចេស្ដានៃការថែរក្សាការពាររបស់ទ្រង់" ។

IV. **"ខ្ញុំមិនដឹងម្ដេចបានជាទ្រង់ផ្ដល់ ព្រះគុណមកលោះខ្លួនខ្ញុំ / ខ្ញុំមិនគួរសោះតែទ្រង់មកដល់ប្រោសខ្ញុំឱ្យរួចបាបធំ / តែខ្ញុំបានស្គាល់ព្រះដែលខ្ញុំជឿតាម ហើយខ្ញុំជឿពិតថា ទ្រង់អាចថែរក្សា បញ្ញើដែលខ្ញុំផ្ញើទុកនឹងទ្រង់ ដរាបដល់ថ្ងៃនោះកាលណា"—(បទចម្រៀងខ្មែរលេខ ២៥៩ , អង់គ្លេសលេខ ៣៣៣) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

# ភាគ៤ ការចម្រើនធំនៅក្នុងជីវិត

# វាក្យសព្ទទី៩៤ សេចក្តីសង្ឃឹមនៃជីវិតគ្រិស្ទាន

## ដកស្រង់ពី :

ភីលីព ៣:២០ ឯយើងរាល់គ្នា យើងជាសាសន៍ឋានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូគ្រិស្ត ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពីឋាននោះឯង ។

ក្នុងនាមជាអ្នកជឿនៅក្នុងព្រះគ្រិស្ត យើងមានជីវិតមួយដែលពេញទៅដោយក្តីសង្ឃឹម ។ ក្តីសង្ឃឹមរបស់យើង គឺការយាងមកវិញរបស់ព្រះអម្ចាស់ ។ ពេលដែលទ្រង់យាងត្រឡប់មក "ទ្រង់នឹងបំផ្លាស់បំប្រែរូបកាយទាបថោករបស់យើង ឱ្យត្រឡប់ដូចជារូបឧត្តមរបស់ទ្រង់" ។

## ខ្លឹមសារ :

ភីលីព ៣:២០ ឯយើងរាល់គ្នា យើងជាសាសន៍ឋានសួគ៌វិញ ក៏នៅចាំព្រះអម្ចាស់យេស៊ូគ្រិស្ត ជាព្រះអង្គសង្គ្រោះ ទ្រង់យាងមកពីឋាននោះឯង ។

២១ ដែលទ្រង់នឹងបំផ្លាស់បំប្រែរូបកាយទាបថោករបស់យើង ឱ្យត្រឡប់ដូចជារូបឧត្តមរបស់ទ្រង់ តាមដែលព្រះចេស្តាទ្រង់ពូកែនឹងបញ្ចុះបញ្ចូលគ្រប់ទាំងអស់នៅក្រោមអំណាចទ្រង់ផង ។

**I. ក្នុងនាមជាអ្នកជឿនៅក្នុងព្រះគ្រិស្ត យើងមានជីវិតមួយដែលពេញទៅដោយក្តីសង្ឃឹម ។ ក្តីសង្ឃឹមរបស់យើង គឺការយាងមកវិញរបស់ព្រះអម្ចាស់ ។**

A. នៅលើផែនដីនេះ យើងមិនមានជោគវាសនា ទិសដៅ ឬអនាគតណាមួយឡើយ ។ អនាគត ជោគវាសនា និងទិសដៅរបស់យើង គឺផ្តោតទាំងស្រុងលើព្រះអម្ចាស់ដែលកំពុងយាងមក—អេភេសូរ ២:១២; ភីលីព ៣:២០ ។

B. ទ្រង់នឹងក្លាយជាក្តីសង្ឃឹម អនាគត និងទិសដៅរបស់យើង ។ យើងកំពុងទៅរកព្រះអម្ចាស់ ហើយជោគវាសនារបស់យើង គឺជាការជួបទ្រង់—១យ៉ូហាន ៣:២ ។

II. "ក៏នៅចាំព្រះអម្ចាស់យេស៊ូគ្រិស្ដជាព្រះអង្គសង្គ្រោះ... ដែលទ្រង់នឹងបំផ្លាស់បំប្រែរូបកាយទាបថោករបស់យើង ឱ្យត្រឡប់ដូចជារូបឧត្ដមរបស់ទ្រង់ តាមដែលព្រះចេស្ដាទ្រង់ពូកែនឹងបញ្ចុះបញ្ចូលគ្រប់ទាំងអស់ នៅក្រោមអំណាចទ្រង់ផង"—ភីលីព ៣:២០-២១ :

A. រូបកាយរបស់យើង ជា "រូបកាយទាបថោករបស់យើង" ហើយត្រូវបានខូចដោយអំពើបាប ភាពទន់ខ្សោយ ជំងឺ និងសេចក្ដីស្លាប់ ។ ប៉ុន្តែថ្ងៃមួយ រូបកាយនេះ នឹងបានបំផ្លាស់បំប្រែ និងបានត្រឡប់ដូចជារូបអង្គឧត្ដមរបស់ព្រះគ្រិស្ដ—ខ២១ ។

B. សព្វថ្ងៃនេះ យើងអាចមើលទៅដូចគ្នានឹងមនុស្សខាងលោកិយ ប៉ុន្តែនៅពេលនោះ យើងនឹងបានដូចនូវអ្វីដែលទ្រង់ជាទាំងស្រុង—១យ៉ូហាន ៣:២ ។

C. ខណៈពេលដែលយើងកំពុងរង់ចាំការយាងត្រលប់មកវិញរបស់ព្រះអម្ចាស់ យើងគួរតែស្រឡាញ់ព្រះអង្គ និងស្រឡាញ់ការលេចចេញរបស់ទ្រង់ ដោយរង់ចាំការយាងមកវិញរបស់ព្រះអម្ចាស់ ហើយនិងយកការយាងមកវិញរបស់ទ្រង់ ធ្វើជាការលើកទឹកចិត្ត—ភីលីព ៣:២០ ។

III. ព្រះគ្រិស្ដជាសង្ឃឹមសិរី ប្រោសលោះខ្ញុំជាមនុស្សថ្មី / ទ្រង់លោះខ្ញុំពីសេចក្ដីស្លាប់ ឱ្យរស់រានមានសេរី / ទ្រង់មកផ្លាស់ប្រែកាយខ្ញុំឱ្យ ដូចព្រះដ៏មានសេរី / ទ្រង់លេបសេចក្ដីស្លាប់ រហូត ខ្ញុំបានជោគជ័យ / *ទ្រង់មកទ្រង់មក ទ្រង់មកឱ្យខ្ញុំមានសិរី / ទ្រង់ប្រែរូបកាយខ្ញុំឱ្យដូចទ្រង់ ចេញផុតពីភាជនៈដី / ទ្រង់មកទ្រង់មកប្រោសលោះខ្ញុំបានអំណរ / ទ្រង់ជាសង្ឃឹមសិរីល្អខ្ញុំឱ្យ ខ្ញុំមានសិរីល្អ* (បទចម្រៀងជាភាសាខ្មែរលេខ ៧៦៣, អង់គ្លេសលេខ ៩៥៩) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី៩៥ វិញ្ញាណមនុស្ស

**ដកស្រង់ពី :**

សាការី ១២:១ខ ព្រះយេហូវ៉ា ជាព្រះដែលបានលាតផ្ទៃមេឃ ហើយដាំឫសនៃផែនដី ព្រមទាំងបង្កបង្កើតវិញ្ញាណនៅក្នុងខ្លួនមនុស្សផង ។

នៅក្នុងព្រះនេត្ររបស់ព្រះ មានរបស់សំខាន់ៗបីយ៉ាងដូចគ្នានៅក្នុងសកលលោក គឺផ្ទៃមេឃ ផែនដី និងវិញ្ញាណរបស់មនុស្ស ។ វិញ្ញាណរបស់មនុស្ស គឺជាសរីរាង្គដែលអាចទទួលយកព្រះចូលមកក្នុង ។ សព្វថ្ងៃនេះ យើងមិនគួរប្រើគំនិតរបស់យើងដើម្បីថ្វាយបង្គំព្រះឡើយ ។ ផ្ទុយទៅវិញ យើងត្រូវតែប្រើវិញ្ញាណរបស់យើងដើម្បីថ្វាយបង្គំព្រះ ។

ខ្លឹមសារ :

សាការី ១២:១ខ ព្រះយេហូវ៉ា ជាព្រះដែលបានលាតផ្ទៃមេឃ ហើយដាំឫសនៃផែនដី ព្រមទាំងបង្កបង្កើតវិញ្ញាណនៅក្នុងខ្លួនមនុស្សផង ។

យ៉ូហាន ៤:២៤ ឯព្រះ ទ្រង់ជាព្រះវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្តីពិតដែរ ។

I. **"ព្រះយេហូវ៉ា ជាព្រះដែលបានលាតផ្ទៃមេឃ ហើយដាំឫសនៃផែនដី ព្រមទាំងបង្កបង្កើតវិញ្ញាណនៅក្នុងខ្លួនមនុស្សផង"—សាការី ១២:១ខ :**

   A. នៅក្នុងព្រះនេត្ររបស់ព្រះ មានរបស់សំខាន់ៗស្មើគ្នាបីយ៉ាង នៅក្នុងសកលលោក គឺផ្ទៃមេឃ ផែនដី និងវិញ្ញាណរបស់មនុស្ស ។ តាមការប៉ាន់ស្មានរបស់ព្រះ វិញ្ញាណរបស់យើង គឺសំខាន់ដូចផ្ទៃមេឃ និងផែនដី ។ មនុស្ស គឺជាចំណុចកណ្តាលនៃសកលលោក រីឯវិញ្ញាណរបស់មនុស្ស គឺជាចំណុចកណ្តាលនៃមនុស្ស—ខ១ ។

   B. ផ្ទៃមេឃគឺសម្រាប់ផែនដី ផែនដីគឺសម្រាប់មនុស្ស រីឯមនុស្សដែលមានវិញ្ញាណគឺសម្រាប់ព្រះ—ខ១ ។

II. **នៅក្នុងយ៉ូហាន ៤:២៤ និយាយថា "ឯព្រះ ទ្រង់ជាព្រះវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ នឹងសេចក្តីពិតដែរ" :**

A. នៅក្នុងរូបកាយរបស់យើងមានមាត់ និងក្រពះដើម្បីដាក់អាហារ ។ បើគ្មានអាហារ យើងដែលជាមនុស្ស មិនអាចមានជីវិតរស់នៅបានឡើយ ។ ប៉ុន្តែ អ្វីដែលព្រះចាត់ទុកថាសំខាន់បំផុតនៅក្នុងខ្លួនរបស់យើង គឺមិនមែនជាសរីរាង្គខាងសរីរៈ ឬចិត្តវិទ្យាឡើយ តែជាវិញ្ញាណរបស់យើង ។ វិញ្ញាណរបស់យើង គឺជា "ក្រពះ" ខាងវិញ្ញាណរបស់យើង ដើម្បីដាក់ព្រះជាម្ចាស់ទ្រង់ផ្ទាល់—រ៉ូម ៩:២៣ ។

B. សព្វថ្ងៃនេះ យើងមិនគួរប្រើគំនិតរបស់យើងដើម្បីថ្វាយបង្គំព្រះនោះទេ ។ ផ្ទុយទៅវិញ យើងត្រូវប្រើវិញ្ញាណរបស់យើងដើម្បីថ្វាយបង្គំព្រះ ។ របស់ដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ ។ មានតែព្រះវិញ្ញាណទេ ដែលអាចបង្កើតវិញ្ញាណ ។ មានតែវិញ្ញាណទេ ដែលអាចថ្វាយបង្គំព្រះវិញ្ញាណ—យ៉ូហាន ៤:២៤ ។

III. **"ទ្រង់ជាវិញ្ញាណបង្កើតមនុស្សមានវិញ្ញាណ / ថ្វាយបង្គំដោយវិញ្ញាណ / ដើម្បីមនុស្សទទួលជីវិតព្រះអង្គ /សម្រាប់ចិញ្ចឹមជីវិត** ។ */វិញ្ញាណបានកើតជាថ្មី / បានបំពេញក្នុងវិញ្ញាណ/ ដោយព្រះបន្ទូលនាំភាពបរិបូរណ៍ទាំងអស់ / ដូចទន្លេហូរទឹករស់"—ព្រះហើយនិងមនុស្សគឺជារឿងរ៉ាវដ៏ពិត—* (បទចម្រៀងខ្មែរលេខ ៩៥០) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី ៩៦ ព្រះវិញ្ញាណដែលបានលាយបញ្ចូល

**ដកស្រង់ពី :**

១កូរិនថូស ៦:១៧ ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជាវិញ្ញាណ តែ១ នឹងទ្រង់ដែរ ។

សព្វថ្ងៃ ពីព្រោះព្រះគ្រិស្តជាព្រះវិញ្ញាណផ្តល់ជីវិត ហើយយើងមានវិញ្ញាណនៅផ្នែកដ៏ជ្រៅបំផុត នោះវិញ្ញាណទាំងពីរនេះមក និងលាយបញ្ចូលគ្នាក្លាយជាវិញ្ញាណតែមួយ ។ យើងត្រូវតែដើរតាមវិញ្ញាណដែលបានលាយបញ្ចូលនេះ ។

**ខ្លឹមសារ :**

១កូរិនថូស ៦:១៧ ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជាវិញ្ញាណតែ១ នឹងទ្រង់ដែរ ។

២កូរិនថូស ៤:៧ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឱ្យឥទ្ធិឫទ្ធិដ៏លើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ ។

២ធីម៉ូថេ ៤:២២ សូមឱ្យព្រះអម្ចាស់យេស៊ូគ្រិស្ត បានគង់នៅជាមួយនឹងវិញ្ញាណអ្នក សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ ។

I. **មានខមួយក្នុងចំណោមខដែលល្អជាងគេបំផុតនៅក្នុងព្រះគម្ពីរគឺ ១កូរិនថូស ៦:១៧ និយាយថា “ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជា វិញ្ញាណតែ១ នឹងទ្រង់ដែរ” :**

   A. វិញ្ញាណរបស់យើង ត្រូវបានលាយបញ្ចូលជាមួយនឹង វិញ្ញាណរបស់ព្រះ ។ ការនេះគឺប្រៀបដូចជាតែ ។ មុនដំបូងទឹកគឺសុទ្ធធម្មតា ប៉ុន្តែពេលដាក់តែចូលទៅក្នុងទឹក នោះយើងមានអង្គធាតុពីរដែលបានលាយបញ្ចូលគ្នា ក្លាយជាភេសជ្ជៈមួយ ។ យើងថែមទាំងហៅភេសជ្ជៈនេះថា ជាទឹកតែទៀងផង ។ តាមពិតទៅ ភេសជ្ជៈនេះមិន

គ្រាន់តែជាតែ ប៉ុន្តែក៏ជាតែដែលបានលាយបញ្ចូលជាមួយទឹកទៀតផង ។ រឿងទាំងពីរត្រូវបានលាយបញ្ចូលគ្នា ក្លាយទៅជាអង្គភាពមួយ—ខ១៧ ។

B. ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធ និង វិញ្ញាណរបស់យើង បានលាយបញ្ចូលគ្នាក្លាយជាវិញ្ញាណតែមួយ ។ នៅលើផែនដី ក្នុងសកលលោកនេះ គឺមានកន្លែងមួយ ដែលព្រះគ្រិស្តដ៏ជា ព្រះវិញ្ញាណផ្តល់ជីវិត ជាតែមួយជាមួយនឹងពួកយើង—២ធីម៉ូថេ ៤:២២ ។

**II. នៅក្នុង ២កូរិនថូស ៤:៧ និយាយថា "យើងមានទ្រព្យសម្បត្តិនេះនៅ ក្នុងភាជនៈដី ដើម្បីឱ្យឥទ្ធិឫទ្ធិដ៏លើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ" ។ ពួកយើងជាពួកអ្នកដែលបានប្រោសលោះ គឺពិតជាមានវិញ្ញាណដែលបានលាយបញ្ចូលដ៏អស្ចារ្យ ទុកធ្វើជាទ្រព្យសម្បត្តិនៅខាងក្នុងខ្លួនយើង :**

A. នៅខាងក្នុងវិទ្យុមានផ្នែកជាក់លាក់មួយ ដែលទទួលរលកវិទ្យុ ។ ដូចគ្នាដែរ នៅខាងក្នុងខ្លួនយើង គឺមានសិរីរាង្គមួយ សម្រាប់ទទួលយកព្រះគ្រិស្ត ទុកធ្វើជាសម្បត្តិដ៏មានតម្លៃ ។ សិរីរាង្គនេះ គឺជាវិញ្ញាណរបស់មនុស្ស ។ ពួកយើងមានវិញ្ញាណនៅខាងក្នុងយើងម្នាក់ៗ ដែលអាចឱ្យយើងទទួលយកព្រះគ្រិស្ត ធ្វើជាទ្រព្យសម្បត្តិដ៏មានតម្លៃបាន ។

B. ក្នុងនាមជាព្រះវិញ្ញាណ ព្រះជាម្ចាស់គង់នៅក្នុងវិញ្ញាណរបស់យើង ប្រយោជន៍ឱ្យយើងជាតែមួយនឹងព្រះអម្ចាស់ ហើយយើងត្រូវការដាក់គំនិតខាងឯវិញ្ញាណ និងដើរតាមវិញ្ញាណដែលបានលាយបញ្ចូល—រ៉ូម.៨:៦ ។

**III. "ពេលនេះទ្រង់ជាវិញ្ញាណជីវិត ហូរនាំពន្លឺភ្លឺពិត យើងរាល់គ្នាដើរនៅក្នុងវិញ្ញាណ ដើរតាមការទ្រង់ដឹកនាំ"— (បទចម្រៀងខ្មែរលេខ ៥៤១, អង់គ្លេសលេខ ៧៤៥) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី៩៧ ការក្លាយជាវិញ្ញាណតែមួយនឹងព្រះអម្ចាស់

**ដកស្រង់ពី:**

១កូរិនថូស ៦:១៧ រីឯអ្នកដែលនៅជាប់ជាមួយព្រះអម្ចាស់ នោះក៏ជាវិញ្ញាណតែ១ រួមនឹងទ្រង់ដែរ ។

ឃ្លាថា "វិញ្ញាណតែ១" ចង្អុលបង្ហាញពីការលាយបញ្ចូលគ្នារវាងព្រះអម្ចាស់ជាព្រះវិញ្ញាណជាមួយនឹងវិញ្ញាណរបស់យើង ។ វិញ្ញាណរបស់យើងត្រូវបានកើតជាថ្មីដោយព្រះវិញ្ញាណរបស់ព្រះ ដែលឥឡូវនេះ គង់នៅក្នុងយើង និងក្លាយជាតែមួយជាមួយវិញ្ញាណរបស់យើង ។ ការហ្វឹកហាត់វិញ្ញាណរបស់យើង គឺជាគន្លឹះសម្ងាត់ក្នុងការក្លាយជាវិញ្ញាណតែមួយនឹងព្រះអម្ចាស់ ។

**ខ្លឹមសារ:**

១កូរិនថូស ៦:១៧ រីឯអ្នកដែលនៅជាប់ជាមួយព្រះអម្ចាស់ នោះក៏ជាវិញ្ញាណតែ១ រួមនឹងទ្រង់ដែរ ។

យ៉ូហាន ១៥:៥ ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ ។

I. **១កូរិនថូស ៦:១៧ ចែងថា រីឯអ្នកដែលនៅជាប់ជាមួយព្រះអម្ចាស់ នោះក៏ជាវិញ្ញាណតែ១ រួមនឹងទ្រង់ដែរ ។ ការនេះសំដៅទៅលើការរួមគ្នាផ្នែកជីវិតរបស់ពួកអ្នកជឿជាមួយព្រះអម្ចាស់ តាមរយៈការជឿចូលទៅក្នុងទ្រង់ ។ ការរួមគ្នានេះ ត្រូវបានពន្យល់បង្ហាញថា ខ្នែងនៅជាប់នឹងដើមទំពាំងបាយជូរ :**

A. ការនៅជាប់នឹងដើមទំពាំងបាយជូរ គឺជាការក្លាយជាវិញ្ញាណតែមួយនឹងព្រះអម្ចាស់ ។ ព្រះអម្ចាស់ដែលជាដើមទំពាំងបាយជូរ គឺជាព្រះវិញ្ញាណផ្តល់ជីវិត រីឯយើងដែលជាខ្នែងរបស់ទ្រង់ គឺមានវិញ្ញាណមនុស្ស ។ ដូច្នេះ យើងបាននៅជាប់នឹងព្រះអម្ចាស់ ដើម្បីក្លាយជាវិញ្ញាណតែមួយនឹងទ្រង់ ។ ដើមទំពាំងបាយជូរ គឺផ្សំពីវិញ្ញាណ វិញ្ញាណ ដូចជាវិញ្ញាណរបស់ព្រះ និងវិញ្ញាណមនុស្សដែលរួមផ្សំជាវិញ្ញាណតែមួយ—យ៉ូហាន ១៥:៥ ។

B. ឥឡូវនេះ ព្រះវិញ្ញាណបរិសុទ្ធ និងវិញ្ញាណមនុស្ស ត្រូវបានលាយបញ្ចូលគ្នាជាតែមួយ ។ នៅលើផែនដីក្នុងសកលលោកនេះ មានកន្លែងមួយដែលព្រះគ្រិស្តជាវិញ្ញាណផ្តល់ជីវិត គឺជាតែមួយនឹងយើង—១ កូរិនថូស ៦:១៧ ។

**II. ការក្លាយជាវិញ្ញាណតែមួយនឹងព្រះអង្គ គឺជាសេចក្តីសង្គ្រោះដ៏អស្ចារ្យបំផុត និងជាបទពិសោធន៍ដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់គ្រិស្ទាន—ខ១៧ ។**

**III. ការហ្វឹកហាត់វិញ្ញាណរបស់យើង គឺជាគន្លឹះសម្ងាត់ក្នុងការក្លាយជាវិញ្ញាណតែមួយនឹងព្រះអម្ចាស់—២ធីម៉ូថេ ១:៦ ។**

A. រាល់បទពិសោធន៍ខាងវិញ្ញាណរបស់យើងនៅបន្ទាប់ពីយើងបានសង្គ្រោះ ដូចជាការប្រកបជាមួយនឹងព្រះអម្ចាស់ សេចក្តីអធិដ្ឋានទៅកាន់ទ្រង់ ការដំណើរជីវិតរស់ជាមួយទ្រង់ និងការស្តាប់បង្គាប់ទ្រង់របស់យើង គឺសុទ្ធតែស្ថិតនៅក្នុងវិញ្ញាណនេះ ដែលជាព្រះវិញ្ញាណរបស់ព្រះអម្ចាស់ និងវិញ្ញាណរបស់យើង បានលាយបញ្ចូលគ្នាចូលទៅក្នុងជីវិតតែមួយ—ខ២៧ ។

B. ក្នុងនាមជាវិញ្ញាណតែមួយ យើងត្រូវតែអនុវត្តការរួមគ្នារបស់យើងជាមួយព្រះអម្ចាស់ ។ យើងត្រូវអធិដ្ឋានថា " ឱ ព្រះអម្ចាស់អើយ ទូលបង្គំជាវិញ្ញាណតែមួយនឹងទ្រង់ ។ ពេលទូលបង្គំនិយាយ ទ្រង់ក៏មានបន្ទូល ហើយពេលទូលបង្គំធ្វើអ្វី ទ្រង់ក៏ធ្វើអ្វីនោះដែរ ដ្បិតទ្រង់ និងទូលបង្គំ ទូលបង្គំនិងទ្រង់ គឺជាវិញ្ញាណតែមួយ" ។

**IV. ព្រះយេស៊ូខ្ញុំរួមជាមួយទ្រង់ រួមតែមួយនៅក្នុងវិញ្ញាណ /ទ្រង់មានជីវិតរស់នៅក្នុងខ្ញុំ ឱ្យខ្ញុំបានអំណរព្រះអង្គ / រួមតែមួយ រួមតែមួយ ទ្រង់នឹងខ្ញុំ រួមតែមួយ / ភាពបរិបូរណ៌ទ្រង់ចិញ្ចឹមខ្ញុំ ព្រះអង្គគឺជាគ្រប់ទាំងអស់ (បទចម្រៀងជាភាសាខ្មែរលេខ ៣៥ , អង់គ្លេសលេខ ៤៧៤) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី ៩៨ ការហ្វឹកហាត់ប្រើវិញ្ញាណ

**ដកស្រង់ពី :**

២ធីម៉ូថេ ១:៦-៧ ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឱ្យបញ្ឆេះរឹតខ្លាំងឡើងនូវអំណោយទានរបស់ព្រះ ។

ការហ្វឹកហាត់វិញ្ញាណរបស់យើង ការប្រើវិញ្ញាណរបស់យើង នោះគឺជាការបញ្ឆេះវិញ្ញាណរបស់យើងឆេះរឹតតែខ្លាំងឡើង ។ ការអំពាវនាវព្រះនាមរបស់ព្រះអម្ចាស់ គឺជាគន្លឹះសំងាត់ដ៏ល្អបំផុតក្នុងការហ្វឹកហាត់វិញ្ញារបស់យើង ។

**ខ្លឹមសារ :**

២ធីម៉ូថេ ១:៦-៧ ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឱ្យបញ្ឆេះរឹតខ្លាំងឡើងនូវអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាច សេចក្ដីស្រឡាញ់ នឹងប្រាជ្ញានឹងធឹងវិញ ។

១ធីម៉ូថេ ៤:៧ កុំឱ្យព្រមស្ដាប់អស់ទាំងរឿងល្បែងរបស់ស្រីចាស់ៗឡើយ ចូរបង្ហាត់ខ្លួនខាងឯសេចក្ដីគោរពប្រតិបត្តិដល់ព្រះវិញ ។

**I. ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឱ្យបញ្ឆេះរឹតតែខ្លាំងឡើងនូវអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ ។ ដ្បិតព្រះទ្រង់មិនបានប្រទានឱ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឱ្យមានវិញ្ញាណដ៏មានអំណាច សេចក្ដីស្រឡាញ់ នឹងប្រាជ្ញានឹងធឹងវិញ—២ធីម៉ូថេ ១:៦-៧ :**

A. រាល់សរីរាង្គដែលនៅក្នុងរាងកាយយើង កាលណាខានប្រើវាអស់រយៈពេលយូរ នោះវានឹងបាត់បង់កម្លាំងនឹងមុខងារប្រើការ ដូចគ្នាផងដែរប្រសិនបើយើងចង់ឱ្យវិញ្ញាណរបស់យើងរឹងមាំនិងមានកម្លាំង យើងត្រូវការហ្វឹកហាត់វា—ហេព្រើរ ៥:១៤ ។

B. យើងត្រូវការហ្វឹកហាត់វិញ្ញាណរបស់យើង ដែលនោះគឺបញ្ចេះវិញ្ញាណរបស់យើងរឹតតែខ្លាំងឡើង ។

**II. ១ធីម៉ូថេ ៤:៧ "...ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ" ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ មានន័យថា ហ្វឹកហាត់ប្រើវិញ្ញាណរបស់យើង :**

A. ពាក្យថា ហ្វឹកហាត់ ជាពាក្យមូលដ្ឋានគ្រឹះនៅក្នុងភាសាអង់គ្លេស គឺជាការធ្វើ លំហាត់ប្រាណ ។ ដើម្បីរួមមានចំណែកក្នុងការធ្វើលំហាត់ប្រាណ គឺយើងត្រូវតែប្រើទាល់តែអស់ទាំងកម្លាំងដែលមាននៅក្នុងរាងកាយយើងទាំងមូល ។ យើងត្រូវការហ្វឹកហាត់វិញ្ញាណរបស់យើងនៅក្នុងវិធីដូចគ្នា ។

B. ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ មានន័យថា ហ្វឹកហាត់វិញ្ញាណរបស់យើង បង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះ អនុញ្ញាតឱ្យព្រះ ដែលស្នាក់នៅក្នុងវិញ្ញាណរបស់យើងបានសម្តែងចេញតាមរយៈយើង—ខ.៧ ។

**III. ការអំពាវនាវព្រះនាមរបស់ព្រះអម្ចាស់ គឺជាគន្លឹះសម្ងាត់ដ៏ល្អបំផុតក្នុងការហ្វឹកហាត់វិញ្ញាណរបស់យើង—១ថែស្សាឡូនីច ៥:១៧; រ៉ូម.១០:១៣ ។**

**IV. "ហ្វឹកហាត់ប្រើប្រាស់វិញ្ញាណ បដិសេធគំនិតរាល់ពេលប្រជុំស្នាលស្និត នេះជាគន្លឹះពិត / ហ្វឹកហាត់ប្រើប្រាស់វិញ្ញាណ ប៉ះពាល់ព្រះអម្ចាស់ វិញ្ញាណស្គាល់បន្ទូលព្រះ បានភ្លក់រសជាតិទ្រង់ / ដោយការប្រើប្រាស់វិញ្ញាណ ជាអ្វីដែលត្រូវការ ដោយការប្រើប្រាស់វិញ្ញាណទ្រង់នាំហើយមេត្តា"—(បទចម្រៀងខ្មែរលេខ ៦២៨, អង់គ្លេសលេខ ៨៦៦) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី ៤៩ ការបានពេញជាព្រះវិញ្ញាណ

**ដកស្រង់ពី :**

អេភេសូរ ៥:១៨ កុំឱ្យស្រវឹងស្រា ដែលនាំឱ្យព្រើលចិត្តឡើយ តែចូរឱ្យបានពេញជាព្រះវិញ្ញាណវិញ ។

"ពេញ" មានន័យថា ការបានពេញនៅខាងក្នុង ។ វិញ្ញាណរបស់យើងមិនគួរនៅទទេទេ ប៉ុន្ដែគួរតែបានពេញជាមួយនឹងភាពបរិបូររបស់ព្រះគ្រិស្ដវិញ ។ ប្រសិនបើយើងចង់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ យើងត្រូវតែអធិដ្ឋាន និងសារភាពបាបជារៀងរាល់ថ្ងៃ ។

ខ្លឹមសារ :

អេភេសូរ ៥:១៨ កុំឱ្យស្រវឹងស្រា ដែលនាំឱ្យព្រើលចិត្តឡើយ តែចូរឱ្យបានពេញជាព្រះវិញ្ញាណវិញ ។

កិច្ចការ ២:៣៨ ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូគ្រិស្ដ ប្រយោជន៍ឱ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ។

I. **អេភេសូរ ៥:១៨ និយាយថា "កុំឱ្យស្រវឹងស្រា ដែលនាំឱ្យព្រើលចិត្តឡើយ តែចូរឱ្យបានពេញជាព្រះវិញ្ញាណវិញ"** ។ វិញ្ញាណរបស់យើងមិនគួរនៅទទេទេ ប៉ុន្ដែគួរតែបានពេញជាមួយនឹងភាពបរិបូររបស់ព្រះគ្រិស្ដវិញ :
   A. ភាពស្រវឹងធ្វើឱ្យមនុស្សវង្វេងស្មារតី ព្រោះស្រាត្រឡប់ជាសកម្មខាងប្រតិបត្តិការថាមពលនៅខាងក្នុង ហើយនាំឱ្យចេញជាការរស់នៅមិនធម្មតា—ខ១៨ ។
   B. ស្រដៀងគ្នាដែរ ការដំណើរជីវិតគ្រិស្ទានដ៏ប្រក្រតី គឺជាការដំណើរជីវិតខាងវិញ្ញាណដែលចេញមកពីការហូរហៀរនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងយើង ដែលជាអំណាច

សកម្ម ។ ដូច្នេះ ការដំណើរជីវិតគ្រិស្ទានដ៏ប្រក្រតី គួរតែជាការដំណើរជីវិតប្រកបដោយសេចក្ដីអរសប្បាយ ដែលពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ—ខ១៨ ។

II. យើងត្រូវតែមានសេចក្ដីអធិដ្ឋានគ្រប់គ្រាន់ និងហ្មត់ចត់ រហូតដល់យើងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ។ ដើម្បីអធិដ្ឋានរហូតដល់យើងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ តម្រូវឱ្យយើងបានបំភ្លឺ និងសារភាពអំពើបាបរបស់យើង—កិច្ចការ ២:៣៨ :

A. នៅពេលបងប្អូនអធិដ្ឋានតាមរបៀបនេះ សូមកុំស្វែងរកពីអារម្មណ៍ឡើយ ។ បងប្អូនត្រូវតែជឿថា ព្រះវិញ្ញាណរបស់ព្រះអម្ចាស់គង់នៅជាមួយបងប្អូន ។ យោងតាមអារម្មណ៍ខាងក្នុង និងការចងចាំរបស់បងប្អូន បងប្អូនក៏ត្រូវការសារភាពអំពើបាបរបស់បងប្អូននៅចំពោះព្រះអម្ចាស់ម្ដងមួយៗ រហូតដល់បងប្អូនមិនមានអ្វីត្រូវសារភាពទៀត ។ ពេលបងប្អូនបានធ្វើបែបនេះហើយ បងប្អូនគួរតែជឿថា វិញ្ញាណរបស់បងប្អូនបានពេញដោយព្រះត្រីឯកហើយ—ខ៣៨ ។

B. ការដកដង្ហើម គឺប្រៀបដូចជាសេចក្ដីអធិដ្ឋានរបស់យើង រីឯការលាងដៃ គឺប្រៀបដូចជាការសារភាពបាបរបស់យើង ។ ប្រសិនបើយើងចង់បានពេញដោយព្រះវិញ្ញាណបរិសុទ្ធ យើងត្រូវតែអធិដ្ឋាន និងសារភាពបាបរាល់ថ្ងៃ—១យ៉ូហាន ១:៩ ។

**III. ទ្រង់អាចមកសណ្ឋិតពោរពេញពិត ដើម្បីធ្វើជាម្ចាស់ជីវិត សូមទ្រង់តាំងលំនៅឱ្យនៅនិត្យ សូមឱ្យសូមសណ្ឋិតឥឡូវ *សូមសណ្ឋិតនៅក្នុងចិត្ត ឱព្រះយេស៊ូសូមថ្នមថ្នឹត ឱ្យវិញ្ញាណនៃព្រះយាងមក សណ្ឋិតពោរពេញក្នុងចិត្តផងខ្ញុំ*—(បទចម្រៀងខ្មែរលេខ ២១៧ អង់គ្លេសលេខ ២៦៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៥ ការដើរយោងតាមវិញ្ញាណ

## វាក្យសព្ទទី៥០ ការដើរយោងតាមវិញ្ញាណ

**ដកស្រង់ពី:**

រ៉ូម ៨:៤ ដើម្បីឱ្យសេចក្តីដែលក្រឹត្យវិន័យបង្គាប់មក បានសម្រេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់ឈាម គឺដើរតាមវិញ្ញាណវិញ ។

ពាក្យ ដើរ ក្នុងឃ្លាពាក្យ ដើរ... យោងតាមវិញ្ញាណ សំដៅលើ ការរស់នៅ ការធ្វើចលនា សកម្មភាព កិរិយាប្រព្រឹត្ត និងសកម្មភាពរបស់យើង ។ ដើរយោងតាមវិញ្ញាណ គឺជាអ្វីដែលយោងតាមវិញ្ញាណ ។ យើងដើរយោងតាមវិញ្ញាណ យើងនឹងមានអារម្មណ៍ស្កប់ចិត្ត និងមានសេចក្តីសុខសាន្ត ។

**ខ្លឹមសារ:**

រ៉ូម ៨:៤ ដើម្បីឱ្យសេចក្តីដែលក្រឹត្យវិន័យបង្គាប់មក បានសម្រេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់ឈាម គឺដើរតាមវិញ្ញាណវិញ ។

រ៉ូម ៨:៦ ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្តីស្លាប់ទទេ ឯគំនិតខាងវិញ្ញាណ នោះទើបជាជីវិត និងសេចក្តីសុខសាន្តវិញ ។

កាឡាទី ៥:២៥ បើសិនជាយើងរស់ដោយនូវព្រះវិញ្ញាណ នោះត្រូវដើរដោយព្រះវិញ្ញាណដែរ ។

**I. រ៉ូម ៨:៤ ចែងថា "ដើម្បីឱ្យសេចក្តីដែលក្រឹត្យវិន័យបង្គាប់មក បានសម្រេចក្នុងខ្លួនយើងរាល់គ្នា ដែលមិនដើរតាមសាច់ឈាម គឺដើរតាមវិញ្ញាណវិញ" ។ ពាក្យ "ដើរ" នៅត្រង់នេះមានន័យថា រស់នៅ ធ្វើចលនា និងរួមទាំងខ្លួនប្រាណយើងទាំងមូល ។ ពាក្យនេះបង្ហាញថា យើងគួរតែ ធ្វើគ្រប់ការទាំងអស់នៅក្នុងវិញ្ញាណ :**

A. ការដើរយោងតាមវិញ្ញាណ មានន័យថា គ្រប់ទាំងផ្នែកនៃការរស់នៅរបស់យើង ទាំងការបរិភោគ និងការផឹក ការដើរ និងធ្វើសកម្មភាព ការងារ និងការបម្រើ ការថ្វាយបង្គំ និងការអធិដ្ឋានរបស់យើង ត្រូវធ្វើតាមវិញ្ញាណ ព្រមទាំងយោង តាម វិញ្ញាណ ។ ជីវិតគ្រិស្ទានរបស់យើងទាំងស្រុង គួរតែនៅក្នុងវិញ្ញាណ ។

B. ការដើរយោងតាមវិញ្ញាណរបស់យើង គឺជាការដកដង្ហើមខាងវិញ្ញាណរបស់យើង ជាអ្វីដែលធ្វើឱ្យយើងអាចធន់នៅបាន ។

II. **"ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្ដីស្លាប់ទេ ឯគំនិតខាងវិញ្ញាណ នោះទើបជាជីវិត និងសេចក្ដីសុខសាន្តវិញ" ។ យើងគួរស្ដាប់បង្គាប់ និងធ្វើអ្វីតាមអារម្មណ៍នៃជីវិត និងសេចក្ដីសុខសាន្តដែលនៅក្នុងយើង តែយើងក៏គួរបញ្ឈប់រាល់ទង្វើណាដែល អារម្មណ៍នេះមិនបានបង្គាប់បញ្ជាផងដែរ ។ ដោយការរស់នៅយ៉ាងដូច្នេះ យើងនឹង ក្លាយទៅជាមនុស្សដែលដើរយោងតាមវិញ្ញាណ** ដែលជាលទ្ធផល យើងត្រឡប់ជារស់នៅស្រស់ស្រាយ និងពោរពេញទៅដោយពន្លឺនៅផ្នែកខាងក្នុង ។

A. ការដាក់គំនិតក្នុងវិញ្ញាណ គឺជាការរួមសហការជាមួយនឹងព្រះអម្ចាស់ ដែលលទ្ធផលគឺជា ជីវិត និងសេចក្ដីសុខសាន្ត ។ ហេតុនេះហើយទើបអស់អ្នកណា ដែលស្គាល់ព្រះអម្ចាស់ ត្រូវអធិដ្ឋានយ៉ាងដូច្នេះថា "ឱ ព្រះអម្ចាស់អើយ! សូមមេត្តាដល់ទូលបង្គំផង ទូលបង្គំ សូមឱ្យទ្រង់គ្រប់គ្រងគំនិតរបស់ទូលបង្គំ ។

B. ប្រសិនបើយើងដាក់គំនិតក្នុងវិញ្ញាណ ហើយរស់នៅ និងធ្វើសកម្មភាពយោងតាមវិញ្ញាណ នោះយើងគឺជាមនុស្សដែលនៅក្នុងវិញ្ញាណ ហើយយើងនឹងមានជ័យជម្នះជានិច្ច ។

III. **ឥឡូវយើងរៀនវិលមកឯវិញ្ញាណវិញ/រៀនទទួលព្រះគ្រិស្ដមកជាជីវិត / រៀនឱ្យទ្រង់ផ្គត់ផ្គង់យើង បញ្ឈប់ខ្លួនឯង / ជួយយើងផុតពីការព្យាយាមប្រឹងប្រែង / ហាលេលូយ៉ា ជីវិតក្នុង វិញ្ញាណ / ហាលេលូយ៉ា ភាពថ្មីនៅខាងក្នុង / ពេលយើង ចេញពីគំនិតវិលមកវិញ្ញាណ / នោះ យើងអំណរភាពបរិបូរណ៍នៃទ្រង់—[បទចម្រៀងលេខ ៩០២ (ខ ៣,៤), អស់គ្លេសលេខ ១១៤១] ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

### វាក្យសព្ទទី៥១ ការប្រោសលោះផ្នែកផ្លូវច្បាប់

ដកស្រង់ពី :

រ៉ូម ៣:២៣-២៤ ពីព្រោះគ្រប់គ្នាបានធ្វើបាបហើយខ្វះមិនដល់សិរីល្អនៃព្រះ តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះ ដែលនៅក្នុងព្រះគ្រិស្តយេស៊ូ ។

មនុស្សបានធ្វើបាប ហើយធ្លាក់ចុះដោយដើរតាមសាតាំង ។ ដូច្នេះ មនុស្សបានបំពានលើសេចក្តីសុចរិតរបស់ព្រះ ។ គ្រប់ទាំងអស់ដែលព្រះមានព្រះហឫទ័យចង់ធ្វើ សម្រាប់មនុស្ស តម្រូវឱ្យព្រះជាម្ចាស់ប្រោសលោះមនុស្សមានបាប នាំត្រឡប់មកផ្នែកផ្លូវច្បាប់ ឱ្យស្របតាមសេចក្តីទាមទារដ៏សុចរិតរបស់ទ្រង់ ។

ខ្លឹមសា:

រ៉ូម ៣:២៣ ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ ។

២៤ តែដោយពឹងដល់ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ ដោយសារសេចក្តីប្រោសលោះ ដែលនៅក្នុងព្រះគ្រិស្តយេស៊ូ ។

៥:១០ ដ្បិតកាលណាយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ។

I. ការប្រោសលោះផ្នែកផ្លូវច្បាប់ គឺជានីតិវិធីនៃសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ តាមរយៈការប្រោសលោះរបស់ព្រះគ្រិស្ត សម្រាប់សេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ ដើម្បីបំពេញសេចក្តីទាមទារដ៏សុចរិតនៃច្បាប់របស់ទ្រង់ទាំងស្រុង—រ៉ូម ៣:២៤ក:

A. ការប្រោសលោះរបស់ព្រះ គឺជាប្រភេទនៃការទិញ ។ ព្រះបានទិញយើងដែលជាមនុស្សមានបាបតាមផ្លូវច្បាប់ ដោយបង់ថ្លៃព្រះលោហិតរបស់ព្រះគ្រិស្ត ជាថ្លៃនៅលើឈើឆ្កាង—រ៉ូម ៣:២៣-២៤ ។

B. គ្រិស្ទានដ៏ត្រឹមត្រូវទាំងអស់ ទទួលស្គាល់ថា ពួកគេត្រូវបានប្រោសលោះ ដោយការបង់ថ្លៃរបស់ព្រះគ្រិស្តចំពោះពួកគេ—ខ ២៤ ។

II. យើងមិនត្រូវបានសង្គ្រោះ ឬបានសង្គ្រោះជារៀងរហូត—ហេព្រើរ ១០:១២; វិវរណៈ ៥:៦ :

A. ប្រសិនបើយើងពិតជាបានទទួលយកយញ្ញបូជារបស់ព្រះអម្ចាស់សម្រាប់អំពើបាបមួយដង ហើយប្រសិនបើយើងពិតជាបានជឿទុកចិត្តលើគុណសម្បត្តិនៃឈើឆ្កាងរបស់ទ្រង់មួយដង នោះឈើឆ្កាងរបស់ទ្រង់នឹងនិយាយសម្រាប់យើងជារៀងរហូត—១ពេត្រុស ២:២៤ក ។

B. ក្នុងពេលអនាគត នៅពេលយើងមើលឃើញឈើឆ្កាងនៅឋានសួគ៌ នោះវានឹងមិនចាស់ទៅតាមសម័យកាលឡើយ ។ ដោយហេតុនេះ សេចក្ដីសង្គ្រោះដែលយើងបានទទួលនឹងមិនក្លាយជារូបសំណាកតាមពេលវេលានោះទេ—ហេព្រើរ ១០:១៩-២០; វិវរណៈ ៥:៦ ។

C. នៅពេលអស់កល្បជានិច្ច យើងនឹងមើលឃើញព្រះដោយការលាតត្រដាងសិរីល្អនៃឈើឆ្កាងចំពោះយើងបន្តិចម្ដងៗ ។ ឱព្រះអម្ចាស់អើយ សូមបង្រៀនយើងរាល់គ្នា អំពីភាពស្រស់ថ្មីដ៏អស់កល្បនៃឈើឆ្កាង!—កាឡាទី ៦:១៤ ។

III. "ទ្រង់បានប្រោះលោះខ្ញុំ ទិញខ្ញុំដោយព្រះលោហិត ទោះយើងជាមនុស្សមានបាប បើជឿក្នុងទ្រង់ពិត នេះជាការសន្យាដែលយើងអាចជឿទុកចិត្ត នឹងបានព្រះគុណ អត់ទោសពីព្រះដ៏វិសិដ្ឋ"—(បទចម្រៀងខ្មែរលេខ ៣៤,បទអង់គ្លេសលេខ ៣៩) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

## វាក្យសព្ទទី៥២ សេចក្តីសង្គ្រោះផ្នែកជីវិត

**ដកស្រង់ពី :**

រ៉ូម ៥:១០ ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ ។

ដើម្បីបានជាសរីរាង្គ មានន័យថា ត្រូវមានជីវិត ។ សេចក្តីសង្គ្រោះផ្នែកជីវិត គឺជាការបំពេញសម្រេចសេចក្តីសង្គ្រោះរបស់ព្រះ ដើម្បីឱ្យពួកអ្នកជឿបានផ្លាស់ប្រែ និងចម្រើនធំពេញវ័យនៅក្នុងជីវិតរបស់ព្រះ ។ នៅពេលយើងអំពាវនាវដល់ទ្រង់ យើងទទួលអំណារជីវិតនៃការជួយសង្គ្រោះ ។

**ខ្លឹមសារ :**

រ៉ូម ៥:១០ ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ ។

១០:១៣ ហើយគ្រប់គ្នា គឺអស់អ្នកណា ដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ។

I. **សេចក្តីសង្គ្រោះផ្នែកជីវិត គឺជាការបំពេញសម្រេចសេចក្តីសង្គ្រោះរបស់ព្រះ ដើម្បីឱ្យពួកអ្នកជឿបានផ្លាស់ប្រែ និងចម្រើនធំពេញវ័យនៅក្នុងជីវិតរបស់ព្រះ—រ៉ូម ៥:១០:**
   A. យើងត្រូវការជីវិតបន្ថែមទៀត ។ យើងត្រូវការជីវិតយ៉ាងបរិបូរ ។ យើងត្រូវតែបានសង្គ្រោះតាមរបៀបដ៏សម្បូរបែបនេះ—យ៉ូហាន ១០:១០ខ ។

B. ការសង្គ្រោះផ្នែកជីវិតរបស់ព្រះ បានបំពេញសម្រេចតាមរយៈជីវិតរបស់ព្រះគ្រិស្ត រួមមាន ការកើតជាថ្មី ការញែកចេញជាបរិសុទ្ធ ការកែជាថ្មី ការផ្លាស់ប្រែ ការថតចម្លង ការទទួលសិរីល្អ ដែលជាគោលបំណងនៃសេចក្តីសង្គ្រោះរបស់ព្រះ—រ៉ូម ៥:១០; ២កូរិនថូស ៣:១៨; រ៉ូម ៨:២៩-៣០ ។

**II. យើងត្រូវតែបានសង្គ្រោះពីទុក្ខវេទនា និងបញ្ហាបរិស្ថានគ្រប់បែបយ៉ាង—៥:៣; ៨:៣៥-៣៩ :**

A. យើងត្រូវការមានលុយដើម្បីមានជីវិតរស់នៅ ប៉ុន្តែលុយត្រឡប់ជាបញ្ហាដល់យើង ។ អ្វីក៏ដោយដែលអ្នកមាន គឺជាបញ្ហា ។ បញ្ហាកើតមានដល់យើងពីគ្រប់ទិសទី ដូច្នេះហើយ ទើបយើងត្រូវការសេចក្តីសង្គ្រោះរបស់ព្រះ—៥:៣; ៨:៣៥-៣៩។

B. នៅពេលដែលយើងអំពាវនាវដល់ទ្រង់ យើងទទួលអំណរនូវជីវិតនៃការជួយសង្គ្រោះ ។ សូមអោយព្រះអម្ចាស់មានព្រះហឫទ័យមេត្តាដល់យើង ប្រយោជន៍ឱ្យយើងអាចទទួលអំណរនូវជីវិតនៃការជួយសង្គ្រោះរបស់ទ្រង់ ដល់កម្រិតពេញលេញបំផុតពីមួយថ្ងៃទៅមួយថ្ងៃ—១០:១៣ ។

**III. "ព្រោះព្រះបិតាយើងមានជីវិត ជាកូនព្រះបិតាពិត មានចំណែកក្នុងនិស្ស័យជីវិត ទទួលអំណរដ៏ពិត ។ ទ្រង់បានប្រទានវិញ្ញាណព្រះអង្គ បោះត្រាក្នុងវិញ្ញាណខ្ញុំឲ្យកើតជាថ្មីហៅព្រះនាមទ្រង់ អ័បាព្រះវរបិតា"—(បទចម្រៀងខ្មែរលេខ២៥,បទអង់គ្លេសលេខ៣០) ។**

## ភាគ៦ សេចក្តីសង្គ្រោះដំពេញលេញរបស់ព្រះ

## វាក្យសព្ទទី ៥៣ ព្រះត្រីឯកដែលជាជីវិតជ្រួលជ្រាបមនុស្សដែលមានបីផ្នែក

**ដកស្រង់ពី :**

១ថែស្សាឡូនីច ៥:២៣ សូមឱ្យព្រះនៃសេចក្តីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់ ហើយឱ្យទាំងវិញ្ញាណនិងព្រលឹង ហើយរូបកាយទាំងមូលបានបម្រុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក ។

ព្រះត្រីឯក គឺព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណ ដែលជាជីវិតជ្រួតជ្រាបមនុស្សដែលមានបីផ្នែក ។ ទ្រង់ចែកចាយអង្គទ្រង់ផ្ទាល់ចូលទៅក្នុងវិញ្ញាណរបស់យើង ហើយបន្ទាប់មកទ្រង់ពង្រីកចេញពីគំនិត ហើយចុងក្រោយពង្រីកដល់រូបកាយដែលតែងតែពុករលួយរបស់យើង ។

**ខ្លឹមសារ :**

រ៉ូម ៨:២ ដ្បិតច្បាប់របស់ព្រះវិញ្ញាណនៃជីវិត ដែលនៅក្នុងព្រះគ្រិស្តយេស៊ូ នោះបានប្រោសឱ្យខ្ញុំរួចពីច្បាប់របស់អំពើបាប និងសេចក្តីស្លាប់ហើយ ។

៨:១០ ហើយបើសិនជាព្រះគ្រិស្តសណ្ឋិតក្នុងអ្នករាល់គ្នា នោះរូបសាច់បានស្លាប់ដោយព្រោះអំពើបាបមែន តែវិញ្ញាណមានជីវិតវិញ ដោយព្រោះសេចក្តីសុចរិត ។

៨:៦ គំនិតខាងវិញ្ញាណ នោះទើបជាជីវិត និងសេចក្តីសុខសាន្តវិញ ។

៨:១១ មួយទៀត បើព្រះវិញ្ញាណនៃព្រះអង្គ ដែលបានប្រោសឱ្យព្រះយេស៊ូរស់ពីស្លាប់ឡើងវិញ ទ្រង់សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា នោះព្រះអង្គនោះឯង ដែលបានប្រោសឱ្យព្រះគ្រិស្តរស់ពីស្លាប់ឡើង ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នាដែលទៀងតែស្លាប់ ឱ្យមានជីវិតឡើងដែរ ដោយសារព្រះវិញ្ញាណទ្រង់ ដែលសណ្ឋិតនៅក្នុងខ្លួនអ្នករាល់គ្នា ។

**I. ម៉ាថាយ ២៨:១៩ និយាយពី "ជ្រមុជទឹកឱ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ..." ។ ទោះបីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ ជាបីក៏ដោយ**

**ក៏ប៉ុន្តែមានព្រះនាមតែមួយ ។ ព្រះនាមមួយសម្រាប់បី ប្រាប់យើងថា ព្រះគឺជាព្រះត្រីឯក ។ យើងមានព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ គឺជាជីវិតសម្រាប់យើង :**

A. ព្រះគឺជាត្រីឯក ទោះបីជាព្រះមានតែមួយអង្គគត់ តែមានភាពបី គឺព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ—ខ៩ ។

B. ជីវិតដែលបានចែកចាយចូលទៅក្នុងបីផ្នែករបស់មនុស្ស នោះគឺជាជីវិតរបស់ព្រះត្រីឯក—យ៉ូហាន ១:៤, ៣:៣៦, ៦:៦៣ ។

II. **មនុស្សមានបីផ្នែក គឺវិញ្ញាណ ព្រលឹង និងរូបកាយ ។ ១ថែស្សាឡូនីច ៥:២៣ និយាយថា "សូមឱ្យព្រះនៃសេចក្តីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់" ។**

III. **ជីវិតរបស់ព្រះត្រីឯក គឺត្រូវបានចែកចាយចូលទៅក្នុងមនុស្សដែលមានបីផ្នែក—រ៉ូម.៨: ២,១០, ៦, ១១ :**

A. រ៉ូម ៨:២ និយាយពីជីវិតរបស់ព្រះត្រីឯក ។

B. ខ១០ បើកសម្តែងថា ជីវិតនេះត្រូវបានចែកចាយចូលក្នុងវិញ្ញាណរបស់យើង ហើយធ្វើឱ្យវិញ្ញាណរបស់យើងក្លាយជាជីវិត ។

C. លើសពីនេះ យោងតាម ខ៦ ជីវិតនេះអាចត្រូវបានចែកចាយចូលទៅក្នុងគំនិតរបស់យើង ហើយធ្វើឱ្យគំនិតរបស់យើងក្លាយជាជីវិតផងដែរ ។

D. ជាចុងក្រោយ ខ១១ បង្ហាញថា សូម្បីតែជីវិតរបស់ព្រះក៏អាចចែករំលែកចូលទៅរូបកាយដែលតែងតែពុករលួយផងដែរ ។

IV. **"ឱសែនជ្រាលជ្រៅ ស្មោះត្រង់បំផុត ព្រះនៅក្នុងជាជីវិត រួមជាតែមួយទ្រង់គង់ក្នុងចិត្ត រួមបញ្ចូលនៅក្នុងវិញ្ញាណ សរសើរតម្កើង ហាលេលូយ៉ា! ព្រះជាជីវិតយើងរាល់គ្នា"—( បទចម្រៀងខ្មែរលេខ ៤៤៣,បទអង់គ្លេសលេខ ៦០២) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ
## វាក្យសព្ទទី៥៩ ការកើតជាថ្មី

**ដកស្រង់ពី :**

យ៉ូហាន ៣:៦ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ ។

ការកើតជាថ្មី មានន័យថា ការបានកើតចេញពីព្រះ នោះគឺ ការទទួលបានជីវិតរបស់ព្រះ បន្ថែមលើជីវិតរបស់មនុស្សយើង ។ យើងបានកើតពីព្រះ ហើយឥឡូវយើង គឺជាកូនរបស់ព្រះ ដោយការជឿក្នុងទ្រង់ ។

**ខ្លឹមសារ :**

យ៉ូហាន ៣:៦ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ ។

១:១២ខ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ ។

I. **ការកើតជាថ្មី មានន័យថា ការបានកើតចេញពីព្រះ នោះគឺ ទទួលបានជីវិតរបស់ព្រះ បន្ថែមលើជីវិតរបស់មនុស្សយើង—យ៉ូហាន ៣:៣, ១៦ ។**

II. **ការកើតជាថ្មីការ គឺថា យើងទទួលបានជីវិតរបស់ព្រះពីព្រះវិញ្ញាណរបស់ព្រះ ។ ព្រះវិញ្ញាណរបស់ព្រះយាងចូលមកក្នុងយើង ហើយប្រទានជីវិតទ្រង់មកឱ្យយើង—ខ ៦ខ :**

A. យ៉ូហាន ៣:៦ និយាយថា "ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ" ។ នៅក្នុងខនេះ ព្រះវិញ្ញាណរបស់ព្រះ សំដៅលើព្រះវិញ្ញាណរបស់ព្រះ រីឯវិញ្ញាណ សំដៅលើវិញ្ញាណរបស់យើង ។ ព្រះវិញ្ញាណព្រះបង្កើតវិញ្ញាណមនុស្ស ហើយ វិញ្ញាណមនុស្សកើតពីព្រះវិញ្ញាណព្រះ ។

B. ព្រះគឺជាព្រះវិញ្ញាណ ហើយយើងគឺមានវិញ្ញាណ ។ វិញ្ញាណរបស់យើងត្រូវបាន កើតជាថ្មីដោយព្រះវិញ្ញាណរបស់ព្រះ ហើយព្រះត្រូវការឱ្យយើងថ្វាយបង្គំទ្រង់ដោយវិញ្ញាណ ។ ពេលដែលព្រះវិញ្ញាណបង្កើតវិញ្ញាណរបស់យើង វិញ្ញាណរបស់យើងអាចថ្វាយបង្គំទ្រង់ ដែលជាព្រះវិញ្ញាណ—៤:២៤ ។

C. យើងត្រូវតែកើតពីព្រះម្តងទៀត ប្រយោជន៍ឱ្យយើងអាចទទួលបានជីវិតខាងឯវិញ្ញាណរបស់ព្រះ—៣:៣, ៥, ១៦ ។

III. **ការកើតជាថ្មីធ្វើឱ្យយើងក្លាយជាកូនព្រះ ។ "គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ"—១:១២ខ :**

A. ព្រះអម្ចាស់យេស៊ូបានជាប់ឆ្កាង និងបានបំពេញសម្រេចការប្រោសលោះ ហើយព្រះអង្គកំពុងរង់ចាំឱ្យយើងជឿលើទ្រង់ ។

B. ប្រសិនបើយើងជឿក្នុងទ្រង់ដោយការហៅព្រះនាមរបស់ទ្រង់ នោះយើងបានកើតពីព្រះ ហើយឥឡូវនេះយើងគឺជាកូនរបស់ព្រះ ដោយសារតែបានទទួលព្រះអម្ចាស់យេស៊ូតាមរយៈការជឿក្នុងទ្រង់ ។

IV. **ខ្ញុំដឹងជាក់ច្បាស់ហើយព្រះទ្រង់ប្រោសខ្ញុំ / ឱសប្បាយណាស់ណានៅឋានឧត្តម / ទ្រង់លោះខ្ញុំមកធ្វើជាកូនព្រះអង្គ / ក៏លាងឱ្យស្អាតដោយព្រះលោហិតទ្រង់ / *នេះជារឿងខ្ញុំថ្លែងនេះបទខ្ញុំច្រៀង / នឹងលើកព្រះយេស៊ូដ៏ជាឧត្តម / នេះជារឿងខ្ញុំថ្លែងនេះបទខ្ញុំច្រៀង / សរសើរព្រះយេស៊ូដែលសង្គ្រោះខ្ញុំ* (បទចម្រៀងជាភាសាខ្មែរលេខ ២៦៥, អង់គ្លេសលេខ ៣០៨) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

## វាក្យសព្ទទី៥៥ ការញែកចេញជាបរិសុទ្ធ

**ដកស្រង់ពី:**

២ពេត្រុស ១:៤ ដែលដោយសារសេចក្តីទាំងនោះ ទ្រង់បានប្រទានសេចក្តីសន្យាដ៏ធំបំផុត ហើយវិសេសផង មកយើងរាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ។

ភាពបរិសុទ្ធ គឺជានិស្ស័យរបស់ព្រះ ។ ព្រះជាម្ចាស់ទ្រង់ផ្ទាល់មិនត្រឹមតែជាព្រះដ៏វិសុទ្ធប៉ុណ្ណោះទេ តែទ្រង់ក៏ចង់ធ្វើឱ្យយើងបរិសុទ្ធផងដែរ ។ នៅពេលដែលយើងអំពាវនាវដល់ព្រះអម្ចាស់យេស៊ូគ្រិស្ត នោះយើងកំពុងតែមានចំណែកនៅក្នុងជីវិត និងនិស្ស័យព្រះរបស់ទ្រង់ ។ ដូច្នេះ យើងត្រូវបានញែកចេញជាបរិសុទ្ធ ។

ខ្លឹមសារ:

២ពេត្រុស ១:៤ ដែលដោយសារសេចក្តីទាំងនោះ ទ្រង់បានប្រទានសេចក្តីសន្យាដ៏ធំបំផុត ហើយវិសេសផង មកយើងរាល់គ្នា ដើម្បីឱ្យអ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ ។

១កូរិនថូស ៦:១១ក ក៏បានញែកជាបរិសុទ្ធ.....ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា ។

I. ព្រះបានញែកយើងចេញជាបរិសុទ្ធ ដើម្បីឱ្យយើងមាននិស្ស័យបរិសុទ្ធរបស់ទ្រង់ ។ នេះគឺជាការបង្កើតនៃសេចក្តីសង្គ្រោះផ្នែកជីវិតរបស់ព្រះ—១កូរិនថូស ៦:១១ក :
   A. នៅក្នុងសកលលោក ព្រះគឺបរិសុទ្ធ ។ ពេលណាមនុស្សប៉ះពាល់ព្រះ ពួកគេប៉ះពាល់ភាពបរិសុទ្ធ—១ពេត្រុស ១:១៦ ។
   B. ព្រះជាម្ចាស់ទ្រង់ផ្ទាល់មិនត្រឹមតែជាព្រះដ៏វិសុទ្ធប៉ុណ្ណោះទេ តែទ្រង់ក៏ចង់ធ្វើឱ្យយើងទៅជាបរិសុទ្ធផងដែរ ។ ការដែលព្រះជាម្ចាស់ទ្រង់ញែកយើងចេញជាបរិសុទ្ធ គឺជាប្រការសំខាន់ និងពិសេសមួយនៅក្នុងសេចក្តីសង្គ្រោះផ្នែកជីវិតរបស់ព្រះ ។

II. ព្រះចែករំលែកនិស្ស័យរបស់ទ្រង់ចូលមកក្នុងយើង ដើម្បីឱ្យយើងអាចបានចំណែកនៃនិស្ស័យព្រះរបស់ទ្រង់—២ពេត្រុស ១:៤:

A. ភាពបរិសុទ្ធ គឺជានិស្ស័យរបស់ព្រះ រីឯការបានទទួលចំណែកនៃភាពបរិសុទ្ធរបស់ព្រះ គឺជាការទទួលចំណែកនៃនិស្ស័យរបស់ទ្រង់ ។ សព្វថ្ងៃនេះ យើងមិនត្រូវការបទបញ្ញាផ្នែកខាងក្រៅនោះឡើយ ។ យើងត្រូវការតែនិស្ស័យបរិសុទ្ធរបស់ព្រះ ដែលអាចធ្វើឱ្យយើងបរិសុទ្ធប៉ុណ្ណោះ ។

B. យើងចាំបាច់ត្រូវតែបានជ្រាបចូល និងជ្រួតជ្រាបទៅដោយនិស្ស័យដ៏បរិសុទ្ធរបស់ទ្រង់ ។ ការនេះធ្វើឱ្យខ្លួនយើងបរិសុទ្ធដូចជាព្រះជាម្ចាស់ទ្រង់ផ្ទាល់នៅក្នុងនិស្ស័យ និងគុណលក្ខណៈរបស់ទ្រង់ ។

C. ១កូរិនថូស ៦:១១ ប្រាប់ថា "ក៏បានញែកជាបរិសុទ្ធ.....ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា" ។ នៅពេលដែលយើងអំពាវនាវដល់ព្រះអម្ចាស់យេស៊ូ យើងគឺនៅក្នុងព្រះនាមរបស់ទ្រង់ នៅក្នុងបុគ្គលដ៏រស់របស់ព្រះគ្រិស្ត នោះយើងមានការរួមគ្នាមួយជាមួយទ្រង់ ដោយរួមមានចំណែកនៅក្នុងជីវិត និងនិស្ស័យព្រះរបស់ទ្រង់ ។ ដូច្នេះហើយទើបយើងត្រូវបានញែកចេញជាបរិសុទ្ធ ។

III. "ព្រះគ្រិស្តជាជី_វិត ខ្ញុំ ទ្រង់រស់នៅខាងក្នុង នាំភាពពោរពេញនៃទ្រង់ បំពេញខ្ញុំ ឥតឈប់ ដោយនិស្ស័យព្រះវិ_សុទ្ធ ញែកខ្ញុំជាបរិ_សុទ្ធ ចេ_ស្តារស់ឡើងនៃព្រះ ខ្ញុំបានជ័យ_ជ_ម្នះ"—(បទចម្រៀងខ្មែរលេខ៣៨១,បទអង់គ្លេសលេខ៨៤១) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

## វាក្យសព្ទទី ៥៦ ការកែជាថ្មី

**ដកស្រង់ពី :**

រ៉ូម ១២:២ កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ។

ការកែជាថ្មី គឺជាគំនិតនៃការកែជាថ្មី ។ វិធីនៃការកែជាថ្មី អាស្រ័យលើ សេចក្តីអធិដ្ឋាន និងការអានព្រះគម្ពីរ ។ ពេលដែលព្រះវិញ្ញាណបរិសុទ្ធមកបំភ្លឺយើង ខណៈពេលដែលយើងអធិដ្ឋាន និងអានព្រះគម្ពីរពីមួយថ្ងៃទៅមួយថ្ងៃ នោះគំនិតនៅខាងក្នុងយើងនឹងបានផ្លាស់ប្តូរពីចាស់ទៅថ្មី ។

**ខ្លឹមសារ :**

រ៉ូម ១២:២ កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ។

ទីតុស ៣:៥ នោះទ្រង់បានជួយសង្គ្រោះយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសម្អាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ ។

I. **រ៉ូម ១២:២ និយាយថា " កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង" ការកែជាថ្មី បានបង្រៀនដោយព្រះគម្ពីរ គឺជាគំនិតបានកែជាថ្មី ទាំងអស់នេះ គឺទាក់ទងទៅនឹងគំនិត :**
   A. គំនិត គឺជាចិត្តគំនិតរបស់យើង ជាទស្សនវិជ្ជា ជាគំនិតបែបសាសនា ការមើលឃើញរបស់យើងចំពោះមនុស្ស និងរបស់ផ្សេងៗ ។ល។—១ពេត្រុស ១:១៦ ។

B. យើងមិនគួរត្រាប់តាមសម័យនេះឡើយ ។ ការនេះមានន័យថា យើងមិនគួរត្រាប់តាមសម័យនេះឡើយ ផ្ទុយទៅវិញ យើងគួរតែបានផ្លាស់ប្រែ ដោយគំនិតបានកែជាថ្មី—ខ២ក ។

C. យើងត្រូវការបានកែជាថ្មីនៅក្នុងគំនិតរបស់យើងជាចម្បង ដោយឱ្យគំនិតនៅក្នុងយើងបានដូចជាព្រះគ្រិស្តយេស៊ូ នោះគឺស្មើនិងការយកគំនិតរបស់ព្រះគ្រិស្តយេស៊ូធ្វើជាគំនិតរបស់យើង—ភីលីព ២:៥ ។

**II. ទីតុស ៣:៥ និយាយថា គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសម្អាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ :**

A. ដើម្បីឱ្យយើងបានកែជាថ្មីនៅក្នុងគំនិតរបស់យើង គឺដើម្បីឱ្យយើងលុបចោលអស់ទាំងទស្សនៈចាស់ៗ ដែលទាក់ទងនឹងរឿងរ៉ាវនៃជីវិតមនុស្ស និងធ្វើឱ្យថ្មីម្តងទៀតដោយការបង្រៀនរបស់ព្រះគម្ពីរបរិសុទ្ធ ហើយនិងការបំភ្លឺដោយព្រះវិញ្ញាណបរិសុទ្ធ ។

B. វិធីនៃការកែជាថ្មី អាស្រ័យលើ សេចក្តីអធិដ្ឋាន និងការអានព្រះគម្ពីរ ។ នៅពេលដែលអ្នកអានព្រះគម្ពីរ ហើយត្រឡប់ជាមានភាពជិតស្និទ្ធជាងមុន នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំភ្លឺអ្នក ហើយនឹងនាំផ្លូវអ្នក ។ ពេលដែលព្រះវិញ្ញាណបរិសុទ្ធមកបំភ្លឺអ្នកខណៈពេលដែលអ្នក អធិដ្ឋាន និងអានព្រះគម្ពីរពីមួយថ្ងៃទៅមួយថ្ងៃនោះគំនិតនៅខាងក្នុងអ្នកនឹងបានផ្លាស់ប្តូរពីចាស់ទៅថ្មី—ទំនុកតម្កើង ១១៩:១៣០, ទីតុស ៣:៥ ។

**III. វិញ្ញាណខ្ញុំពង្រីកពង្រឹង សម្រេចគ្រប់ផ្នែកក្នុងព្រលឹង គ្រប់ផ្នែកខាងក្នុងព្រះអង្គស្អាងថ្មី ស្តាប់បន្ទូលជ្រួតជ្រាបក្នុងរាងកាយ ។ សូមព្រះអង្គប្រោសព្រលឹងគ្រប់ផ្នែក ប្រែដូចរូបអង្គទ្រង់សព្វគ្រប់ ដោយព្រះវិញ្ញាណ ជ្រួតជ្រាប់ក្នុងខ្ញុំ សម្បូរដូចរូបភាព ព្រះអង្គ—(បទចម្រៀងលេខ៥៤៦ , អង់គ្លេសលេខ ៧៥០) ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្តីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

## វាក្យសព្ទទី ៥៧ ការផ្លាស់ប្រែ

**ដកស្រង់ពី:**

២កូរិនថូស ៣:១៨ ហើយយើងរាល់គ្នាទាំងអស់...... យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។

ការផ្លាស់ប្រែ គឺមិនមែនជាការផ្លាស់ប្តូរ ឬការកែតម្រូវផ្នែកខាងក្រៅនោះទេ តែជាមុខងារមេតាប៉ូលីសនៃជីវិតរបស់ព្រះនៅក្នុងពួកអ្នកជឿ ។ យើងកំពុងត្រូវបានផ្លាស់ប្រែពីព្រះវិញ្ញាណរបស់ព្រះអម្ចាស់ ។ យើងត្រូវការបើកគំនិត ចិត្ត និងវិញ្ញាណរបស់យើង ។

**ខ្លឹមសារ:**

២កូរិនថូស ៣:១៨ ហើយយើងរាល់គ្នាទាំងអស់......យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។

រ៉ូម ១២:២ កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ។

I. **ការផ្លាស់ប្រែ មិនមែនជាការផ្លាស់ប្តូរ ឬការកែតម្រូវផ្នែកខាងក្រៅនោះទេ តែជាមុខងារមេតាប៉ូលីសនៃជីវិតរបស់ព្រះនៅក្នុងពួកអ្នកជឿ—២កូរិនថូស ៣:១៨; រ៉ូម ១២:២ក :**
   A. ការនេះមិនមែនជាការបណ្តុះបណ្តាលខាងសីលធម៌ ដោយការពិនិត្យមើលខ្លួនឯង និងជាវិធីកែលម្អមួយ ដូចដែលលោកខុងជឺបានបង្រៀននៅប្រទេសចិននោះឡើយ ដ្បិតនោះគឺជាការបណ្តុះបណ្តាលខាងសីលធម៌ផ្ទាល់ខ្លួនរបស់មនុស្សតែប៉ុណ្ណោះ ។
   B. ប្រសិនបើពួកអ្នកជឿមានឆន្ទៈចង់ចម្រើនធំនៅក្នុងជីវិតព្រះ នោះអង្គធាតុនៃជីវិតព្រះនឹងកើនឡើងនៅក្នុងពួកគេ ហើយនិងនាំមកនូវការផ្លាស់ប្តូរមេតាប៉ូលីស ។ ដូច្នេះ

អត្តចរិតខាងក្នុងរបស់ពួកគេ នឹងត្រូវបានផ្លាស់ប្រែ ហើយរូបភាពខាងក្រៅរបស់ពួកគេក៏នឹងត្រូវបានផ្លាស់ប្រែឱ្យដូចជារូបភាពរបស់ព្រះអម្ចាស់ដែរ—២កូរិនថូស ៣:១៨ ។

II. **២កូរិនថូស ៣:១៨ ចែងថា "ហើយយើងរាល់គ្នាទាំងអស់.....យើងកំពុងតែផ្លាស់ប្រែទៅឱ្យដូចជារូបឆ្លុះនោះឯង...... គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ" ព្រះវិញ្ញាណនេះផ្ទុកនូវការផ្គត់ផ្គង់ដ៏បរិបូរណ៍ ដើម្បីក្លាយជាអង្គធាតុថ្មីរបស់យើង—ភីលីព ១:១៩:**

III. **យើងត្រូវការបើកគំនិត ចិត្ត វិញ្ញាណ ព្រមទាំងខ្លួនរបស់យើងទាំងមូល ដើម្បីផ្តល់ឱកាសឱ្យទ្រង់ហូរនៅក្នុងយើង និងសម្រេចការងារផ្លាស់ប្រែរបស់ទ្រង់ ។**

IV. ព្រះទ័យព្រះអង្គបានផ្តល់ឱ្យខ្ញុំ ដូចរូបភាពនៃព្រះរាជបុត្រា /ដូច្នេះការផ្លាស់ប្រែនៃវិញ្ញាណឱ្យសម្រេចក្នុងខ្ញុំគ្រប់យ៉ាង / សូមព្រះអង្គប្រោសព្រលឹងគ្រប់ផ្នែក / ប្រែដូចរូបអង្គទ្រង់សព្វគ្រប់ /ដោយព្រះវិញ្ញាណជ្រួតជ្រាបក្នុងខ្ញុំ / សម្បូរដូចរូបភាពព្រះអង្គ (បទចម្រៀងជាភាសាខ្មែរលេខ ៥៤៦ អង់គ្លេសលេខ ៧៥០) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្ដីសង្គ្រោះដ៏ពេញលេញរបស់ព្រះ

## វាក្យសព្ទទី ៥៨ ការថតចម្លង

**ដកស្រង់ពី :**

រ៉ូម ៨:២៩ "នោះទ្រង់ក៏តម្រូវទុកជាមុន ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឱ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន" ។

ការថតចម្លងគឺជាលទ្ធផលចុងក្រោយបង្អស់នៃការផ្លាស់ប្រែ ។ វាមានរួមបញ្ចូលទាំងការផ្លាស់ប្ដូរអង្គធាតុ និងនិស្ស័យ ហើយនឹងការផ្លាស់ប្ដូរទម្រង់ផ្នែកខាងក្រៅរបស់យើង ។ កូនជាច្រើននឹងត្រូវបាននាំចូលទៅក្នុងសិរីល្អ ។ " នេះជាគោលបំណងដ៏អស់កល្បរបស់ព្រះ ដែលយើងនឹងត្រលប់ទៅដូចរូបអង្គនៃព្រះរាជបុត្រា នោះយើងនឹងត្រូវបានថតចម្លងទាំងស្រុង" ។

**ខ្លឹមសារ :**

រ៉ូម ៨:២៩ នោះទ្រង់ក៏តម្រូវទុកជាមុន ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ។

២៨ តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្ដីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ ។

១យ៉ូហាន ៣:២ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ។

I. **រ៉ូម ៨:២៩ បានប្រាប់យើងថា "នោះទ្រង់ក៏តម្រូវទុកជាមុន ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់" :**
   A. ព្រះគ្រិស្តដែលជាព្រះរាជបុត្រារបស់ព្រះ គឺជាគំរូពុម្ព ហើយព្រះជាម្ចាស់បានដាក់យើងចូលទៅក្នុងទ្រង់ ដើម្បីឱ្យយើងបានត្រលប់ទៅដូចរូបអង្គទ្រង់—១កូរិនថូស ១:៣០ ។
   B. បានត្រលប់ទៅដូចរូបអង្គនៃព្រះរាជបុត្រានៃព្រះ មានន័យថាយើងមាននិស្ស័យនិងអង្គធាតុដូចជាព្រះរាជបុត្រានៃព្រះនៅផ្នែកខាងក្នុង និងដូចជារូបអង្គទ្រង់នៅផ្នែក

ខាងក្រៅ ទាំងនេះគឺត្រូវការឱ្យយើងផ្លាស់ប្រែនៅផ្នែកខាងក្នុង និងថតចម្លងនៅផ្នែកខាងក្រៅ—រ៉ូម.៨:២៩; ២កូរិនថូស ៣:១៨ ។

II. **"តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ ។ ការថតចម្លង គឺអាចបំពេញសម្រេចបានតាមរយៈ គ្រប់មនុស្ស បញ្ហា និងគ្រប់ការទាំងអស់"—រ៉ូម ៨:២៨-២៩ :**

A. យើងត្រូវការដាក់ខ្លួនយើងចូលទៅក្នុងគំរូពុម្ពនៃរូបអង្គព្រះរាជបុត្រាព្រះ ដើម្បីឱ្យយើងបានត្រឡប់ទៅដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដោយសារ "ទ្ប"—ខ២៨ ។

B. ព្រះជាម្ចាស់បានប្រើរូបអង្គទ្រង់ផ្ទាល់ជាអង្គធាតុ ដើម្បីផ្លាស់ប្រែយើង ហើយទ្រង់ក៏ប្រើគ្រប់ការទាំងអស់ជាឧបករណ៍ដើម្បីឱ្យយើងបានថតចម្លង ដូច្នេះហើយតាមរយៈការងារផ្នែកខាងក្នុង និងផ្នែកខាងក្រៅ យើងត្រឡប់ទៅដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់—៣:៨; យ៉ូហាន ៣:១៦ ។

C. ព្រះជាម្ចាស់បានប្រទានអង្គធាតុរបស់ទ្រង់នៅផ្នែកខាងក្នុង ដើម្បីក្លាយជាធាតុដើមរបស់យើង ហើយទ្រង់ក៏ប្រើគ្រប់រឿងរ៉ាវ និងគ្រប់ការទាំងអស់ ដើម្បីជួយយើងឱ្យបានត្រឡប់ទៅដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ។ តើយើងគួរតែភ័យខ្លាចអ្វី ? គ្រប់ការទាំងអស់គឺសម្រាប់យើង និងជាសេចក្តីល្អដល់យើង ។

III. **"យើងនឹងថតចម្លង ផ្គត់ផ្គង់ក្នុងវិញ្ញាណផង ទទួលជីវិតចេស្តា ទ្រង់ជ្រាបរាល់តម្រូវការ ហាលេលូយ៉ាសេចក្តីសង្គ្រោះ ហាលេលូយ៉ារង្វាន់ ហាលេលូយ៉ាបរិបូរគ្រប់គ្រាន់ សម្រាប់ជីវិតយើង" បទចម្រៀងលេខ ៩៩៥ ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៦ សេចក្ដីសង្គ្រោះដ៏ពេញលេញរបស់ព្រះ
## វាក្យសព្ទទី ៥៩ ការទទួលសិរីល្អ

**ដកស្រង់ពី :**

រ៉ូម ៨:៣០ខ ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានតម្កើងឡើងដែរ ។

ការទទួលសិរីល្អ គឺថា ពួកអ្នកជឿដែលបានពេញវ័យចាស់ទុំ នឹងសម្ដែងចេញភាពពេញវ័យនៅក្នុងជីវិតរបស់ពួកគេពីខាងក្នុងពួកគេ ។ ពួកអ្នកជឿនឹងមិនបានលើកតម្កើង (ទទួលសិរីល្អ) ឡើយ ទាល់តែពួកគេឈានដល់ភាពពេញវ័យចាស់ទុំនៅក្នុងជីវិត ។

ខ្លឹមសារ :

រ៉ូម ៨:៣០ខ ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានតម្កើងឡើងដែរ ។

១ពេត្រុស ២:២ នោះត្រូវឱ្យសង្វាតរកទឹកដោះសុទ្ធ ខាងឯព្រលឹងវិញ្ញាណវិញ ដូចជាទារ-កដែលទើបនឹងកើត ដើម្បីឱ្យអ្នករាល់គ្នាបានចម្រើនធំឡើង ដរាបដល់បានសង្គ្រោះ ។

I. ការទទួលសិរីល្អ គឺថា ពួកអ្នកជឿដែលបានពេញវ័យចាស់ទុំ នឹងលេចចេញភាពពេញវ័យនៅក្នុងជីវិតរបស់ពួកគេពីខាងក្នុងពួកគេ—**រ៉ូម ៨:៣០ខ :**
   A. ការបានលើកតម្កើង(ទទួលសិរីល្អ) គឺការបានដូចព្រះទាំងស្រុង ពីព្រោះសិរីល្អ គឺជាព្រះជាម្ចាស់ទ្រង់ផ្ទាល់ ។
   B. ព្រះ គឺជាព្រះនៃសិរីល្អ ។ យើងមានរូបភាពរបស់ព្រះ ហើយយើងគួរសម្ដែងចេញសិរីល្អរបស់ព្រះ—កិច្ចការ ៧:២ ។

C. សព្វថ្ងៃនេះ ប្រសិនបើបងប្អូនស្រឡាញ់ព្រះអម្ចាស់ ហើយបងប្អូនរស់ចេញសិរីល្អរបស់ព្រះអម្ចាស់ពីខាងក្នុងបងប្អូន បន្ទាប់មកនៅពេលព្រះអម្ចាស់យាងមកនោះទ្រង់នឹងដាក់បងប្អូននៅក្នុងសិរីល្អកម្រិតដ៏ខ្ពង់ខ្ពស់បំផុត ។

II. ពួកអ្នកជឿនឹងមិនបានលើកតម្កើង (ទទួលសិរីល្អ) ដែលជាការបាននាំចូលទៅក្នុងការសម្ដែងចេញពេញលេញនៃព្រះត្រីឯកឡើយ ទាល់តែពួកគេឈានដល់ភាពពេញវ័យចាស់ទុំនៅក្នុងជីវិត—១ពេត្រុស ២:២; រ៉ូម ៨:៣០ :

A. ដូចជា ផ្ការបស់ផ្កាកុលាប គឺចេញមកពីការលូតលាស់បន្តិចម្ដងៗនៃរុក្ខជាតិដើមកុលាប ។ ផ្កាកុលាប មិនចេញផ្កាទេ ទាល់តែវាបានឈានដល់ភាពពេញវ័យ ។

B. ព្រះគ្រិស្ត ដែលជាសិរីល្អនៃក្ដីសង្ឃឹម ត្រូវបានព្រោះចូលទៅក្នុងយើងជាគ្រាប់ពូជនៃសិរីល្អ ហើយគ្រាប់ពូជនេះនឹងរីកលូតលាស់ រហូតដល់ឈានដល់ដំណាក់កាលនៃការចេញផ្កា នៅពេលនោះហើយ សិរីល្អនឹងលេចចេញមក—កូល៉ុស ១:២៧ ។

**III. អាថ៌កំបាំងច្រើនសម័យ សម្ដែងដល់ /ខ្ញុំច្បាស់ ព្រះគ្រិស្ត គឺជាសភាពពិតនៃព្រះ/ ទ្រង់ប្រែសភាពជាមនុស្ស ក្លាយជាជីវិតខ្ញុំ / ទ្រង់ជាសិរីនៃក្ដីសង្ឃឹមខ្ញុំ /*សិរីសិរីព្រះគ្រិស្តជីវិតខ្ញុំ/ សិរីទ្រង់ជាក្ដីសង្ឃឹមដ៏ធំ /ទ្រង់គឺជាអាថ៌កំបាំងនៅក្នុងវិញ្ញាណខ្ញុំ/ សិរីទ្រង់ដល់ខ្ញុំប្រសើរឧត្តម* (បទចម្រៀងខ្មែរលេខ ៧៦៩ , អង់គ្លេសលេខ ៩៥៨) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៦០ ផែនការគ្រប់គ្រងរបស់ព្រះ

**ដកស្រង់ពី:**

១ធីម៉ូថេ ១:៤ ឬស្តាប់តាមរឿងព្រេង និងពង្សាវតារ ដែលមិនចេះអស់មិនចេះហើយនោះឡើយ ដែលរឿងទាំងនោះតែងបង្កើតឱ្យមាន សេចក្តីដេញដោល ជាជាងចម្រើនការនៃព្រះក្នុងសេចក្តីជំនឿ ។

ពាក្យ ផែនការគ្រប់គ្រង សំដៅលើ ការចាត់ចែងក្នុងផ្ទះ ការគ្រប់គ្រង និងការកាន់កាប់ត្រួតត្រាក្នុងផ្ទះ ។ ពិតណាស់ ព្រះវរបិតានៃយើង មានផ្ទះធំណាស់ ហើយត្រូវការ ការគ្រប់គ្រង និងការកាន់កាប់ត្រួតត្រា ដើម្បីចាត់ចែង និងចែកចាយ នូវភាពបរិបូរដ៏ប្រមាណមិនបាននៃព្រះគ្រិស្តដល់ប្រជារាស្ត្ររបស់ព្រះ ។

**ខ្លឹមសារ:**

អេភេសូរ ៣:៩ ហើយឱ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំង ដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារពើ ដោយសារព្រះយេស៊ូគ្រិស្ត ។

១ធីម៉ូថេ ១:៤ ឬស្តាប់តាមរឿងព្រេង និងពង្សាវតារ ដែលមិនចេះអស់មិនចេះហើយនោះឡើយ ដែលរឿងទាំងនោះតែងបង្កើតឱ្យមាន សេចក្តីដេញដោល ជាជាងចម្រើនការនៃព្រះក្នុងសេចក្តីជំនឿ ។

អេភេសូរ ១:១០ សម្រាប់ការកាន់កាប់ត្រួតត្រាក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ ក្នុងព្រះគ្រិស្ត ទាំងរបស់នៅឋានសួគ៌ និងរបស់នៅផែនដីផង ។

I. "ហើយឱ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំង ដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារពើ ដោយសារព្រះគ្រិស្ត—អេភេសូរ ៣:៩ :

A. ផែនការគ្រប់គ្រងរបស់ព្រះ គឺពិតជាខ្ពង់ខ្ពស់ណាស់ ។ មានជាងបីរយឃ្លា នៅក្នុងព្រះគម្ពីរ ដែលនិយាយទាក់ទងទៅនឹងផែនការគ្រប់គ្រងរបស់ព្រះ ទាំងនិយាយចំៗ និងដោយប្រយោល—ខ៩, ១:១០ ។

B. សេចក្តីអាថ៌កំបាំងនេះ បានលាក់ទុកក្នុងព្រះ ចាប់តាំងពីមនុស្សជាច្រើនជំនាន់ (តាំងពីអស់កល្បរៀងមក) និងពីពួកមនុស្សពីសម័យមុនៗ តែឥឡូវនេះត្រូវបាននាំចូលមកឯពន្លឺ បានមកដល់ពួកអ្នកជឿក្នុងសញ្ញាថ្មី—៣:៩ ។

II. **" ឬស្តាប់តាមរឿងព្រេង និងពង្សាវតារ ដែលមិនចេះអស់មិនចេះហើយនោះឡើយ ដែលរឿង ទាំងនោះតែងបង្កើតឱ្យមាន សេចក្តីដេញដោល ជាជាងចម្រើនការនៃព្រះក្នុងសេចក្តីជំនឿ។"—១ធីម៉ូថេ ១:៤ ។**

A. ពាក្យ ផែនការគ្រប់គ្រប សំដៅលើ ការចាត់ចែងក្នុងផ្ទះ ការគ្រប់គ្រង និងបែងចែកក្នុងផ្ទះ គឺជា ចាត់ចែង និងបែងចែក ទ្រព្យសម្បត្តិដ៏ស្តុកស្តមក្នុងផ្ទះ—ខ៤ ។

B. ពិតណាស់ ព្រះវរបិតានៃយើង មានផ្ទះធំណាស់ ជាមួយនិងឃ្លាំងនៃភាពបរិបូរដ៏ប្រមាណមិនបាននៃព្រះគ្រិស្ត ។ ផ្ទះដ៏ធំនេះ ត្រូវការ ការកាន់កាប់ត្រួតត្រា និងការគ្រប់គ្រង ព្រមទាំងរចនាសម្ព័ន្ធ ក៏ត្រូវការមានផែនការ ក្នុងការចាត់ចែង និងចែកចាយ នូវភាពបរិបូរដ៏ប្រមាណមិនបាននៃព្រះគ្រិស្តដល់ប្រជារាស្ត្ររបស់ព្រះ—៣:៨, យ៉ូហាន ៣:១៦ ។

III. **"សម្រាប់ការកាន់កាប់ត្រួតត្រា ក្នុងកាលដែលពេលពេញកំណត់បានមកដល់ ដើម្បីនឹងបំព្រួមគ្រប់ទាំងអស់ ក្នុងព្រះគ្រិស្ត ទាំងរបស់នៅឋានសួគ៌ និងរបស់នៅផែនដីផង"—អេភេសូរ ១:១០ ។**

IV. **ព្រះអង្គត្រាស់ហៅនៅទីនេះ / ដើម្បីផែនការអស់កល្បនៃព្រះ/នេះជាគោលដៅនៃជីវិតយើង /ព្រះត្រីឯកទ្រង់ក្លាយមកជាមនុស្ស / ដើម្បីមនុស្សផ្លាស់ប្រែក្លាយជាព្រះ / ជាប់ឆ្កាងរស់ឡើងជាព្រះវិញ្ញាណ / នៅក្នុងវិញ្ញាណជាចំណែកយើង។បន្ទរះនិមិត្តផែនការដ៏អស់កល្បរបស់ព្រះ / កំណត់ទិសដៅគ្រប់ផ្នែករបស់យើង / បំភ្លឺយើង និងវិញ្ញាណយើងភ្លឺថាំង / រឹងមាំឡើង / ចម្លងដូចរូបភាពរបស់ព្រះគ្រិស្ត / ជាស្តេចនៅក្នុងជីវិត/យេរូសាឡិមថ្មី / ហាលេលូយ៉ា—ព្រះអង្គត្រាស់ហៅនៅទីនេះ (បទចម្រៀងខ្មែរនៅទំព័រលេខ ៥៩១, អង់គ្លេសលេខ ១៣៥៩) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី៦១ ការចែកចាយរបស់ព្រះ

**ដកស្រង់ពី** :

អេភេសូរ ៣:៨ ទ្រង់បានប្រទានព្រះគុណនេះជាសម្បត្តិរបស់ព្រះគ្រិស្ដដ៏ប្រមាណមិនបានមកខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធទាំងអស់ ឱ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ ។

ការចែកចាយរបស់ព្រះ គឺជាការចែកចាយភាពបរិបូរដ៏ប្រមាណមិនបានរបស់ព្រះ ចូលទៅក្នុងវិញ្ញាណរបស់យើង ។ យើងហ្វឹកហាត់វិញ្ញាណរបស់យើងដោយការអធិដ្ឋានទៅកាន់ទ្រង់ ។ ពេលយើងសរសើរតម្កើងព្រះអង្គ ខាងយើង គឺត្រូវទទួលបានការចែកចាយរបស់ទ្រង់ ឯខាងទ្រង់ គឺត្រូវចែកចាយ ។

**ខ្លឹមសារ:**

អេភេសូរ ៣:៨ ទ្រង់បានប្រទានព្រះគុណនេះជាសម្បត្តិរបស់ព្រះគ្រិស្ដដ៏ប្រមាណមិនបានមកខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធទាំងអស់ ឱ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ ។

២ធីម៉ូថេ ១:៦ ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឱ្យដាស់តឿនអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ ។

I. **ការចែកចាយរបស់ព្រះ គឺជាការចែកចាយសភាពត្រីឯក ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ ចូលទៅក្នុងយើង ។ សភាពត្រីឯក គឺជាភាពបរិបូរដ៏ប្រមាណមិនបានរបស់ព្រះ—អេភេសូរ ៣:៨ :**

    A. នៅក្នុងអេភេសូរ ៣:៨ ចែងថា "ទ្រង់បានប្រទានព្រះគុណនេះជាសម្បត្តិរបស់ព្រះគ្រិស្ដដ៏ប្រមាណមិនបានមកខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធទាំងអស់ឱ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ ។"

B. ព្រះសព្វព្រះហឫទ័យចែកចាយភាពបរិបូរដ៏ប្រមាណមិនបានរបស់ព្រះគ្រិស្ត ទុកជាព្រះគុណចូលទៅក្នុងយើង—ខ៨ ។

II. **វិញ្ញាណរបស់យើង មិនត្រឹមតែជាសរីរាង្គនៃការទទួលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសរីរាង្គនៃការបើកចំពោះការចែកចាយរបស់ព្រះផងដែរ ។ ទ្រង់ចែកចាយអង្គទ្រង់ផ្ទាល់ចូលទៅក្នុងវិញ្ញាណរបស់យើង—២ធីម៉ូថេ ៤:២២ ។**

III. **ការចែកចាយរបស់ព្រះ គឺអាស្រ័យលើការរួមសហការរបស់យើង ឯការរួមសហការរបស់យើង គឺការហ្វឹកហាត់វិញ្ញាណរបស់យើង—១:៦ :**

A. នៅពេលដែលវិញ្ញាណរបស់យើងបើកធំទូលាយ ខ្លួនទាំងមូលរបស់យើង ត្រូវបានបើក ។ បន្ទាប់មក ព្រះមានផ្លូវដើម្បីចែកចាយអង្គទ្រង់ផ្ទាល់ចូលទៅក្នុងយើង—រ៉ូម ១២:១១ ។

B. មានតែសេចក្ដីអធិដ្ឋានប៉ុណ្ណោះ ហ្វឹកហាត់វិញ្ញាណរបស់យើង ។ នៅពេលដែលយើងអធិដ្ឋានទាក់ទងនឹងព្រះអម្ចាស់ និងនៅពេលយើងសរសើរតម្កើងទ្រង់ ខាងយើងគឺត្រូវទទួលបានការចែកចាយរបស់ទ្រង់ ឯខាងទ្រង់ គឺត្រូវចែកចាយ—២ធីម៉ូថេ ១:៦ ។

IV. **"ព្រះគុណខ្ពង់_ខ្ពស់ ដែលទ្រង់បានប្រោសមេ_ត្តា គឺប្រ_ទានព្រះអង្គផ្ទាល់ក្នុងព្រះបុ_ត្រា គ្រប់យ៉ាងមិនត្រឹម ស_ម្រាប់ ឱ្យយើងអំ_ណរ តែទ្រង់ជាចំ_ណែក ដ៏មានសិ_រី_ល្អ"—(បទចម្រៀងខ្មែរលេខ៣៧៦,បទអង់គ្លេសលេខ៤៩៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី៦២ ការលាយបញ្ចូលគ្នារវាងព្រះជាមួយមនុស្ស

**ដកស្រង់ពី :**

យ៉ូហាន ១:១៤ក ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា មានពេញជាព្រះគុណ និងសេចក្តីពិត ។

ព្រះបានលាយបញ្ចូលជាមួយមនុស្ស គឺជាការលាយបញ្ចូលគ្នារវាងព្រះជាមួយមនុស្សនោះឯង ។ យើងអាចប្រៀបធៀបខ្លួនយើងទៅនឹងកែវដាក់ទឹកមួយ ។ ប្រសិនបើតែត្រូវបានដាក់បន្ថែមចូលទៅក្នុងកែវដាក់ទឹកនេះ ក្រោយមក ទឹកនិងតែ តែនិងទឹកត្រូវបានលាយបញ្ចូលគ្នា ។ យើងទាំងអស់គ្នាត្រូវមានសេចក្តីជំនឿមួយថា យើងត្រូវបានលាយបញ្ចូលជាមួយព្រះបន្ទូលរបស់ព្រះ ។

**ខ្លឹមសារ :**

យ៉ូហាន ១:១៤ក ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា មានពេញជាព្រះគុណ និងសេចក្តីពិត ។

ហេព្រើរ ៤:២ ដ្បិតដំណឹងល្អបានផ្សាយមកយើងរាល់គ្នាដូចជាដល់គេដែរ ប៉ុន្តែ ព្រះបន្ទូលដែលគេឮ នោះគ្មានប្រយោជន៍ដល់គេសោះ ដោយព្រោះមិនបានលាយនឹងសេចក្តីជំនឿ ក្នុងចិត្តនៃពួកអ្នកដែលឮនោះ ។

**I. អាថ៌កំបាំងដែលត្រូវបានបើកសម្តែងមកដល់យើងតាមរយៈព្រះគម្ពីរទាំងមូលនេះ គឺការលាយបញ្ចូលលាយគ្នារវាងព្រះជាមួយមនុស្ស—យ៉ូហាន១:១៤ ។**

**II. យើងអាចប្រៀបធៀបខ្លួនយើងទៅនឹងកែវដាក់ទឹកមួយ ។ ប្រសិនបើតែត្រូវបានដាក់បន្ថែមចូលទៅក្នុងកែវដាក់ទឹកនេះ អង្គធាតុមួយផ្សេងទៀតត្រូវបានដាក់ចូលទៅក្នុងទឹក ក្រោយមក សារធាតុទាំងពីរ ទឹកនិងតែ តែនិងទឹកត្រូវបានលាយបញ្ចូលគ្នា—១កូរិនថូស ៦:១៧ ។**

III. "ដ្បិតដំណឹងល្អបានផ្សាយមកយើងរាល់គ្នាដូចជាដល់គេដែរ ប៉ុន្តែ ព្រះបន្ទូលដែលគេឮនោះគ្មានប្រយោជន៍ដល់គេសោះ ដោយព្រោះមិនបានលាយនឹងសេចក្ដីជំនឿ ក្នុងចិត្តនៃពួកអ្នកដែលឮនោះ"—ហេព្រើរ ៤:២ :

A. សេចក្តីជំនឿដ៏ពិត គឺជាអ្នកដែលជឿតែក្នុងព្រះបន្ទូលរបស់ព្រះប៉ុណ្ណោះ ហើយមិនស្ថិតនៅក្នុងបទពិសោធន៍ អារម្មណ៍ ឬបរិយាកាសដ៏ខ្មៅងងឹតរបស់ខ្លួនឯងឡើយ ។

B. យើងទាំងអស់គ្នាត្រូវតែមានសេចក្តីជំនឿមួយថា យើងត្រូវបានលាយបញ្ចូលជាមួយព្រះបន្ទូលរបស់ព្រះ ។ ចំពោះសេចក្តីជំនឿដ៏ពិតប្រាកដ គឺមានសេចក្តីសប្បាយរីករាយ និងសេចក្តីអំណរ—៣:៩ ។

IV. ខ្ញុំស្រឡាញ់ព្រះអង្គ ស្រឡាញ់ទ្រង់ឥតប្រៀបបាន / ខ្វះព្រះអង្គរស់នៅ ឥតមានន័យ ព្រះអង្គទ្រង់ទាញចិត្តខ្ញុំ / ឱ្យខ្ញុំលង់ដួងហឫទ័យ ទ្រង់បរិបូរឥតអ្វីប្រៀបបាន / នាមព្រះអង្គផ្អែមជាប់ចិត្ត ហៅព្រះនាមនេះស្កប់ចិត្ត / ទ្រង់ជារបស់ខ្ញុំ ខ្ញុំរបស់ទ្រង់ ទ្រង់គង់ជាមួយមនុស្ស / ព្រះនិងខ្ញុំរួមតែមួយ ភ្លក់រសជាតិយេរូសាឡិមថ្មី (បទជាភាសាខ្មែរនៅទំព័រលេខ ៤៦០ ) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៦៣ ព័ន្ធកិច្ចនៃយុគសម័យ

**ដកស្រង់ពី :**

អេភេសូរ ៤:១២ ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការងារនៃព័ន្ធកិច្ច ហើយនិងស្អាងរូបកាយព្រះគ្រិស្តឡើង ។

នៅគ្រប់យុគសម័យ ព្រះអម្ចាស់មានការពិសេសដែលទ្រង់ចង់បំពេញសម្រេច នោះគឺព័ន្ធកិច្ចនៃយុគសម័យនោះ ។ យើងទាំងអស់គ្នានៅក្នុងនិមិត្តនៃយុគសម័យនេះ យើងត្រូវដើរតាមនិមិត្តនេះជានិច្ច ។

**ខ្លឹមសារ :**

អេភេសូរ ៤:១២ ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការងារព័ន្ធកិច្ច ហើយនិងកសាងរូបកាយព្រះគ្រិស្តឡើង ។

១ធីម៉ូថេ ៤:៦ ព្រះបន្ទូលនៃសេចក្តីជំនឿ និង សេចក្តីបង្រៀនដ៏ល្អបានចិញ្ចឹមអ្នក ដោយអ្នកបានកាន់តាមស្មោះចំពោះមែន ។

I. **នៅគ្រប់យុគសម័យ ព្រះអម្ចាស់តែមានការពិសេសដែលទ្រង់ចង់បំពេញសម្រេច ។ ទ្រង់មានការស្តារឡើងវិញនិងការងាររបស់ទ្រង់ផ្ទាល់ ហើយការស្តារឡើងវិញ និងការងារដ៏ពិសេសដែលទ្រង់ធ្វើនៅក្នុងយុគសម័យនីមួយៗ នោះគឺជាព័ន្ធកិច្ចនៃយុគសម័យនោះ—ប្រៀបធៀបនឹង លោកុប្បត្តិ ៦:១៣-១៤; ២ពង្សាវតារក្សត្រ ២:២-១៥ :**
   A. នៅក្នុងសញ្ញាចាស់ មានព័ន្ធកិច្ចនៃយុគសម័យរបស់ណូអេ គឺកសាងទូក ហើយព័ន្ធកិច្ចនៃយុគសម័យរបស់ម៉ូសេ គឺត្រូវកសាងរោងឱបោសថ ហើយនិងព័ន្ធកិច្ចនៃយុគសម័យរបស់ដាវិឌ និងសាឡូម៉ូន គឺត្រូវកសាងព្រះវិហារ—លោកុប្បត្តិ ៦:១៤-១៦ ។
   B. នៅក្នុងសញ្ញាថ្មី មានព័ន្ធកិច្ចរបស់ព្រះអម្ចាស់ គឺត្រូវកសាងរូបកាយរបស់ព្រះគ្រិស្តឡើង—ម៉ាថាយ ១៦:១៨ ។

II. និមិត្តដែលត្រូវនឹងយុគសម័យ ត្រូវតែពង្រីកចាប់ពីនិមិត្តទីមួយរបស់អ័ដាមនៅក្នុងលោកុប្បត្តិ ហូតដល់និមិត្តចុងក្រោយបំផុតរបស់យ៉ូហាននៅក្នុងវិវរណៈ ដែលជាក្រុងយេរូសាឡិមថ្មី ហើយនៅខាងក្នុងនៃការបំពេញសម្រេចចុងក្រោយនេះ គឺត្រូវបានរួមបញ្ចូលគ្រប់ទាំងអស់—លោកុប្បត្តិ ២:៩, វិវរណៈ ២១:២, ៩-១០ ។

III. ចំណេះដឹង និងការរកឃើញការបើកសម្តែងរបស់ព្រះ ត្រូវអភិវឌ្ឍននិងជឿនទៅមុខទៅតាមយុគសម័យនីមួយៗ—ហេព្រើរ ១:១-២ :

   A. នៅឆ្នាំ ១៥២០ លូធឺ (Luther)ត្រូវបានជ្រើសតាំងឡើងឱ្យមានការកែប្រែ ហើយនៅសតវត្សទី ១៧ ម៉ាដាម ហ្គូយ៉ន (Madam Guyon) បានស្តារឡើងនូវចំណេះដឹងអំពីជីវិត ហើយបន្ទាប់មកនៅសតសត្សទី ១៨ ខោនថ៍ ហ្ស៊ិនហ្សេនដហ្វ (Count Zinzendorf) មានការស្តារឡើងវិញនូវការចាកចេញពីអង្គការ និងនិកាយនានា ហើយក្រោយមកទៀតនៅក្នុងសតវត្សទី ១៩ ជេ អេន ដាប៊ី (J. N. Darby) បានស្តារឡើងវិញនូវសេចក្តីពិត ហើយនៅក្នុងសតវត្សទី ២០ និមិត្តបានមកដល់យើងរាល់គ្នា—ខ១-២ ។

   B. បងប្អូន នី បានស្រង់យកខ្លឹមសារដើមនៃការបើកសម្តែងរបស់ព្រះ ពីគ្រប់ទំព័រប្រវត្តិសាស្ត្រ ហើយបានជឿនទៅទៀត ព្រមទាំងបានតាំងមូលដ្ឋានគ្រឹះដ៏អស្ចារ្យ សម្រាប់ការស្តារឡើងវិញរបស់ព្រះអម្ចាស់ក្នុងពេលសព្វថ្ងៃនេះ ។ រួចបងប្អូន លី បានបន្តព័ន្ធកិច្ចនេះ ព្រមទាំងកសាងលើការបើកសម្តែងរបស់ព្រះថែមទៀត ឆ្ពោះទៅរកការបើកសម្តែងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះ—អេភេសូរ ១:១៧, ៣:៩ ។

IV. នេះគឺជាព្រះមេត្តារបស់ព្រះ ដែលមនុស្សអាចមើលឃើញ ហើយមានទំនាក់ទំនងជាមួយនឹងព័ន្ធកិច្ចនៃយុគសម័យនោះ ។ យើងគ្រប់គ្នានៅក្នុងយុគសម័យនេះ ទទួលគ្រងនិមិត្តទាំងអស់ យើងត្រូវដើរតាមនិមិត្តនេះជានិច្ច—ប្រៀបធៀប ១ពង្សាវតារក្សត្រ ១៩:១-៩៦; ២ពង្សាវតារក្សត្រ ៦:១៦ ។

V. ព្រះនឹងមនុស្សរស់នៅរួមគ្នា នៅក្នុងវិញ្ញាណរួមបញ្ចូលគ្នា / យើងរួមសហការនឹងទ្រង់ពិត ក្លាយជារូបកាយមានជីវិត / នេះជានិមិត្តនៃយុគសម័យ គ្រប់គ្រងជីវិតរស់នៅរាល់ថ្ងៃ / ព្រះអម្ចាស់នឹងមានរូបកាយទ្រង់ ពន្លឺបរិសុទ្ធបំភ្លឺទីក្រុង ។— (បទចម្រៀងខ្មែរ ទំព័រ ៤៩១ ,អង់គ្លេស ១៣៤៩) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី៦៤ ព្រះត្រីឯកដែលបានឆ្លងកាត់ដំណាក់កាល

**ដកស្រង់ពី:**

១ធីម៉ូថេ ៣:១៦ ពិតប្រាកដជាសេចក្តីអាថ៌កំបាំងរបស់សាសនានៃយើង នោះជ្រាលជ្រៅណាស់ គឺដែលព្រះបានលេចមកក្នុងសាច់ឈាម បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មនុស្សបានប្រកាសប្រាប់ពីទ្រង់ដល់ពួកសាសន៍ដទៃ មានគេជឿដល់ទ្រង់ក្នុងលោកិយនេះរួចព្រះបានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ ។

ព្រះនាមរបស់ព្រះត្រីឯកគឺ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ ។ នៅក្នុងដំណាក់កាលរបស់ ទ្រង់បានឆ្លងកាត់ការក្លាយជាសាច់ឈាម ដំណើរជីវិតជាមនុស្ស បានយាងចូលទៅក្នុងសេចក្តីស្លាប់ ព្រះគ្រិស្តបានរស់ឡើងវិញ ។ យើងបទពិសោធព្រះត្រីឯកដែលបានឆ្លងកាត់ដំណាក់កាល នៅពេលដែលយើងហៅ "អូ ព្រះអម្ចាស់យេស៊ូ" ។

**ខ្លឹមសារ:**

យ៉ូហាន ១:១៤ក ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា មានពេញជាព្រះគុណ និងសេចក្តីពិត ។

២៩ លុះស្អែកឡើង យ៉ូហានឃើញព្រះយេស៊ូ ដែលទ្រង់កំពុងតែយាងមកឯគាត់ នោះក៏ពោលថា នុ៎ះន៍ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក ។

កិច្ចការ ៣:១៥ អ្នករាល់គ្នាបានសម្លាប់ព្រះអម្ចាស់ជីវិតនោះទៅ តែព្រះបានប្រោសឱ្យទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ យើងខ្ញុំនេះជាទីបន្ទាល់ពីការនោះឯង ។

I. **ព្រះគឺតែមួយ ប៉ុន្តែបី គឺ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណ ។ ព្រះត្រីឯក គឺជាការហូរនៃព្រះជាមួយនឹងព្រះវរបិតាជាក្បាលទឹក ព្រះរាជបុត្រាជារន្ធទឹក និងព្រះ**

**វិញ្ញាណជាទន្លេ សម្រាប់ការបទពិសោធន៍ និងសេចក្ដីអំណររបស់យើង—យ៉ូហាន ៤:១៤; ២កូរិថូស ១៣:១៤ ខអធិប្បាយ១ :**

A. នៅក្នុងការក្លាយជាសាច់ឈាមរបស់ទ្រង់ ព្រះអម្ចាស់យេស៊ូបានចាប់ផ្ទៃដោយព្រះវិញ្ញាណបរិសុទ្ធ ។ "មើលនាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយព្រះនាមបុត្រនោះត្រូវហៅថា អេម៉ាញូអែល" ។ អេម៉ាញូអែល មានន័យថា ព្រះគង់ជាមួយយើង—ម៉ាថាយ ១:២៣; យ៉ូហាន ១:១៤ ។

B. នៅក្នុងការដំណើរជីវិតជាមនុស្សរបស់ទ្រង់ ទ្រង់គឺជា "ឃើញទ្រង់មានភាពជាមនុស្សដូច្នោះ" ក្នុងរូបជាមនុស្សផង នោះក៏បន្ទាបព្រះអង្គទ្រង់—ភីលីព ២:៦-៨ ។

C. នៅក្នុងសេចក្ដីស្លាប់របស់ព្រះគ្រិស្ដ ទ្រង់បានដោះស្រាយបាប សាតាំង លោកិយ... ក៏បានបញ្ចេញជីវិតព្រះផងដែរ ។ ពេលដែលទ្រង់ត្រូវបានជាប់ឆ្កាង ព្រះលោហិតនិងទឹកបានហូរចេញ ។ ព្រះលោហិត គឺសម្រាប់ការប្រោសលោះ រីឯទឹកគឺសម្រាប់ការចែករំលែកជីវិត—យ៉ូហាន ១:២៩; ហេព្រើរ ២:១៩ខ ។

D. បន្ទាប់ពីសេចក្ដីស្លាប់របស់ទ្រង់ ព្រះគ្រិស្ដត្រូវបានរស់ឡើងវិញ ហើយបានចែករំលែកជីវិតព្រះចូលទៅក្នុងយើងនៅក្នុងសេចក្ដីរស់ឡើងវិញ ដើម្បីឱ្យយើងអាចក្លាយជាកូនព្រះ និងពួកបងប្អូនរបស់ទ្រង់ជាច្រើន—១ពេត្រុស ១:៣; កិច្ចការ ២:៣២ ។

II. **យើងបទពិសោធព្រះត្រីឯកដែលបានឆ្លងកាត់ដំណាក់កាល នៅពេលដែលយើងហៅ "អូព្រះអម្ចាស់យេស៊ូ" ។ ព្រះត្រីឯកដែលបានឆ្លងកាត់ដំណាក់កាលទាំងមូល គឺត្រូវបានប្រែសភាពនៅក្នុងព្រះនាមនេះ ។ ពេលដែលយើងប៉ះពាល់ព្រះនាមនេះ ហៅព្រះនាមនេះ នោះអង្គដ៏អស្ចារ្យនឹងយាងមក—រ៉ូម ១០:១២ ។**

III. "សរ_សើរ បិ_តា ប្រ_ភព ព្រះពរ សរ_សើរ បុ_ត្រា ស_ម្រេចប្រោសលោះ សរ_សើរ ព្រះវិ_ញ្ញាណ ដំ_ណើរ_ការ សរ_សើរ បិ_តា បុ_ត្រា វិ_ញ្ញាណ ។ សរសើរបិតាជាប្រភពទឹក សរសើរបុត្រាជាខ្សែទឹកហូរ សរសើរព្រះវិញ្ញាណចូលខាងក្នុង ព្រះអង្គត្រីឯកជាចំណែកខ្ញុំ។"—( បទចម្រៀងខ្មែរលេខ៥,អង់គ្លេសលេខ៨) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី៦៥ ព្រះគ្រិស្តរួមបញ្ចូលគ្រប់ទាំងអស់

**ដកស្រង់ពី:**

កូល៉ុស ១:១២ ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឱ្យយើងបានគួរនឹងទទួលចំណែកកេរ្តិ៍អាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង ។

សព្វថ្ងៃនេះ ចំណែករបស់យើង គឺជាព្រះគ្រិស្តដែលរួមបញ្ចូលទាំងអស់ ។ ទឹកដីល្អបានផ្តល់នូវអ្វីដែលយើងត្រូវការ ដូចជាទឹកដោះ ទឹកឃ្មុំ គោក្របី ធញ្ញជាតិ រ៉ែ ។ យើងពិតជាត្រូវអរព្រះគុណដល់ព្រះវរបិតា សម្រាប់ការប្រទានព្រះគ្រិស្តដល់យើង ទុកជាចំណែកកេរ្តិ៍អាករព្រះរបស់យើង!

ខ្លឹមសារ:

កូល៉ុស ១:១២ ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឱ្យយើងបានគួរនឹងទទួលចំណែកកេរ្តិ៍អាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង ។

ចោទិយកថា ៨:៧-៩ ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់នាំឯងចូលទៅក្នុងស្រុកដ៏ល្អ ជាស្រុក ដែលមានស្ទឹង មានរន្ធទឹក ហើយនឹងក្បាលទឹកហូរចេញនៅក្នុងច្រក ហើយក្នុងភ្នំផង ។ ជាស្រុកដែលមានស្រូវសាលី នឹងស្រូវឱក ក៏មានទំពាំងបាយជូមានល្វា នឹងទទឹម ហើយមានដើមអូលីវ និងទឹកឃ្មុំផង ។ ជាស្រុកដែលឯងនឹងបរិភោគអាហារ មិនមែនដោយរិតត្បិតទេ ឯងនឹងមិនខ្វះខាតអ្វីនៅស្រុកនោះឡើយ ឯថ្មនៅស្រុកនោះសុទ្ធតែជាដែក ហើយនៅក្នុងភ្នំនោះនឹងជីករកបានទង់ដែង ។

I. កូល៉ុស ១:១២ ចែងថា ព្រះគ្រិស្តដែលរួមបញ្ចូលគ្រប់ទាំងអស់ ជា**ចំណែកកេរ្តិ៍អាករព្រះដើម្បីក្លាយ**ជាសេចក្តីអំណរដល់ពួកអ្នកជឿរបស់ទ្រង់:
   A. ពាក្យជាភាសាក្រិកបានបកប្រែ ចំណែក ថា ចំណែក និងកេរ្តិ៍អាកររបស់យើង ដែលសព្វថ្ងៃនេះ គឺជាព្រះគ្រិស្តដែលរួមបញ្ចូលគ្រប់ទាំងអស់ ។

B. ពាក្យ ចំណែក ចង្អុលបង្ហាញពីសេចក្ដីអំណរ ។ ព្រះគ្រិស្ដ គឺជាសេចក្ដីអំណរតែមួយគត់សម្រាប់ពួកបរិសុទ្ធទាំងអស់ ។ គ្មានអ្វីគួរអនុញ្ញាតឱ្យមកជំនួសទ្រង់ជាចំណែករបស់យើងឡើយ ។

II. **ចោទិយកថា ៨:៧-៩ និយាយថា "ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់នាំឯងចូលទៅក្នុងស្រុកដ៏ល្អ ជាស្រុកដែលមានស្ទឹង មានរន្ធទឹក ហើយនិងក្បាលទឹកហូរចេញនៅក្នុងច្រកហើយក្នុងភ្នំផង ។ ជាស្រុកដែលមានស្រូវសាលី និងស្រូវឱក ក៏មានទំពាំងបាយជូរ មានល្វា និងទទឹម ហើយមានដើមអូលីវ និងទឹកឃ្មុំផង ។ ជាស្រុកដែលឯងនឹងបរិភោគអាហារ មិនមែនដោយរិតត្បិតទេ ឯងនឹងមិនខ្វះខាតអ្វីនៅស្រុកនោះឡើយ ឯថ្មនៅស្រុកនោះសុទ្ធតែជាដែក ហើយនៅក្នុងភ្នំនោះនឹងជីករកបានទង់ដែង" :**

A. ប៉ុលបានប្រើវាក្យសព្ទនេះជាមួយកំណត់ត្រាគម្ពីរសញ្ញាចាស់ អំពីស្រុកទុកជាសាវតារ ។ ព្រះបានប្រទានទឹកដីល្អដល់កូនចៅអ៊ីស្រាអែល ជាប្រជារាស្ដ្រដែលទ្រង់បានជ្រើសរើស សម្រាប់ទុកជាមរតក និងជាសេចក្ដីអំណររបស់ពួកគេ ។

B. ស្រុកគឺជារបស់គ្រប់យ៉ាងសម្រាប់ពួកយើង ព្រោះស្រុកបានផ្គត់ផ្គង់អ្វីៗដែលកូនចៅអ៊ីស្រាអែលត្រូវការ ដូចជាទឹកដោះ ទឹកឃ្មុំ គោក្របី ធញ្ញជាតិ និងរ៉ែ ។ យើងពិតជាត្រូវអរព្រះគុណដល់ព្រះវរបិតា សម្រាប់ការប្រទានព្រះគ្រិស្ដដល់យើង ទុកជាចំណែកកេរ្ដិ៍អាករព្រះរបស់យើង!

III. **"ព្រះអង្គជាបុ_ត្រាស្ងួន_ភ្ងា ជារូបភាពរ_បស់ព្រះ ទ្រង់ជាចំ_ណែកពួកបរិ_សុទ្ធ យើងត្រូវអំ_ណរ ឥតឈប់ ទ្រង់បានក្លាយមកជាបងច្បងប្រ_មុខ លើគ្រប់ទាំងពួងគ្រប់រ_បស់ទ្រង់ប_ង្កើត ផង នៅក្រោមព្រះដ៏មានជ័យ"—(បទចម្រៀងខ្មែរលេខ១៦៣,អង់គ្លេសលេខ១៨៩) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៦៦ ព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់

**ដកស្រង់ពី:**

យ៉ូហាន ៧:៣៩ តែសេចក្តីនេះ គឺទ្រង់មានបន្ទូល ពីព្រះវិញ្ញាណ ដែលអស់អ្នកជឿដល់ទ្រង់នឹងត្រូវទទួល ដ្បិតព្រះវិញ្ញាណបរិសុទ្ធ មិនទាន់យាងមក ដោយព្រោះព្រះយេស៊ូមិនទាន់បានតម្កើងឡើងនៅឡើយ ។

វិញ្ញាណលាយបញ្ចូល បានឆ្លងកាត់គ្រប់ដំណាក់កាល—ការក្លាយជាសាច់ឈាម ការដំណើរជីវិតរស់ជាមនុស្ស សេចក្តីស្លាប់ដែលរួមបញ្ចូលគ្រប់ទាំងអស់ ការបញ្ចេញជីវិតរស់ឡើងវិញដែលមានគ្រប់ទាំងអស់—ព្រះត្រីឯកក្លាយជាព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់ ជា មួយនឹងវិញ្ញាណរបស់មនុស្ស ។ "នៅពេលដែលយើងហៅ 'ព្រះអម្ចាស់យេស៊ូ' តើវិញ្ញាណរបស់យើងនឹងផុសឡើងយ៉ាងណាទៅ ។ ចំពោះការនេះ ព្រះវិញ្ញាណផ្តល់ជីវិតគង់នៅខាងក្នុងយើង!"

**ខ្លឹមសារ:**

យ៉ូហាន ៧:៣៩ខ ដ្បិតព្រះវិញ្ញាណបរិសុទ្ធ មិនទាន់យាងមក ដោយព្រោះព្រះយេស៊ូមិនទាន់បានតម្កើងឡើងនៅឡើយ ។

១កូរិនថូស ៦:១៧ ឯអ្នកដែលនៅជាប់នឹងព្រះអម្ចាស់ នោះក៏ជា វិញ្ញាណតែ១នឹងទ្រង់ដែរ ។

I. **សព្វថ្ងៃនេះព្រះគ្រិស្តលាយបញ្ចូលគ្រប់ទាំងអស់ បានក្លាយជា ព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់—យ៉ូហាន ៧:៣៩:**
   A. ព្រះវិញ្ញាណដែលយើងមានសព្វថ្ងៃនេះ គឺជាព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់ ។ ព្រះវិញ្ញាណបរិសុទ្ធ មិនទាន់យាងមក ដោយព្រោះព្រះយេស៊ូមិនទាន់បានតម្កើង

ឡើងនៅឡើយ ។ នៅពេលដែលទ្រង់មានព្រះជន្មរស់ឡើងវិញ នោះព្រះយេស៊ូបានតម្កើងឡើង—លូកា ២៤:២៦ ។

B. ឥឡូវនេះព្រះវិញ្ញាណ រួមមាន សភាពព្រះ សភាពមនុស្ស ប្រសិទ្ធភាពនៃការសុគតរបស់ព្រះគ្រិស្ត និងអំណាចនៃការរស់ឡើងវិញរបស់ទ្រង់ ។ យើងមានព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់ដែលមានច្រើនលើសលុបខ្លាំងណាស់ !

II. **ទ្រង់បានមកដល់យើង ហើយចូលមកខាងក្នុងយើងជា ព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់ ជាព្រះវិញ្ញាណគង់នៅខាងក្នុងវិញ្ញាណរបស់យើង ក្លាយជា តែ១ជាមួយវិញ្ញាណរបស់យើង—១កូរិនថូស ៦:១៧:**

A. នៅពេលដែលយើងជឿលើព្រះអម្ចាស់យេស៊ូ ព្រះត្រីឯកដែលសម្រេចចុងក្រោយបង្អស់ប៉ះពាល់ ទៅដល់ ហើយថែមទាំងចូលទៅខាងក្នុងខ្លួនយើង ដើម្បីធ្វើឱ្យវិញ្ញាណរបស់យើងបានកើតជាថ្មីជាមួយនឹងជីវិតរបស់ព្រះ—ខ៤ ។

B. បន្ទាប់ពីនេះ ព្រះវិញ្ញាណបរិសុទ្ធ ឋិតនៅ និងគង់នៅក្នុងវិញ្ញាណរបស់យើង ។ ការនេះបង្កើតឱ្យមានការរួមគ្នា ឬ ការលាយបញ្ចូលគ្នា ។ វិញ្ញាណដែលបានកើតជាថ្មីរបស់ពួកអ្នកជឿ ហើយនិងព្រះវិញ្ញាណសម្រេចចុងក្រោយបង្អស់របស់ព្រះត្រូវបានលាយបញ្ចូលគ្នាជាវិញ្ញាណតែមួយ—ខ.១៧; រ៉ូម.៨:១៦ ។

III. **"ព្រះវិញ្ញាណចាក់ប្រេងលាប ឱ្យខ្ញុំបានជ្រួតជ្រាប ទាំងព្រលឹងនិងវិញ្ញាណ ពោរពេញដោយព្រះអង្គ ឱ្យខ្ញុំបានផ្លាស់ប្រែទៅ ថែមទាំងចតចម្លង រហូតចម្រើនឡើងធំ ពេញវ័យជាចាស់ទុំ។—(បទចម្រៀងខ្មែរលេខ៣៨១,អង់គ្លេសលេខ៨៤១) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៦៧ ព្រះជាជីវិតអស់កល្ប

**ដកស្រង់ពី:**

១យ៉ូហាន ១:២ ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទីបន្ទាល់ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ចដែលពីដើម ស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឱ្យយើងខ្ញុំឃើញ ។

ជីវិតអស់កល្ប គឺជាជីវិតព្រះ ឬជាជីវិតរបស់ព្រះ ។ ការផឹកទឹកដ៏រស់ គឺជាការផឹកជីវិតដ៏អស់កល្ប ។ យើងត្រូវការផឹកទឹកដ៏រស់ ហើយយើងក៏ត្រូវការ "ការហូរតាមយើង ទ្រង់អាចប្រើការយើងបាន គ្រប់ម៉ោងគ្រប់ទីកន្លែង" (ដកស្រង់ពីបទអង់គ្លេសលេខ ២៦៨) ។

**ខ្លឹមសារ :**

១យ៉ូហាន ១:២ ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជា ទីបន្ទាល់ ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ចដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឱ្យយើងខ្ញុំឃើញ ។

៥:១៣ ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្ប ជានិច្ចហើយ ។

យ៉ូហាន ៤:១៤ តែអ្នកណាដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យ នឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ចមានតែជីវិតរបស់ព្រះទេ គឺជាជីវិត ។

I. **មានតែជីវិតរបស់ព្រះទេ ដែលជាជីវិត និងជាព្រះ ។ បទគម្ពីរថែងពី ជីវិតរបស់ព្រះថា ជាជីវិតអស់កល្ប—១យ៉ូហាន ៥:១២-១៣ :**

A. មានតែអស់អ្នកដែលមានសេចក្តីត្រូវការខាងក្នុងខ្លាំង ហើយនិងអ្នកដែលប្តេជ្ញាចិត្ត ដើម្បីជួបព្រះប៉ុណ្ណោះ ទើបនឹងទទួលបានព្រះពររបស់ទ្រង់—១:២ ។

B. ជីវិតអស់កល្ប គឺជាជីវិតដែលមាននៅក្នុងព្រះរាជបុត្រានៃព្រះ ។ នៅពេលយើងទទួលព្រះរាជបុត្រាដោយការជឿលើទ្រង់ នោះយើងមានជីវិតអស់កល្ប ។

**II. ក្នុងនាមជាពួកអ្នកជឿព្រះគ្រិស្ត យើងបានទទួលជីវិតអស់កល្បតាមរយៈសេចក្តីជំនឿ—យ៉ូហាន ៦:៤៧ ។**

**III. "តែអ្នកណាដែលផឹកទឹកដែលខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យនឹងត្រឡប់ជារន្ធនៅក្នុងអ្នកនោះ ដែលផុសឡើងរហូតដល់ទៅជីវិតអស់កល្បជានិច្ច"—៤:១៤:**

A. បន្ទាប់ពីយើងបានជឿចូលទៅក្នុងព្រះគ្រិស្ត នោះព្រះត្រីឯកដែលជាជីវិតអស់កល្បបានចូលទៅក្នុងយើង—៦:៤៧ ។

B. ការផឹកទឹកដ៏រស់ គឺជាការផឹកជីវិតអស់កល្បជានិច្ច ។ ខណៈពេលយើងផឹកទឹកដ៏រស់ នោះទ្រង់បាញ់ចេញឡើងនៅក្នុងយើង ហើយយើងត្រូវបាននាំចូលទៅដល់ជីវិតអស់កល្បជានិច្ច ដើម្បីបំបាត់ការស្រេករបស់យើង—៤:១៤ ។

C. ដោយការក្លាយជាទរបង្ហូរ យើងត្រូវចែកចាយជីវិតនេះ ដើម្បីឱ្យជីវិតអស់កល្បអាចហូរទៅដល់អវយវៈនៃរូបកាយដទៃទៀត ។

**IV. ជីវិតអស់កល្បនាំយើងខ្ញុំឱ្យមានការប្រកប / រួមចែកចាយរួមចំណែក រួចផុតការបាក់បែក / យើងបានក្លាយជាតែមួយ នៅក្នុងការប្រកប / ជីវិតដែលទ្រង់ប្រទាន គឺជាព្រះវិញ្ញាណ (បទចម្រៀងជាភាសា ៥៣៣, អង់គ្លេសលេខ ៧៣៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទ ៦៨ រូបកាយរបស់ព្រះគ្រិស្ត

**ដកស្រង់ពី :**

អេភេសូរ ១:២២-២៣ ...ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។

អេភេសូរ ១:២២ និង២៣ បើកសម្តែងពីក្រុមជំនុំគឺជារូបកាយរបស់ព្រះគ្រិស្ត ។ នៅក្នុងសកលលោកនេះ មានរូបកាយព្រះគ្រិស្តតែមួយប៉ុណ្ណោះ ។ នៅក្នុងព្រះវិញ្ញាណតែ១ យើងគ្រប់គ្នាក៏បានត្រូវជ្រមុជចូលក្នុងរូបកាយតែ១ ផឹកពីព្រះវិញ្ញាណតែ១ដែរ ។

**ខ្លឹមសារ :**

អេភេសូរ ១:២២-២៣ ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់ នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់មកធ្វើជាសិរសាលើគ្រប់ទាំងអស់ ដល់ពួកជំនុំ ដែលជារូបកាយទ្រង់ គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។

១កូរិនថូស ១២:១៣ ដ្បិតយើងទាំងអស់គ្នាទោះបើជាសាសន៍យូដា ឬសាសន៍ក្រេក បាវបម្រើ ឬអ្នកជាក្តី យើងបានទទួលពិធីជ្រមុជទឹក ចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១ ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ ។

**I. ការបើកសម្តែងដ៏ខ្ពង់ខ្ពស់បំផុតនៅក្នុងព្រះគម្ពី គឺជារូបកាយរបស់ព្រះគ្រិស្ត—អេភេសូរ ១:២២-២៣ ។**

**II. នៅក្នុងសកលលោកនេះ មានរូបកាយព្រះគ្រិស្តតែមួយប៉ុណ្ណោះ—៩:៩ :**

A. រូបកាយព្រះគ្រិស្តគឺមានតែមួយប៉ុណ្ណោះនៅក្នុងសកលលោកនេះ មិនមានរូបកាយព្រះគ្រិស្តនៅអាមេរិច ហើយរូបកាយមួយទៀតនៅជប៉ុននោះទេ ។ នៅក្នុងគ្រប់ទីកន្លែង រូបកាយព្រះគ្រិស្តគឺមានតែមួយ ដែលមានព្រះត្រីឯកជាចំណុះ—ខ៤-៦ ។

B. ភាពតែមួយនៃរូបកាយរបស់ព្រះគ្រិស្ត គឺត្រូវបានរក្សា និងសម្ដែងចេញតាមរយៈក្រុមជំនុំតំបន់ដែលនៅក្នុងតំបន់នោះ—កិច្ចការ ៨:១; វិវរណៈ ១:១១ ។

**III. "តែអវយវៈទាំងនោះ ទោះមានច្រើនក៏ពិត គង់តែរួមគ្នាមកជារូបតែ១ទេ នោះព្រះគ្រិស្តក៏ដូច្នោះដែរ ដ្បិតយើងទាំងអស់គ្នាទោះបើជាសាសន៍យូដា ឬសាសន៍ក្រេក បាវបម្រើ ឬអ្នកជាក្តី យើងបានទទួលពិធីជ្រមុជទឹក ចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១ ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ"—១កូរិនថូស ១២:១២-១៣ :**

A. រូបកាយព្រះគ្រិស្តត្រូវបានផ្សំឡើងពីពួកអ្នកជឿទាំងអស់ ដែលជាអវយវៈនៃរូបកាយ ។

B. ១កូរិនថូស ១២:១៣ និយាយថា ដោយសារព្រះវិញ្ញាណតែ១នេះ យើងទាំងអស់បានជ្រមុជទឹកចូលក្នុងរូបកាយដ៏រស់តែ១នេះ ដែលយើងអាចសម្ដែងព្រះគ្រិស្ត ដូច្នេះហើយយើងទាំងអស់គ្នា មិនគួរគិតពី ពូជសាសន៍ សញ្ជាតិ និងឋានៈនៅក្នុងសង្គមនោះទេ យើងជារូបកាយតែមួយ ។

C. ១កូរិនថូស ១២:១៣ បញ្ជាក់ថា យើងផឹកពីព្រះវិញ្ញាណតែមួយនៅក្នុងរូបកាយ ។ យើងបានទទួលជ្រមុជទឹក ចូលក្នុងរូបកាយតែ១ ដោយសារព្រះវិញ្ញាណតែ១ ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែ១ដែរ ។ ព្រះវិញ្ញាណគឺនៅក្នុងរូបកាយ ដរាបណាយើងនៅក្នុងរូបកាយ នោះយើងអាចផឹកពីព្រះវិញ្ញាណបាន ។

**IV. "ពួកយើងរាល់គ្នាជារូបកាយរួមនៃក្រុមជន មានចំនួនច្រើនតែយើងរួមមកតែមួយ ដោយជីវិតទ្រង់ យើងទាំងអស់គ្នារួមជារូបកាយ ក្នុងជីវិតទ្រង់យើងរួមមកជាតែមួយ ។ ក្នុងពិភពលោកមានរូបកាយមួយប៉ុណ្ណោះ យើងទាំងអស់គ្នាទាំងអស់គ្នា សម្ដែងចេញមក ជំហរតែមួយនៅលើទីគ្រឹះតំបន់ មានបណ្ដាជនច្រៀងស្ញើចសរសើរ"—(បទចម្រៀងខ្មែរលេខ ៨២៩, អង់គ្លេសលេខ ១១០៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៦៩ ក្រុមជំនុំ

**ដកស្រង់ពី :**

ម៉ាថាយ ១៦:១៨ ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារឋានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។

ក្រុមជំនុំ មានន័យថា ពួកជំនុំដែលត្រូវបានត្រាស់ហៅចេញមក ។ ក្រុមជំនុំមិនមែនជាអង្គការទេ ប៉ុន្តែជារូបកាយដ៏មានជីវិត ដែលពោរពេញទៅដោយជីវិតនៅខាងក្នុង ។ "អូ ផ្ទះពោរពេញដោយក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់! យើងចែករំលែកទឹកទន្លេជីវិតរបស់ព្រះ ។ ខ្ញុំត្រូវបានចម្រើនកម្លាំងរាល់ថ្ងៃ និងបានដឹកនាំគ្រប់វិធី" (ដកស្រង់ពីបទចម្រៀងភាសាអង់គ្លេសលេខ ៦៧០៥) ។

**ខ្លឹមសារ :**

ម៉ាថាយ ១៦:១៨ ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារឋានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ ។

អេភេសូរ ១:២៣ គឺជាសេចក្ដីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ ក្នុងទាំងអស់ ។

I. ក្រុមជំនុំ មានន័យថា ពួកជំនុំដែលត្រូវបានត្រាស់ហៅចេញមក—**ម៉ាថាយ ១៦:១៨ :**
   A. ក្រុមជំនុំ គឺជាបណ្ដាជនដែលព្រះបានត្រាស់ហៅចេញមក ។ នៅកន្លែងណាក៏ដោយឱ្យតែមានពួកអ្នកជឿដូចបងប្អូន និងខ្ញុំ នោះហើយគឺជាបណ្ដាជនដែលព្រះបានត្រាស់ហៅចេញមក ។
   B. ក្រុមជំនុំ គឺផ្សំឡើងពីគ្រប់អស់អ្នកដែលបានជឿចូលទៅក្នុងព្រះគ្រិស្ដ ហើយនិងអ្នកដែលមានជីវិតរបស់ទ្រង់ ។ បុគ្គលណាដែលមិនជឿចូលទៅក្នុងព្រះគ្រិស្ដ និងមិន

ទាន់បានសង្គ្រោះ មិនអាចក្លាយជាសមាសធាតុរបស់ក្រុមជំនុំបានឡើយ—១កូរិនថូស ១:២; ហេព្រើរ ២:១២ ។

II. ក្រុមជំនុំ គឺជារូបកាយរបស់ព្រះគ្រិស្ត—**អេភេសូរ ១:២៣ :**

A. ក្រុមជំនុំ គឺជារូបកាយរបស់ព្រះគ្រិស្ត ។ មនុស្សគ្រប់រូបមានរូបកាយ ដូចជារូបកាយមនុស្សរបស់យើង ។ ក្រុមជំនុំដែលជារូបកាយរបស់ព្រះគ្រិស្តដ៏មានជីវិត គឺពោរពេញទៅដោយជីវិតនៅខាងក្នុង ដ្បិតជីវិតនៃរូបកាយរបស់ព្រះគ្រិស្ត គឺជាជីវិតរបស់ព្រះ ។

B. ម្យ៉ាងទៀត រូបកាយរបស់បុគ្គលម្នាក់ គឺមានសម្រាប់ការសម្ដែងចេញឱ្យគាត់ ។ ប្រសិនបើបុគ្គលម្នាក់មានតែក្បាល ប៉ុន្តែមិនមានរូបកាយ នោះគាត់គ្មានការ សម្ដែងចេញឡើយ ។ ក្រុមជំនុំ គឺជាការសម្ដែងរបស់ព្រះគ្រិស្ត—កូល៉ុស ១:១៨ ។

III. **ក្រុមជំនុំជាផ្ទះទីឈប់ សម្រាកយ៉ាងច្បាស់រាល់ថ្ងៃ / ពួកបងប្អូនអំណរ ខ្លាំងណាស់ ព្រះគ្រិស្តជាជីវិតធ្លាប់ជួប / តែការប្រឹងប្រែងឥឡូវ យើងហាលេលូយ៉ានៅផ្ទះ /*ក្រុមជំនុំជាផ្ទះទីនេះ គ្រប់យ៉ាងឈប់សម្រាក / យ៉ាងច្បាស់អស់មួយជីវិតយើងឱ្យទ្រង់ /បានលើកតម្កើងហាលេលូយ៉ា ព្រះគ្រិស្តក្រុមជំនុំ*—(បទចម្រៀងខ្មែរលេខ ៨២៦ , អង់គ្លេសលេខ ១២៣៣) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី ៧០ នគរ

**ដកស្រង់ពី:**

ម៉ាកុស ៤:២៦ ទ្រង់ក៏មានព្រះបន្ទូលថា នគរព្រះធៀបដូចជាមនុស្សម្នាក់ ដែលព្រោះពូជនៅដី ។

នគរ គឺជាព្រះគ្រិស្តដ៏អស្ចារ្យ ដែលបានសាបព្រោះចូលមកក្នុងយើង និងចម្រើនធំនៅខាងក្នុងយើង រហូតដល់យើងឈានដល់ភាពពេញវ័យជាចាស់ទុំ ។ នគរព្រះសព្វថ្ងៃ គឺជាការហ្វឹកហ្វឺនដ៏ពិត តែនៅពេលព្រះគ្រិស្តយាងមកសោយរាជ្យ នគរនឹងក្លាយជារង្វាន់ដ៏ធំ ។

**ខ្លឹមសារ** :

ម៉ាកុស ៤:២៦ ទ្រង់ក៏មានព្រះបន្ទូលថា នគរព្រះធៀបដូចជាមនុស្សម្នាក់ ដែលព្រោះពូជនៅដី ។

រ៉ូម ៥:១៧ ដ្បិតបើសិនជាសេចក្តីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្តីរំលង ដូច្នេះ ប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូគ្រិស្ត ។

### VI. នគរ គឺជាព្រះគ្រិស្តដ៏អស្ចារ្យ ដែលប្រៀបដូចជាគ្រាប់ពូជមួយគ្រាប់ដែលបានសាបព្រោះចូលទៅក្នុងមនុស្សនៅលើផែនដី ហើយគ្រាប់ពូជនេះ ចម្រើនធំនៅក្នុងចិត្តរបស់យើង ដើម្បីក្លាយជានគរ—ម៉ាកុស ៤:២ ។

C. នគរព្រះ គឺជារឿងរ៉ាវនៃជីវិត ។ ពេលដែលគ្រាប់ពូជចម្រើនធំនៅខាងក្នុងពួកគេ នោះហើយគឺជាការចម្រើនធំនៃនគរ ។

D. អាចិកំបាំងក្នុងការចូលទៅក្នុងនគរ គឺការចម្រើនធំក្នុងជីវិត ។ យើងចូលទៅក្នុងនគររាល់ថ្ងៃ ដោយការចម្រើនធំនៃជីវិតផ្នែកខាងក្នុង—ខ២៦-២៧ ។

**VII. សម្រាប់យើង សព្វថ្ងៃនេះ នគរ គឺជាការហ្វឹកហ្វឺន ។ យើងត្រូវតែរៀនពីរបៀបការបានហ្វឹកហ្វឺន ដើម្បីក្លាយជាស្តេច—រ៉ូម៥:១៧ ។**

C. គ្រួសាររាជវង្សនៅចក្រភពអង់គ្លេស ត្រូវតែបង្វឹកបង្ហាត់ព្រះរាជា ឬមហាក្សត្រី តាំងពីជំនាន់យុវវ័យមកម្ល៉េះ ។ ដូច្នេះ យើងត្រូវតែហ្វឹកហ្វឺន និងត្រូវបានគ្រប់គ្រង ដើម្បីមានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការធ្វើជាស្តេចនៅឋានសួគ៌ ។

D. យើងត្រូវសោយរាជ្យជាស្តេច លើអំពើបាប សេចក្តីស្លាប់ និងសាតាំង ។ ដើម្បីសោយរាជ្យបាន គឺត្រូវធ្វើជាស្តេច ។ សព្វថ្ងៃនេះ ជីវិតគ្រិស្ទានរបស់យើង គួរតែជាជីវិតក្នុងភាពជាស្តេច និងជាជីវិតដែលសោយរាជ្យ ។

**VIII. យើងនឹងមានភាពជាស្តេចជារួមគ្នា និងទទួលសេចក្តីអំណរបំផុតនៃជីវិតព្រះជាមួយទ្រង់ នៅក្នុងនគរមួយពាន់ឆ្នាំ—២០:៤, ៦ ។**

**IX. ថ្ងៃនេះនគរព្រះជាការហ្វឹកហ្វឺនដល់ខ្ញុំ / តែពេលព្រះគ្រិស្តសោយរាជ្យនឹងក្លាយជារង្វាន់ធំ / ដើម្បីបំពេញសម្រេចផែនការរបស់ព្រះអង្គ / ដើម្បីបំពេញសម្រេចផែនការរបស់ព្រះអង្គ ។ យើងបានកើតជាថ្មីជាស្តេចនិងជាកូនព្រះ / ទើបត្រូវហ្វឹកហ្វឺនឱ្យក្លាយជាអ្នកមានជ័យជម្នះ / ឱ្យដឹងពីការគ្រប់គ្រងជាស្តេចក្នុងនគរព្រះ / អំណាចជាស្តេចត្រូវបានសម្តែងដោយឫទ្ធិតេជះ—(ចម្រៀងខ្មែរលេខ ៧៥១ បទអង់គ្លេសលេខ ៩៤៧) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៧ ផែនការគ្រប់គ្រងរបស់ព្រះ

## វាក្យសព្ទទី៧១ ការយាងមកជាលើកទីពីររបស់ព្រះគ្រិស្ត

**ដកស្រង់ពី :**

កិច្ចការ ១:១១ខ ព្រះយេស៊ូនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នា ឡើងទៅលើឋានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែលដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ ។

ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ គឺជាប់ទាក់ទងនឹងទិដ្ឋភាពពីរ ។ មានតែពួកអ្នកជឿដែលមានជ័យជម្នះប៉ុណ្ណោះ ដែលនឹងរួមមានចំណែកនៅក្នុងទិដ្ឋភាពលាក់កំបាំង ។ ពិភពលោកនឹងមើលឃើញទិដ្ឋភាពបើកចំហ ។ ប្រសិនបើ យើងចង់រួមមានចំណែកនៅក្នុងទិដ្ឋភាពលាក់កំបាំងនៃការយាងមកជាលើកទី២របស់ព្រះអម្ចាស់ យើងត្រូវតែក្លាយជាអ្នកមានជ័យជម្នះ ដែលចាំយាម និងត្រៀមខ្លួនរួចជាស្រេច សម្រាប់ការយាងមករបស់ព្រះអម្ចាស់ ។

**ខ្លឹមសារ :**

កិច្ចការ ១:១១ខ ព្រះយេស៊ូនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នា ឡើងទៅលើឋានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែលដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ ។

វិវរណៈ ១:៧ក មើល ទ្រង់យាងមកតាមពពក នោះគ្រប់ទាំងភ្នែកនឹងឃើញទ្រង់ ។

៣:៣ខ បើឯងមិនចាំយាមទេ នោះអញនឹងមកឯឯងដូចជាចោរ ហើយឯងនឹងមិនដឹងជាវេលាណា ដែលអញមកឯឯងឡើយ ។

I. "ព្រះយេស៊ូនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នា ឡើងទៅលើឋានសួគ៌ ទ្រង់នឹងយាងមកវិញ តាមបែបដដែលដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ"—កិច្ចការ ១:១១ខ :
   A. ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ នឹងក្លាយជាការយាងមកដ៏ពិតប្រាកដ ហើយនឹងក្លាយជាពិតដូចការយាងឡើងរបស់ទ្រង់ ។

B. ទ្រង់នឹងយាងមកវិញតាមបែបដដែល ដូចជាទ្រង់បានយាងឡើងទៅឋានសួគ៌នោះដែរ ។ ទ្រង់បានយាងទៅឋានសួគ៌នៅក្នុងពពក ហើយទ្រង់នឹងយាងមកវិញលើពពក ។

II. **ការយាងត្រឡប់មកវិញរបស់ព្រះគ្រិស្ត មានទិដ្ឋភាពអាថ៌កំបាំង និងទិដ្ឋភាពបើកចំហ—វិវរណៈ ៣:៣; ១:៧ :**

A. នៅក្នុងទិដ្ឋភាពអាថ៌កំបាំងនៃការយាងត្រឡប់មកវិញរបស់ទ្រង់ ព្រះគ្រិស្តនឹងមកដូចជាចោរដល់អស់អ្នកដែលស្រឡាញ់ទ្រង់ ហើយនឹងដកយកពួកគេទុកជាទ្រព្យវិសេសរបស់ទ្រង់ ។ ការយាងមកដ៏អាថ៌កំបាំងរបស់ព្រះគ្រិស្ត នឹងក្លាយជារង្វាន់ដល់ពួកអ្នកជឿដែលកំពុងតែចាំយាម—២:២៨; ម៉ាថាយ ២៤:៤២-៤៤ ។

B. នៅក្នុងទិដ្ឋភាពបើកចំហនៃការត្រឡប់មកវិញរបស់ទ្រង់ ព្រះគ្រិស្តនឹងយាងមកដោយអំណាច និងសិរីរុងរឿងដ៏អស្ចារ្យ ដើម្បីឱ្យគ្រប់អម្បូរនៃទឹកដីទាំងអស់បានមើលឃើញ ។ នៅវេលានៃទិដ្ឋភាពបើកចំហនេះ នឹងក្លាយជាត្រែចុងក្រោយ គឺនៅចុងបញ្ចប់នៃគ្រាទុក្ខវេទនាដ៏ធំ—វិវរណៈ ១៨:១; ១:៧ ។

III. **អាកប្បកិរិយារបស់ពួកអ្នកជឿចំពោះការយាងមករបស់ព្រះគ្រិស្ត —២ធីម៉ូថេ ៤:៨ :**

A. នៅប៉ុន្មានថ្ងៃទៀតដែលសេសសល់នៅ យើងគួរតែត្រៀមខ្លួនរួចជាស្រេច ។ សូមឱ្យយើងក្លាយជាពួកអ្នកដែលស្រឡាញ់ និងបម្រើព្រះអម្ចាស់ ដែលបានរស់ឡើង និងកំពុងតែមានជ័យជម្នះរាល់ថ្ងៃ ហើយនិងអ្នកដែលអនុញ្ញាតឱ្យពិភពលោកនេះកន្លងទៅ ហើយកំពុងរង់ចាំដោយអស់ពីចិត្ត ចំពោះការយាងមករបស់ព្រះអម្ចាស់—ខ៨ ។

B. ដូច្នេះ ដរាបណាយើងមាននៅថ្ងៃនេះ ដរាបណាយើងនៅតែមានដង្ហើម យើងគួរតែស្រឡាញ់ព្រះអម្ចាស់ និងការលេចមករបស់ទ្រង់ ដោយរង់ចាំការយាងមករបស់ព្រះអម្ចាស់ ហើយនិងតែងតែយកការយាងមករបស់ទ្រង់ ធ្វើជាការលើកទឹកចិត្ត—ភីលីព ៣:២០ ។

IV. **"ព្រះគ្រិស្តនឹងយាងមកឱ្យបាវបានរង្វាន់ បម្រើស្រឡាញ់ទ្រង់បានមកុដនោះ ក្រោកឡើងៗយើងកុំអាល័យលោកា បម្រើព្រះបុត្រាស្មោះអស់ពីចិត្ត"—(បទចម្រៀងខ្មែរលេខ ៧៥៥,អង់គ្លេសលេខ៩៥៦) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្តីបើកសម្តែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី៧២ ព្រះបានក្លាយជាមនុស្ស ដើម្បីឱ្យមនុស្សអាចក្លាយជាព្រះ

**ដកស្រង់ពី :**

រ៉ូម ៨:៣០ ឯពួកអ្នកដែលទ្រង់បានតម្រូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ក៏រាប់ទុកជាសុចរិត ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានតម្កើងឡើងដែរ ។

"ព្រះបានក្លាយជាមនុស្ស ដើម្បីឱ្យមនុស្សអាចក្លាយជាព្រះ" គឺជាធាតុដើមរបស់ព្រះគម្ពីរទាំងមូល ។ ព្រះបានក្លាយជាមនុស្សតាមរយៈការក្លាយជាសាច់ឈាម រីឯមនុស្សក្លាយជាព្រះតាមរយៈការផ្លាស់ប្រែ ។

**ខ្លឹមសារ :**

យ៉ូហាន ១២:២៤ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង ។

រ៉ូម ៨:២៩-៣០ ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឱ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន ។ ឯពួកអ្នកដែលទ្រង់បានតម្រូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ក៏រាប់ទុកជាសុចរិត ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានតម្កើងឡើងដែរ ។

**I. ក្នុងនាមជាគ្រាប់ស្រូវសាលីមួយគ្រាប់ដែលធ្លាក់ចុះទៅដីហើយងាប់ និងក្រោយមក ដុះឡើងដើម្បីបង្កើតផលជាច្រើន ព្រះអម្ចាស់បានយាងមក ដើម្បីឱ្យបានចម្រើនផលផ្លែជាច្រើនទ្វេឡើង ។**

II. **ព្រះជាម្ចាស់ក្លាយជាមនុស្ស ដោយឆ្លងកាត់ការបង្កបង្កើតមនុស្ស ហើយការយាងមករបស់ព្រះអង្គផ្ទាល់ គឺដើម្បីក្លាយជាមនុស្សនោះឯង—លោកុប្បត្តិ ១:២៦, យ៉ូហាន ១:១៤:**

A. ចំពោះព្រះ ដើម្បីក្លាយជាមនុស្ស ទ្រង់ត្រូវតែបង្កើតមនុស្សជាមុនសិន ។ ព្រះជាម្ចាស់បានបង្កើតមនុស្សតាមរូបនិងភាពដូចរបស់ទ្រង់ ។ នេះគឺជាសំបក ។

B. នៅដំណាក់កាលបន្ទាប់ ព្រះទ្រង់ផ្ទាល់បានយាងមកដើម្បីបានក្លាយជាមនុស្ស ។ ព្រះអម្ចាស់ បានដំណើរជីវិតរស់ និងធ្វើការនៅលើផែនដីអស់រយៈពេលសាមសិបបីឆ្នាំកន្លះ ហើយចុងក្រោយ ទ្រង់បានសុគតនៅលើឈើឆ្កាង ដើម្បីបំពេញសម្រេចការប្រោសលោះ ។ បន្ទាប់មក ទ្រង់បានរស់ពីការសុគតឡើងវិញ ដើម្បីក្លាយជាព្រះវិញ្ញាណផ្តល់ជីវិត ។ នេះគឺអង្គដែលបានឆ្លងកាត់ដំណើរការទាំងអស់នេះដើម្បីបំពេញសម្រេចដំណាក់កាល សម្រាប់ឱ្យទ្រង់ក្លាយជាមនុស្សប្រយោជន៍ឱ្យទ្រង់អាចធ្វើឱ្យមនុស្សក្លាយជាព្រះ ។

III. មនុស្សក្លាយជាព្រះ ដោយឆ្លងកាត់ការកើតជាថ្មី ការញែកជាបរិសុទ្ធ ការកែជាថ្មី ការផ្លាស់ប្រែ ការថតចម្លង និងការទទួលសិរីល្អ—រ៉ូម ៨:២៩-៣០ :

A. ព្រះបានក្លាយជាមនុស្សតាមរយៈការក្លាយជាសាច់ឈាម រីឯមនុស្សក្លាយជាព្រះតាមរយៈការផ្លាស់ប្រែ ។

B. ការទទួលសិរីល្អ គឺជាលទ្ធផលនៃការផ្លាស់ប្រែ ។ ព្រះគ្រិស្តត្រូវបានព្រោះចូលទៅក្នុងយើងដូចជាគ្រាប់ពូជនៃសិរីល្អ ហើយគ្រាប់ពូជនេះនឹងលូតលាស់រហូតដល់វាឈានដល់ដំណាក់កាលចេញផ្កា នៅពេលនោះហើយដែលសិរីល្អនឹងលេចចេញមក ។

IV. ព្រះអង្គទ្រង់កើតមកជាមនុស្ស ពាក់ជីវិតនិស្ស័យមនុស្ស / ដើម្បីឱ្យមនុស្សក្លាយជាព្រះ នេះជារឿងដែលខ្ញុំប្រាថ្នា / ដើម្បីផែនការគ្រប់គ្រងអស់កល្ប របស់ទ្រង់នឹងបានសម្រេច / ព្រះអង្គបានជ្រើសរើស និងចែកចាយ រូបអង្គទ្រង់ចូលក្នុងខ្លួនខ្ញុំ / យើងត្រូវបានបង្កើត ពីព្រះអង្គក្លាយជាកូនព្រះអង្គ / ដូចព្រះអង្គក្នុងជីវិតនិស្ស័យ តែមិនមានឋានៈដូចទ្រង់ / ជាក្រុមជនសម្តែង ឱ្យព្រះអង្គលេចមកក្នុងសាច់ឈាម / ជាដំណាក់នៃព្រះអង្គដ៏រស់ និងជាកូនក្រមុំព្រះអង្គ / ព្រះអង្គទ្រង់ក្លាយជាមនុស្ស ដោយមានព្រះហឫទ័យ / ឱ្យមនុស្សបានក្លាយជាព្រះនៅក្នុងជីវិត និស្ស័យតែមិនមាន / នៅក្នុងឋានៈរបស់ទ្រង់ សូមសម្រេចគោលដៅនេះក្នុងខ្លួនខ្ញុំ—**(បទជាភាសាខ្មែរនៅទំព័រលេខ ៤៧២, New Song #១៥១)** ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្តីបើកសម្តែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី ៧៣ ព័ន្ធកិច្ចដ៏ពេញលេញរបស់ព្រះគ្រិស្តនៅក្នុងបីដំណាក់កាល

**ដកស្រង់ពី :**

វិវរណៈ ៥:៦ មានទាំងស្នែង ៧ និង ភ្នែក ៧ ...គឺជាព្រះវិញ្ញាណទាំងប្រាំពីររបស់ព្រះ ដែលទ្រង់ចាត់ទៅពេញលើផែនដី ។

ព័ន្ធកិច្ចដ៏ពេញលេញរបស់ព្រះគ្រិស្ត គឺរួមបញ្ចូលគ្រប់ការទាំងអស់ដែលព្រះគ្រិស្តបានបំពេញសម្រេច ។ បីដំណាក់កាលរបស់ព្រះគ្រិស្ត គឺដំណាក់កាលនៃការក្លាយជាសាច់ឈាម ដំណាក់កាលនៃការរួមបញ្ចូល ដំណាក់កាលនៃការចម្រើនកម្លាំង ។ បច្ចុប្បន្នព្រះវិញ្ញាណទាំងប្រាំពីរ គឺកំពុងឆេះ យើងត្រូវទទួលស្វាគមន៍ឱ្យទ្រង់បន្សុទ្ធ វិនិច្ឆ័យ និងជម្រះយើង ។

**ខ្លឹមសារ :**

យ៉ូហាន ១:១៤ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នាយើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែមួយដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត ។

១កូរិនថូស ១៥:៤៥ អ័ដាមក្រោយបង្អស់ក្លាយជាព្រះវិញ្ញាណផ្តល់ជីវិត ។

វិវរណៈ ៥:៦ ខ្ញុំក្រឡេកទៅឃើញមានកូនចៀមមួយ ដែលមើលទៅដូចជាបានសម្លាប់ហើយ មានទាំងស្នែងប្រាំពីរ និង ភ្នែកប្រាំពីរ កំពុងតែឈរនៅកណ្តាលបល្ល័ង្ក និងតួមានជីវិតទាំងបួន ហើយនៅកណ្តាលពួកចាស់ទុំទាំងប៉ុន្មាន ឯភ្នែកទាំងនោះ គឺជាព្រះវិញ្ញាណទាំងប្រាំពីររបស់ព្រះ ដែលទ្រង់ចាត់ទៅពេញលើផែនដី ។

I. **ព័ន្ធកិច្ចដ៏ពេញលេញរបស់ព្រះគ្រិស្ត គឺរួមបញ្ចូលគ្រប់ការទាំងអស់ដែលទ្រង់បានបំពេញសម្រេច—ហេព្រើរ ២:១៤; យ៉ូហាន ២០:២២; វិវរណៈ ៤:៥ ។**

II. **បីដំណាក់កាលរបស់ព្រះគ្រិស្ត—យ៉ូហាន ១:១៤; ១កូរិនថូស ១៥:៤៥; វិវរណៈ ៥:៦ :**

A. ដំណាក់កាលនៃការក្លាយជាសាច់ឈាម គឺព្រះគ្រិស្តបានក្លាយជាមនុស្ស ហើយរស់នៅផែនដីអស់សាមសិបបីឆ្នាំកន្លះ បន្ទាប់មកទ្រង់បានសុគតនៅលើឈើឆ្កាង ហើយការសុគតនៅលើជាប់ឆ្កាង បានបញ្ចប់ដំណាក់កាលនៃការក្លាយជាសាច់ឈាមរបស់ទ្រង់—យ៉ូហាន ១:១៤ ។

B. ដំណាក់កាលនៃការរួមបញ្ចូល គឺនៅបន្ទាប់ពីការសុគត រស់ឡើងវិញចូលទៅក្នុងដំណាក់កាលនៃការរួមបញ្ចូល ។ នៅក្នុងដំណាក់កាលនេះ ព្រះគ្រិស្ត គឺជាព្រះវិញ្ញាណរួមបញ្ចូលគ្រប់ទាំងអស់—១កូរិនថូស ១៥:៤៥ ។

C. ដំណាក់កាលនៃការចម្រើនកម្លាំង គឺព្រះគ្រិស្តបានក្លាយជាព្រះវិញ្ញាណចម្រើនកម្លាំងទាំងប្រាំពីរដង ដើម្បីចម្រើនកម្លាំងសេចក្តីសង្គ្រោះផ្នែកជីវិតរបស់ទ្រង់ និង ដើម្បីបង្កើតពួកអ្នកមានជ័យជម្នះ សម្រាប់ការសម្រេចចុងក្រោយនៃក្រុងយេរូសាឡិមថ្មី—វិវរណៈ ៥:៦ ។

III. **បច្ចុប្បន្ននេះ គឺជាគ្រានៃព្រះវិញ្ញាណទាំងប្រាំពីរ ហើយព្រះវិញ្ញាណទាំងប្រាំពីរកំពុងតែឆេះ ដើម្បីវិនិច្ឆ័យ ជម្រះ និង បន្សុទ្ធ ដោយមានគោលបំណង—៤:៥ :**

A. យើងរឹតតែឱ្យព្រះវិញ្ញាណជម្រះនិងបន្សុទ្ធយើងយ៉ាងណា ទ្រង់រឹតតែចាំងពន្លឺតាមរយៈយើង ហើយពន្លឺនេះ គឺជាសេចក្តីបន្ទាល់របស់ក្រុមជំនុំ ។

B. ហេតុដូច្នេះហើយ យើងត្រូវបើកខ្លួនរបស់យើងទទួលស្វាគមន៍ទ្រង់ ឱ្យទ្រង់បន្សុទ្ធ វិនិច្ឆ័យ កម្ចាត់ និង ជម្រះយើងរៀងរាល់ថ្ងៃ ។

IV. **ថ្ងៃនេះវិញ្ញាណរបស់ព្រះ ជាវិញ្ញាណព្រះយេស៊ូគ្រិស្ត ទ្រង់សុគតហើយរស់ឡើងវិញយាងទៅគង់នៅឋានឧត្តម—(បទចម្រៀងខ្មែរលេខ ១៩៦, អង់គ្លេស ២៤២) ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្តីបើកសម្តែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី៧៤ ការដំណើរជីវិតជាមនុស្សព្រះ

**ដកស្រង់ពី:**

យ៉ូហាន ១២:២៤ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង ។

ព្រះយេស៊ូ គឺជាពុម្ពគំរូមនុស្ស-ព្រះ ជាគំរូដើមសម្រាប់បង្កើតមនុស្ស-ព្រះជាច្រើន ។ ក្នុងនាមជាមនុស្ស-ព្រះ ការដំណើរជីវិតរបស់យើង ត្រូវតែសក្តិសមនឹងឋានៈជាមនុស្ស-ព្រះរបស់យើង ។

**ខ្លឹមសារ:**

យ៉ូហាន ១២:២៤ ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង ។

១:១២ ប៉ុន្តែ អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឱ្យបានត្រឡប់ជាកូនព្រះ ។

កាឡាទី ២:២០ក ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រិស្ត ប៉ុន្តែ ខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រិស្តទ្រង់រស់ក្នុងខ្ញុំវិញ ។

**I. ព្រះគ្រិស្ត គឺជាមនុស្ស-ព្រះដំបូងគេ ។ ទ្រង់ក៏ជាពុម្ពគំរូមនុស្ស-ព្រះ ជាគំរូដើមសម្រាប់បង្កើតមនុស្ស-ព្រះជាច្រើនផងដែរ—យ៉ូហាន ១២:២៤ ។**

**II. យើងដែលជាពួកអ្នកជឿក្នុងព្រះគ្រិស្ត យើងបានកើតពីព្រះ ដើម្បីក្លាយជាកូនជាច្រើនរបស់ទ្រង់ ។ ក្នុងនាមជាកូនៗរបស់ព្រះ ប្រាកដណាស់យើងគឺជាមនុស្ស-ព្រះ—១:១២-១៣:**

A. មិនខ្វល់ថាយើងមានសញ្ជាតិអ្វី និងមិនថាយើងជាប្រុសឬស្រី ក្មេង ឬចាស់ក៏ដោយ យើងទាំងអស់គ្នាត្រូវតែជឿថា យើងជាមនុស្ស-ព្រះ ។
B. នៅពេលដែលយើងដឹងថា យើងគឺជាមនុស្ស-ព្រះ យើងនឹងនិយាយថា "ព្រះ អម្ចាស់អើយ ទ្រង់គឺជាមនុស្ស-ព្រះដំបូងគេ ហើយយើងគឺជាមនុស្ស-ព្រះជាច្រើននៅបន្ទាប់ពីទ្រង់" ។

**III. ក្នុងនាមជាមនុស្ស-ព្រះ ការដំណើរជីវិតរបស់យើង ត្រូវតែសក្តិសមនឹងឋានៈជាមនុស្ស-ព្រះរបស់យើង—កូល៉ុស ១:១០; កាឡាទី ២:២០:**

A. យើងត្រូវតែរៀនពីរបៀបរស់នៅ ដោយការលាយបញ្ចូលជីវិតរបស់ព្រះជាមួយនឹងជីវិតមនុស្សរបស់យើង ដើម្បីធ្វើឱ្យយើងក្លាយជាព្រះ ។ ការនេះមិនគ្រាន់តែធ្វើឱ្យយើងក្លាយជាគ្រិស្ទានប៉ុណ្ណោះទេ ប៉ុន្តែជាមនុស្ស-ព្រះ ជាប្រភេទតែមួយនឹងព្រះ—ខ២០ ។
B. ក្នុងនាមជាមនុស្ស-ព្រះ យើងត្រូវការរស់ជាជីវិតមួយ ដែលមិនរស់ដោយខ្លួនឯង ប៉ុន្តែរស់ដោយជីវិតរបស់ទ្រង់ មិនរស់សម្តែងចេញខ្លួនឯង ប៉ុន្តែរស់សម្តែងចេញគុណលក្ខណៈរបស់ទ្រង់ ដែលក្លាយជាគុណធម៌របស់មនុស្សយើង ។

**IV. "មិនមែនខ្លួនខ្ញុំរស់តែម្នាក់ឯង ព្រះអង្គនិងខ្ញុំរស់ជាមួយគ្នា ជាក្រុមជនដែលសម្តែងព្រះអង្គ សង់ផ្ទះត្រើឯកផ្នែកសកលលោក ក្លាយជារូបកាយដ៏មានជីវិត សម្តែងព្រះអង្គជាក្រុមជនពិត ក្លាយជារូបកាយដ៏មានជីវិត សម្តែងព្រះអង្គជាក្រុមជនពិត។"—(បទចម្រៀងខ្មែរទំព័រ៤៤០,អង់គ្លេសលេខ១៣៤៩) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្តីបើកសម្តែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី៧៥ ពួកអ្នកមានជ័យជម្នះ

**ដកស្រង់ពី :**

វិវរណៈ ១២:១១ គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តី បន្ទាល់របស់គេ ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់ ។

អស់អ្នកប្រក្រតីក្នុងកំឡុងពេលដែលមិនប្រក្រតី គឺជាពួកអ្នកមានជ័យជម្នះ ។ គេបានឈ្នះវា (១) ដោយសារឈាមនៃកូនចៀម (២) ដោយសារសេចក្តីបន្ទាល់របស់គេ ។ ពួកអ្នកមានជ័យជម្នះ ត្រូវតែប្រកាសនូវជ័យជម្នះរបស់ព្រះគ្រិស្តជារឿយៗ ។

ខ្លឹមសារ:

វិវរណៈ ២:២៦ ឯអ្នកណាដែលឈ្នះ ហើយកាន់តាមការអញ ដរាបដល់ចុងបំផុត នោះអញនឹង ឱ្យមានអំណាចលើពួកសាសន៍ដទៃ ។

១២:១១ គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តីបន្ទាល់របស់គេ ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់ ។

I. ដោយសារតែការធ្លាក់ចុះរបស់ក្រុមជំនុំ ព្រះអម្ចាស់បានយាងមក ដើម្បីត្រាស់ហៅពួកអ្នកមានជ័យជម្នះជំនួសឱ្យក្រុមជំនុំ នៅក្នុងការបំពេញសម្រេចផែនការគ្រប់គ្រងរបស់ព្រះ—វិវរណៈ ២:២៦:

A. ពួកអ្នកមានជ័យជម្នះ គឺ ធម្មតា សាមញ្ញ ដ្បិតពួកអ្នកដែលប្រក្រតីក្នុងអំឡុងពេលដែលមិនប្រក្រតី គឺជាពួកអ្នកមានជ័យជម្នះ ។

B. មានតែមនុស្សមួយក្រុមប៉ុណ្ណោះ ដែលបានចាកចេញទៅ ដើម្បីធ្វើការងារសម្រាប់ក្រុមជំនុំ និងទទួលយកទំនួលខុសត្រូវរបស់ក្រុមជំនុំ ។ ក្រុមនេះហើយ គឺជាពួកអ្នកមានជ័យជម្នះ ។

II. **"គេបានឈ្នះវា ដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្ដីបន្ទាល់របស់គេ ក៏មិនបានស្ដាយជីវិតខ្លួនដរាបដល់ស្លាប់"—១២:១១ :**

A. គេបានឈ្នះវា (១) ដោយសារឈាមនៃកូនចៀម (២) ដោយសារសេចក្ដីបន្ទាល់របស់គេ—១២:១១ ។

B. ឈាម គឺជាមូលដ្ឋាននៃជ័យជម្នះ និងជាឧបករណ៍ដើម្បីយកឈ្នះសាតាំង ។ សាតាំងអាចចោទប្រកាន់យើង ប៉ុន្តែយើងអាចឆ្លើយតបថា ព្រះលោហិតនៃព្រះយេស៊ូគ្រិស្ដជាព្រះរាជបុត្រានៃព្រះ សម្អាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់—១យ៉ូហាន ១:៧ ។

C. សេចក្ដីបន្ទាល់ គឺជាអ្វីដែលត្រូវបាននិយាយចេញ រីឯពួកអ្នកមានជ័យជម្នះ ត្រូវតែប្រកាសនូវជ័យជម្នះរបស់ព្រះគ្រិស្ដជារឿយៗ ដ្បិតសាតាំងខ្លាចខ្លាំងបំផុតនៅពេលដែលហេតុការណ៍នេះកើតឡើងម្ដងហើយម្ដងទៀត ។

III. **"អ្នកចង់ក្លាយជាអ្នកឈ្នះឬទេ / ព្រះគ្រិស្ដត្រាស់ហៅអ្នក / ត្រូវដើរតាមទ្រង់ឥតពេលទំនេរ / លំបាកក៏មិនរវេ / អ្នកចង់ក្លាយជាអ្នកឈ្នះឬទេ / ឱ្យទ្រង់សព្វព្រះទ័យ / ព្រះគ្រិស្ដត្រាស់ហៅអ្នកមកជាថ្មី / ឱ្យបានមកុដសិរី"—(បទចម្រៀងខ្មែរលេខ ៦៤៧, អង់គ្លេសលេខ ៨៩៤) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្ដីបើកសម្ដែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី ៧៦ សភាពពិតនៃរូបកាយព្រះគ្រិស្ដ

**ដកស្រង់ពី:**

យ៉ូហាន ១៦:១៣ក កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្ដីពិត បានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នា ចូលក្នុងគ្រប់ទាំងសេចក្ដីពិត។

សភាពពិតនៃរូបកាយព្រះគ្រិស្ដ គឺជាប្រភេទការរស់នៅជាក្រុមជន ។ ការរស់នៅជាក្រុមជននេះ គឺជាការប្រមូលផ្ដុំគ្នានៃពួកបរិសុទ្ធ ដែលជាមនុស្សដ៏ជាក់លាក់ ប៉ុន្តែពួកគេមិនរស់នៅតាមជីវិតរបស់ខ្លួនឯងនោះទេ តែរស់ដោយជីវិតរបស់ព្រះដែលបានឆ្លងកាត់ដំណាក់កាល ។

**ខ្លឹមសារ:**

យ៉ូហាន ១៦:១៣ក កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្ដីពិត បានមកដល់នោះទ្រង់នឹងនាំអ្នករាល់គ្នា ចូលក្នុងគ្រប់ទាំងសេចក្ដីពិត ។

កាឡាទី ២:២០ក ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រិស្ដ ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រិស្ដទ្រង់រស់ក្នុងខ្ញុំវិញ ។

ភីលីព ៣:១០ ដើម្បីឱ្យខ្ញុំស្គាល់ទ្រង់ និង ព្រះចេស្ដានៃដំណើរ ដែលទ្រង់រស់ឡើងវិញ ហើយនិងសេចក្ដីប្រកប ក្នុងការរងទុក្ខរបស់ទ្រង់ ព្រមទាំងត្រឡប់ ទៅដូចជាទ្រង់ក្នុងសេចក្ដីស្លាប់ផង ។

I. **សភាពពិតនៃរូបកាយព្រះគ្រិស្ដ គឺជាការរស់នៅជាក្រុមជន តាមរយៈមនុស្សព្រះដែលឥតខ្ចោះ—យ៉ូហាន ១៦:១៣, កាឡាទី ២:២០:**
   A. អ្នកដែលជាមនុស្សដ៏ជាក់លាក់ គឺមិនរស់នៅតាមជីវិតរបស់ខ្លួនឯងឡើយ តែរស់តាមជីវិតរបស់ព្រះដែលបានឆ្លងកាត់ដំណាក់កាល ដែលគ្រប់គុណលក្ខណៈរបស់ទ្រង់ត្រូវបានសម្ដែងចេញតាមរយៈគុណធម៌របស់ពួកគេ ។
   B. ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រិស្ដ ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រិស្ដទ្រង់រស់ក្នុងខ្ញុំវិញ—ខ២០ ។

II. **សភាពពិតនៃរូបកាយព្រះគ្រិស្ត គឺជាការរស់នៅជាក្រុមជននៃការត្រឡប់ទៅដូចជាព្រះគ្រិស្តក្នុងសេចក្ដីស្លាប់ តាមរយៈព្រះចេស្ដានៃដំណើរដែលព្រះគ្រិស្តរស់ឡើងវិញ—ភីលីព ៣:១០ :**

A. ប៉ុល បានរស់នៅក្នុងជីវិតដែលត្រឡប់ទៅដូចជាព្រះគ្រិស្តក្នុងសេចក្ដីស្លាប់ ។ ជីវិតចាស់របស់គាត់ បានត្រឡប់ដូចជារូបភាពរបស់ព្រះគ្រិស្តក្នុងសេចក្ដីស្លាប់ តាមរយៈព្រះចេស្ដាដែលព្រះគ្រិស្តរស់ឡើងវិញ ។ ព្រះចេស្ដានៃការរស់ឡើងវិញបានចម្រើនកម្លាំងគាត់ឱ្យរស់នៅដោយជីវិតមនុស្សព្រះ ។

B. ខ្លួនយើងបានជាប់ឆ្កាង គឺមិនមែនដោយជីវិតធម្មជាតិ ឬ កម្លាំងធម្មជាតិ ប៉ុន្តែដោយព្រះចេស្ដានៃដំណើរដែលព្រះគ្រិស្តរស់ឡើងវិញ ។

III. **នៅពេលដែលយើងរស់នៅក្នុងវិញ្ញាណដែលបានលាយបញ្ចូល យើងនឹងអាចរស់សម្ដែងចេញរូបកាយព្រះគ្រិស្ត និងក្លាយជាការសម្ដែងចេញជាក្រុមជនរបស់ទ្រង់—១កូរិនថូស ៦:១៧ ។**

IV. “សូមកុំទុកឱ្យខ្ញុំឯកា_នាំខ្ញុំកសាងជាមួយគ្នា_ គ្រប់យ៉ាងសូមតាមគម្រោងការ_ប្រកបរួមគ្នាយ៉ាងរឹងមាំ_ក្នុងបទពិសោធន៍ផ្នែកវិញ្ញាណ_មិនអំនួតព្រោះអំណោយទាន_គ្រប់យ៉ាងមានដើម្បីកសាង_សម្ដែងសិរីទ្រង់ច្រើនឡើង”—( បទចម្រៀង ៦០៤,អង់គ្លេស ៨៣៩ ) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៨ សេចក្ដីបើកសម្ដែងព្រះដ៏ខ្ពង់ខ្ពស់

## វាក្យសព្ទទី ៧៧ យេរូសាឡិមថ្មី

**ដកស្រង់ពី:**

វិវរណៈ ២១:២ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីឋាន សួគ៌មកអំពីព្រះ គាត់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី ។

យេរូសាឡិមថ្មី មិនមែនជាទីក្រុងខាងផ្នែកសម្ភារៈនោះទេ តែជាគូស្វាមីភរិយានៅក្នុងសកលលោក ។ ការបំពេញសម្រេចនៃសេចក្ដីសង្គ្រោះផ្នែកជីវិតរបស់ព្រះ គឺជាយេរូសាឡិមថ្មី ។ យើងត្រូវការបានសង្គ្រោះខាងផ្នែកជីវិត ដើម្បីក្លាយជាយេរូសាឡិមថ្មី ។

**ខ្លឹមសារ :**

វិវរណៈ ២១:២ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីឋាន សួគ៌មកអំពីព្រះ គាត់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី ។

៩ ខ្ញុំនឹងបង្ហាញឱ្យអ្នកឃើញប្រពន្ធថ្មោងថ្មី ជាភរិយារបស់កូនចៀម ។

២២:១៧ ព្រះវិញ្ញាណ នឹងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលឮ ក៏ថា អញ្ជើញមកដែរ អ្នកណាដែលស្រេក នោះមានតែមក ។

I. **ក្រុងយេរូសាឡិមថ្មី មិនមែនជាទីក្រុងខាងផ្នែកសម្ភារនោះទេ—វិវរណៈ ២១:២:**

A. សៀវភៅវិវរណៈ គឺជាសៀវភៅនៃទីសម្គាល់ ។ គ្រប់លេខទាំងអស់នៅក្នុងសៀវភៅវិវរណៈ គឺជាទីសម្គាល់ ។ ជើងចង្កៀង គឺជាទីសម្គាល់ ។ កូនចៀមដែលត្រូវបានសម្លាប់ គឺជាទីសម្គាល់ ។

B. ក្រុងយេរូសាឡិមថ្មី ដែលជាទីក្រុងបរិសុទ្ធ គឺមាន ២៤០០គីឡូម៉ែត ក្នុង៣ខ្នាត ដែលមានចម្ងាយប្រហែល១៣៥០ ម៉ាយល៍ ។ ប្រសិនបើក្រុងយេរូសាឡិមថ្មីនេះ គឺជាទី

ក្រុងពិតដើម្បីស្នាក់នៅមែន តើគ្រប់ទាំងអស់ដែលព្រះបានប្រោសលោះទូទាំងគ្រប់សតវត្សរ៍ នឹងអាចស្នាក់នៅក្នុងទីក្រុងមួយ ដែលមានត្រឹមតែផ្លូវរង់រាងគូថខ្យងធំមួយនេះបានដោយរបៀបណាទៅ?

II. **យេរូសាឡិមថ្មី គឺជាគូស្វាមីភរិយានៅក្នុងសកលលោក ជា "គូស្នេហ៍មួយគូដ៏អស់កល្បជានិច្ច" ដែលជាការបំពេញសម្រេចនៃក្តីស្នេហ៍ដ៏ស័ក្តិសិទ្ធិ(ស្នេហារបស់ព្រះ)—២២:១៧:**

A. វិវរណៈ ២១:២ ប្រាប់យើងថា ក្រុងយេរូសាឡិមថ្មី ត្រូវបានតាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្តី ។

B. ២១:១៧ ប្រាប់យើងថា ព្រះគ្រិស្ត និងភរិយារបស់ទ្រង់នឹងរួមគ្នាក្លាយជាក្រុងយេរូ-សាឡិមថ្មី សម្រាប់ការសម្តែងចេញរបស់ព្រះ ។

III. **យើងត្រូវបានសង្គ្រោះខាងផ្នែកជីវិត ដើម្បីក្លាយជាក្រុងយេរូសាឡិមថ្មី—២១:២:**

A. យើងត្រូវបានញែកចេញជាបរិសុទ្ធ ដោយការរួមចំណែកនៅក្នុងនិស្ស័យរបស់ព្រះ ដើម្បីក្លាយជាបរិសុទ្ធ ឱ្យដូចជាទីក្រុងបរិសុទ្ធ ។

B. យើងត្រូវបានកែជាថ្មីដោយការរួមចំណែកនៅក្នុងគំនិតរបស់ព្រះ ដើម្បីក្លាយជាភាពស្រស់ថ្មី ឱ្យដូចជាក្រុងយេរូសាឡិមថ្មី ។

C. យើងត្រូវបានតម្កើងឡើងដោយការរួមចំណែកនៅក្នុងសិរីល្អរបស់ព្រះ ដើម្បីបានជ្រាបចូលទាំងស្រុងដោយសិរីល្អនៃក្រុងយេរូសាឡិមថ្មី—រ៉ូម ៨:២១ ។

IV. **ព្រះអង្គត្រាស់ហៅយើងនៅទីនេះ ដើម្បីផែនការអស់កល្បនៃព្រះ / នេះជាគោលដៅនៃជីវិតយើង គឺជាដែននៃជីវិតយើង/ ព្រះត្រឹឯកទ្រង់ក្លាយមកជាមនុស្ស ដើម្បីមនុស្សផ្លាស់ប្រែក្លាយជាព្រះ/ ជាប់ឆ្កាងរស់ឡើងជាព្រះវិញ្ញាណ នៅក្នុងវិញ្ញាណជាចំណែកយើង / *និមិត្តផែនការអស់កល្បរបស់ព្រះ កំណត់ទិសដៅគ្រប់ផ្នែករបស់យើង បំភ្លឺ យើង និងវិញ្ញាណយើងភ្លឺថាំង រឹងមាំឡើង ចម្លងដូចរូបភាពរបស់ព្រះគ្រិស្ត ជាស្តេចនៅក្នុងជីវិត យេរូសាឡិមថ្មី ហាលេលូយ៉ា ។***

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទ ៧៨ សេចក្តីអាថ៌កំបាំងអស្ចារ្យ ព្រះគ្រិស្ត និងក្រុមជំនុំ

**ដកស្រង់ពី:**

អេភេសូរ ៥:៣១-៣២ ដោយហេតុនោះបានជាមនុស្សប្រុស នឹងលាចេញពីឪពុកម្តាយ ទៅនៅជាប់នឹងប្រពន្ធ ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១វិញ សេចក្តីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រិស្តនឹងពួកជំនុំវិញ ។

ព្រះគ្រិស្ត គឺជាសេចក្តីអាថ៌កំបាំងរបស់ព្រះ សេចក្តីអាថ៌កំបាំងរបស់ព្រះគ្រិស្ត គឺជាក្រុមជំនុំ ។ ការពិតព្រះគ្រិស្តហើយនិងក្រុមជំនុំ គឺជាវិញ្ញាណតែមួយ និមិត្តរូបពីប្តី ឯប្រពន្ធដែលបានត្រឡប់ជាសាច់តែមួយនេះ ជាសេចក្តីអាថ៌កំបាំងដ៏អស្ចារ្យ ។

**ខ្លឹមសារ:**

អេភេសូរ ៥:៣២ សេចក្តីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រិស្ត នឹងពួកជំនុំវិញ ។

កូល៉ុស ២:២ ដើម្បីឱ្យបានស្គាល់សេចក្តីអាថ៌កំបាំងនៃព្រះយ៉ាងពេញលេញ គឺជាព្រះគ្រិស្ត ។

អេភេសូរ ៣:៤-៦ កាលណាអ្នករាល់គ្នាមើលសំបុត្រនោះ នោះនឹងអាចយល់ពីចំណេះខ្ញុំខាងឯការអាថ៌កំបាំងរបស់ព្រះគ្រិស្តបាន ...គឺដែលពួកសាសន៍ដទៃបានត្រឡប់ជាអ្នកគ្រងមរដកជាមួយគ្នានឹងជារូបកាយជាមួយគ្នា ...ជាមួយគ្នាក្នុងព្រះគ្រិស្តដែរ ។

**I. នៅក្នុងអេភេសូរ ៥:៣២ សាវកប៉ុលបាននិយាយថា "សេចក្តីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រិស្ត និងពួកជំនុំវិញ" ស្វាមីនិងភរិយាដំបូងគេនៅក្នុងព្រះគម្ពីរ គឺ អ័ដាមនិងអេវ៉ា ជានិមិត្តរូបយ៉ាងពេញលេញបង្ហាញពី ព្រះគ្រិស្ត និងក្រុមជំនុំ ។**

A. លោកុប្បត្តិ ២:២៤ បានបង្ហាញថា បុរសនិងប្រពន្ធរបស់គាត់បានត្រឡប់ជាសាច់តែមួយ ។

B. អ័ដាម និងអេវ៉ា បានត្រឡប់ជាសាច់តែមួយ ប៉ុន្តែព្រះគ្រិស្តនិងក្រុមជំនុំបានត្រឡប់ជាវិញ្ញាណតែមួយ—១កូរិនថូស ៦:១៧ ។

C. ការពិតព្រះគ្រិស្ត និងក្រុមជំនុំជាវិញ្ញាណតែមួយ ជានិមិត្តរូបពី ប្ដីនិងប្រពន្ធដែលបានត្រឡប់ជាសាច់តែមួយ នេះជាសេចក្ដីអាថ៌កំបាំងអស្ចារ្យ—ខ១៧; អេភេសូរ ៥:៣១-៣២ ។

**II. នៅក្នុង កូល៉ុស ២:២ សាវកប៉ុលបាននិយាយថា សេចក្ដីអាថ៌កំបាំងរបស់ព្រះនោះ គឺជាព្រះគ្រិស្ដ ហើយនៅ អេភេសូរ៣:៤ ប្រាប់ថា សេចក្ដីអាថ៌កំបាំងរបស់ព្រះគ្រិស្ត គឺជាក្រុមជំនុំ :**

A. ព្រះគ្រិស្ត គឺជាសេចក្ដីអាថ៌កំបាំងរបស់ព្រះ ក្នុងព្រះជាម្ចាស់ទ្រង់ផ្ទាល់ គឺអាថ៌កំបាំង ហើយសេចក្ដីអាថ៌កំបាំងរបស់ព្រះនេះ គឺជាការប្រែសភាពនៅក្នុងព្រះគ្រិស្ត ដូច្នេះហើយ ព្រះគ្រិស្តគឺជាសេចក្ដីអាថ៌កំបាំងរបស់ព្រះ—កូល៉ុស ២:២-៣ ។

B. ព្រះគ្រិស្តដែលជាសេចក្ដីអាថ៌កំបាំងរបស់ព្រះ កំពុងបង្កើតក្រុមជំនុំចេញមក ដែលជាសេចក្ដីអាថ៌កំបាំងរបស់ព្រះគ្រិស្ត ។ ក្រុមជំនុំ គឺអាថ៌កំបាំង ពីព្រោះតែព្រះគ្រិស្តនៅក្នុងយើងគឺអាថ៌កំបាំង ជារូបកាយព្រះគ្រិស្ត ក្រុមជំនុំគឺជាការសម្ដែងចេញនៃព្រះគ្រិស្ត—អេភេសូរ ១:២៣; ៣:៣-៦ ។

**III. "ក្រុមជំនុំព្រះគ្រិស្តមានសិរី យើងក៏រួមមានចំណែកដែរ យើងរីករាយក្លាយជាតែមួយ ត្រូវបានផ្លាស់ប្រែមានរូបកាយមួយលើសកលលោក ហើយយើងមានជារបស់រូបកាយ ហាលេលូយ៉ាទ្រង់ឱ្យយើងក្លាយជាតែមួយ ហាលេលូយ៉ាសម្រាប់រូបកាយ យើងជាអវយវៈរូបកាយ យើងរាល់គ្នារស់សម្រាប់រូបកាយ ហាលេលូយ៉ាទ្រង់ឱ្យយើងក្លាយជាតែមួយ"—(បទចម្រៀងខ្មែរលេខ ៩៩៨ , អង់គ្លេសលេខ ១២១៦) ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី ៧៩ ប្រាំពីរដំណាក់កាលរបស់ក្រុមជំនុំ

**ដកស្រង់ពី :**

វិវរណៈ ១:៤ក សំបុត្រយ៉ូហានខ្ញុំ ផ្ញើមកពួកជំនុំទាំង៧ នៅស្រុកអាស៊ី ។

ក្រុមជំនុំទាំង៧នៅស្រុកអាស៊ី ជានិមិត្តរូបពីក្រុមជំនុំ៧ប្រភេទ ដែលមាននៅក្នុងប្រវត្តិសាស្រ្ត ក្រុមជំនុំ ដូចជា ក្រុមជំនុំដើមដំបូង ក្រុមជំនុំដែលរងទុក្ខវេទនា ក្រុមជំនុំខាងលោកិយ ក្រុមជំនុំដែលរាថយ ក្រុមជំនុំដែលបានធ្វើកំណែទម្រង់ ក្រុមជំនុំដែលបានស្តារឡើយវិញ និងក្រុមជំនុំដែលបានស្តារឡើងវិញត្រូវបានធ្លាក់ចុះ ។

**ខ្លឹមសារ :**

វិវរណៈ ១:៤ សំបុត្រយ៉ូហានខ្ញុំ ផ្ញើមកពួកជំនុំទាំង៧ នៅស្រុកអាស៊ី សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្ត អំពីព្រះដ៏គង់នៅ ក៏គង់នៅតាំងតែពីដើម ហើយត្រូវយាងមកទៀត និងអំពីព្រះវិញ្ញាណទាំង៧ ដែលនៅចំពោះបល្ល័ង្កទ្រង់ ។

I. ក្រុមជំនុំទាំងប្រាំពីរនៅស្រុកអាស៊ី តាមពិតទៅជាក្រុមជំនុំតំបន់ ជានិមិត្តរូបដែលបានទាយទុកនៅក្នុងដំណាក់កាលទាំងប្រាំពីរ ដែលក្រុមជំនុំបានឆ្លងកាត់ ហើយនឹងត្រូវឆ្លងកាត់រហូតដល់ការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់—វិវរណៈ ១:៤; ២:១, ៨, ១២, ១៨; ៣:១, ៧, ១៤:
   A. សំបុត្រទី១ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងអេភេសូរ បង្ហាញពីរូបភាពរបស់ក្រុមជំនុំដែលនៅចុងបំផុតនៃដំណាក់កាលទីមួយ ក្នុងអំឡុងផ្នែកចុងក្រោយនៃសតវត្សរ៍ទី១—២:១-៧ ។
   B. សំបុត្រទី២ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងស្មឺណា ជានិមិត្តរូបពីក្រុមជំនុំដែលរងទុក្ខវេទនានៅក្រោមការធ្វើទុក្ខបុកម្នេញពីចក្រភពរ៉ូម៉ាំង ដោយចាប់តាំងពីផ្នែកចុងក្រោយនៃសតវត្សរ៍ទី១ រហូតដល់ដើមផ្នែកនៃសតវត្សរ៍ទី៤ នៅពេលដែលអធិរាជខនស្ទែនធីនទីនដ៏អស្ចារ្យ (Constantine the Great) បាននាំយកសាសនាគ្រិស្ទានធ្វើជាសាសនាប្រចាំជាតិ—ខ៨-១១ ។

C. សំបុត្រទី៣ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងពើកាម៉ុស ជានិមិត្តរូបពីក្រុមជំនុំខាងលោកិយ ក្រុមជំនុំដែលបានរៀបការនឹងលោកិយ ដោយចាប់តាំងពីពេលដែលអធិរាជខនស្ទែនធីនទីន (Constantine) បានទទួលយកសាសនាគ្រិស្ទាន រហូតដល់គ្រាដែលប្រព័ន្ធសន្តប៉ាប៉ា (papal) ត្រូវបានតាំងឡើងនៅចុងក្រោយនៃសតវត្សរ៍ទី៦—ខ១២-១៧ ។

D. សំបុត្រទី៤ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងធាទេរ៉ា ពិពណ៌នាពីក្រុមជំនុំដែលរាថយ ដោយចាប់ផ្តើមតាំងពីនៅចុងក្រោយនៃសតវត្សរ៍ទី៦ រហូតដល់ប្រព័ន្ធសន្តប៉ាប៉ា (papal) បានតែងតាំងឡើង ដល់ទីបញ្ចប់នៃយុគសម័យនេះ នៅពេលដែលព្រះគ្រិស្តទ្រង់យាងត្រឡប់មកវិញ—ខ១៨-២៩ ។

E. សំបុត្រទី៥ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងសើដេស និមិត្តរូបពីក្រុមជំនុំ ប្រូតេស្តង់ ដោយចាប់ពីការកើតកំណែទម្រង់នៅដើមសតវត្សរ៍ទី១៦ រហូតដល់ការយាងត្រឡប់មកវិញរបស់ព្រះគ្រិស្ត—៣:១-៦ ។

F. សំបុត្រទី៦ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងភិឡាដិលភា បានទាយពីក្រុមជំនុំដែលមានបងប្អូនស្រឡាញ់គ្នាទៅវិញទៅមក ដែលជាការស្តារឡើងវិញនៃជីវិតក្រុមជំនុំដ៏ត្រឹមត្រូវ ដោយចាប់ពីដើមសតវត្សរ៍ទី១៩ នៅពេលដែលពួកបងប្អូនទាំងឡាយនៅក្នុងប្រទេសអង់គ្លេសបានក្រោកឈរឡើង រហូតដល់ការលេចចេញជាលើកទីពីររបស់ព្រះអម្ចាស់—ខ៧-១៣ ។

G. សំបុត្រទី៧ ដែលសរសេរផ្ញើទៅកាន់ក្រុមជំនុំនៅក្រុងឡៅឌីសេ បង្ហាញពីជីវិតក្រុមជំនុំនៅបន្ទាប់ពីពួកបងប្អូនបានធ្លាក់ចុះ នៅក្នុងសតវត្សទី១៩ ដោយចាប់ពីផ្នែកចុងក្រោយនៃសតវត្សទី១៩ រហូតដល់ព្រះអម្ចាស់យាងត្រឡប់មកវិញ—ខ១៤-២២ ។

**II.** "ព្រះអង្គខ្ញុំស្រឡាញ់ដំណាក់ទ្រង់_គឺក្រុមជំនុំឧត្តម_ព្រះទ័យព្រះស្រឡាញ់យ៉ាងខ្លាំង_ខ្ញុំបានទីពឹងពំនាក់"—(បទចម្រៀង៦១៦, អង់គ្លេស៨៥២) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី ៨០ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

**ដកស្រង់ពី:**

ម៉ាថាយ ១៩:៨ ទ្រង់ក៏មានព្រះបន្ទូលតបថា បានជាលោកម៉ូសេអនុញ្ញាតឱ្យអ្នករាល់គ្នាលែងប្រពន្ធទៅ គឺដោយព្រោះតែចិត្តអ្នករាល់គ្នារឹងរបឹងប៉ុណ្ណោះ តែពីដើមមកមិនមែនដូច្នោះទេ ។

ការស្តារឡើងវិញ មានន័យថា ការស្តារអ្វីមួយដែលបានបាត់បង់ ឱ្យមាននៅដូចដើម ។ ឥឡូវនេះវាត្រូវបានស្តារឡើងវិញ ។ ការស្តារឡើងវិញរបស់ព្រះអម្ចាស់ គឺជាការស្តារឡើងវិញនូវរឿងរ៉ាវសំខាន់ៗបីយ៉ាង: ព្រះគ្រិស្តជាគ្រប់ទាំងអស់ក្នុងទាំងអស់ដល់យើង ភាពតែមួយនៃរូបកាយព្រះគ្រិស្ត មុខងារប្រើការរបស់អវយវៈទាំងអស់នៃរូបកាយព្រះគ្រិស្ត ។

**ខ្លឹមសារ:**

ម៉ាថាយ ១៩:៨ ទ្រង់ក៏មានព្រះបន្ទូលតបថា បានជាលោកម៉ូសេអនុញ្ញាតឱ្យអ្នករាល់គ្នាលែងប្រពន្ធទៅ គឺដោយព្រោះតែចិត្តអ្នករាល់គ្នារឹងរបឹងប៉ុណ្ណោះ តែពីដើមមកមិនមែនដូច្នោះទេ។

I. **ការស្តារឡើងវិញរបស់ព្រះអម្ចាស់ គឺជាការស្តារឡើងវិញនូវសេចក្តីពិតរបស់ព្រះ ដូចបានបើកសម្តែងនៅក្នុងបទគម្ពីរបរិសុទ្ធ—ម៉ាថាយ ១៩:៨ :**

   A. ការស្តារឡើងវិញ មានន័យថា ការស្តារអ្វីមួយដែលធ្លាប់មានស្រាប់តាំងពីដើម តែវាបានបាត់បង់ ។ ឥឡូវនេះវាត្រូវបានស្តារឡើងវិញ—ខ៨ ។

   B. ព្រះគម្ពីរ គឺជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅជាច្រើន ពីព្រោះព្រះគម្ពីរមាននៅក្នុងសៀវភៅនេះហើយ ទើបយើងអាចមើលឃើញរាល់អស់ទាំងសេចក្តីពិតរបស់ព្រះ ។ សេចក្តីពិត ត្រូវបានបើកសម្តែងនៅក្នុងបទគម្ពីរ ដែលបានបាត់បង់ ខ្វះចន្លោះ មានការយល់ច្រឡំមានការបកស្រាយខុស និងត្រូវបានបង្រៀនខុសទូទាំង

គ្រប់ជំនាន់ ។ ដូច្នេះហើយទើបត្រូវការការស្តារឡើងវិញរបស់ព្រះអម្ចាស់—ខ៨; ១ យ៉ូហាន ១:១ ។

II. **ការស្តារឡើងវិញរបស់ព្រះអម្ចាស់ គឺជាការស្តារឡើងវិញនូវរឿងរ៉ាវសំខាន់ៗបីយ៉ាង—កូល៉ុស ៣:១១; រ៉ូម ១២:៤-៥:**

A. ការស្តារឡើងវិញ គឺជាការស្តារឡើងវិញនូវព្រះគ្រិស្តជាគ្រប់ទាំងអស់ក្នុងទាំងអស់ដល់យើង ។ ទ្រង់ គឺជាចំណុចកណ្តាល ហើយទ្រង់ក៏ជាបរិវេណខាងក្រៅដែលព័ទ្ធជុំវិញផងដែរ ។ យើងយកចិត្តទុកដាក់ចំពោះតែព្រះគ្រិស្តប៉ុណ្ណោះ—កូល៉ុស ៣:១១ ។

B. ការស្តារឡើងវិញរបស់ព្រះអម្ចាស់ គឺជាការស្តារឡើងវិញនូវភាពតែមួយ នៃរូបកាយព្រះគ្រិស្ត ។ ការស្តារឡើងវិញរបស់ព្រះអម្ចាស់ កំពុងតែធ្វើបន្ទាល់ ដោយមិនគិតពីពូជសាសន៍ វប្បធម៌ ឬកម្រិតនៃការអប់រំផ្សេងគ្នាឡើយ គឺគ្រិស្ទានគ្រប់រូបគួរតែជាតែមួយ ។ នេះត្រូវបានបើកសម្តែង យ៉ាងច្បាស់នៅក្នុងគម្ពីរសញ្ញាថ្មី—រ៉ូម ១២:៥ ។

C. ទីបី ការស្តារឡើងវិញរបស់ព្រះអម្ចាស់ គឺការស្តារឡើងវិញនូវមុខងារប្រើការរបស់ អវយវៈទាំងអស់នៃរូបកាយព្រះគ្រិស្ត ។ ព្រះអម្ចាស់សព្វព្រះហឫទ័យឱ្យគ្រប់អវយវៈនៃរូបកាយរបស់ទ្រង់ ក្លាយជាអវយវៈដែលមានមុខងារប្រើការ—ខ៩ ។

III. **"យើងទៅមុខដើម្បីក្រុមជំនុំ / ព្រះគ្រិស្តស្តារឡើងវិញ / រៀនប្រើវិញ្ញាណដោយមិនរួញរា / និមិត្តប្រាកដច្បាស់ / បាប៊ីឡូននឹងត្រូវបានបំផ្លាញ / សាតាំងត្រូវវិនាស / យេរូសាឡិមចុះពីសួគ៌ា / ពេញដោយសិរីល្អ ។" / យើងដើម្បីព្រះគ្រិស្ត / យើងដើម្បីព្រះគ្រិស្ត / ដើម្បីក្រុមជំនុំស្តារឡើងវិញ (២ដង) (ចម្រៀងខ្មែរលេខ ១០០២, អង់គ្លេសលេខ ១២៥៥) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី៨១ យើងជាអ្វី

**ដកស្រង់ពី:**

២ពេត្រុស ១:១២ ដូច្នេះ ខ្ញុំប្រុងប្រៀបនឹងរម្លឹក ដល់អ្នករាល់គ្នា អំពីសេចក្តីទាំងនេះជានិច្ច ទោះបីអ្នករាល់គ្នាស្គាល់ និងបានតាំងខ្ជាប់ខ្ជួនក្នុងសេចក្តីពិតដែលមានហើយក៏ដោយ ។

ក្នុងនាមជាក្រុមជំនុំ យើងនៅទីនេះមិនធ្វើអ្វីទាំងអស់ តែចែកចាយព្រះគ្រិស្តដល់អ្នកដទៃ ។ ការងាររបស់យើង គឺការបន្លឺសម្លេងអំពាវនាវហៅកូនៗរបស់ព្រះ ឱ្យត្រឡប់មករកគោលបំណងសំខាន់របស់ព្រះវិញ ដើម្បីយកព្រះគ្រិស្តធ្វើជាចំណុចកណ្តាលនៃអ្វីៗទាំងអស់ ហើយយកការសុគត ការរស់ឡើងវិញ និងការយាងទៅឋានដ៏ខ្ពស់របស់ទ្រង់ធ្វើជាមូលដ្ឋាននៃគ្រប់អ្វីៗទាំងអស់ ។

**ខ្លឹមសារ:**

២ពេត្រុស ១:១២ ដូច្នេះ ខ្ញុំប្រុងប្រៀបនឹងរម្លឹក ដល់អ្នករាល់គ្នា អំពីសេចក្តីទាំងនេះជានិច្ចទោះបីអ្នករាល់គ្នាស្គាល់ និងបានតាំងខ្ជាប់ខ្ជួនក្នុងសេចក្តីពិតដែលមានហើយក៏ដោយ ។

កូល៉ុស ១:១៨ ទ្រង់ជាសិរសារបស់រូបកាយគឺជាពួកជំនុំ ព្រះអង្គជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់ ។

**I. នៅជំនាន់មុន ព្រះបានបង្ហាញសេចក្តីពិតខុសៗគ្នា ។ សេចក្តីពិតនេះបានក្លាយជា "សេចក្តីពិតបច្ចុប្បន្ន" នៅក្នុងយុគសម័យនោះ—២ពេត្រុស ១:១២:**

A. រាល់សេចក្តីពិតរបស់ព្រះពីមុន បានបង្កើតជាគ្រឹះនៃសេចក្តីពិតក្នុងពេលសព្វថ្ងៃនេះ ។ អ្វីដែលយើងមើលឃើញសព្វថ្ងៃនេះ គឺជាការបើកសម្តែងថែមទៀតរបស់ព្រះជាម្ចាស់ ។

B. ព្រះមានព្រះទ័យចង់ឃើញព្រះគ្រិស្តជាទីមួយនៅក្នុងគ្រប់ការទាំងអស់ ។ មូលដ្ឋាននៃគ្រប់ទាំងអស់ គឺការសុគត ការរស់ឡើងវិញ និងការយាងទៅឋានដ៏ខ្ពស់របស់ព្រះគ្រិស្ត ។ ក្រៅពីព្រះគ្រិស្ត គ្មានសភាពពិតខាងវិញ្ញាណទេ ។ នេះគឺជា «សេចក្តីពិតបច្ចុប្បន្ន» របស់ព្រះ—កូល៉ុស ១:១៨ ។

II. **ក្នុងនាមជាក្រុមជំនុំ យើងនៅទីនេះមិនធ្វើអ្វីផ្សេងក្រៅពីចែកចាយព្រះគ្រិស្តដល់អ្នកដទៃនោះទេ ។ ការងាររបស់យើង គឺការបន្លឺសម្លេងអំពាវនាវហៅកូនៗរបស់ព្រះឱ្យត្រឡប់មករកគោលបំណងសំខាន់របស់ព្រះវិញ ដើម្បីយកព្រះគ្រិស្តធ្វើជាចំណុចកណ្តាលនៃគ្រប់ទាំងអស់ ហើយយកការសុគត ការរស់ឡើងវិញ និងការយាងទៅឋានដ៏ខ្ពស់របស់ទ្រង់ធ្វើជាមូលដ្ឋាននៃគ្រប់ទាំងអស់—១ធីម៉ូថេ ៣:១៥; កូល៉ុស ១:១៨:**

A. យើងគួរតែធ្វើអ្វីៗគ្រប់យ៉ាង ដែលយើងអាចធ្វើដើម្បីបង្ហាញមនុស្សថា ព្រះអម្ចាស់គឺជាព្រះមេដឹកនាំលើគ្រប់ទាំងអស់ ។ សូមឱ្យព្រះជាម្ចាស់ផ្តល់ព្រះគុណដល់យើង ដើម្បីកុំឱ្យយើងក្លាយជាលុងចេញពី "សេចក្តីពិតបច្ចុប្បន្ន" នេះ—រ៉ូម ៩:៥ ។

B. សព្វថ្ងៃនេះ យើងមានទំនួលខុសត្រូវបួនយ៉ាង គឺទាក់ទងនឹងមនុស្សមានបាបយើងត្រូវតែប្រកាសដំណឹងល្អ ។ ទាក់ទងនឹងសាតាំង យើងត្រូវតែដឹងថា មាន សង្គ្រាមខាងឯវិញ្ញាណ ។ ទាក់ទងនឹងក្រុមជំនុំ យើងត្រូវតែប្រកាន់ខ្ជាប់នូវអ្វីដែលយើងមើលឃើញក្នុងពេលសព្វថ្ងៃនេះ ។ ទាក់ទងនឹងព្រះគ្រិស្ត យើងគួរតែថ្លែងទីបន្ទាល់ពីការពិតនៃភាពលេចធ្លោរបស់ទ្រង់ក្នុងគ្រប់ការទាំងអស់—១កូរិនថូស ៩:១៦; អេភេសូរ ៦:១២; ១:២៣; កូល៉ុស ១:១៨ ។

III. **"ក្រុមជំនុំរូបកាយព្រះគ្រិស្ត_ ព្រះទ្រង់គង់នៅទីនេះ_ជាទីជំនុំពួកបរិសុទ្ធ មនុស្សរួមនឹងព្រះវិសុទ្ធ_ជ្រើសរើសមុនកំណើតលោកិយ _សុគតប្រោសលោះបង់ថ្លៃ_ជាតុពិតឋានៈនៅសួគ៌ា មិនមែននៅឯលោកា"—(បទចម្រៀង៥៩៨, អង់គ្លេស ៨២៤ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី៨២ មូលដ្ឋាននៃក្រុមជំនុំ

**ដកស្រង់ពី :**

វិវរណៈ ១:១១ ការអ្វីដែលឯងឃើញ នោះចូរកត់ទុកក្នុងសៀវភៅចុះ រួចផ្ញើរទៅពួកជំនុំទាំង៧ ដែលនៅស្រុកអាស៊ីផង គឺនៅក្រុងអេភេសូរ ក្រុងស្មឺនា ក្រុងពើកាម៉ុស ក្រុងធាទេរ៉ា ក្រុងសើដេស ក្រុងភីឡាដិលភា ហើយនៅក្រុងឡៅឌីសេដែរ ។

ទីក្រុងនីមួយៗនៅក្នុងតំបន់អាស៊ីម៉ៃនីរ៍ មានក្រុមជំនុំតែមួយប៉ុណ្ណោះ ។ សម្រាប់តំបន់មួយ មានក្រុមជំនុំមួយសម្រាប់ទីក្រុងមួយ ។ តម្រូវការដើម្បីប្រជុំនៅលើមូលដ្ឋាននៃភាពតែមួយរបស់យើង គឺថា ត្រូវនៅក្នុងទីក្រុងដែលយើងរស់នៅ ។ រូបភាពនេះពិតជាស្រស់ល្អ ហើយសមគួរយ៉ាងណាទៅ!

**ខ្លឹមសារ :**

វិវរណៈ ១:១១ ការអ្វីដែលឯងឃើញ នោះចូរកត់ទុកក្នុងសៀវភៅចុះ រួចផ្ញើរទៅពួកជំនុំទាំង៧ ដែលនៅស្រុកអាស៊ីផង គឺនៅក្រុងអេភេសូរ ក្រុងស្មឺនា ក្រុងពើកាម៉ុស ក្រុង ធាទេរ៉ា ក្រុងសើដេស ក្រុងភីឡាដិលភា ហើយនៅក្រុងឡៅឌីសេដែរ ។

កិច្ចការ ១៣:១ រីឯក្នុងពួកជំនុំនៅក្រុងអាន់ទីយ៉ូក នោះមានគ្រូអធិប្បាយ និងគ្រូបង្រៀន ។

**I. ទីក្រុងនីមួយៗនៅក្នុងតំបន់អាស៊ីម៉ៃនីរ៍ មានក្រុមជំនុំតែមួយប៉ុណ្ណោះ ។ សម្រាប់តំបន់មួយ មានក្រុមជំនុំមួយសម្រាប់ទីក្រុងមួយ—វិវរណៈ ១:១១; កិច្ចការ ១៣:១ :**

A. យោងទៅតាមការបើកសម្ដែងនៅក្នុងគម្ពីរសញ្ញាថ្មី ការបង្ហាញពីក្រុមជំនុំ គឺថា ក្រុមជំនុំមួយសម្រាប់ទីក្រុងមួយ—វិវរណៈ ១:១១ ។

B. ទីក្រុងមិនត្រឹមតែកំណត់ព្រំដែនឱ្យក្រុមជំនុំតំបន់ប៉ុណ្ណោះទេ ប៉ុន្តែទីក្រុងផ្ទាល់ គឺជាមូលដ្ឋាននៃក្រុមជំនុំ ពីព្រោះមានតែក្រុមជំនុំមួយគត់នៅក្នុងសកលលោក ការនោះ

គួរតែមានការសម្តែងចេញពីក្រុមជំនុំតែមួយគត់ នៅតាមតំបន់ណាមួយដែលបាន ផ្តល់ឱ្យ ។

1. យើងអាចពន្យល់បង្ហាញពីរឿងរ៉ាវនៃក្រុមជំនុំមួយសម្រាប់ទីក្រុងមួយ ដោយមកពិចារណាពីរបៀបដែលជនជាតិអាម៉េរិក័ង ធ្វើកុងស៊ុលប្រតិបត្តិការនៅបរទេស ។ នៅតាមទីក្រុងផ្សេងៗគ្នានៅទូទាំងពិភពលោក អាចមានជនជាតិអាម៉េរិក័ងតែម្នាក់គត់ ដែលអាចធ្វើកុងស៊ុលបាន ដោយមិនគិតពីទំហំរបស់ក្រុងឡើយ ។
2. ប្រសិនបើទីក្រុងជាក់លាក់មួយមានទំហំធំខ្លាំង ជនជាតិអាម៉េរិក័ងធ្វើកុងស៊ុលនៅទីនោះ ប្រហែលជាត្រូវអនុវត្តអាជីវកម្មរបស់ខ្លួននៅក្នុងម្តៃប្រាំបីការិយាល័យដាច់ដោយឡែកពីគ្នា ប៉ុន្តែម្តៃប្រាំបីការិយាល័យនៅតែជាកម្មសិទ្ធិរបស់ស្ថានកុងស៊ុលជនជាតិអាម៉េរិក័ងម្នាក់នៅក្នុងទីក្រុងនោះ ។
3. ដូចគ្នានេះដែរ ទីក្រុងមួយអាចមានសាលប្រជុំ ឬស្រុកជាច្រើន ប៉ុន្តែនៅតែមានក្រុមជំនុំតែមួយប៉ុណ្ណោះ ។ នៅតាមតំបន់ធំៗ ក្រុមជំនុំអាចប្រជុំនៅកន្លែងផ្សេងៗគ្នាជាច្រើន ធ្វើដូចក្រុមជំនុំនៅក្រុងយេរូសាឡិមដែរ ។

A. មូលដ្ឋាននៃក្រុមជំនុំ គឺជាមូលដ្ឋាននៃភាពតែមួយនៅក្នុងតំបន់មួយ ។ តម្រូវការដើម្បីប្រជុំនៅលើមូលដ្ឋាននៃភាពតែមួយរបស់យើង គឺថា ត្រូវនៅក្នុងទីក្រុងដែលយើងរស់នៅ ។

II. **រូបភាពនេះពិតជាស្រស់ល្អ ហើយសមគួរយ៉ាងណាទៅ ដូចជានៅ ទំនុកតម្កើង ១៣៣:១ និយាយថា "មើល ដែលបងប្អូននៅមូលជាមួយគ្នា ដោយចិត្តព្រមព្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ!"**

III. **យើងទៅមុខដើម្បីក្រុមជំនុំ ព្រះគ្រិស្តស្តារឡើងវិញ / យើងធ្វើឱ្យក្រុមជំនុំតំបន់ ពង្រីកគ្រប់ទិសទី រួមគ្នាឈរលើទីគ្រឹះតំបន់ រក្សាភាពតែមួយ / កសាងព្រះវិហាររបស់ទ្រង់សម្រេចតាមព្រះទ័យ /*យើងដើម្បីព្រះគ្រិស្ត / យើងដើម្បីព្រះគ្រិស្ត / ដើម្បីក្រុមជំនុំស្តារឡើងវិញ/ យើងដើម្បីព្រះគ្រិស្ត / យើងដើម្បីព្រះគ្រិស្ត / ដើម្បីក្រុមជំនុំស្តារឡើងវិញ* (បទចម្រៀងភាសាខ្មែរលេខ , ១០០២ អង់គ្លេសលេខ ១២៥៥) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី ៨៣ វ៉ចម៉ែន នី

**ដកស្រង់ពី:**

កិច្ចការ ២៦:១៩ ដូច្នេះ បពិត្រស្តេចអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការបើកសម្តែងពីឋានសួគ៌នោះទេ ។

បងប្អូន នី ត្រូវបានចាត់ទុកថា ជាអ្នកមើលឃើញនិមិត្តរបស់ព្រះ នៅក្នុងយុគសម័យបច្ចុប្បន្ន ។ គាត់បានឃើញនិមិត្តយ៉ាងច្បាស់អំពីព្រះគ្រិស្ត ហើយក៏បានទទួលការបើកសម្តែងដ៏ពេញលេញអំពីក្រុមជំនុំ ។ សេចក្តីស្មោះត្រង់របស់គាត់ចំពោះបេសកម្មនេះ ធ្វើឱ្យគាត់លះបង់ជីវិត ។ សង្ឃឹមថាអ្នករាល់គ្នា នឹងដើរតាមនិមិត្តនេះ ។

**ខ្លឹមសារ:**

កិច្ចការ ២៦:១៩ ដូច្នេះ បពិត្រស្តេចអ័គ្រីប៉ាអើយ ទូលបង្គំមិនបានចចេសនឹងការបើកសម្តែងពីឋានសួគ៌នោះទេ ។

កូល៉ុស ៣:១១ ...ព្រះគ្រិស្តទ្រង់ជាគ្រប់ទាំងអស់ ហើយទ្រង់ក៏គង់នៅក្នុងគ្រប់ទាំងអស់ផង។

អេភេសូរ ៥:៣២ សេចក្តីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រិស្ត និងក្រុមជំនុំវិញ ។

**I. បងប្អូន នី ជាអំណោយទានតែមួយគត់ដែលព្រះអម្ចាស់បានប្រទានដល់រូបកាយ សម្រាប់ចលនានៃការស្តារឡើងវិញរបស់ទ្រង់នៅលើផែនដី ហើយគាត់ត្រូវបានចាត់ទុកថា ជាអ្នកមើលឃើញនិមិត្តរបស់ព្រះ នៅក្នុងយុគសម័យបច្ចុប្បន្ននេះ—អេភេសូរ ៣:៣; ២កូរិនថូស ៩:១៥ ។**

II. **ព័ន្ធកិច្ចរបស់គាត់ គឺមានពីរទិដ្ឋភាពយ៉ាងច្បាស់ ទីមួយអំពីព្រះគ្រិស្ត និង ទីពីរអំពីក្រុមជំនុំ—កូល៉ុស ៣:១១; អេភេសូរ ៥:៣២ :**

A. ទីមួយ គាត់ផ្ទាល់ រៀនស្គាល់ព្រះអម្ចាស់យ៉ាងជ្រាលជ្រៅ ដោយបទពិសោធន៍ការសុគតរួមបញ្ចូលគ្រប់ទាំងអស់ និង សេចក្តីរស់ឡើងវិញរបស់ព្រះគ្រិស្ត—រ៉ូម ៦:៤ :

1. កូល៉ុស ៣:១១ គឺព្រះគ្រិស្តទ្រង់ជាគ្រប់ទាំងអស់ ហើយទ្រង់ក៏គង់នៅក្នុងគ្រប់ទាំងអស់ផង ។

2. ដោយសារបទពិសោធន៍របស់គាត់ផ្ទាល់ស្របនឹងការនេះ ទើបគាត់មានបន្ទុកយ៉ាងច្បាស់ ហើយព្រះអម្ចាស់ធ្វើឱ្យគាត់ជាស្មរបន្ទាល់នូវសេចក្តីពិត ។

B. ទីពីរ បន្ទុកចុងក្រោយរបស់បងប្អូន វ៉ចម៉ែន នី គឺត្រូវតាំង និងកសាងក្រុមជំនុំតំបន់ឡើង សម្រាប់ជាទីស្តប់បំណងព្រះទ័យរបស់ព្រះ ។ នេះជាបេសកកម្មចុងក្រោយបង្អស់របស់គាត់ពីព្រះអម្ចាស់ ដោយពឹងផ្អែកលើការដែលគាត់បានឃើញនិងបទពិសោធន៍ព្រះ—វិវរណៈ ១:១១ ។

C. "សេចក្តីអាថ៌កំបាំងនេះអស្ចារ្យណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រិស្ត និង ក្រុមជំនុំវិញ" ក្នុងពេញមួយជីវិតរបស់គាត់ ព័ន្ធកិច្ចរបស់គាត់ គឺសម្រាប់ព្រះគ្រិស្ត និង ក្រុមជំនុំ មិនត្រឹមព្រះគ្រិស្តទេ តែព្រះគ្រិស្ត និងក្រុមជំនុំ—អេភេសូរ ៥:៣២ ។

D. បងប្អូន វ៉ចម៉ែន នី គឺដូចជាសាវកប៉ុល មានបន្ទក់ និងមានបេសកកម្មដោយការបើកសម្តែងនេះ ។ ភាពស្មោះត្រង់របស់គាត់ចំពោះបេសកកម្មនេះ ធ្វើឱ្យគាត់លះបង់ជីវិត—២កូរិនថូស ៤:១ ។

III. **ការស្តារឡើងវិញរបស់ព្រះអម្ចាស់បានមកដល់យើងតាមរយៈបងប្អូន នីជាទីស្រឡាញ់ ។ ខ្ញុំបានប្រាប់បងប្អូន នី ថា "ប្រសិនបើថ្ងៃណាមួយ អ្នកមិនជ្រើសយកផ្លូវនេះទេ ខ្ញុំនឹងនៅតែជ្រើសយកផ្លូវនេះ ។ ខ្ញុំបានឃើញថា នេះគឺជាផ្លូវរបស់ព្រះអម្ចាស់ ។ ខ្ញុំបានមើលឃើញនិមិត្ត" ។ ហើយខ្ញុំសង្ឃឹមថា អ្នករាល់គ្នានឹងមើលឃើញយ៉ាងច្បាស់លាស់អំពីនិមិត្តនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់ ហើយនឹងដើរតាមនិមិត្តនេះផងដែរ ។**

IV. **ព្រះអង្គបានខ្ញុំមួយជីវិត ឱ្យខ្ញុំថ្វាយខ្លួនដល់ព្រះគ្រិស្ត / ថ្វាយវេលាខ្ញុំរាល់ថ្ងៃយប់បម្រើព្រះមួយជីវិត / ព្រោះខ្ញុំព្រះអង្គព្រមលះបង់ជីវិត ព្រោះខ្ញុំព្រះអង្គព្រមរងទុក្ខដល់ស្លាប់ / ខ្ញុំរីករាយថ្វាយក្តីស្រឡាញ់ និងជីវិត បម្រើដល់ព្រះអង្គមួយជីវិត ។ (បទចម្រៀងខ្មែរ ៣៣៩ )**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី៨៤ វិថនេសលី

**ដកស្រង់ពី:**

១កូរិនថូស ៤:១ ដូច្នេះ មនុស្សត្រូវរាប់យើងខ្ញុំ ទុកដូចជាអ្នកជំនួយនៃព្រះគ្រិស្ត ហើយជាអ្នករ៉ាប់រងចំពោះសេចក្ដីអាថ៌កំបាំងនៃព្រះវិញ ។

បងប្អូនវិថនេសលី ជាបាវបម្រើរបស់ព្រះអម្ចាស់យេស៊ូ ដែលជាអ្នកស្នងមរតកនៃការបើកសម្ដែងរបស់ព្រះ ។ បងប្អូនលីបានបន្តព័ន្ធកិច្ចរបស់បងប្អូននី ហើយឆ្ពោះទៅរកការបើកសម្ដែងព្រះដ៏ខ្ពង់ខ្ពស់ ។ ខ្ញុំទូន្មានឱ្យបងប្អូនដើរតាមនិមិត្តនេះ ។

**ខ្លឹមសារ:**

១កូរិនថូស ៤:១ ដូច្នេះ មនុស្សត្រូវរាប់យើងខ្ញុំ ទុកដូចជាអ្នកជំនួយនៃព្រះគ្រិស្ត ហើយជាអ្នករ៉ាប់រងចំពោះសេចក្ដីអាថ៌កំបាំងនៃព្រះវិញ ។

កូល៉ុស ១:២៥ ខ្ញុំបានត្រឡប់ជាអ្នកបម្រើដល់ពួកជំនុំនោះ តាមការកាន់កាប់ត្រួតត្រារបស់ព្រះ ដែលបានប្រគល់មកខ្ញុំសម្រាប់អ្នករាល់គ្នា ដើម្បីនឹងបំពេញព្រះបន្ទូល ។

**I. បងប្អូនវិថនេសលី ជាបាវបម្រើរបស់ព្រះអម្ចាស់យេស៊ូ ដែលជាអ្នកស្នងមរតកនៃការបើកសម្ដែងរបស់ព្រះ និងជាអ្នកបម្រើដ៏ស្មោះត្រង់នៅក្នុងក្រុមជំនុំការស្តារឡើងវិញរបស់ព្រះអម្ចាស់នៅសម័យបច្ចុប្បន្ននេះ—កូល៉ុស ១:២៥-២៦ ។**

**II. បងប្អូនលីបានបន្តព័ន្ធកិច្ចរបស់បងប្អូននី និងកសាងលើការបើកសម្ដែងរបស់ព្រះបន្ថែមទៀត ដោយឆ្ពោះទៅរកការបើកសម្ដែងព្រះដ៏ខ្ពង់ខ្ពស់—កូល៉ុស ១:២៥-២៦:**

A. បងប្អូននី បានជាប់គុកក្នុងឆ្នាំង១៩៥២ ឯបងប្អូនលី បានបន្តព័ន្ធកិច្ចរបស់គាត់ ដោយមេរៀនដំបូងរបស់គាត់ បានផ្ដោតទៅលើព្រះគ្រិស្ត ព្រះវិញ្ញាណ ជីវិត ក្រុមជំនុំ និង

រូបកាយព្រះគ្រិស្ត និងបានជឿនទៅមុខពីមូលដ្ឋានគ្រឹះនេះ—១កូរិថូស ១៥:៤៥; កូល៉ុស ៣:៤, អេភេសូរ ១:២៣ ។

B. នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ព្រះអម្ចាស់បានបើកសម្តែងនូវការចែកចាយរបស់ព្រះត្រីឯក តាមរយៈបងប្អូនលី ដោយបានបើកសម្តែងផែនការគ្រប់គ្រងសញ្ញាណថ្មីរបស់ព្រះ នោះគឺព្រះជាម្ចាស់ចង់ចែកចាយរូបអង្គទ្រង់ផ្ទាល់ចូលទៅក្នុងប្រជារាស្ត្រ ដែលទ្រង់បានជ្រើសរើស ដើម្បីបំពេញសម្រេចផែនការគ្រប់គ្រងព្រះរបស់ទ្រង់—៣:៩ ។

C. នៅរដូវស្លឹកឈើជ្រុះ ឆ្នាំ១៩៩៤ បងប្អូនលីបានមើលឃើញសេចក្តីពិតដ៏ខ្ពង់ខ្ពស់របស់ព្រះនៅក្នុងព្រះគម្ពីរ ដោយចាប់ពីព្រះអម្ចាស់មានបន្ទូលថា "ព្រះបានក្លាយជាមនុស្ស ដើម្បីមនុស្សបានក្លាយជាព្រះ" ប៉ុន្តែ មិននៅក្នុងឋានៈជាព្រះនោះទេ—យ៉ូហាន ១:១, ១៤; ១យ៉ូហាន ៣:២ ។

III. **នេះគឺជាសេចក្តីមេត្តារបស់ព្រះ ដែលទ្រង់បានបើកសម្តែងនូវនិមិត្តមកដល់ខ្ញុំ ។ នេះគឺជានិមិត្តដែលលាតសន្ធឹងពីព្រឹត្តិការណ៍ដំបូងរបស់អ័ដាម រហូតដល់ព្រឹត្តិការណ៍ចុងក្រោយនៃក្រុងយេរូសាឡិម ។ ខ្ញុំទូន្មានឱ្យបងប្អូនដើរតាមនិមិត្តនេះ ។**

IV. **រឿងដ៏អស្ចារ្យ រឿងអាថ៌កំបាំង ព្រះនិងមនុស្សរួមមកតែមួយ / ទ្រង់គឺជាព្រះក្លាយជាមនុស្ស ដើម្បីមនុស្សក្លាយជាព្រះអង្គ / ដោយព្រោះសេចក្តីស្រឡាញ់នៃទ្រង់ ដែលមាននៅក្នុងព្រះ ទ័យឧត្តម / ដោយព្រោះសេចក្តីស្រឡាញ់នៃទ្រង់ ដែលមាននៅក្នុងព្រះទ័យឧត្តម (បទចម្រៀងខ្មែរនៅទំព័រលេខ ៤៩០ , អង់គ្លេសលេខ ១៣៨៩) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី៨៥ ការស្គាល់បក្សពួកនិកាយ

**ដកស្រង់ពី:**

កាឡាទី ៥:១៩-២០ រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សម្អប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ។

បក្សពួកនិកាយ គឺជាក្រុមមនុស្ស ។ ព្រះគ្រិស្តមិនត្រូវបានបែកបាក់ឡើយ យើងជឿលើព្រះអម្ចាស់តែមួយ ។ ក្រុមជំនុំ គឺជារូបកាយរបស់ព្រះគ្រិស្ត ។ ដូច្នេះ គ្មានមូលដ្ឋាន ហើយនៅទីនោះគួរតែគ្មានមូលដ្ឋានសម្រាប់ការបាក់បែកឡើយ ។ ពួកយើងគួរតែបដិសេធវាទាំងស្រុង ។

ខ្លឹមសារ:

កាឡាទី ៥:១៩-២០ រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តីកំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សម្អប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ។

១កូរិនថូស ១:១៣ ដូច្នេះ តើព្រះគ្រិស្តបានបាក់បែកឬអី តើប៉ុលត្រូវឆ្កាងជំនួសអ្នករាល់គ្នាឬអី តើអ្នករាល់គ្នាបានទទួលជ្រមុជ ដោយនូវឈ្មោះប៉ុលឬអី ?

អេភេសូរ ៤:៤-៦ មានរូបកាយតែ១.....មានព្រះអម្ចាស់តែ១....មានព្រះតែ១ គឺជាព្រះវរបិតានៃទាំងអស់ .....។

I. បក្សពួកនិកាយ គឺជាក្រុមមនុស្សដែលត្រូវបានកកើតឡើងទៅជាការបាក់បែកគ្នា—៥:៩-២០ :
   A. សព្វថ្ងៃនេះ មនុស្សមួយចំនួនដែលបានជ្រមុជទឹកចូលទៅក្នុងព្រះគ្រិស្ត និយាយថាពួកគេជារបស់លូសធឺរ Luther (ក្រុមនិកាយលូសធឺរីន Lutheran) ឬជារបស់វ៉េសលី

Wesley (ក្រុមនិកាយវេស្លីន Wesleyan) ឬជារបស់ក្រុមជំនុំបាទីស្ទ (ក្រុមនិកាយបាទីស្ទ) ឬជារបស់ក្រុមជំនុំព្រេស្ប៊ីធីរៀន Presbyterian (ក្រុមនិកាយព្រេស្ប៊ីធីរៀន Presbyterian) ។

B. មានចំណុចជាក់ស្តែងបីនៅក្នុងនិកាយមួយ ។ ដំបូងមានគោលលទ្ធិពិសេសមួយ ។ ទីពីរមានការប្រកបពិសេស និងទីបីមានឈ្មោះពិសេស ។ "ពិសេសៗ" ទាំងបីនេះអាចត្រូវបានរកឃើញស្ទើរតែនៅក្នុងក្រុមទាំងអស់ នៅក្នុងសាសនាគ្រិស្ទានសព្វថ្ងៃនេះ ។

II. **"មានរូបកាយតែ១ .....មានព្រះអម្ចាស់តែ១....មានព្រះតែ១ គឺជាព្រះវរបិតានៃទាំងអស់"—អេភេសូរ ៤:៤-៦:**

A. ព្រះគ្រិស្តមិនត្រូវបានបែកបាក់ឡើយ ។ យើងជឿលើព្រះអម្ចាស់តែមួយ ។ ព្រះគ្រិស្តគឺជាអង្គតែមួយគត់នៅក្នុងសកលលោក ។ ទ្រង់មិនត្រូវបានបែកបាក់ឡើយ ដូច្នេះពួកយើងដែលជឿលើទ្រង់ ក៏មិនគួរបែកបាក់គ្នាដែរ—៩៥ ។

B. ឯទីពីរ ក្រុមជំនុំ គឺជារូបកាយរបស់ព្រះគ្រិស្ត ។ គ្រប់គ្នាមានរូបកាយតែមួយប៉ុណ្ណោះ ។ ដូចគ្នាផងដែរ រូបកាយរបស់ព្រះគ្រិស្ត ក៏មានតែមួយគត់ផងដែរ ។ ដូច្នេះ គ្មានមូលដ្ឋាន ហើយនៅទីនោះគួរតែគ្មានមូលដ្ឋានសម្រាប់ការបាក់បែកឡើយ—១:២៣ ។

C. ក្រុមជំនុំ គឺជាក្រុងយេរូសាឡិមដ៏ពិតប្រាកដ ហើយក្រុមជំនុំផ្អែកលើគោលការណ៍នៃភាពតែមួយដោយគ្មានការភាន់ច្រឡំ ។ ការកំណត់ទុករបស់ព្រះ គឺទាក់ទងនឹងក្រុងយេរូសាឡិម ប៉ុន្តែក្រុងយេរូសាឡិមមានបញ្ហាដោយការបែកបាក់ និងការភាន់ច្រឡំនៃបាប៊ីឡូន—វិវរណៈ ១៨:២ ។

III. **"យើងរួមតែមួយគ្មានអ្នកណាអាចបំបែកបាន_ក្នុងភាពតែមួយយើងជារូបកាយព្រះគ្រិស្ត_កាយមួយពែងមួយយើងរាល់គ្នារួមហូបផឹកទ្រង់_ប្រាកដច្បាស់ថាពួកយើងគឺជាបន្ទាល់"—(បទចម្រៀង ៨២៩, អង់គ្លេស ១១០៧) ។**

## ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី ៨៦ ការដូចគ្នាប៉េះបិទជាមួយនឹងសេចក្តីខុសឆ្គង

### ដកស្រង់ពី:

២ពេត្រុស ២:១ តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំសេចក្តីវិនាសក៏ឆាប់រហ័សឱ្យមកលើខ្លួនផង ។

"សេចក្តីបង្រៀនខុសឆ្គង" មានន័យថា "ការជ្រើសរើសគោលលិទ្ធិដោយខ្លួនឯង ដោយចាកចេញពីសេចក្តីពិត" ដូច្នេះបណ្តាលឱ្យមានការបែងចែក ឬ បែកបាក់ និង បង្កើតចេញជានិកាយនានា ។ ពួកយើងគួរតែរៀន កុំប៉ះពាល់អ្វីដែលជាសេចក្តីខុសឆ្គង និងរៀនរត់គេចចេញពីពួកទាំងនោះ ព្រមទាំងបដិសេធពួកគេ ។

### ខ្លឹមសារ:

២ពេត្រុស ២:១ តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំសេចក្តីវិនាសក៏ឆាប់រហ័សឱ្យមកលើខ្លួនផង ។

២យ៉ូហាន ១:១០ បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឱ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឱ្យទាំងជំរាបសួរដល់អ្នកនោះផង ។

**I. ២ពេត្រុស.២:១ និយាយថា "តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញគេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំសេចក្តីវិនាសក៏ឆាប់រហ័សឱ្យមកលើខ្លួនផង" :**

A. "សេចក្ដីខុសឆ្គង" ដែលមានន័យថា ជម្រើសនៃទស្សនៈ អំពីគោលលិទ្ធិ ដែលខុសគ្នាពីអ្វីដែលបានទទួលយកជាធម្មតា "ការជ្រើសរើសគោលលិទ្ធិដោយខ្លួនឯង ដោយចាកចេញពីសេចក្ដីពិត" ដូច្នេះបណ្ដាលឱ្យមានការបែងចែក ឬ បាក់បែក និង បង្កើតចេញជានិកាយនានា ។

B. ពាក្យនៅទីនេះ ចង្អុលបង្ហាញពីគោលលិទ្ធិក្លែងក្លាយ និង ខុសឆ្គង ដែលនាំមកដោយគ្រូក្លែងក្លាយ ពួកគោលលិទ្ធិនិយម ស្រដៀងគ្នាទៅនឹងគោលលិទ្ធិឯកនិយមសព្វថ្ងៃ ដែលបដិសេធភាពជាព្រះរបស់ព្រះគ្រិស្ដ និងការសុគតប្រោសលោះរបស់ព្រះគ្រិស្ដ ។

II. **២យ៉ូហាន ១:១០ និយាយថា "បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឱ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឱ្យទាំងជំរាបសួរដល់អ្នកនោះផង!" :**

A. សព្វនាម "គាត់ (អ្នកនោះ)" សំដៅលើពួកគោលលិទ្ធិនិយម ពួកទាស់ប្រឆាំងនឹងព្រះគ្រិស្ដ និងហោរាក្លែងក្លាយ ។ ក្នុងចំណោមពួកនេះ យើងគួរតែបដិសេធកុំឱ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ ក៏កុំឱ្យទាំងជំរាបសួរដល់អ្នកនោះផង—ខ៧ ។

B. វាមិនងាយស្រួលនោះទេ សម្រាប់អ្នកជឿក្មេងៗ ដើម្បីដឹងពីសេចក្ដីខុសឆ្គងទាំងនេះ ។ ពួកយើងគួរតែរៀនកុំប៉ះពាល់អ្វីដែលជាសេចក្ដីខុសឆ្គង និងរៀនរត់គេចចេញពីពួកទាំងនោះ ព្រមទាំងបដិសេធពួកគេ—ខ២០ ។

III. **"ព្រះអង្គទ្រង់ជាបន្ទូលជីវិត_ហើយទ្រង់ជាកូនព្រះពិត _ព្រះអង្គមានរូបភាពដូចជាព្រះ _ ហើយមានភាពដូចជាព្រះ"—( បទចម្រៀង៥៥, អង់គ្លេស ៥៦ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់

## វាក្យសព្ទទី ៨៧ អាកប្បកិរិយារបស់យើងចំពោះពួកអ្នកជឿដូចគ្នា

**ដកស្រង់ពី:**

រ៉ូម ១៤:២-៣ ដ្បិតម្នាក់ជឿថា បរិភោគបានគ្រប់មុខទាំងអស់ ម្នាក់ទៀតដែលខ្សោយបរិភោគតែបន្លែទេ កុំឱ្យអ្នកដែលបរិភោគមើលងាយដល់អ្នកដែលមិនបរិភោគឡើយ ក៏កុំឱ្យអ្នកដែលមិនបរិភោគនិន្ទាចំពោះអ្នកដែលបរិភោគដែរ ដ្បិតព្រះទ្រង់ទទួលអ្នកនោះដូចគ្នា ។

ដរាបណាមនុស្សម្នាក់ជឿក្នុងព្រះគ្រិស្តដ៏ជាព្រះអម្ចាស់នៃយើង យើងត្រូវតែទទួលគាត់ ។ យើងត្រូវតែរៀនបើកគ្រប់ពេលវេលាដល់គ្រិស្ទានទាំងអស់ ដោយបង្រៀនសេចក្តីពិត និងចែកចាយនូវការផ្គត់ផ្គង់ជីវិតដល់ពួកគេ ។

**ខ្លឹមសារ :**

រ៉ូម ១៤:២-៣ ដ្បិតម្នាក់ជឿថា បរិភោគបានគ្រប់មុខទាំងអស់ ម្នាក់ទៀតដែលខ្សោយបរិភោគតែបន្លែទេ កុំឱ្យអ្នកដែលបរិភោគ មើលងាយដល់អ្នកដែលមិនបរិភោគឡើយ ក៏កុំឱ្យអ្នកដែលមិនបរិភោគនិន្ទាចំពោះអ្នកដែលបរិភោគដែរ ដ្បិតព្រះទ្រង់ទទួលអ្នកនោះដូចគ្នា ។

២កូរិនថូស ៦:១១ ឱពួកកូរិនថូសអើយ មាត់យើងខ្ញុំបើកចំពោះអ្នករាល់គ្នាហើយ ចិត្តយើងខ្ញុំបានទូលាយឡើង ។

**I. ដរាបណាមនុស្សម្នាក់ជឿក្នុងព្រះគ្រិស្តដ៏ជាព្រះអម្ចាស់នៃយើង ដរាបណាគាត់ទទួលយកទ្រង់ធ្វើជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់គាត់ នោះយើងត្រូវតែទទួលគាត់ដោយមិនចាំបាច់ទាមទារអ្វីទាំងអស់—រ៉ូម ១៤:២-៣ :**

A. អាកប្បកិរិយារបស់សាវកប៉ុល ដែលទាក់ទងនឹងការមានគំនិតផ្សេងគ្នានៃការបរិភោគ និងការកាន់រក្សាថ្ងៃទាំងឡាយ គឺជារឿងរ៉ាវដោយសេរី និងទូទៅជាទីបំផុត ។ តាមរយៈការនេះ យើងត្រូវបានប្រាប់យ៉ាងច្បាស់ថា យើងត្រូវតែទទួលពួកបរិសុទ្ធដែលខុសពីយើងនៅក្នុងរឿងទាំងនេះ ។ អាកប្បកិរិយារបស់យើង គឺថា យើងបើកដល់ពួកបរិសុទ្ធទាំងអស់—ខ២-៣ ។

B. ដរាបណាពួកបរិសុទ្ធស្រឡាញ់ព្រះអម្ចាស់ និងមកជាមួយគ្នានៅលើមូលដ្ឋានគ្រឹះដ៏ត្រឹមត្រូវនៃភាពតែមួយ ដើម្បីចែកចាយព្រះគ្រិស្តដល់គ្នាទៅវិញទៅមក នោះគឺគ្រប់គ្រាន់ហើយ ។ យើងមិនត្រូវយកចិត្តទុកដាក់នឹងអ្វីផ្សេងទៀតទេ—១ពេត្រុស ៤:១០ ។

**II. ឥឡូវនេះ យើងជាមនុស្សដែលមានទីបន្ទាល់របស់ព្រះនៅក្នុងសេចក្តីពិតរបស់ទ្រង់ និងនៅក្នុងជីវិតរបស់ទ្រង់ ម្លោះហើយយើងត្រូវតែរៀនបើកទៅចំពោះគ្រិស្ទានគ្រប់រូបដោយការបង្រៀនសេចក្តីពិត និងការចែកចាយនូវការផ្គត់ផ្គង់ជីវិតដល់ពួកគេ—ខ១០ :**

A. ព្រះអម្ចាស់ស្រឡាញ់មនុស្សលោក រីឯយើងក៏ត្រូវស្រឡាញ់មនុស្សលោកដូចគ្នា ដោយការប្រកាសដំណឹងល្អដល់ពួកគេ—យ៉ូហាន ៣:១៦ ។

B. យើងស្រឡាញ់ពួកគ្រិស្ទានគ្នាយើង ទោះបីជាពួកគេមិននៅជាមួយយើងក៏ដោយ ក៏ត្រូវបង្រៀនសេចក្តីពិត និងចែកចាយជីវិតដល់ពួកគេដែរ—ហេព្រើរ ៦:១០ ។

C. ចុងក្រោយ យើងត្រូវផ្តល់សេរីភាពឱ្យអ្នកដទៃក្នុងការធ្វើសកម្មភាព និងអនុញ្ញាតឱ្យពួកគ្រិស្ទានឯទៀត មានជម្រើសផ្ទាល់ខ្លួនរបស់ពួកគេទាក់ទងនឹងរឿងរ៉ាវក្រុមជំនុំ—១ពេត្រុស ៥:៣ ។

**III. នៅលើផ្លូវរត់ប្រណាំងពេញដោយព្រះគុណ / ពួកអ្នកបានចិញ្ចឹមដោយឧត្តមពេកពន់ /ពួកអ្នក ស្រឡាញ់ទ្រង់ជំរុញខ្ញុំឆ្ពោះទៅ / បានប្រើក្តី ស្រឡាញ់ ស្រឡាញ់ជ្រាលជ្រៅ ។ ទន់ខ្សោយរួមស្រែកយំចំពោះព្រះភ័ក្ត្រា / ទោះចាញ់ក៏សូមដួលក្នុងបងប្អូនស្ងួនភ្ងា / ចិត្តខ្ញុំមានតែអរគុណគ្រប់ពេលវេលា / ខ្ញុំចម្រើនធំឡើង ព្រោះពួកអ្នករាល់គ្នា ។ */ដោយសារអ្នកខ្ញុំសសើរទ្រង់ពិត / បងប្អូនគួរឱ្យស្រឡាញ់ស្នាលស្និទ្ធ/ ទាំងវិញ្ញាណខ្ញុំព្រលឹងខ្ញុំនឹងកាយចិត្ត / រីករាយនឹងថ្វាយខ្លួនដល់ពួកអ្នកពិត / ពួកយើងជាយញ្ញបូជាជីវិតសិរី / បម្រើមុខព្រះភ័ក្ត្រឱ្យទ្រង់សព្វព្រះទ័យ / ទោះនៅទីណាក្លាហានមោះមុតឥតបី / ផ្លូវនៃជីវិតព្រោះមានបងប្អូនប្រុសស្រី ។***

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ
# ភាគ៩ ការស្តារឡើងវិញរបស់ព្រះអម្ចាស់
# វាក្យសព្ទទី ៨៨ ការចុះចូលចំពោះអ្នកដែលមានសិទ្ធអំណាចគ្រប់គ្រងលើយើង

**ដកស្រង់ពី:**

រ៉ូម.១៣:១ ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ ដ្បិតគ្មានអំណាចណាទេ លើកតែមកពីព្រះ គឺព្រះទ្រង់បានតាំងពួកលោកទាំងនោះឱ្យមានអំណាច ។

យោងទៅតាមសេចក្តីបង្រៀនដែលមានផាសុខភាពនៅក្នុងសញ្ញាថ្មី យើងគួរតែគោរពរដ្ឋាភិបាល ។ ការចុះចូលនឹងរាជការ គឺជាការទទួលស្គាល់នូវសិទ្ធអំណាចរបស់ព្រះ ។ យើងត្រូវការចុះចូលចំពោះ អ្នកគ្រប់គ្រង សិទ្ធអំណាច ហើយត្រូវការស្តាប់បង្គាប់ និងប្រុងប្រៀបរហូតដល់គ្រប់ទាំងការល្អ ។

**ខ្លឹមសារ :**

រ៉ូម ១៣:១ ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ ដ្បិតគ្មានអំណាចណាទេ លើកតែមកពីព្រះ គឺព្រះទ្រង់បានតាំងពួកលោកទាំងនោះឱ្យមានអំណាច ។

ទីតុស.៣:១ ចូររំឭកគេ ឱ្យចុះចូលនឹងពួកនាម៉ឺន ហើយនឹងពួកមានអំណាចទាំងអស់ ព្រមទាំងស្តាប់បង្គាប់ ហើយប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ ។

១ពេត្រុស ២:១៣ ចូរឱ្យចុះចូល នឹងគ្រប់ទាំងច្បាប់ នៃមនុស្សលោកដោយយល់ដល់ព្រះអម្ចាស់ ទោះបើនឹងស្តេច ទុកជាធំបណ្តាច់ ។

I. **រ៉ូម ១៣:១ និយាយថា "ចូរឱ្យគ្រប់ទាំងមនុស្សចុះចូលនឹងរាជការ ដ្បិតគ្មានអំណាចណាទេ លើកតែមកពីព្រះ គឺព្រះទ្រង់បានតាំងពួកលោកទាំងនោះឱ្យមានអំណាច" :**
   A. ខ៤ និយាយថា សិទ្ធអំណាច "គឺជាអ្នកបម្រើរបស់ព្រះ សំរាប់សេចក្តីល្អដល់អ្នក" តាមរយៈសិទ្ធអំណាចទាំងអស់ ព្រះជាម្ចាស់នឹងអនុញ្ញាតឱ្យយើងរស់នៅលើផែនដី

នេះ ក្នុងសេចក្តីសុខសាន្ត ក្លាយជាទីបន្ទាល់របស់ទ្រង់ ។ នេះសម្រាប់ជាសេចក្តីល្អដល់យើង ។

B. នៅក្នុង ១៣:៧ សាវកប៉ុលបានប្រាប់យើងថា ត្រូវមានសេចក្តីកោតខ្លាច ចំពោះលោកណាដែលគួរកោតខ្លាច ហើយត្រូវគោរពប្រតិបត្តិ ដល់លោកណាដែលគួរគោរពដែរ ។ គ្រប់អ្នកជឿទាំងអស់ ត្រូវការរៀនដាក់ខ្លួនចុះចូលចំពោះសិទ្ធអំណាចទាំងអស់ ហើយត្រូវគោរពនិងកោតខ្លាចដល់ពួកគេ ។

II. ១ ពេត្រុស ២:១៣ និយាយថា "ចូរឱ្យចុះចូល នឹងគ្រប់ទាំងច្បាប់ នៃមនុស្សលោកដោយយល់ដល់ព្រះអម្ចាស់ ទោះបើនឹងស្តេច ទុកជាធំបណ្តាច់" សម្រាប់ផលប្រយោជន៍របស់ព្រះ ការនេះគឺសម្រាប់ជាការសម្តែងចេញនិងថ្វាយសិរីល្អដល់ព្រះ ។ យើងគួរតែចុះចូលចំពោះ រដ្ឋាភិបាលមនុស្ស ដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះ ។

III. ទីតុស ៣:១ និយាយថា "ចូររំឭកគេ ឱ្យចុះចូលនឹងពួកនាម៉ឺន ហើយនឹងពួកមានអំណាចទាំងអស់ ព្រមទាំងស្តាប់បង្គាប់ ហើយប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ" ប្រុងប្រៀបធ្វើការល្អមានន័យថា រស់នៅធ្វើជាទីបន្ទាល់របស់ព្រះ ។

IV. "ថ្ងៃនេះយើងត្រូវរៀនចុះចូលអំណាចព្រះអង្គ រស់នៅក្រោមការគ្រប់គ្រងរបស់ទ្រង់ដោយស្មោះត្រង់ ទ្រង់នឹងប្រទានឱ្យនូវរង្វាន់សិទ្ធអំណាចឫទ្ធិចេស្តា គ្រប់គ្រងលើជាតិសាសន៍រួមគ្នាជាមួយព្រះបុត្រា" បទ ចម្រៀងលេខ ៧៥១( អ ៩៤៧) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៨៩ ការកសាងក្រុមជំនុំឡើង

**ដកស្រង់ពី :**

អេភេសូរ ២:២១-២២ ដែលដោយសារទ្រង់ ដំណាក់ទាំងមូលនោះបានផ្គុំភ្ជាប់គ្នា ទាំងចម្រើនឡើងជាវិហារបរិសុទ្ធក្នុងព្រះអម្ចាស់ ហើយអ្នករាល់គ្នាក៏បានស្អាងឡើងក្នុងទ្រង់ដែរ សម្រាប់ជាលំនៅនៃព្រះដោយនូវព្រះវិញ្ញាណ ។

ជីវិត និង ការកសាង គឺជាគំនិតកណ្តាលនៃបទគម្ពីរ ។ ការកសាងក្រុមជំនុំឡើង គឺអាស្រ័យលើការចម្រើនធំនៅក្នុងជីវិតរបស់យើង ។ ការកសាងក្រុមជំនុំ គឺជារឿងរ៉ាវនៃជីវិត ។ យើងត្រូវការចម្រើនធំនៅក្នុងព្រះអម្ចាស់ និងជួយអ្នកដទៃឱ្យចម្រើនធំ សម្រាប់ការកសាងក្រុមជំនុំឡើង ។

**ខ្លឹមសារ :**

អេភេសូរ ២:២១-២២ ដែលដោយសារទ្រង់ ដំណាក់ទាំងមូលនោះបានផ្គុំភ្ជាប់គ្នា ទាំងចម្រើនឡើងជាវិហារបរិសុទ្ធក្នុងព្រះអម្ចាស់ ហើយអ្នករាល់គ្នាក៏បានស្អាងឡើងក្នុងទ្រង់ដែរ សម្រាប់ជាលំនៅនៃព្រះដោយនូវព្រះវិញ្ញាណ ។

លោកុប្បត្តិ ២:២២ រីឯឆ្អឹងដែលព្រះយេហូវ៉ាដ៏ជាព្រះបានយកពីអ័ដាមមក នោះទ្រង់ជបឱ្យកើតឡើងជាមនុស្សស្រី ក៏នាំទៅឯអ័ដាម ។

វិវរណៈ ២១:២ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីឋានសួគ៌មកអំពីព្រះ តាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី ។

I. ព្រះគម្ពីរចាប់ផ្តើមដោយជីវិត និងការកសាង ។ ច្បាស់ណាស់ដែលព្រះគម្ពីរចប់ដូចដែលពេលចាប់ផ្តើមដោយជីវិត និងការកសាង ដ្បិតជីវិត និងការកសាង គឺជាគំនិតកណ្តាលនៃបទគម្ពីរ—លោកុប្បត្តិ ២:២២; វិវរណៈ ២១:២:

A. មើលពីខាងក្រៅ លោកុប្បត្តិជំពូក ១ និង ២ គឺជាកំណត់ត្រានៃការបង្កបង្កើត ។ តាមពិត បំណងប្រាថ្នារបស់ព្រះ គឺជាការបើកសម្តែងឱ្យឃើញពីជីវិត និងការ កសាងទៅវិញទេ ។

B. នៅលោកុប្បត្តិជំពូក ២ យើងមើលឃើញពីជីវិត ជាសម្ភារៈដែលបន្តចេញពីការហូរនៃជីវិត និង "បានជបឱ្យកើតឡើងជាមនុស្សស្រី"—ខ ២២ ។

C. នៅក្នុងជំពូកពីរចុងក្រោយនៃវិវរណៈ ដែលជាជំពូកពីរចុងក្រោយនៃព្រះគម្ពីរ យើងមើលឃើញការកសាងនៃក្រុងយេរូសាឡិមថ្មី ។ "តាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្តី"—វិវរណៈ ២១:២ ។

**II. ការកសាងក្រុមជំនុំឡើង គឺអាស្រ័យលើការចម្រើនធំនៅក្នុងជីវិតរបស់យើង—អេភេសូរ២:២១-២២ :**

A. ការកសាងក្រុមជំនុំ គឺជារឿងរ៉ាវនៃជីវិត ។ យើងត្រូវការចម្រើនធំនៅក្នុងព្រះអម្ចាស់ និងជួយអ្នកដទៃឱ្យចម្រើនធំ សម្រាប់ការកសាងក្រុមជំនុំឡើង ។

B. ជីវិត គឺជាព្រះអម្ចាស់ទ្រង់ផ្ទាល់ រីឯការកសាង គឺកើតមកពីការបទពិសោធន៍ព្រះ អម្ចាស់ជាជីវិត ។

III. ព្រះទ័យស្រឡាញ់និងប្រាថ្នា ឱ្យក្លាយជាត្បូងដ៏ភ្លឺថ្លា / ហើយនាំមកកសាងរួមគ្នា ជាដំណាក់មានសិរីល្អ / ព្រះគ្រិស្តទ្រង់ជាគ្រប់ទាំងអស់ ឱ្យក្រុមជំនុំបានកសាង / នោះសិរី និងភាពបរិបូរណ៍ បានបំភ្លឺសម្តែងចេញមក (បទចម្រៀងខ្មែរលេខ , ៦០៤ អង់គ្លេសលេខ ៨៣៩) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី៩០ ផ្លូវដែលព្រះជាម្ចាស់បានកំណត់ទុក

**ដកស្រង់ពី:**

អេភេសូរ ៤:១១-១២ ហើយទ្រង់បានប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវក ខ្លះជាគ្រូអធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនិងស្អាងរូបកាយព្រះគ្រិស្តឡើង ។

ផ្លូវខាងព្រះគម្ពីរដើម្បីប្រជុំ និងបម្រើ ជាផ្លូវដែលព្រះបានកំណត់ទុក ។ នៅក្នុងផ្លូវនេះ មនុស្សគ្រប់គ្នា ត្រូវបានធ្វើឱ្យគ្រប់លក្ខណ៍ដើម្បីមានមុខងារប្រើការ ។

**ខ្លឹមសារ:**

អេភេសូរ ៤:១១-១២ ហើយទ្រង់បានប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវក ខ្លះជាគ្រូអធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនិងស្អាងរូបកាយព្រះគ្រិស្តឡើង ។

១៦ ដែលរូបកាយទាំងមូលបានផ្គុំ ហើយភ្ជាប់គ្នាមកអំពីទ្រង់ ដោយសារគ្រប់ទាំងសន្លាក់ដែលផ្គត់ផ្គង់ឱ្យ តាមខ្នាតការងាររបស់អវយវៈនីមួយៗ នោះរូបកាយបានបង្កើនឡើង ដើម្បីនឹងស្អាងខ្លួន ក្នុងសេចក្តីស្រឡាញ់ ។

I. **ផ្លូវដែលព្រះជាម្ចាស់បានកំណត់ទុក គឺធ្វើឱ្យគ្រប់គ្នាបានគ្រប់លក្ខណ៍ ដើម្បីឱ្យមានមុខងារប្រើការ ក្នុងការកសាងរូបកាយព្រះគ្រិស្ត—អេភេសូរ ៤:១១-១២ ។**
   A. ផ្លូវដែលព្រះជាម្ចាស់បានកំណត់ទុក គឺជាផ្លូវដែលល្អឥតខ្ចោះបំផុត ផ្លូវខាងព្រះគម្ពីរ និងជាផ្លូវដែលមានប្រសិទ្ធិភាពបំផុត—ខ១១-១២ ។

B. ផ្លូវនៃការប្រជុំ និងការបម្រើខាងបទគម្ពីរ គឺអាចធ្វើឱ្យអវយវៈរបស់ព្រះគ្រិស្ត ចម្រើនធំក្នុងជីវិត—ខ១៥ ។

C. ដើម្បីប្រជុំ និងបម្រើ ផ្លូវខាងបទគម្ពីរ គឺអាចធ្វើឱ្យមានការកើនឡើងនូវមុខងារប្រើការផ្នែកជីវិត និងបង្កើននូវសមត្ថភាពដល់គ្រប់អវយវៈរបស់ព្រះគ្រិស្តទាំងអស់ ហើយក៏អាចកសាងរូបកាយព្រះគ្រិស្តបានផងដែរ—ខ១២, ១៦ ។

II. **ជំហានទាំង៤នៃផ្លូវដែលព្រះបានកំណត់ទុក—ខ១៦ :**

A. ការស្វែងរក ការសួរសុខទុក្ខ និងការទាក់ទងមនុស្សមានបាប ។

B. ការចិញ្ចឹម និងការថ្នាក់ថ្នមអ្នកថ្មីនៅក្នុងការប្រជុំតាមផ្ទះ ។

C. ការបង្រៀននៅក្នុងការប្រជុំតាមក្រុម ។

D. ការអធិប្បាយនៅក្នុងការប្រជុំក្រុមជំនុំ ។

III. **យើងមិនចាំបាច់ធ្វើអ្វីទាំងអស់ គ្រាន់តែថ្វាយគ្រប់ទាំងអស់ដែលយើងមាន ដើម្បីបន្តព្យាយាមនៅក្នុងការបំពេញសម្រេចតាមផ្លូវថ្មីដែលព្រះបានកំណត់ទុក ។ ប្រសិនបើយើងថ្វាយអស់ទាំងកម្លាំង ព្រមទាំងថវិកាតាមលទ្ធភាពរបស់យើង ហើយគ្រប់មនុស្សនៅលើផែនដីទាំងអស់ ធ្វើចលនានៅក្នុងចិត្តគំនិតតែមួយ នោះតើព្រះអម្ចាស់អាចប្រទានពរដល់យើងច្រើនយ៉ាងណាទៅ !**

IV. **"ព្រះពរដែលទ្រង់ប្រទានមកឱ្យ / គឺថ្មីឥតចាស់សោះឡើយ / ក្តីសន្យាថ្មីឯផ្លូវក៏ថ្មី / គ្រប់យ៉ាងថ្មីទាំងអស់ហើយ ។ / ទ្រង់គឺជាព្រះដែលនៅតែថ្មី / មិនចាស់មិនផ្លាស់ប្តូរថ្មី / ទោះរាប់លានឆ្នាំកន្លងផុតទៅ / ទ្រង់នៅតែថ្មីអស់កល្ប"—(ចម្រៀងខ្មែរ លេខ១១, អង់គ្លេស លេខ ១៦) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី៩១ ជីពចរជីវិតនៅក្នុងការអនុវត្តផ្លូវដែលព្រះបានកំណត់ទុក

**ដកស្រង់ពី:**

កិច្ចការ ៥:៤២ ហើយអ្នកទាំងនោះចេះតែបង្រៀន ព្រមទាំងប្រាប់ដំណឹងល្អរបស់ព្រះយេស៊ូ គ្រិស្ត នៅក្នុងព្រះវិហារ ហើយនៅអស់ទាំងផ្ទះរាល់ថ្ងៃជានិច្ច ។

ក្នុងអំឡុងពេលនៃពួកសាវក ក្រុមជំនុំត្រូវបានកសាងឡើងនៅក្នុងផ្ទះរបស់ពួកអ្នកជឿ ។ នៅពេលយើងបើកផ្ទះរបស់យើង ដំណឹងល្អនឹងមានច្រកចេញមួយ ។ នេះជាហេតុផលដែលយើងត្រូវតែខំប្រឹងខ្នះខ្នែងឱ្យអស់ពីថាមពល កម្លាំង និងពេលវេលាដែលព្រះអម្ចាស់បានប្រទានដល់យើង ដើម្បីស្តារបរិយាកាសនៃផ្ទះយ៉ាងត្រឹមត្រូវ ។

**ខ្ទឹមសារ:**

កិច្ចការ ៥:៤២ ហើយអ្នកទាំងនោះចេះតែបង្រៀន ព្រមទាំងប្រាប់ដំណឹងល្អរបស់ព្រះយេស៊ូ គ្រិស្ត នៅក្នុងព្រះវិហារ ហើយនៅអស់ទាំងផ្ទះរាល់ថ្ងៃជានិច្ច ។

លូកា ៥:២៩ លេវីបានរៀបចំជប់លៀងជាធំថ្វាយទ្រង់នៅផ្ទះគាត់ ហើយមានអ្នកយកពន្ធទាំងហ្វូង និងមនុស្សឯទៀតមកអង្គុយនៅតុជាមួយគ្នាដែរ ។

I. **ក្នុងអំឡុងពេលនៃពួកសាវក ក្រុមជំនុំត្រូវបានកសាងឡើងនៅក្នុងផ្ទះរបស់ពួកអ្នកជឿ—កិច្ចការ ៥:៤២ :**
   A. ជីវិតក្រុមជំនុំនៅក្នុងគ្រាពួកសាវក មានបរិយាកាសយ៉ាងខ្លាំងខ្លាតាមផ្ទះ ។ នេះជាហេតុផលដែលយើងត្រូវតែខំប្រឹងខ្នះខ្នែងឱ្យអស់ពីថាមពល កម្លាំង និងពេលវេលាដែលព្រះអម្ចាស់បានប្រទានដល់យើង ដើម្បីស្តារបរិយាកាសនៃផ្ទះយ៉ាងត្រឹមត្រូវ ។
   B. យើងជាអ្នកនិយាយសម្រាប់ប្រកាសដំណឹងល្អ ផ្ទះរបស់យើងជាច្រកចេញសម្រាប់ប្រកាសដំណឹងល្អ ។

II. **ក្នុងអំឡុងពេលនៃពួកសាវក ក្រុមជំនុំត្រូវបានកសាងឡើងនៅក្នុងផ្ទះរបស់ពួកអ្នកជឿ—កិច្ចការ ៥:៤២ :**

A. លូកាជំពូក ៥ បានឱ្យឧទាហរណ៍យ៉ាងល្អ ។ ដោយការព្រនៃការត្រាស់ហៅរបស់ព្រះអម្ចាស់ លេវីបានបោះបង់ចោលគ្រប់ទាំងអស់ ហើយក្រោកឡើងដើរតាមព្រះអម្ចាស់ ។ តាមផ្លូវនេះគាត់បានទទួលសេចក្តីសង្គ្រោះ ។ ពេលគាត់បានទទួលសេចក្តីសង្គ្រោះ គាត់បានទទួលស្វាគមន៍យ៉ាងធំសម្រាប់ព្រះអម្ចាស់យេស៊ូនៅក្នុងផ្ទះរបស់គាត់—ខ៤៧-៤៩ ។

B. នៅពេលដែលយើងបើកផ្ទះរបស់យើង ដំណឹងល្អនឹងមានច្រកចេញ ។

III. **តាមផ្លូវនេះ ព្រះពរនឹងមិនត្រឹមតែមានដល់យើងប៉ុណ្ណោះទេ តែក៏មានដល់កូនប្រុស និងកូនស្រីរបស់យើង ពីមួយជំនាន់ទៅមួយជំនាន់ផងដែរ—និក្ខមនំ ២០:៦**

A. ខ្ញុំសង្ឃឹមថា យើងទាំងអស់គ្នានឹងបើកផ្ទះរបស់អ្នក ដើម្បីទទួលស្វាគមន៍ដ៏ធំសម្រាប់ព្រះអម្ចាស់យេស៊ូ ដោយគ្រាន់តែអញ្ជើញ "មនុស្សមានបាប" ជាភ្ញៀវរបស់អ្នក ដើម្បីឱ្យអ្នកអាចប្រកាសដំណឹងល្អដល់ពួកគេ—លូកា ៥:៤៧-៤៩ ។

B. ដើម្បីជាប្រយោជន៍នៃភាពអស់កល្បជានិច្ច យើងទាំងអស់គ្នាគួរតែបើកផ្ទះរបស់យើង និងផ្តល់ច្រកចេញសម្រាប់ដំណឹងល្អរបស់ព្រះអម្ចាស់ ។

IV. **"ព្រះអង្គខ្ញុំសូមថ្វាយខ្លួន_កសាងរូបកាយរបស់ទ្រង់_បើកផ្ទះខ្ញុំ បានយុវជន_មើលថៃមនុស្សឱ្យគ្រប់លក្ខ័_ចូលក្រុមជំនុំមានសិរី_ឆាប់ឡើងព្រះអង្គយាងមក"—(កសាងដំណាក់របស់ព្រះ.) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៩២ ការដំណើរជីវិតរស់តែមួយគត់សម្រាប់ដំណឹងល្អ

**ដកស្រង់ពី :**

រ៉ូម ១:១៦ខ "ដំណឹងល្អ គឺជាព្រះចេស្តានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ ។"

ដំណឹងល្អ គឺជាដំណឹងដ៏រីករាយ និងជាដំណឹងល្អនៃសេចក្តីអរសប្បាយដ៏អស្ចារ្យ ដែលព្រះបានសូមឱ្យពួកបាវបម្រើរបស់ទ្រង់ប្រកាសដល់មនុស្សទាំងឡាយ ។ ប្រសិនបើយើងស្មោះត្រង់នឹងព្រះអម្ចាស់ ដោយការដំណើរជីវិតរស់តែមួយគត់សម្រាប់ដំណឹងល្អរបស់ទ្រង់ នោះព្រះអម្ចាស់នឹងប្រទានពរ ។

**ខ្លឹមសារ :**

រ៉ូម ១:១៦ខ ដំណឹងល្អ គឺជាព្រះចេស្តានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ ។

យ៉ូហាន ១៥:១៦ក មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឱ្យទៅបង្កើតផល ហើយឱ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង ។

១កូរិនថូស ៩:១៦-១៧ ពីព្រោះបើខ្ញុំផ្សាយដំណឹងល្អទៅ នោះមិនមែនជាហេតុឱ្យខ្ញុំអួតខ្លួនទេ.....បើខ្ញុំធ្វើដោយស្ម័គ្រពីចិត្ត នោះខ្ញុំបានរង្វាន់ ។

I. **"ដំណឹងល្អ គឺជាព្រះចេស្តានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ"—រ៉ូម ១:១៦ខ :**

A. ដំណឹងល្អ គឺជាព្រះត្រីឯកដែលបានក្លាយជាព្រះវិញ្ញាណគង់នៅក្នុងយើង ធ្វើជាសេចក្ដីសង្គ្រោះ ជីវិត ជីវិតនៃការផ្គត់ផ្គង់ និងជាសេចក្ដីអំណររួមបញ្ចូលគ្រប់ទាំងអស់—ខ៩; ១:១០ ។

B. យើងត្រូវតែទៅសួរសុខទុក្ខ (ទៅលេង) មនុស្សដើម្បីចែកចាយដំណឹងល្អដ៏ខ្ពង់ខ្ពស់ដល់ពួកគេ នោះគឺចែកចាយព្រះត្រីឯកទ្រង់ផ្ទាល់ ដើម្បីបានក្លាយជាជីវិត និងខ្លឹមសាររបស់យើង ។

II. **"មិនមែនអ្នករាល់គ្នាដែលបានរើសខ្ញុំទេ គឺខ្ញុំទេតើ ដែលរើសអ្នករាល់គ្នាវិញ ទាំងតាំងអ្នករាល់គ្នាឱ្យទៅបង្កើតផល ហើយឱ្យផលរបស់អ្នករាល់គ្នាបាននៅជាប់ផង"—យ៉ូហាន ១៥:១៦ក :**

A. ព្រះអម្ចាស់បានបង្គាប់ឱ្យយើងរស់នៅសម្រាប់ដំណឹងល្អនេះតែមួយគត់ ។

B. យើងម្នាក់ៗត្រូវភ្ញាក់ខ្លួនឱ្យមែនទែន ដើម្បីដំណើរជីវិតរស់តែមួយគត់សម្រាប់ដំណឹងល្អ ។

III. **"ពីព្រោះបើខ្ញុំផ្សាយដំណឹងល្អទៅ នោះមិនមែនជាហេតុឱ្យខ្ញុំអួតខ្លួនទេ.....បើខ្ញុំធ្វើដោយស្ម័គ្រពីចិត្ត នោះខ្ញុំបានរង្វាន់"—១កូរិនថូស ៩:១៦-១៧ :**

A. ប្រសិនបើយើងស្មោះត្រង់នឹងព្រះអម្ចាស់ ដោយការដំណើរជីវិតរស់តែមួយគត់សម្រាប់ដំណឹងល្អរបស់ទ្រង់ នោះព្រះអម្ចាស់នឹងប្រទានពរ ។

B. ប្រសិនបើយើងស្វែងរកនគរ និងសេចក្ដីសុចរិតរបស់ព្រះអង្គ នោះព្រះអង្គនឹងប្រទាននគរ និងសេចក្ដីសុចរិតរបស់ទ្រង់មកដល់យើង ព្រមទាំងបន្ថែមនូវរាល់តម្រូវការចាំបាច់ប្រចាំថ្ងៃរបស់យើងថែមទៀត ។

IV. **ចូរស្រង់ពួកអ្នកលិចលង់ និងអ្នកដែលជិតស្លាប់ / ឆក់ចេញពីរណ្ដៅបាបដោយអនុគ្រោះ ចូរយំស្ដាយអ្នកវង្វេង / លើកអ្នកដែលដួលផ្កាប់ ទាំងប្រាប់ពីព្រះយេស៊ូដែលជួយសង្គ្រោះ / *ចូរស្រង់ពួកអ្នកលិចលង់ និងអ្នកដែលជិតស្លាប់ / ព្រះគ្រិស្តទ្រង់សប្បុរស និងប្រោសឱ្យរួច*—(បទចម្រៀងខ្មែរលេខ ៦៦៤ , អង់គ្លេសលេខ ៩២១) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

# ភាគ១០ ការកសាងក្រុមជំនុំ

# វាក្យសព្ទទី ៩៣ ការឃ្វាលហ្វូងចៀមរបស់ព្រះអម្ចាស់

## ដកស្រង់ពី:

យ៉ូហាន ២១:១៦ រួចទ្រង់មានបន្ទូលទៅគាត់ម្តងទៀតថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើស្រឡាញ់ខ្ញុំឬអី គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ទ្រង់មានព្រះបន្ទូលទៅគាត់ថាចូរឃ្វាលហ្វូងចៀមរបស់ខ្ញុំចុះ ។

ការឃ្វាល គឺសំដៅដល់ការយកចិត្តទុកដាក់រាល់តម្រូវការរបស់ចៀម ការថែរក្សាដ៏ទន់ភ្លន់ដែលរួមបញ្ចូលគ្រប់ទាំងអស់ចំពោះហ្វូងចៀម ។ ហើយកាលណាមេគង្វាលលេចមកនោះអ្នករាល់គ្នានឹងទទួលមកុដសិរីដែលមិនចេះស្រពោនឡើយ ។

## ខ្លឹមសារ:

យ៉ូហាន ១០:១១ ខ្ញុំជាអ្នកគង្វាលល្អ ឯអ្នកគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម ។

២១:១៦ រួចទ្រង់មានព្រះបន្ទូលទៅគាត់ម្តងទៀតថា ស៊ីម៉ូន កូនយ៉ូណាសអើយ តើស្រឡាញ់ខ្ញុំឬអី គាត់ទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ ទ្រង់ជ្រាបថា ទូលបង្គំពេញចិត្តនឹងទ្រង់ហើយ ទ្រង់មានព្រះបន្ទូលទៅគាត់ថា ចូរឃ្វាលហ្វូងចៀមរបស់ខ្ញុំ ។

១ពេត្រុស ៥:២-៤ ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ... រួចកាលណាមេពួកអ្នកគង្វាលលេចមក នោះអ្នករាល់គ្នានឹងទទួលមកុដសិរីដែលមិនចេះស្រពោនឡើយ ។

I. "ខ្ញុំជាអ្នកគង្វាលល្អ ឯអ្នកគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម"—យ៉ូហាន ១០:១១ :

A. ព្រះគ្រិស្ត គឺជាមេគង្វាល ជាអ្នកគង្វាលដ៏ធំ ជាអ្នកគង្វាលល្អ ។

B. ព្រះអម្ចាស់នៃយើងទ្រង់ឃ្វាលយើងរាល់គ្នា ដោយការថែរក្សាដែលធ្វើឱ្យចម្រើនឡើងនៅផ្នែកខាងក្នុងរបស់យើង ។

C. ១ពេត្រុស ២:២៥ ប្រាប់យើងថា មេគង្វាលគឺជាអ្នកគង្វាលនៃព្រលឹងរបស់យើង ។ ព្រលឹងរបស់យើងគឺជាខ្លួនផ្នែកខាងក្នុងរបស់យើង ជាបុគ្គលដ៏ពិតរបស់យើង ។

II. **"ទ្រង់មានព្រះបន្ទូលទៅគាត់ថា ចូរឃ្វាលហ្វូងចៀមរបស់ខ្ញុំចុះ"—យ៉ូហាន ២១:១៦ :**

A. ការឃ្វាល គឺសំដៅដល់ការយកចិត្តទុកដាក់រាល់តម្រូវការរបស់ហ្វូងចៀម ការថែរក្សាដ៏ទន់ភ្លន់ដែលរួមបញ្ចូលគ្រប់ទាំងអស់ចំពោះហ្វូងចៀម ។

B. នៅក្នុងយ៉ូហាន ២១:១៥ ព្រះអម្ចាស់បានបង្គាប់យើងរាល់គ្នាឱ្យចំណីកូនចៀមរបស់ទ្រង់ ។

C. យើងមិនគ្រាន់តែជាហ្វូងចៀមទេ តែយើងក៏ជាហ្វូងអ្នកគង្វាលផងដែរ ។

III. **ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ... រួចកាលណាមេពួកអ្នកគង្វាលបានលេចមក នោះអ្នករាល់គ្នានឹងទទួលមកុដសិរីដែលមិនចេះស្រពោនឡើយ"—១ពេត្រុស ៥:២-៤ ។**

IV. **ព្រះអង្គជាអ្នកគង្វាលរបស់ខ្ញុំ ឱ្យខ្ញុំឈប់សម្រាកក្នុងទ្រង់ ព្រះបាននាំខ្ញុំទៅក្បែរមាត់ទឹកហូរ ទ្រង់ស្ដុកព្រះទ័យទ្រង់បរិបូរ ។ (បទចម្រៀងខ្មែរ ទំព័រ៨៨៤, អង់គ្លេសលេខ ១១៧០) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៩៤ ក្រុមទ្រទ្រង់ជីវិត

**ដកស្រង់ពី :**

កិច្ចការ ២:៤២ អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀនរបស់ពួកសាវក ហើយក្នុងសេចក្ដីប្រកបគ្នា ព្រមទាំងការកាច់នំប៉័ង និងសេចក្ដីអធិដ្ឋានផង ។

ក្រុមទ្រទ្រង់ជីវិត គឺជាក្រុមគ្រិស្ទានប្រក្រតី ។ ក្រុមទ្រទ្រង់ជីវិត អាចចូលមកបានតែពួកបរិសុទ្ធដែលមានចិត្តអន្ទះសា និងដាច់ខាតចំពោះការកើនឡើងនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់ប៉ុណ្ណោះ ។ ពួកយើងគួរតែចម្រើនកម្លាំងក្រុមទ្រទ្រង់ជីវិត ដោយធ្វើឱ្យក្រុមទ្រទ្រង់ជីវិត ស្រស់ស្អាត ខ្ពង់ខ្ពស់ និងគួរឱ្យទាក់ទាញ ។

ខ្លឹមសារ :

កិច្ចការ ២:៤២ អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្ដីបង្រៀនរបស់ពួកសាវក ហើយក្នុងសេចក្ដីប្រកបគ្នា ព្រមទាំងការកាច់នំប៉័ង និងសេចក្ដីអធិដ្ឋានផង ។

៤៦-៤៧ រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា ឯកាលនៅផ្ទះ ក៏កាច់នំប៉័ង ហើយបរិភោគអាហារ ដោយអំណរ និងចិត្តស្មោះត្រង់ ។ ព្រមទាំងសរសើរដល់ព្រះ ហើយបណ្ដាជនទាំងអស់គ្នាក៏រាប់អានគេ ចំណែកព្រះអម្ចាស់ ទ្រង់ក៏បន្ថែមនូវអស់អ្នក ដែលកំពុងតែបានសង្គ្រោះរាល់តែថ្ងៃ ទៅក្នុងពួកជំនុំថែមទៀត ។

I. ក្រុមទ្រទ្រង់ជីវិត គឺជាខ្សែជីវិតនៃផ្លូវដែលព្រះបានកំណត់ទុក—កិច្ចការ ២:៤២, ៤៦-៤៧:
   A. ក្រុមទ្រទ្រង់ជីវិត គឺជាក្រុមគ្រិស្ទានប្រក្រតី ។ ក្រុមទ្រទ្រង់ជីវិត អាចចូលមកបានតែពួកបរិសុទ្ធដែលមានចិត្តអន្ទះសា និងដាច់ខាតចំពោះការកើនឡើងនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់ប៉ុណ្ណោះ ។

B. បងប្អូនបរិសុទ្ធដែលដែលមានចិត្តអន្ទះសាបែបនេះ នឹងទាក់ទងមនុស្សដទៃដោយស្ម័យប្រវត្ត តាមរយៈការដឹកនាំរបស់ព្រះអម្ចាស់ និងទទួលបានដៃគូ រឺដៃគូមួយចំនួន ដើម្បីឱ្យគាត់មានក្រុមទ្រទ្រង់ជីវិត ។

II. ក្រុមទ្រទ្រង់ជីវិត គឺការរស់នៅដែលពោពេញទៅដោយសកម្មភាព—ខ៤៦-៤៧:

A. ដើម្បីក្លាយជាមនុស្សរស់រវើក ជាដំបូង យើងត្រូវតែមានការប្រកបយ៉ាងហ្មត់ចត់ជាមួយព្រះអម្ចាស់ ។

B. ដើម្បីបានបណ្តាលនៅក្នុងសេចក្តីស្រឡាញ់ដ៏ល្អបំផុតចំពោះព្រះអម្ចាស់ តាមរយៈការប្រែចិត្តអធិដ្ឋាន ។

C. ដើម្បីធ្វើឱ្យមានការសារភាពបាបយ៉ាងហ្មត់ចត់ចំពោះព្រះអម្ចាស់ ។

D. ដើម្បីមានភាពស្និទ្ធស្នាល ជិតស្និទ្ធ និងប្រកបយ៉ាងហ្មត់ចត់ជាមួយព្រះអម្ចាស់ ព្រមទាំងការស្វែងរកពួកបរិសុទ្ធ ។

III. យើងគួរតែចំណាយរាល់ដំណក់ឈាម រាល់កម្លាំងបន្តិចបន្តួច និងរាល់នាទីនៃពេលវេលារបស់យើង ដើម្បីចម្រើនកម្លាំងក្រុមទ្រទ្រង់ជីវិត ដោយធ្វើឱ្យក្រុមទ្រទ្រង់ជីវិត ស្រស់ស្អាតខ្ពង់ខ្ពស់ និងគួរឱ្យទាក់ទាញ—វិវរណៈ ៣:៨ ។

IV. "គ្រប់ទាំងអស់ខ្ញុំថ្វាយព្រះយេស៊ូ ថ្វាយសព្វគ្រប់ដាច់ដល់ព្រះអង្គ_ខ្ញុំមានចិត្តស្រឡាញ់ទ្រង់ស្មោះត្រង់_ទាំងជីវិតក៏ថ្វាយទ្រង់ផង ។ បន្ទរ. គ្រប់ទាំងអស់ខ្ញុំថ្វាយ_ថ្វាយដាច់ដល់ព្រះអង្គ_ថ្វាយទាំងខ្លួនជីវិតវិញ្ញាណផង_ថ្វាយដាច់ដល់ព្រះអង្គ"—(បទចម្រៀង៣៣៧, អង់គ្លេស ៤៩១ ) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី៩៥ ការប្រជុំក្រុម

**ដកស្រង់ពី :**

ហេព្រើរ ១០:២៤-២៥ ហើយត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឱ្យមានសេចក្តីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ។

ការប្រជុំក្រុម គឺជាការប្រជុំគ្នាទៅវិញទៅមក ដែលមានពួកបរិសុទ្ធទាំងអស់ចូលរួម ។ នៅពេលយើងមកជាមួយគ្នានៅក្នុងការប្រជុំក្រុម យើងបណ្តាល (ជំរុញ) និងកម្លាចិត្តគ្នាទៅវិញទៅមក ។ យើងគួរតែចែករំលែកសេចក្តីអំណររបស់យើង ក៏ដូចជាការរងទុក្ខរបស់យើងដែរ ។

ខ្លឹមសារ:

ហេព្រើរ ១០:២៤-២៥ ហើយត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឱ្យមានសេចក្តីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឱ្យកម្លាចិត្តគ្នាវិញ ។

កិច្ចការ ២:៤៦ រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង ហើយបរិភោគអាហារ ដោយអំណរនឹងចិត្តស្មោះត្រង់ ។

I. ការប្រជុំក្រុម គឺជាខ្សែជីវិតនៃផ្លូវដែលព្រះបានកំណត់ទុក—ហេព្រើរ ១០:២៥; កិច្ចការ ២:៤៦:

A. ការប្រជុំក្រុម គឺជាការប្រជុំផ្ទាល់ខ្លួនរបស់យើង និងជាខ្សែជីវិតនៃផ្លូវដែលព្រះបានកំណត់ទុក—ហេព្រើរ ១០:២៤-២៥ ។

B. ៨០ភាគរយ ជីវិតក្រុមជំនុំ គឺពឹងផ្អែកលើការប្រជុំក្រុម—ខ២៤-២៥; កិច្ចការ ២:៤៦ ។

II. “**ហើយត្រូវឱ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឱ្យមានសេចក្ដីស្រឡាញ់ ហើយឱ្យប្រព្រឹត្តការល្អផង”—ហេព្រើរ ១០:២៤**; កិច្ចការ ២:៤៦ :

A. ការប្រជុំក្រុម គឺជាការប្រជុំគ្នាទៅវិញទៅមកដែលមានពួកបរិសុទ្ធទាំងអស់ចូលរួម ។ មនុស្សគ្រប់គ្នាអាចប្រកប សូមអង្វរ ផ្ដល់នូវការយកចិត្តទុកដាក់ និងការថែរក្សា (ការឃ្វាល) គ្នាទៅវិញទៅមក ហើយនៅក្នុងការប្រជុំក្រុម ទាំងអស់គ្នាសុទ្ធតែជាគ្រូបង្រៀន—ហេព្រើរ ១០:២៤ ។

B. យើងបណ្ដាល (ជំរុញ) និងកម្លាចិត្តគ្នាទៅវិញទៅមក ។ បងប្អូនកម្លាចិត្តខ្ញុំ រីឯខ្ញុំកម្លាចិត្តបងប្អូន ។ បងប្អូនរៀន ឯខ្ញុំក៏រៀនដែរ—ខ២៤; កូល៉ុស ៣:១៦ ។

C. ពេលយើងជួបជុំគ្នាជាក្រុមតូចមួយ យើងអាចប្រកបអំពីបញ្ហា និងបន្ទុករបស់យើងដោយមានការយកចិត្តទុកដាក់ស្និទ្ធស្នាលចំពោះគ្នាទៅវិញទៅមក ។ យើងគួរតែចែករំលែកសេចក្ដីអំណររបស់យើង ក៏ដូចជាការរងទុក្ខរបស់យើងដែរ—ហេព្រើរ ១០: ២៤-២៥ ។

III. **“ហ្វឹកហាត់ប្រើប្រាស់វិញ្ញាណ_បដិសធគំនិត_រាល់ពេលប្រជុំស្នាលស្និទ្ធ_នេះជាគន្លឹះពិត_ហ្វឹកហាត់ប្រើប្រាស់វិញ្ញាណ_បដិសេធសាសនា_ប្រកបរួមមានចំណែក_ព្រះគ្រិស្តជាគ្រប់ផ្នែក”—( បទចម្រៀង ៦២៨,អង់គ្លេស ៨៦៦ ) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៩៦ ការប្រជុំតុព្រះអម្ចាស់

**ដកស្រង់ពី:**

១កូរិនថូស ១១:២៣-២៥ ព្រះអម្ចាស់យេស៊ូ...បានយកនំប៉័ង...ក៏កាច់នំប៉័ង ដោយបន្ទូលថា ចូរយកពិសាចុះ នេះជារូបកាយខ្ញុំ...នោះទ្រង់ក៏យកពែងបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះ ជាសញ្ញាថ្មី ដោយនូវឈាមខ្ញុំ...ចូរធ្វើដូច្នេះរាល់វេលាណា ដែលផឹក ទុកជាសេចក្តីរំឭកដល់ខ្ញុំ ។

ការប្រជុំដែលសំខាន់ជាងគេបំផុត គឺការប្រជុំតុព្រះអម្ចាស់ ដែលជាការប្រជុំតែមួយគត់ ដែលអាចឱ្យយើងថ្វាយការរំឭកដល់ទ្រង់ ។ គ្រប់ពេលដែលយើងរំឭកពីទ្រង់ សូមឱ្យយើងបរិភោគ ផឹក និងទទួលអំណរទ្រង់ ។

**ខ្លឹមសារ:**

១កូរិនថូស ១១:២៣-២៥ ព្រះអម្ចាស់យេស៊ូ...បានយកនំប៉័ង...ក៏កាច់នំប៉័ង ដោយបន្ទូលថា ចូរយកពិសាចុះ នេះជារូបកាយខ្ញុំ...នោះទ្រង់ក៏យកពែងបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះ ជាសញ្ញាថ្មី ដោយនូវឈាមខ្ញុំ...ចូរធ្វើដូច្នេះរាល់វេលាណា ដែលផឹក ទុកជាសេចក្តីរំឭកដល់ខ្ញុំ ។

I. **ការប្រជុំដែលសំខាន់ជាងគេបំផុត គឺការប្រជុំតុព្រះអម្ចាស់—១កូរិនថូស ១១:២៣-២៥; កិច្ចការ ២:៤១-៤២ :**
   A. ការប្រជុំតុព្រះអម្ចាស់ គឺជាការប្រជុំតែមួយគត់ ដែលអាចឱ្យយើងថ្វាយការអរព្រះគុណ ការសរសើរ ការថ្វាយបង្គំ និងការរំឭកពីព្រះអម្ចាស់ទ្រង់ផ្ទាល់ ។ គ្មានអ្វីដែលសំខាន់ជាងការនេះឡើយ—១កូរិនថូស ១១:២៣-២៥ ។
   B. គ្រប់ពេលដែលយើងរំឭកពីទ្រង់ សូមឱ្យយើងបរិភោគ ផឹក និងទទួលអំណរទ្រង់នៅផ្ទៃកខាងក្នុង បន្ទាប់មកសូមឱ្យយើងទទួលយកភាពបរិបូររបស់ទ្រង់ត្រឡប់មកវិញ

ជាមួយយើង ដើម្បីឱ្យយើងមានទ្រង់ជាទីស្កប់ចិត្ត សេចក្តីរីករាយ និងការផ្គត់ផ្គង់របស់យើង—ខ២៣-២៥; យ៉ូហាន ៦:៣៥,៤៨ ។

II. **"ព្រះអម្ចាស់យេស៊ូ...បានយកនំបុ័ង... ក៏កាច់នំបុ័ង ដោយបន្ទូលថា ចូរយកពិសាចុះ នេះជារូបកាយខ្ញុំ...នោះទ្រង់ក៏យកពែងបែបដូច្នោះដែរ ដោយបន្ទូលថា ពែងនេះ ជាសញ្ញាថ្មីដោយនូវឈាមខ្ញុំ...ចូរធ្វើដូច្នេះរាល់វេលាណា ដែលផឹក ទុកជាសេចក្តីរំឭកដល់ខ្ញុំ "—១ កូរិនថូស ១១:២៣-២៥ :**

A. ការប្រជុំកាច់នំបុ័ង គ្មានអ្វីផ្សេងក្រៅពីការរំឭកពីព្រះអង្គឡើយ ។ លើសពីនេះ គឺដើម្បីទទួលអំណរព្រះអម្ចាស់ និងគ្រប់ការទាំងអស់ដែលទ្រង់បានបំពេញសម្រេចសម្រាប់យើង ។

B. ការប្រជុំនេះ គឺបែងចែកជាពីរផ្នែក ផ្នែកទី១ សម្រាប់ការរំឭកពីព្រះអម្ចាស់ ហើយផ្នែកចុងក្រោយ គឺសម្រាប់ថ្វាយបង្គំព្រះវរបិតា—ខ២៣-២៥ ; ហេព្រើរ ២:១២ ។

C. ដើម្បីទទួលអំណរព្រះអម្ចាស់ជាការផ្គត់ផ្គង់របស់យើង គឺដោយការបរិភោគនំបុ័ង ហើយដើម្បីទទួលព្រះពរមកពីព្រះ គឺដោយការផឹកពែង—យ៉ូហាន ៦:៣៥, ៤៨ ។

III. **យើងហូបនំបុ័ងហើយផឹកពែងនេះ / ទទួលក្តីសុខជីវិតព្រះអង្គ / វិញ្ញាណស្រូបចូលទទួលយកទ្រង់ / ខ្ញុំភ្លក់រស់ជាតិជីវិតអស្ចារ្យ ។/ ខ្ញុំតាំងចិត្តហូបហើយផឹកព្រះអង្គ / វិញ្ញាណទទួលទ្រង់ឡើងជាទ្វេ / រហូតពោរពេញដោយទ្រង់ក្នុងកាយ / ទ្រង់ប្រទានឱ្យព្រះពរជីវិត—(បទចម្រៀងខ្មែរលេខ ១៧៧ , អង់គ្លេសលេខ ២៣៣)**

# ការបកស្រាយពន្យល់សង្ខេបនៃការស្ដារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៩៧ ការប្រជុំអធិប្បាយ

**ដកស្រង់ពី:**

១កូរិនថូស ១៤:៣១ ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា តែត្រូវសម្ដែងម្នាក់ម្ដងៗ ដើម្បីឱ្យគ្រប់គ្នាបានរៀនតាម ហើយឱ្យគ្រប់គ្នាបានសេចក្ដីទូន្មានដែរ ។

ការអធិប្បាយ គឺការនិយាយសម្រាប់ព្រះគ្រិស្ដ និងជាការនិយាយព្រះគ្រិស្ដចេញ ដើម្បីចែកចាយព្រះគ្រិស្ដទៅដល់មនុស្ស ។ ពួកអ្នកជឿទាំងអស់មានសមត្ថភាពអធិប្បាយ បន្ទាប់មកអ្នកទាំងអស់គ្នា នឹងរៀនតាម ហើយឱ្យគ្រប់គ្នាបានសេចក្ដីទូន្មានដែរ នោះលទ្ធផលគឺថាអ្នកទាំងអស់គ្នា នឹងត្រូវបានផ្គត់ផ្គង់ រីឯក្រុមជំនុំនឹងត្រូវបានកសាងឡើង ។

**ខ្លឹមសារ :**

១កូរិនថូស ១៤:៣១ ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា តែត្រូវសម្ដែងម្នាក់ម្ដងៗ ដើម្បីឱ្យគ្រប់គ្នាបានរៀនតាម ហើយឱ្យគ្រប់គ្នាបានសេចក្ដីទូន្មានដែរ ។

២៦ កាលណាអ្នករាល់គ្នាប្រជុំ នោះគ្រប់គ្នាមានទំនុកតម្កើង មានសេចក្ដីបង្រៀន មានសេចក្ដីបើកសម្ដែង មាននិយាយភាសាដទៃ មានសេចក្ដីបកប្រែដែរ ត្រូវឱ្យធ្វើការទាំងអស់សម្រាប់នឹងស្អាងចិត្តឡើង ។

I. **ការអធិប្បាយ គឺជាការនិយាយសម្រាប់ព្រះគ្រិស្ដ និងនិយាយព្រះគ្រិស្ដចេញ ដោយការបម្រើ និងការចែកចាយព្រះគ្រិស្ដទៅដល់មនុស្ស—១កូរិនថូស ១៤:៣-៤ :**

   A. មធ្យោបាយដ៏ល្អបំផុត ដើម្បីការកសាងក្រុមជំនុំ គឺការអធិប្បាយ នោះគឺការនិយាយសម្រាប់ព្រះគ្រិស្ដ និងការនិយាយព្រះគ្រិស្ដចេញ ដោយការបម្រើ និងការចែកចាយព្រះគ្រិស្ដទៅដល់មនុស្ស ដូចគ្នានឹងអ្នកបម្រើចែកចាយម្ហូបអាហារដែរ—ខ៣-៤ ។

B. មុខងារដ៏ខ្ពស់បំផុតនៅក្នុងការប្រជុំក្រុមជំនុំ គឺការអធិប្បាយ ដ្បិតការអធិប្បាយ គឺជាការនិយាយព្រះជាអង្គធាតុចិញ្ចឹមចូលទៅកាន់អ្នកដទៃ—ខ១២ ។

II. **"ដ្បិតអ្នករាល់គ្នាមានច្បាប់នឹងអធិប្បាយបានទាំងអស់គ្នា តែត្រូវសម្ដែងម្នាក់ម្ដងៗ ដើម្បីឱ្យគ្រប់គ្នាបានរៀនតាម ហើយឱ្យគ្រប់គ្នាបានសេចក្ដីទូន្មានដែរ"—ខ៣១ :**

A. ពួកអ្នកជឿទាំងអស់មានសមត្ថភាពអធិប្បាយ ។ គ្រប់ភាពបរិបូរណ៍របស់ព្រះគ្រិស្ដទាំងអស់ ត្រូវបានបញ្ចេញមកតាមរយៈការអធិប្បាយរបស់អវយវៈរបស់ព្រះគ្រិស្ដទាំងអស់ នោះលទ្ធផលគឺថា អ្នកទាំងអស់គ្នា នឹងត្រូវបានផ្គត់ផ្គង់ រីឯក្រុមជំនុំនឹងត្រូវបានកសាងឡើង—ខ២៦, ៣១ ។

B. ឧបមាថា បងប្អូនប្រុសស្រីទាំងអស់គ្នាអាចអធិប្បាយ ឯអ្នកទាំងអស់គ្នាអាចធ្វើបទបង្ហាញពីភាពបរិបូរខ្លះៗ ការនេះនឹងបានដូចជាពិធីលៀងដ៏មានសេចក្ដីស្រឡាញ់នៅក្នុងក្រុមជំនុំ ដែលគ្រប់គ្នានាំយកម្ហូប ពេលដែលគ្រប់គ្នានាំយកអ្វីម្យ៉ាង នោះពិធីលៀងដ៏មានសេចក្ដីស្រឡាញ់ ប្រាកដជានឹងមានភាពបរិបូរណ៍—ខ២៦ ។

III. **"ចូរដេញតាមសេចក្ដីស្រឡាញ់ចុះ ហើយសង្វាតចង់បានទាំងអំណោយទានខាងឯវិញ្ញាណដែរ តែស៊ូឱ្យចេះអធិប្បាយជាដើម"—ខ១ ។**

IV. **នំប៉័ងនេះថែមទាំងអធិប្បាយ / អាថ៌កំបាំងនៃរូបកាយ / យើងជាចំណែកដែលមានជីវិត / ជាតែមួយនឹងទ្រង់ពិត / យើងរួបរួមគ្នាដោយនំប៉័ងនេះ / ទ្រង់សព្វព្រះទ័យដូច្នេះ / ពួកបរិសុទ្ធរួមប្រកបគ្នា / សម្ដែងភាពបរិបូរ ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ៩៨ ការថ្វាយទ្រព្យសម្បត្តិ

**ដកស្រង់ពី:**

កិច្ចការ ២០:៣៥ ហើយនឹងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូ ដែលទ្រង់មានបន្ទូលថា ដែលឱ្យ នោះបានពរជាជាងទទួល ។

វិធីដែលដ៏ល្អបំផុតដើម្បីទទួលបានពរខាងសំភារៈបរិបូរពីព្រះ នោះគឺ ឱ្យ ។ ការឱ្យ គឺមានពរជាងទទួល ។ ប្រសិនបើយើងពិតជាថ្វាយគ្រប់ទាំងអស់ទៅចំពោះព្រះ នូវអ្វីដែលជារបស់ទ្រង់ នោះព្រះជាម្ចាស់នឹងចាក់ព្រះពរដល់យើងជាមិនខាន ។ ទ្រង់នឹងវាល់មកឱ្យយើងវិញ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឱ្យហៀរ នឹងយកមកដាក់បំពេញចិត្តយើងផង ។

**ខ្លឹមសារ:**

| | |
|---|---|
| លូកា ៦:៣៨ | ចូរឱ្យទៅគេ នោះនឹងបានឱ្យមកអ្នកដែរ គេនឹងវាល់ឱ្យអ្នកយ៉ាងល្អ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឱ្យហៀរ នឹងយកមកដាក់បំពេញចិត្តអ្នកផង ដ្បិតគេនឹងវាល់ឱ្យអ្នក តាមរង្វាល់ណាដែលអ្នកវាល់ឱ្យគេ ។ |
| កិច្ចការ ២០:៣៥ | ហើយនឹងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូ ដែលទ្រង់មានបន្ទូលថា ដែលឱ្យ នោះបានពរជាជាងទទួល ។ |

I. **"ចូរឱ្យទៅគេ នោះនឹងបានឱ្យមកអ្នកដែរ គេនឹងវាល់ឱ្យអ្នកយ៉ាងល្អ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឱ្យហៀរ នឹងយកមកដាក់បំពេញចិត្តអ្នកផង ដ្បិតគេនឹងវាល់ឱ្យអ្នក តាមរង្វាល់ណាដែលអ្នកវាល់ឱ្យគេ"—លូកា ៦:៣៨ :**

   A. នេះជាសេចក្តីសន្យាដែលបានមានបន្ទូលចេញពីព្រះឱស្ឋព្រះមក ប្រសិនបើយើងស្ម័គ្រចិត្តចែកទ្រព្យសម្បត្តិរបស់យើង ចំពោះតម្រូវការសម្រាប់ជាផលប្រយោជន៍របស់ព្រះ នោះទ្រង់នឹងប្រទានមកយើងវិញជាទីពេញចិត្តផង ។

B. នេះជាអ្វីដែលបរិបូរណ៍ និងហូរហៀរ គឺទាំងញាត់ ទាំងរលាក់ ហើយដាក់ឱ្យហៀរ ទ្រង់នឹងមិនប្រទានមកក្នុងដៃយើងវិញ នូវអ្វីដែលបន្តិចបន្តួច និងមានកំណត់នោះទេ ។ អ៊ូ! តើនេះជាការចំណេញមកវិញយ៉ាងណាទៅ!—ខ៣៨ ។

II. **"ត្រូវចងចាំព្រះបន្ទូលរបស់ព្រះអង្គម្ចាស់យេស៊ូ ដែលបានមានបន្ទូលដោយអង្គទ្រង់ផ្ទាល់ថា ដែលឱ្យ នោះបានពរជាជាងទទួល"—កិច្ចការ ២០:៣៥ :**

A. នៅក្នុងព្រះនេត្យរបស់ព្រះ ដូចជាជង្វាយ គឺជាប្រភេទនៃការសាបព្រោះ ដែលនឹងអាចទទួលផលដោយការច្រូត ។ នណារដែលព្រោះតិច នោះនឹងច្រូតបានតិច ហើយអ្នកណាដែលព្រោះច្រើន នោះនឹងច្រូតបានច្រើន ។

B. វិធីដ៏ល្អបំផុតដើម្បីទទួលបានពរខាងសំភារៈបរិបូរពីព្រះ នោះគឺឱ្យ មិនមែនទទួលទេ ដូច្នេះហើយព្រះអម្ចាស់ទ្រង់ផ្ទាល់បានសន្យាថា ការដែលឱ្យ គឺមានពរជាងទទួល—ខ៣៥ ។

III. **"ចូរនាំយកជង្វាយ១ភាគក្នុង១០ទាំងអស់ មកដាក់ក្នុងឃ្លាំងចុះ ដើម្បីឱ្យមានស្បៀងអាហារនៅក្នុងដំណាក់នៃអញ ហើយល្បងលអញឥឡូវ បើអញមិនបើកទ្វារឋានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ នេះហើយជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ"—ម៉ាឡាគី ៣:១០ ។**

IV. **"គ្រប់ទាំងអស់ខ្ញុំថ្វាយព្រះយេស៊ូ ឥតសំចៃទុកអ្វីមួយសោះ សូមព្រះអង្គយាងមកមេត្តាប្រោស ដោយព្រះទ័យស្រឡាញ់សន្តោស គ្រប់ទាំងអស់ខ្ញុំថ្វាយ ថ្វាយដាច់ដល់ព្រះអង្គ ថ្វាយទាំងខ្លួនជីវិតវិញ្ញាណផងថ្វាយដាច់ដល់ព្រះអង្គ"—(បទចម្រៀងលេខ ៣៣៧, អង់គ្លេសលេខ ៤៨១) ។**

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១០ ការកសាងក្រុមជំនុំ

## វាក្យសព្ទទី៩៩ ការចូលរួមនៅក្នុងការប្រជុំធំៗ និងការហ្វឹកហ្វឺនទាំងឡាយ

**ដកស្រង់ពី:**

អេភេសូរ ៤:១២ ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រិស្តឡើង ។

យើងត្រូវការការប្រជុំធំៗតាមកាលកំណត់ ដើម្បីជំរុញ និងលើកទឹកចិត្តដល់ពួកបរិសុទ្ធ ហើយនិងដើម្បីបើកភ្នែកពួកអ្នកដែលមានចិត្តស្វែងរក ។ យើងក៏ត្រូវតែបានហ្វឹកហ្វឺនផងដែរ ប្រយោជន៍ឱ្យយើងអាចចម្រើនធំនៅក្នុងជីវិត ដើម្បីក្លាយជាមនុស្សមានជំនាញនៅក្នុងមុខងារប្រើការ និងមានប្រយោជន៍កាន់តែច្រើននៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។

**ខ្លឹមសារ :**

អេភេសូរ ៤:១១-១២ ហើយទ្រង់បានប្រទានឱ្យអ្នកខ្លះបានធ្វើជាសាវក ខ្លះជាគ្រូអធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន ។ ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រិស្តឡើង ។

I. **"ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សម្រាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រិស្តឡើង"—អេភេសូរ៤:១២ :**
   A. ការធ្វើឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង គឺជាការធ្វើឱ្យគាត់ពេញបរិបូរណ៍ ធ្វើឱ្យគាត់បានប្រដាប់ខ្លួន និងធ្វើឱ្យគាត់បានរៀបគ្រប់ប្រដាប់ ។
   B. យើងដែលជាពួកអ្នកជឿ ត្រូវតែបានគ្រប់លក្ខណ៍ឡើង ដើម្បីមានមុខងារប្រើការនៅក្នុងរូបកាយរបស់ព្រះគ្រិស្ត រហូតដល់ការកសាងឡើងនៃរូបកាយរបស់ព្រះគ្រិស្ត—ខ១២ ។

II. នៅក្នុងចលនាថ្មីរបស់ព្រះអម្ចាស់នៅក្នុងក្រុមជំនុំ យើងត្រូវការការប្រជុំធំៗតាមកាលកំណត់ ដ្បិតការជួបជុំប្រភេទនេះ ជំរុញ និងលើកទឹកចិត្តដល់ពួកបរិសុទ្ធ—កិច្ចការ ២:៤០-៤១ :

A. ការប្រជុំធំៗ ជំរុញ និងលើកទឹកចិត្តដល់ពួកបរិសុទ្ធ ។ ការនេះនឹងបើកភ្នែកពួកអ្នកមានចិត្តស្វែងរកឱ្យមើលឃើញអ្វីមួយបន្ថែមទៀត ។

B. ពួកគេត្រូវបានប្រដាប់ខ្លួន ដើម្បីទ្រូបន្ទុកកាន់តែច្រើន សម្រាប់ព្រះអម្ចាស់ ហើយពួកគេនឹងទទួលបានទស្សនៈនៃចលនារបស់ព្រះអម្ចាស់កាន់តែទូលំទូលាយ ។

III. យើងត្រូវតែបានហ្វឹកហ្វឺន សម្រាប់ការអនុវត្តន៍ជីវិតក្រុមជំនុំ ដើម្បីឱ្យមានប្រយោជន៍កាន់តែច្រើននៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់—អេភេសូរ ៤:១១-១២ :

A. ការបានហ្វឹកហ្វឺន គឺការមានការផ្គត់ផ្គង់ដ៏បរិបូរណ៌នៃព្រះគ្រិស្ត បានចែកចាយដល់យើង ដើម្បីឱ្យយើងអាចចម្រើនធំ—កូល៉ុស ២:១៩ ។

B. ហើយក៏ត្រូវបានប្រដាប់ខ្លួន ដើម្បីឱ្យយើងអាចមានជំនាញក្នុងមុខងារប្រើការ—អេភេសូរ ៤:១៦ ។

IV. "ម្ចាស់ខ្ញុំមិនគ្រាន់តែជាង_ស្មូនជាអ្នកកសាងដ៏វិសិរី_ថែមទាំងស្មូនខ្ញុំនឹងកែឆ្នៃ_តុបតែងខ្ញុំឱ្យល្អប្រពៃ_ខ្ញុំមិនគ្រាន់តែជាមនុស្សដី_តែជាត្បូងដែលកសាងថ្មី_មិនគ្រាន់តែជាភាជនៈដីតែជាព្រះវិហារស្តឹមស្តៃ_មិនគ្រាន់តែជាភាជនៈដីតែជាព្រះវិហារស្តឹមស្តៃ"—( បទចម្រៀង ៦០៤, អង់គ្លេស៨៤០) ។

# ការបកស្រាយពន្យល់សង្ខេបនៃការស្តារឡើងវិញរបស់ព្រះអម្ចាស់—១០០វាក្យសព្ទ

## ភាគ១0 ការកសាងក្រុមជំនុំ

## វាក្យសព្ទទី ១០០ ការរួមបញ្ចូលនៃរូបកាយព្រះគ្រិស្ត

**ដកស្រង់ពី :**

១កូរិនថូស ១២:២៤ តែអវយវៈណារបស់យើងដែលល្អមើល នោះមិនត្រូវការអ្វីទេ ដូច្នេះ ព្រះទ្រង់បានផ្សំរូបកាយ ព្រមទាំងប្រទានឱ្យអវយវៈណាដែលខ្វះ បានប្រសើរលើសជាងទៅទៀត ។

បានរួមបញ្ចូល (បានផ្សំ) បង្កប់ន័យពីការបាត់បង់នៃភាពខុសៗគ្នា ព្រះបានរួមបញ្ចូលពួកអ្នកជឿទាំងអស់ ។ ដូច្នេះ ពួកអ្នកដែលមិនល្អមើលចែករំលែកភាពសមសួនជាមួយពួកអ្នកដែលល្អមើល ហើយពួកអ្នកខ្លាំងជាងចិញ្ចឹម និងផ្គត់ផ្គង់ពួកអ្នកខ្សោយជាង ។ បន្ទាប់មកទើបយើងមានរូបកាយ ។

**ខ្លឹមសារ:**

១កូរិនថូស ១២:២៤ តែអវយវៈណារបស់យើងដែលល្អមើល នោះមិនត្រូវការអ្វីទេ ដូច្នេះ ព្រះទ្រង់បានផ្សំរូបកាយ ព្រមទាំងប្រទានឱ្យអវយវៈណាដែលខ្វះ បានប្រសើរលើសជាងទៅទៀត ។

១០:១៧ ដ្បិតដែលមាននំបុ័ងតែ១ដុំនោះយ៉ាងណា ចំណែកពួកយើងដែលមានគ្នាច្រើន ក៏ជារូបកាយតែ១យ៉ាងនោះដែរ ពីព្រោះយើងទាំងអស់គ្នាទទួលទានពីដុំនំបុ័ងតែមួយនោះឯង ។

I. **ក្នុងនាមជារូបកាយដ៏រស់ ការកសាងពួកបរិសុទ្ធឡើង គឺត្រូវបានបំពេញសម្រេច ដោយគ្រប់អវយវៈទាំងអស់ បានរួមបញ្ចូលគ្នាទៅវិញទៅមក—១កូរិនថូស ១០:១៧ :**
   A. គ្រាប់ជាច្រើន ទាំងអស់សុទ្ធតែក្លាយជានំបុ័ងតែមួយដុំ តាមរយៈគ្រាប់ទាំងអស់បានបំបែកទៅជាបំណែកតូចៗ កិនឱ្យទៅជាម្សៅម៉ត់ ហើយបន្ទាប់មករួមបញ្ចូលជាមួយគ្នា ដើម្បីឱ្យបានក្លាយជានំបុ័ងតែមួយដុំ—យ៉ូហាន ១២:២៤ ។

B. ក្រុមជំនុំ គឺជានំបុ័ងមួយដុំ ជានំមួយដុំ ដែលធ្វើពីម្សៅម៉ត់ ។ ម្សៅម៉ត់នេះ បានមកពីគ្រាប់ស្រូវសាលី ពួកយើងគឺជាគ្រាប់ជាច្រើន ដើម្បីឱ្យយើងអាចបានកិនទៅជាម្សៅម៉ត់ សម្រាប់ធ្វើនំ នំបុ័ង នៃក្រុមជំនុំ—១កូរិនថូស ១០:១៧ ។

**II. "តែអវយវៈណារបស់យើងដែលល្អមើល នោះមិនត្រូវការអ្វីទេ ដូច្នេះ ព្រះទ្រង់បានផ្សំរូបកាយ ព្រមទាំងប្រទានឱ្យអវយវៈណាដែលខ្វះ បានប្រសើរលើសជាងទៅទៀត" ។ បានរួមបញ្ចូល (បានផ្សំ) ត្រង់នេះ បង្កប់ន័យពីការបាត់បង់នៃភាពខុសគ្នា ។**

A. ពួកអ្នកដែលមិនល្អមើល ចែករំលែកភាពសមសួនជាមួយពួកអ្នកដែលល្អមើល ហើយពួកអ្នកខ្លាំងជាងចិញ្ចឹម និងផ្គត់ផ្គង់ពួកអ្នកខ្សោយជាង ។ បន្ទាប់មកទើបយើងមានរូបកាយ—ខ២៤ ។

B. នៅក្នុងជីវិតក្រុមជំនុំ យើងមានពណ៌សម្បុរ ពូជសាសន៍ សញ្ជាតិ និងឋានៈនៅក្នុងសង្គម ។ ប៉ុន្តែ ព្រះបានរួមបញ្ចូលពួកអ្នកជឿនៃពូជសាសន៍ និងសម្បុរផ្សេងៗគ្នាទាំងអស់ ។

C. នៅក្នុងក្រុមជំនុំតំបន់ទាំងឡាយ មានពួកបរិសុទ្ធផ្សេងៗគ្នា ។ ភាពខុសគ្នារបស់បងប្អូនម្នាក់ អាចជាភាពរហ័សរហួន ឯម្នាក់ទៀតអាចជាភាពយឺតយ៉ាវ ប៉ុន្តែនៅក្នុងជីវិតរូបកាយ ភាពយឺតយ៉ាវបាត់សូន្យ ឯភាពរហ័សរហួនត្រូវបានដកយកចេញ ។ ភាពខុសគ្នាទាំងអស់ ត្រូវបានបាត់បង់ទៅ ។

**III. "រាល់ពេលប្រជុំនាំព្រះគ្រិស្តមក នាំភាពសម្បូរដែលទ្រង់ប្រទាន នាំគ្នាយកមកថ្វាយជាតង្វាយ ដើម្បីសម្តែងព្រះគ្រិស្ត គ្រប់ពាក្យបន្ទាល់នឹងអធិដ្ឋាន ចែកចាយដល់គ្នាដោយប្រើវិញ្ញាណ សេចក្តីបង្រៀននិងអំណោយទាន ដើម្បីសម្តែងព្រះគ្រិស្តបន្ទរ យើងមកសម្តែងព្រះគ្រិស្ត យើងមកសម្តែងព្រះគ្រិស្ត នាំគ្នាយកភាពសម្បូរនៃព្រះ យើងមកសម្តែងព្រះគ្រិស្ត ។"—( បទចម្រៀង ៦២៤, អង់គ្លេស ៨៦៤) ។**

[មាតិកាតាពង](#)